**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Économiques

Royal University of Law and Economics


# សារណាបញ្ចប់ការសិក្សា

# ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ
# ក្នុងឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ
# ករណីសិក្សាឆ្នាំ ២០២១-២០២៣

ស្រាវជ្រាវចាប់ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **កញ្ញា សាន មរកដ**

**កញ្ញា សុន រក្សា**

ណែនាំដោយ

លោក **ឡាញ់ ដា**


ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**

ជំនាន់ទី១៧

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

# សេចក្ដីថ្លែងអំណរគុណ

ជាបឋមនាងខ្ញុំ **សាន មរកដ** និងនាងខ្ញុំ **សុន រក្សា** ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែករដ្ឋបាលសាធារណៈ ឆ្នាំទី៤ ជំនាន់ទី១៧ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមថ្លែងសេចក្ដីអំណរគុណ និងសេចក្ដីដឹងគុណយ៉ាងជ្រាលជ្រៅជូនចំពោះ ៖

មាតាបិតាទាំងទ្វេដែលលោកជាអ្នកផ្តល់នូវកំណើតដល់រូបយើងខ្ញុំ ព្រមទាំងបានចិញ្ចឹមបីបាច់ថែរក្សា ប្រៀនប្រដៅ ទំនុកបម្រុង និងផ្គត់ផ្គង់នូវសេចក្ដីខ្វះខាតទាំងឡាយរបស់កូនគ្រប់រូបឱ្យសិក្សារៀនសូត្របានខ្ពង់ខ្ពស់។ លោកទាំងពីរបានទូន្មានអប់រំ ប្រៀនប្រដៅ ដាស់តឿនកូនឱ្យប្រព្រឹត្តតែអំពើល្អ សេពគប់មិត្តភក្តិល្អ និងម្យ៉ាងវិញទៀតលោកបានខិតខំធ្វើការសព្វគ្រប់បែបយ៉ាង ដោយមិនខ្លាចនឿយហត់ ដើម្បីបានថវិកាយកមកទំនុកបម្រុងការសិក្សារបស់កូន ព្រមទាំងផ្តល់ការស្រឡាញ់ ការថ្នាក់ថ្នម និងការរស់នៅប្រកបដោយសេចក្តីសុខដុមរមនាដល់កូនៗទាំងអស់គ្នា ។

**ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ**គ្រប់រូប នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានយកចិត្តទុកដាក់បង្រៀននិស្សិតទាំងអស់ដោយយកចិត្តទុកដាក់ និងមិនដែលគិតពីបញ្ហាការលំបាកភាពនឿយហត់អ្វីឡើយ ផ្ទុយទៅវិញលោកខិតខំដាស់តឿន អប់រំ ទូន្មាន និស្សិតគ្រប់រូបឱ្យខិតខំប្រឹងប្រែងសិក្សារៀនសូត្រ ស្វែងរកពុទ្ធិ ចំណេះវិជ្ជា និងពង្រីកនូវចំណេះដឹងរបស់ខ្លួនបន្ថែម ដើម្បីធ្វើយ៉ាងណាឱ្យក្លាយជាមនុស្សម្នាក់ដែលពោពេញទៅដោយសមត្ថភាពក្នុងការជួយសង្គមជាតិឱ្យមានការអភិវឌ្ឍទៅមុខជានិរន្តរ៍ ។

ជាពិសេសជូនចំពោះ **លោកគ្រូ ឡាញ់ ដា** ដែលជាគ្រូណែនាំដល់រូបយើងខ្ញុំ នៅក្នុងការសរសេរសារណា និងបានចំណាយពេលវេលាដ៏មានតម្លៃនៅក្នុងការតម្រង់ទិស អប់រំ ណែនាំ ផ្តល់ឯកសារ ព្រមទាំងបានជួយផ្តល់ជាគំនិតក្នុងការសរសេរ និងត្រួតពិនិត្យកែលម្អសារណាមួយនេះយ៉ាងយកចិត្តទុកដាក់ និងទឹកចិត្តរីករាយបំផុតរហូតឈានដល់ស្នាដៃនេះបានលេចជារូបរាងឡើង។

ជាមួយគ្នានេះផងដែរ សូមថ្លែងអំណរអរគុណយ៉ាងជ្រាលជ្រៅ ចំពោះលោកអ៊ុំ **កែវ រ៉ន** ជាមេឃុំសែនដីដែលលោកបានអនុញ្ញាតឱ្យយើងខ្ញុំទាំងពីរបានចុះសិក្សាស្រាវជ្រាវ និងលោកស្រី **ណុប ដារ៉ា** ជាស្មៀនឃុំបានចូលរួមបានផ្តល់ជាឯកសារផ្សេងៗ សម្រាប់ការចងក្រងស្នាដៃនេះឡើង។

ដោយឡែកសូមថ្លែងអំណរគុណយ៉ាងក្រៃលែងជូនចំពោះលោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ និងគណៈកម្មការ ដែលបានជួយរៀបចំកម្មវិធីទ្រទ្រង់សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រនេះ  និងបានចូលរួមសណ្ដាប់  និងធ្វើការវាយតម្លៃការការពារសារណាបញ្ចប់ការសិក្សាប្រកបដោយតម្លាភាព និងកិត្តិយសបំផុត។

ជាទីបញ្ចប់យើងខ្ញុំសូមជូនពរ បួងសួងដល់វត្ថុស័ក្តិសិទ្ធិក្នុងលោក តាមជួយថែរក្សាដល់លោកឪពុក អ្នកម្ដាយ រួមទាំងថ្នាក់ដឹកនាំនៅក្នុងឃុំសែនដី លោកគ្រូ អ្នកគ្រូ ទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចសូម ជួបប្រកបតែសេចក្ដីសុខ សេចក្ដីចម្រើន សុភមង្គល ព្រមទាំងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាងឡើយ។

# អារម្ភកថា

យើងខ្ញុំទាំងពីរជានិស្សិត ក្រុមP4A5 ថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈជំនាន់ទី១៧ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានសម្រេចយកនូវការស្រាវជ្រាវសារណាសម្រាប់បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈរបស់ពួកយើង ដោយចង់បន្សល់ទុកនូវឯកសារចងក្រងនិងការស្រាវជ្រាវមួយដែលអាចជួយដល់និស្សិតជំនាន់ក្រោយ អាចយកទៅសិក្សាបន្ត និងមានបំណងចែករំលែកចំណេះដឹងដែលខ្លួនបានទទួលបានក្នុងអំឡុងពេល៤ឆ្នាំមកនេះ។

ហេតុដូច្នេះហើយ យើងខ្ញុំបានជ្រើសរើសប្រធានបទមួយស្តីពី « **ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈក្នុងឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ករណីសិក្សាឆ្នាំ២០២១-២០២៣** » ដើម្បីធ្វើការបង្ហាញអំពីការអនុវត្តកិច្ចលទ្ធកម្មដែលធ្វើឡើងដោយ ឃុំ សង្កាត់ ក្នុងគោលបំណងដើម្បីគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការចូលរួមលើកកម្ពស់ និងរួមចំណែកក្នុងការសន្សំសំចៃថវិកាជាតិ ប្រកបដោយប្រសិទ្ធភាព និងជួយជំរុញដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិឱ្យកាន់តែប្រសើរឡើង។

ដោយមានឆន្ទៈដែលប្រកបដោយទស្សនៈវិស័យក្នុងការសិក្សាបន្ថែមពីការទទួលបានការបង្ហាត់បង្រៀន និងណែនាំយ៉ាងយកចិត្តទុកដាក់ពីសំណាក់សាស្ត្រាចារ្យដែលមានជំនាញ និងបទពិសោធន៍ខ្ពស់ក្នុងវិស័យអប់រំផងទៀតនោះ ទើបនាំឱ្យយើងខ្ញុំសម្រេចបាននូវលទ្ធផលសិក្សាដ៏ល្អប្រសើរដោយបានសម្រេចនូវការសរសេរសារណាបញ្ចប់ការសិក្សានេះបានដោយរលូន។

បើទោះបីជាខ្លឹមសារទាំងស្រុងនៅក្នុងសារណានេះ មានការពិនិត្យយ៉ាងយកចិត្តទុកដាក់យ៉ាងណាក្តី យើងខ្ញុំគិតថាកំហុសអចេតនាតែងតែមានដូចជា ការប្រើពាក្យពេចន៍ ការប្រើភាសា អក្ខរាវិរុទ្ធ ការប្រើប្រាស់វេយ្យាករណ៍ជាដើម ដែលមិនអាចជៀសផុតឡើយ។ ដូចនេះយើងខ្ញុំព្រមនិងទទួលរាល់ការកែតម្រូវ និងមតិរិះគន់ទាំងឡាយក្នុងន័យស្ថាបនា ដើម្បីឱ្យស្នាដៃស្រាវជ្រាវមួយនេះកាន់តែមានភាពប្រសើរឡើងបន្ថែមទៀត។

ជាកិច្ចបញ្ចប់យើងខ្ញុំសូមខន្តី អភ័យទោសទុកជាមុនរាល់កំហុសខុសឆ្គងដោយអចេតនាណាមួយ ហើយពួកយើងខ្ញុំទាំងពីរ សង្ឃឹមថាសារណានេះនឹងផ្តល់ជាជំនួយ និងគន្លឹះខ្លះៗសម្រាប់មិត្តអ្នកអាន ដែលមានបំណងចង់សិក្សាស្រាវជ្រាវ ស្វែងយល់ពីគ្រប់មជ្ឈដ្ឋានទាំងអស់។

# មាតិកា

ទំព័រ

**សន្ធានុក្រម** ............ vii

**សេចក្តីផ្តើម** ............ ១

១. លំនាំបញ្ហានៃការស្រាវជ្រាវ ............ ១

២. ចំណោទបញ្ហានៃការស្រាវជ្រាវ ............ ២

៣. គោលបំណងនៃការស្រាវជ្រាវ ............ ២

៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ............ ៣

៥. សារៈប្រយោជន៍នៃការស្រាវជ្រាវ ............ ៣

៦. វិធីសាស្ត្រនៃការស្រាវជ្រាវ ............ ៣

៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ............ ៣

**ជំពូកទី១**

**រដ្ឋបាលដែនដីឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ**

**ផ្នែកទី១៖ ទីតាំងភូមិសាស្ត្រ**

១. ស្ថានភាពទូទៅ ............ ៤

១.១ ស្ថានភាពប្រជាជន ............ ៤

១.២ ការបែងចែកមណ្ឌលរដ្ឋបាលដែនដី និងស្ថានភាពនៃការប្រើប្រាស់ដី ............ ៥

១.២.១ មណ្ឌលរដ្ឋបាលដែនដី ............ ៥

១.២.២ ស្ថានភាពនៃការប្រើប្រាស់ដីធ្លី ............ ៦

២. ស្ថានភាពនៃការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ............ ៦

២.១ ការគ្រប់គ្រងរដ្ឋបាល ............ ៦

២.២ សមាសភាពនៃក្រុមប្រឹក្សាឃុំ សង្កាត់........................................................................................៦
២.៣ រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាល .................................................................................................... ៧
២.៤ តួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់...........................................................................៨
២.៤.១ ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់..................................................................................................៨
២.៤.២ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់................................................................................................៨
២.៥ តួនាទី និងភារកិច្ច........................................................................................................................៩
២.៥.១ មេឃុំចៅ សង្កាត់ ........................................................................................................................៩
២.៥.២ ជំទប់ទី១ ចៅសង្កាត់រងទី១ .......................................................................................................៩
២.៥.៣ ជំទប់ទី២ ចៅសង្កាត់រងទី២.........................................................................................................៩
**ផ្នែកទី២ ៖ ស្ថានភាពបច្ចុប្បន្ន និងការងារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ**.....................៩
១. ស្ថានភាពបច្ចុប្បន្នក្នុងមូលដ្ឋានឃុំសែនដី........................................................................................៩
១.១ ស្ថានភាពសេដ្ឋកិច្ច..........................................................................................................................៩
១.២ ស្ថានភាពសង្គមកិច្ច.......................................................................................................................១១
២. ការគ្រប់គ្រងស្ថិតិ និងការងារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ .....................................................១២
២.១ ការងារគ្រប់គ្រងស្ថិតិ.....................................................................................................................១២
២.២ ការងារសន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈ .........................................................................១២
**ជំពូកទី២**
**សញ្ញាណលទ្ធកម្មសាធារណៈនៅកម្ពុជា**
**ផ្នែកទី១ ៖ បរិបទទូទៅនៃការអនុវត្តលទ្ធកម្មសាធារណៈ**
១. សាវតានៃលទ្ធកម្មសាធារណៈនៅកម្ពុជា ........................................................................................ ១៤
២. និយមន័យ........................................................................................................................................ ១៥

២.១ គោលបំណងនៃកិច្ចលទ្ធកម្ម........................................................................................ ១៥

២.២ ផលប្រយោជន៍នៃកិច្ចលទ្ធកម្មសាធារណៈ........................................................................ ១៦

៣. ប្រភេទនៃកិច្ចលទ្ធកម្មឃុំ សង្កាត់.................................................................................... ១៦

៣.១ លទ្ធកម្មសំណង់.................................................................................................... ១៦

៣.២ លទ្ធកម្មទំនិញ....................................................................................................... ១៧

៣.៣ លទ្ធកម្មសេវាកម្ម .................................................................................................. ១៧

៤. គោលការណ៍នៃកិច្ចលទ្ធកម្មសាធារណៈ ........................................................................... ១៧

៤.១ ការសន្សំសំចៃ ..................................................................................................... ១៨

៤.២ តម្លាភាព ............................................................................................................. ១៨

៤.៣ គណនេយ្យភាព...................................................................................................... ១៨

៤.៤ ប្រសិទ្ធភាព .......................................................................................................... ១៩

៤.៥ សមភាព............................................................................................................... ១៩

៤.៦ ក្រមសីលធម៌វិជ្ជាជីវៈ............................................................................................... ១៩

**ផ្នែកទី២ ៖ វិធីសាស្រ្ត និងនីតិវិធីលទ្ធកម្មរបស់រដ្ឋបាលឃុំ សង្កាត់**

១.ក្របខណ្ឌគតិយុត្ត........................................................................................................ ២០

២. វិធីសាស្រ្តលទ្ធកម្មឃុំ សង្កាត់ .......................................................................................... ២០

២.១ វិធីសាស្រ្តការដេញថ្លៃដោយប្រកួតប្រជែងជាចំហ ...................................................... ២០

២.២ វិធីសាស្រ្តផ្សេងទៀតដែលមិនមែនជាការដេញថ្លៃ ដោយប្រកួតប្រជែងជាចំហ............................. ២១

២.២.១ ការស្ទង់តម្លៃក្នុងស្រុក.......................................................................................... ២១

២.២.២ ការទិញផ្ទាល់ ឬការចុះកិច្ចសន្យាផ្ទាល់..................................................................... ២១

៣. នីតិវិធីលទ្ធកម្មឃុំ សង្កាត់.............................................................................................. ២៣

៣.១ នីតិវិធីលទ្ធកម្មសំណង់ ........ ២៣

៣.១.១ ការកំណត់អ្នកដែលមានសិទ្ធដាក់សំណើរដេញថ្លៃដោយក្រុមប្រឹក្សាឃុំ សង្កាត់ ........ ២៣

៣.១.២ ដំណាក់កាលនៃកិច្ចលទ្ធកម្មសម្រាប់ការដេញថ្លៃដោយប្រកួតប្រជែងជាចំហ ........ ២៤

៣.២ នីតិវិធីលទ្ធកម្មទំនិញ ........ ២៨

៣.២.១ វិធីសាស្ត្រដេញថ្លៃជាសាធារណៈ ........ ២៨

៣.២.២ វិធីសាស្ត្រស្ទង់តម្លៃក្នុងស្រុក ........ ២៨

៣.២.៣ វិធីសាស្ត្រការទិញផ្ទាល់ ឬការចុះកិច្ចសន្យាផ្ទាល់ ........ ២៩

៣.៣ នីតិវិធីលទ្ធកម្មសេវាកម្ម ........ ២៩

## ជំពូកទី៣
## ការគ្រប់គ្រង និងការអនុវត្ត
## កិច្ចលទ្ធកម្មសាធារណៈក្នុងឃុំសែនដីស្រុកសំរោងទងខេត្តកំពង់ស្ពឺ

**ផ្នែកទី ១ ៖ ការគ្រប់គ្រងកិច្ចលទ្ធកម្មសាធារណៈ នៅឃុំសែនដី**

១. ការរៀបចំ និងការសិក្សាគម្រោងថវិកាឃុំ សង្កាត់ ........ ៣១

១.១ ការរៀបចំគម្រោង ........ ៣១

១.២ ការសិក្សាគម្រោង (គម្រោងហេដ្ឋារចនាសម្ព័ន្ធ) ........ ៣២

២. ការគ្រប់គ្រង និងការអនុវត្តគម្រោង ........ ៣៣

២.១ មេឃុំ និងចៅសង្កាត់ ........ ៣៣

២.២ ក្រុមប្រឹក្សាឃុំ សង្កាត់ ........ ៣៣

២.៣ គណៈកម្មការគ្រប់គ្រងគម្រោង ........ ៣៣

២.៣.១ ក្នុងការរៀបចំគម្រោង ........ ៣៣

២.៣.២ ក្នុងការអនុវត្តគម្រោង ........ ៣៤

២.៤ អ្នកជំនួយបច្ចេកទេស ........ ៣៤
២.៥ ការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់ និងការិយាល័យផែនការ និងអភិវឌ្ឍន៍ ........ ៣៤
២.៦ ទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្ត ........ ៣៤
២.៧ ការអនុវត្តគម្រោង ........ ៣៥
៣. ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការលទ្ធកម្ម ........ ៣៦
៣.១ គណៈកម្មការលទ្ធកម្ម របស់ឃុំសែនដី ........ ៣៦
៣.២ តួនាទី និងទំនួលខុសត្រូវ នៅក្នុងការអនុវត្តកិច្ចលទ្ធកម្មឃុំសង្កាត់ ........ ៣៦
៣.២.១ ក្រុមប្រឹក្សាឃុំ សង្កាត់ ........ ៣៦
៣.២.២ មេឃុំ ចៅសង្កាត់ ........ ៣៧
៣.២.៣ គណៈកម្មការលទ្ធកម្ម ........ ៣៧
៣.២.៤ មន្ត្រីគាំទ្របច្ចេកទេសរាជធានី ខេត្ត ........ ៣៨
៣.២.៥ អ្នកត្រួតពិនិត្យ ........ ៣៨
៣.២.៦ អង្គភាពរដ្ឋបាលមូលដ្ឋានរខេត្ត ក្រុង ........ ៣៩
៣.២.៧ អភិបាលរខេត្ត ក្រុង ........ ៣៩
**ផ្នែកទី ២ ៖ ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ នៅឃុំសែនដី** ........ ៤០
១. ផែនការកិច្ចលទ្ធកម្មសាធារណៈប្រចាំឆ្នាំ ........ ៤០
១.១ គម្រោងផែនការកិច្ចលទ្ធកម្មប្រចាំឆ្នាំ ២០២១ ........ ៤០
១.២ គម្រោងផែនការកិច្ចលទ្ធកម្មប្រចាំឆ្នាំ ២០២២ ........ ៤០
១.៣ គម្រោងផែនការកិច្ចលទ្ធកម្មប្រចាំឆ្នាំ ២០២៣ ........ ៤១
២. ការអនុវត្ត និង លទ្ធផល នៃការអនុវត្តកិច្ចលទ្ធកម្ម ........ ៤២
២.១ ការអនុវត្តផែនការគម្រោងនៃកិច្ចលទ្ធកម្ម ........ ៤២

២.២ លទ្ធផលនៃការអនុវត្តកិច្ចលទ្ធកម្មក្នុង ឃុំសែនដី ..... ៤២
២.២.១ ផលចំណេញផ្នែកហិរញ្ញវត្ថុ..... ៤២
២.២.២ សមិទ្ធិផលផ្នែកគុណភាព ..... ៤៤
៣. របាយការណ៍រីកចម្រើននៃការអនុវត្តកិច្ចសន្យាសំណង់..... ៤៤
៣.១ របាយការណ៍រីកចម្រើន ដំណាក់កាលទី ១ និងទី ២..... ៤៤
៣.២ របាយការណ៍បញ្ចប់ នៃការអនុវត្តកិច្ចសន្យាសំណង់..... ៤៥
៣.៣ អាណត្តិបើកប្រាក់ ..... ៤៥
៤. បណ្ដឹងតវ៉ា និងការអនុវត្តកិច្ចលទ្ធកម្ម..... ៤៥
៥. ចំណុចខ្លាំង ចំណុចខ្សោយ និងកាលានុវត្តភាព នៃកិច្ចលទ្ធកម្ម..... ៤៦
៥.១ ចំណុចខ្លាំង ..... ៤៦
៥.២ ចំណុចខ្សោយ..... ៤៧
៦.កាលានុវត្តភាព ..... ៤៧
៧. បញ្ហាប្រឈម និងដំណោះស្រាយ ..... ៤៧
៧.១ បញ្ហាប្រឈម ..... ៤៧
៧.២ ដំណោះស្រាយ..... ៤៨
សេចក្ដីសន្និដ្ឋាន..... ៥០
អនុសាសន៍..... ៥២
ឯកសារយោង
ឧបសម្ព័ន្ធ

# សទ្ទានុក្រម

- **កិច្ចលទ្ធកម្ម** សំដៅទៅដល់ដំណើរការលទ្ធកម្មសាធារណៈ ចាប់ពីពេលរៀបចំឯកសារដេញថ្លៃរហូតដល់ទទួលបានទំនិញ សំណង់ សេវាកម្ម ឬសេវាទីប្រឹក្សា។
- **កិច្ចសន្យា** គឺជាកិច្ចព្រមព្រៀងរវាងអ្នកទិញ និងអ្នកផ្គត់ផ្គង់ ដើម្បីផ្តល់នូវទំនិញ ឬរវាងអ្នកម្ចាស់ការ និងអ្នកទទួលការ ដើម្បីអនុវត្តការងារសាងសង់ ជួសជុល ឬសេវាកម្ម ក្នុងលក្ខខណ្ឌដែលស្រុះស្រួលដោយភាគីទាំងពីរ។
- **ក្រមសីលធម៌លទ្ធកម្ម** សំដៅដល់ក្រមដែលអ្នកចូលរួមពាក់ព័ន្ធនឹងលទ្ធកម្មសាធារណៈត្រូវយល់ដឹងនិងអនុវត្តដោយស្មោះត្រង់តាមបទប្បញ្ញត្តិគតិយុត្តជាធរមាននិងអនុវត្តឱ្យបានត្រឹមត្រូវតាមតួនាទីនិងមុខងាររបស់ខ្លួន។
- **ការដេញថ្លៃ** គឺជាសកម្មភាពប្រកួតប្រជែង ដើម្បីធ្វើការផ្គត់ផ្គង់ ទំនិញ សេវា ឬការងារសាងសង់ ។
- **ការប្រកួតប្រជែង** សំដៅដល់ការប្រើប្រាស់នីតិវិធីលទ្ធកម្មដែលមានការចូលរួមពីអ្នកដេញថ្លៃ ដើម្បីជ្រើសរើសសំណុំឯកសារស្នើដេញថ្លៃ ដែលឆ្លើយតបពេញលេញ ឬសមស្របជាងគេនឹងមានតម្លៃល្អបំផុត។
- **ការសន្សំសំចៃ** សំដៅដល់ការប្រើប្រាស់ថវិកាសមស្របបំផុតក្នុងចំណាយ ដែលក្នុងនោះត្រូវពិចារណាផងដែរលើកត្តាពាក់ព័ន្ធនានាក្នុងការអនុវត្តនីតិវិធីលទ្ធកម្មដើម្បីជ្រើសរើសអ្នកផ្គត់ផ្គង់ឬអ្នកទទួលការ។
- **ការងារសាងសង់** សំដៅដល់រាល់សកម្មភាពដែលពាក់ពន្ធ័ដល់ការសាងសង់ ការជួសជុល ការធ្វើឡើងជាថ្មី ការដំឡើង ការជីក ការបូម និង ការងារប្រហាក់ប្រហែល ដែលបង្កើតឱ្យមានការប្រើប្រាស់កម្លាំងពលកម្ម គ្រឿងម៉ាស៊ីន បរិក្ខារ និងបច្ចេកវិទ្យា ។
- **គណនេយ្យភាព** សំដៅដល់ការទទួលខុសត្រូវរបស់ស្ថាប័នអនុវត្តលទ្ធកម្ម ក្នុងការធ្វើសេចក្តីសម្រេចនិងចាត់វិធានការក្នុងអំឡុងដំណើរការលទ្ធកម្មសាធារណៈ។
- **តម្លាភាព** សំដៅដល់ការទទួលបាននូវព័ត៌មានដែលពាក់ព័ន្ធនឹងលទ្ធកម្មសាធារណៈដោយចំហ និងសិទ្ធិចូលរួមក្នុង ដំណើរការលទ្ធកម្មសាធារណៈតាមវិធីសាស្ត្រ និងនីតិវិធីលទ្ធកម្មសាធារណៈ។
- **ទំនិញ** គឺជាវត្ថុក្នុងភាពរឹង រាវ ឬជាឧស្ម័នដែលមានតម្លៃ ឬផលប្រយោជន៍ សេដ្ឋកិច្ច ដូចជាគ្រឿងចក្រ បរិក្ខារ សម្ភារ គ្រឿងផ្គត់ផ្គង់ វត្ថុសម្រាប់ដោះដូរ ផលិតផលផ្សេងៗ រួមទាំងអគ្គិសនីផង ។
- **ប្រសិទ្ធភាព** សំដៅដល់ចំណាយចំគោលដៅចំពោះមុខចំណាយដែលត្រូវអនុវត្តនីតិវិធីលទ្ធកម្ម។
- **មន្ត្រីលទ្ធកម្ម** សំដៅដល់ប្រធាន អនុប្រធាន និងមន្ត្រីទាំងអស់របស់អង្គភាពលទ្ធកម្មនៃស្ថាប័នអនុវត្តលទ្ធកម្ម។

- **មន្ត្រីគាំទ្របច្ចេកទេស** គឺជាមន្ត្រីដែលបានជ្រើសរើសមកពីមន្ទីរជំនាញខេត្ត ក្រុង និងត្រូវតែងតាំងដោយអភិបាលខេត្ត ក្រុង មានភារកិច្ចត្រូវត្រួតពិនិត្យតាមដានដំណើរការលទ្ធកម្មក្នុងនាមអភិបាលខេត្ត ក្រុង។ ក្នុងករណីមានសំណើរពីឃុំ សង្កាត់ មន្ត្រីគាំទ្របច្ចេកទេសត្រូវជួយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការគ្រប់គ្រងការងារបច្ចេកទេស ការចាត់ចែងនៃដំណើរការដេញថ្លៃ និងអនុវត្តកិច្ចសន្យា និងអាចបំពេញភារកិច្ចជាអ្នកត្រួតពិនិត្យបច្ចេកទេសផងដែរដោយ មិនគិតថ្លៃ។
- **លទ្ធកម្ម** គឺជាការរកបាននូវទំនិញ និងសេវាពាក់ពន្ធ័ ឬជាការជួលអ្នកទទួលការ សម្រាប់ការងារសាងសង់តាមរយៈវិធីសាស្រ្តលទ្ធកម្មសាធារណៈ ។
- **លទ្ធកម្មសាធារណៈ** គឺជាលទ្ធកម្មដែលធ្វើឡើងដោយក្រសួង ស្ថាប័ន ខេត្ត ក្រុង ឃុំ សង្កាត់ និងស្ថាប័នដែលរដ្ឋកាន់កាប់ ឬស្វ័យគ្រប់គ្រង ។
- **សេវាកម្ម** គឺជាសកម្មភាពដែលពាក់ពន្ធ័ដល់ការប្រើប្រាស់កម្លាំងមនុស្ស គ្រឿងបរិក្ខារ ឬបច្ចេកវិទ្យាដែលនាំមកនូវផលប្រយោជន៍ដល់ស្ថាប័នសាធារណៈ ប៉ុន្តែមិនរាប់បញ្ចូលការងារសាងសង់ និងមុខរបរសេវាទីប្រឹក្សាទេ។
- **សំណើដេញថ្លៃ** គឺជាសំណើសុំដើម្បីផ្គត់ផ្គង់ សេវា ឬធ្វើការសាងសង់ ដែលធ្វើឡើងតាមលក្ខខណ្ឌដែលកំណត់ដោយអ្នកទិញ ឬអ្នកម្ចាស់ការ ។
- **សមភាព** សំដៅដល់ទម្រង់ឯកភាពតែមួយលើគោលនយោបាយ និងនីតិវិធីលទ្ធកម្មបង្កើតឱ្យមានភាពស្មើគ្នាសម្រាប់ការប្រកួតប្រជែង។
- **សវនកម្ម** គឺជាសកម្មភាពផ្ទៀងផ្ទាត់នៅនឹងកន្លែងដូចជា ការត្រួតពិនិត្យឬការពិនិត្យដំណើរការឬប្រព័ន្ធគុណភាព ដើម្បីធានានូវការអនុលោមទៅតាមតម្រូវការ។
- **អ្នកដេញថ្លៃ** សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានបំណងចូលរួមក្នុងលទ្ធកម្មសាធារណៈនិងបានដាក់សំណុំឯកសារស្នើដេញថ្លៃ ឬការស្នើបញ្ជាក់ពីចំណាប់អារម្មណ៍។
- **អ្នកម្ចាស់ការ** គឺជាស្ថាប័នសាធារណៈ រួមមានទាំងឃុំ សង្កាត់ (តំណាងដោយមេឃុំ ចៅសង្កាត់) ដែលចុះកិច្ចសន្យាស្តីពីការសាងសង់ ឬសេវាជួលជាមួយអ្នកទទួលការ ។
- **អ្នកផ្គត់ផ្គង់** សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលចុះកិច្ចសន្យាលក់ទំនិញ ជាមួយនឹងស្ថាប័នអនុវត្តលទ្ធកម្ម។
- **អំពើឃុបឃិត** សំដៅដល់ផែនការ ឬការរៀបចំឡើងរវាងអ្នកដេញថ្លៃពីរឬច្រើននាក់ ដើម្បីបង្កើតតម្លៃដេញថ្លៃសិប្បនិម្មិត គ្មានលក្ខណៈប្រកួតប្រជែងពិតប្រាកដ ឬធ្វើឱ្យមានឥទ្ធិពលលើសកម្មភាពរបស់ភាគីណាមួយ ក្នុងដំណើរការលទ្ធកម្មសាធារណៈឬធ្វើឱ្យមានការជះឥទ្ធិពលលើការអនុវត្តកិច្ចសន្យា។

- **អំពើបង្ខិតបង្ខំ** សំដៅដល់ការហាមឃាត់ ឬការគំរាមកំហែងដោយផ្ទាល់ ឬដោយប្រយោលធ្វើឱ្យមានគ្រោះថ្នាក់ដល់បុគ្គល ឬទ្រព្យសម្បត្តិរបស់បុគ្គល ដើម្បីធ្វើឱ្យមានឥទ្ធិពលដល់ការចូលរួមក្នុងដំណើរការលទ្ធកម្មសាធារណៈរបស់បុគ្គលនោះ ឬធ្វើឱ្យមានការជះឥទ្ធិពលលើការអនុវត្តកិច្ចសន្យា។
- **អំពើបន្លំ** សំដៅដល់ការបកស្រាយបំភ្លៃហេតុការណ៍ដើម្បីធ្វើឱ្យមានឥទ្ធិពល លើដំណើរការលទ្ធកម្មសាធារណៈ។
- **ឯកសារដេញថ្លៃ** សំដៅដល់សំណុំឯកសារដែលអង្គភាពលទ្ធកម្មនៃស្ថាប័នអនុវត្តលទ្ធកម្មបានរៀបចំនិងផ្តល់ជាដំបូងទៅឱ្យអ្នកដេញថ្លៃ ដើម្បីប្រើសម្រាប់រៀបចំសំណុំឯកសារស្នើដេញថ្លៃ ដែលរួមមានពាក្យសុំដេញថ្លៃ សេចក្តីអញ្ជើញឱ្យចូលរួមដេញថ្លៃ ការស្នើឱ្យដាក់សំណុំឯកសារស្នើដេញថ្លៃ សេចក្តីអញ្ជើញឱ្យចូលរួមក្នុងការកំណត់បុរេលក្ខណៈសម្បត្តិ សេចក្តីណែនាំចំពោះអ្នកដេញថ្លៃ លក្ខណៈបច្ចេកទេស ទំហំការងារ លក្ខខណ្ឌយោងការងារ និងលក្ខខណ្ឌនៃកិច្ចសន្យា។

# សេចក្ដីផ្ដើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជាបានឆ្លងកាត់នូវសង្គ្រាមផ្ទៃក្នុងអស់រយៈកាលជាយូរ ដែលធ្វើឱ្យប្រទេសជាតិទទួលរងនូវការបំផ្លិចបំផ្លាញ ទាំងហេដ្ឋារចនាសម្ព័ន្ធ ស្ពានថ្នល់ សាលារៀន មន្ទីពេទ្យ បាត់បង់ទាំងធនធានមនុស្ស ការអភិវឌ្ឍក៏ត្រូវបានបង្អាក់លើគ្រប់វិស័យ និងធ្វើឱ្យប្រទេសគ្មានគោលជំហររឹងមាំ។ ក្រោយបើកទំព័រថ្មីនៃប្រព័ន្ធគ្រប់គ្រងរដ្ឋមក រាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែងក្នុងការស្តារប្រព័ន្ធគ្រប់គ្រងរដ្ឋបាលរបស់ប្រទេសឱ្យមានតម្លាភាព ស្ថេរភាព ប្រសិទ្ធភាព និងបានព្យាយាមវិវត្តន៍ខ្លួនយ៉ាងឆាប់រហ័ស ដោយបានយកចិត្តទុកដាក់ទៅលើការបង្កើតជាគោលនយោបាយនិងយុទ្ធសាស្ត្រនានា ដើម្បីកសាងប្រទេសឱ្យមានការអភិវឌ្ឍខ្លាំងក្លាបំផុត។

រាជរដ្ឋាភិបាលក៏បានបង្កើតជាយុទ្ធសាស្ត្រចតុកោណដែលមានគោលដៅចម្បង ក្នុងការជម្រុញលើកកម្ពស់កំណើនសេដ្ឋកិច្ច ការដោះស្រាយបញ្ហាការងារសម្រាប់ពលករកម្ពុជា ការធានាសមធម៌ និងយុត្តិធម៌សង្គម និងការលើកស្ទួយប្រសិទ្ធភាពនៃវិស័យសាធារណៈ តាមរយៈផែនការសកម្មភាពអភិបាលកិច្ចល្អ និងកំណែទម្រង់ស៊ីជម្រៅ និងប្រទាក់ក្រឡាគ្នាគ្រប់ផ្នែក និងគ្រប់វិស័យ។[1]

ជាការពិតណាស់ស្នូលនៃយុទ្ធសាស្ត្រចតុកោណ គឺអភិបាលកិច្ចល្អ ដែលផ្តោតលើការយកចិត្តទុកដាក់ទៅលើកំណែទម្រង់ទាំងបួនយ៉ាង។ ដែលចំណុចទីមួយនៃស្នូលយុទ្ធសាស្ត្រចតុកោណ បានឆ្លុះបង្ហាញអំពីការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ តាមរយៈការលើកកម្ពស់ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពហិរញ្ញវត្ថុក្នុងការធ្វើលទ្ធកម្មគ្រប់គ្រងលើការចំណាយធនធានហិរញ្ញវត្ថុសាធារណៈ ក៏ដូចជាការជំរុញការអនុវត្តលើកំណែទម្រង់ដែលមានការពាក់ព័ន្ធលើគ្រប់វិស័យ ដើម្បីធានាអភិបាលកិច្ចល្អ។ ក្នុងគោលបំណងដើម្បីធានាឱ្យបានថាការអនុវត្តកិច្ចលទ្ធកម្មសាធារណៈនៅគ្រប់មជ្ឈដ្ឋានដំណើរការទៅប្រកបដោយប្រសិទ្ធភាព តម្លាភាព សមភាព គណនេយ្យភាព និងការសន្សំសំចៃ រាជរដ្ឋាភិបាលក៏សម្រេចដាក់ចេញនូវ ប្រកាសស្តីពីការងារលទ្ធកម្មរបស់ឃុំសង្កាត់ សៀវភៅណែនាំស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងបានចេញនូវគោលការណ៍ជាច្រើនទៀតផង។ កន្លងមកនៅក្នុងក្របខណ្ឌនៃកម្មវិធីកំណែទម្រង់នេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានប្រគល់សិទ្ធិជាបន្តបន្ទាប់ជូនស្ថាប័នអនុវត្តកិច្ចលទ្ធកម្ម ក្នុងការអនុវត្តនិងសម្រេចលើកិច្ចលទ្ធកម្មសាធារណៈនៅក្នុងមូលដ្ឋានរបស់ខ្លួន។

ជាក់ស្តែង គណៈកម្មការលទ្ធកម្មឃុំសែនដី ត្រូវបានបង្កើតឡើងក្រោមកំណែទម្រង់រដ្ឋបាលរបស់រាជរដ្ឋាភិបាល តាមរយៈការធ្វើវិសហមជ្ឈការលទ្ធកម្មសាធារណៈ ដែលបានអនុញ្ញាតឱ្យរដ្ឋបាលឃុំសែនដី មាននីតិសម្បទា

[1] - យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី១ នីតិកាលទី៣ នៃរដ្ឋសភា ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព នៅកម្ពុជា។

ក្នុងការអនុវត្តកិច្ចលទ្ធកម្មរបស់ខ្លួន ដែលទាក់ទងនិងការចំណាយនៅក្នុងមូលដ្ឋានដូចជា ការទិញទំនិញ ការសាងសង់ ការជួសជុលជាដើម។

យ៉ាងណាមិញ ចំពោះប្រធានបទស្តីពី « **ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈក្នុងឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ករណីសិក្សាឆ្នាំ២០២១-២០២៣** » បានឆ្លុះបញ្ចាំង អំពីនីតិវិធីនៃការធ្វើលទ្ធកម្ម និងគោលការណ៍សំខាន់ៗដែលទាក់ទងទៅនឹងកិច្ចលទ្ធកម្មនៅឃុំ សង្កាត់។ ឯកសារនេះពិតជាមានសារៈសំខាន់ណាស់ សម្រាប់ជំនួយដល់ការសិក្សាស្រាវជ្រាវរបស់សិស្ស និស្សិត និងអ្នកសិក្សាវៀនសូត្រ ដែលមានបំណងស្វែងយល់អំពីភាពចាំបាច់នៃការធ្វើកិច្ចលទ្ធកម្មនៅឃុំ សង្កាត់។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ដើម្បីជាស្ពាន ឆ្ពោះទៅកាន់ការសិក្សាស្រាវជ្រាវលើប្រធានបទស្តីពី«**ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈក្នុងឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ករណីសិក្សាឆ្នាំ២០២១-២០២៣**» ទទួលបានជោគជ័យ និងកាន់តែស៊ីជម្រៅថែមទៀតនោះ យើងបានលើកចោទនូវបញ្ហាមួយចំនួនដែលទាក់ទងនិង៖

- ចំណោទបញ្ហាសំខាន់
  - តើការអនុវត្តកិច្ចលទ្ធកម្មសាធារណៈក្នុងឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ មាននីតិវិធីនៃការរៀបចំ និងការប្រព្រឹត្តទៅយ៉ាងដូចម្តេចខ្លះ?
- ចំណោទបញ្ហាបន្ទាប់បន្សំ
  - តើវិធីសាស្ត្រលទ្ធកម្មនៅឃុំ សង្កាត់មានប៉ុន្មានប្រភេទ ? អ្វីខ្លះ ?
  - ដើម្បីឱ្យការអនុវត្តកិច្ចលទ្ធកម្មឃុំ សង្កាត់ ទទួលបានប្រសិទ្ធភាពខ្ពស់ តើមន្ត្រីដែលទទួលបន្ទុកអនុវត្តលទ្ធកម្មត្រូវធ្វើដូចម្តេចខ្លះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ចំពោះគោលបំណងចម្បងនៃការសិក្សាស្រាវជ្រាវអំពីប្រធានបទនេះ គឺដើម្បីរួមចំណែកក្នុងការលើកកម្ពស់ប្រសិទ្ធភាព ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការប្រយុទ្ធប្រឆាំងនិងអំពើពុករលួយ។ លើសពីនេះក៏បានបង្ហាញ អំពីគុណសម្បត្តិ គុណវិបត្តិ ព្រមទាំងបញ្ហាប្រឈមនានា ដែលកើតមានក្នុងពេលអនុវត្តកិច្ចលទ្ធកម្ម ក៏ដូចជាបានផ្តល់ជាយុទ្ធសាស្ត្រដ៏សមស្របណាមួយ សម្រាប់ចូលរួមជាគំនិត យោបល់ និងបានផ្តល់ជាអនុសាសន៍យ៉ាងសំខាន់ ក្នុងគោលបំណង ធ្វើឱ្យដំណើរការនៃការអនុវត្តកិច្ចលទ្ធកម្មក្នុងឃុំ សង្កាត់ មានភាពល្អប្រសើរនិងត្រឹមត្រូវបំផុត។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

នៅក្នុងការសិក្សាស្រាវជ្រាវទៅលើប្រធានបទខាងលើ មានវិសាលភាពទៅលើ ៖

- ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈក្នុងឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ស្ថិតក្នុងករណីសិក្សាឆ្នាំ ២០២១-២០២៣
- នីតិវិធីនៃការអនុវត្តលទ្ធកម្ម គុណសម្បត្តិ គុណវិបត្តិ បញ្ហាប្រឈមនានា និងដំណោះស្រាយទាំងឡាយ ទៅលើដំណើរការនៃការអនុវត្តកិច្ចលទ្ធកម្មសាធារណៈនៅក្នុងរដ្ឋបាលដែនដីរបស់ ឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺតែប៉ុណ្ណោះ។

## ៥. សារៈប្រយោជន៍នៃការស្រាវជ្រាវ

ចំពោះសារៈប្រយោជន៍នៃប្រធានបទស្រាវជ្រាវនេះ គឺបានរួមចំណែកអភិវឌ្ឍន៍ ជំរុញដល់ដំណើរការកិច្ចលទ្ធកម្មរបស់ឃុំ សង្កាត់មានលក្ខណៈប្រសើរ និងច្បាស់លាស់បន្ថែមទៀត។

ចំពោះអត្ថន័យក្នុងសៀវភៅនេះ ក៏បានជួយផ្តល់ជាចំណេះដឹង ផ្តល់ជាឯកសារដល់បណ្ឌិតសិស្ស និស្សិត និងអ្នកសិក្សាស្រាវជ្រាវក្រោយៗបានសិក្សាស្វែងយល់បន្ថបន្ថែម ដើម្បីអភិវឌ្ឍន៍ខ្លួន និងសង្គមជាតិឱ្យមានការអភិវឌ្ឍជឿនលឿនជានិរន្តរ៍។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវប្រធានបទនេះ គឺផ្តោតសំខាន់ទៅលើដំណើរការនៃការអនុវត្តកិច្ចលទ្ធកម្មសាធារណៈរបស់ឃុំ សង្កាត់ ដោយប្រមូលផ្តុំបាននូវទិន្នន័យ របាយការណ៍ និងឯកសារមួយចំនួនដែលទាក់ទងនឹងការអនុវត្តកិច្ចលទ្ធកម្មឃុំ សង្កាត់ តាមរយៈការប្រើវិធីសាស្ត្រការប្រមូលទិន្នន័យចម្បង និងការប្រមូលទិន្នន័យបន្ទាប់បន្សំ។

- វិធីសាស្ត្រនៃការប្រមូលទិន្នន័យចម្បង គឺធ្វើឡើងដោយតាមរយៈការចុះស្រាវជ្រាវស្រង់ទិន្នន័យ និងសុំឯកសារសម្ភាសន៍ ដោយផ្ទាល់ពីមន្ត្រីអាជ្ញាធរជំនាញដែលបម្រើការនៅសាលាឃុំសែនដីផ្ទាល់។
- វិធីសាស្ត្រនៃការប្រមូលទិន្នន័យបន្ទាប់បន្សំ គឺធ្វើឡើងដោយតាមរយៈការស្វែងរកនូវឯកសារនានា តាមប្រព័ន្ធអ៊ីនអឺណេត គេហទំព័រនានា ព្រមទាំងលិខិតបទដ្ឋានគតិយុត្តដែលទាក់ទងនិងលទ្ធកម្មសាធារណៈ ក៏ដូចជាឯកសារផ្សេងៗក្នុងបណ្ណាល័យជាដើម។

## ៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សារណាបញ្ចប់ការសិក្សានេះចែកចេញជា ៣ ជំពូកសំខាន់ៗដូចជា ៖

**ជំពូកទី១៖** រំលឹកទ្រឹស្តី

**ជំពូកទី២៖** រដ្ឋបាលដែនដីឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ

**ជំពូកទី៣៖** ការគ្រប់គ្រង និងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈក្នុងឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។

# ជំពូកទី ១

# រដ្ឋបាលដែនដីឃុំសែនដី

# ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ

# ជំពូកទី១
# រដ្ឋបាលដែនដីឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ

## ផ្នែកទី១៖ ទីតាំងភូមិសាស្ត្រ

### ១. ស្ថានភាពទូទៅ

ឃុំសែនដី ជាឃុំមួយស្ថិតនៅទិសអាគ្នេយ៍នៃស្រុកសំរោងទង ខេត្តកំពង់ស្ពឺ និងមានចម្ងាយប្រមាណ ២០គីឡូម៉ែត្រពីសាលាស្រុក និងប្រមាណ៣០គីឡូម៉ែត្រ ពីសាលាខេត្តកំពង់ស្ពឺ ដោយមានព្រំប្រទល់ខាងកើតទល់និងឃុំរកាកោះ ស្រុកគងពិសី ខាងត្បូងទល់និងឃុំពេជ្រមុន្នី ស្រុកគងពិសី ខាងលិចទល់និងឃុំស្ទុះ និងខាងជើងទល់ឃុំរលាំងគ្រើលនិងឃុំរលាំងចក។ ឃុំសែនដីចែកចេញជា២១ភូមិ និងមានផ្ទៃដីសរុបចំនួន១៦៩៨.៧៧ ហិកតា។

ប្រព័ន្ធគមនាគមន៍សំខាន់ៗរបស់ឃុំសែនដី មានផ្លូវជាតិលេខ៤១កាត់តាមភាគខាងកើតនៃឃុំ និងមានផ្លូវលំជាច្រើនទៀត តភ្ជាប់ទំនាក់ទំនងឃុំទៅឃុំផ្សេងទៀត និងពីភូមិមួយទៅភូមិមួយទៀតក្នុងឃុំ។ ប្រព័ន្ធធារាសាស្ត្រសំខាន់ៗក្នុងឃុំ មានប្រឡាយមេមួយខ្សែ និងប្រឡាយរងបីខ្សែ ព្រមទាំងទំនប់៨កន្លែង។ ឃុំសែនដីមានអនុវិទ្យាល័យចំនួន១កន្លែង បឋមសិក្សាចំនួន៤កន្លែង និងមត្តេយ្យសហគមន៍ចំនួន៨កន្លែង។ ឃុំសែនដី មិនទាន់មានមណ្ឌលសុខភាពទេ ប្រជាពលរដ្ឋក្នុងឃុំអាចទទួលបានសេវាសុខភាពពីមន្ទីរពេទ្យបង្អែកខេត្ត កំពង់ស្ពឺ ឬមណ្ឌលសុខភាពរលាំងសែន រកាកោះ និងរលាំងចក។ ចំពោះវត្តអារាមឃុំសែនដីមានវត្តចំនួន៤កន្លែង ជាវត្តមហានិកាយដែលជាកន្លែងសម្រាប់បងប្អូនប្រជាពលរដ្ឋគោរពបូជាតាមក្បួនព្រះពុទ្ធសាសនា។[2]

#### ១.១ ស្ថានភាពប្រជាជន

ប្រជាពលរដ្ឋទូទាំងឃុំសរុប ១៥,៦៧៧នាក់ ស្រី៧,៩៧៨នាក់ គ្រួសារសរុប ៣៣៣១គ្រួសារ(គិតត្រឹមខែធ្នូ ឆ្នាំ២០២៣)។ ប្រជាពលរដ្ឋភាគច្រើនប្រកបរបរកសិកម្ម និងជាកម្មកររោងចក្រ ហើយមួយចំនួនតូចទៀតប្រកបរបរលក់ដូរជាលក្ខណៈគ្រួសារ។

**តារាងទី១.តារាងទិន្នន័យចម្បងរបស់ឃុំសែនដី[3]**

| ល.រ | បរិយាយ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|
| **ព័ត៌មានទូទៅ** | | | | |
| ១. | ផ្ទៃដីឃុំ(គ.ម$^២$) | ១៧ | ១៦.៣៩ | ១៦.៩៩ |
| ២. | ចំនួនភូមិ | ២១ | ២១ | ២១ |

[2] - សៀវភៅស្តីពីកម្មវិធីវិនិយោគបីឆ្នាំរំកិល២០២៤ - ២០២៦ ឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។

[3] - សៀវភៅស្តីពីកម្មវិធីវិនិយោគបីឆ្នាំរំកិល២០២៤ - ២០២៦ ឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។

| | | | | |
|---|---|---|---|---|
| ៣. | ចំនួនគ្រួសារ | ៣៣៣១ | ៣៤០៧ | ៣៤៣២ |
| ៤. | ចំនួនប្រជាជនសរុប | ១៤៩៦១ | ១៥២២៩ | ១៥៦៧៧ |
| ៥. | ចំនួនស្រី | ៧៦១៨ | ៧៧៣៦ | ៧៩៧៨ |
| ៦. | ចំនួនប្រុស | ៧៣៤៣ | ៧៤៩៣ | ៧៦៩៩ |
| ៧. | %អ្នកមានអាយុពី០-១៧ឆ្នាំ | ៣៦.៣ | ៣៤.៤ | ៣៣.៨ |
| ៨. | %អ្នកមានអាយុពី១៨ឆ្នាំឡើង | ៥៥.១ | ៥៦.៨ | ៥៦.៦ |
| ៩. | %អ្នកមានអាយុ៦១ឆ្នាំឡើង | ៨.៦ | ៨.៩ | ៩.៦ |
| ១០. | %មេគ្រួសារជាស្ត្រី | ១៨ | ១៧.៣ | ១៩.១ |
| ១១. | %កំណើនប្រជាជនប្រចាំឆ្នាំ | ១.៨ | ១.៧៤ | ១.០៣ |
| ១២. | %អត្រានៃភាពក្រីក្រ | ៨.៦១ | ៨.៤៨ | ៨.៤៥ |
| ១៣. | %អ្នកមានមុខរបរផ្នែកកសិកម្ម | ៥៨ | ៥២.១ | ៤៨ |
| ១៤. | %អ្នកមានមុខរបរផ្នែកសិប្បកម្ម | 0 | 0 | 0 |
| ១៥. | %អ្នកមានមុខរបរផ្នែកសេវាកម្ម | ៤១ | ៤៧.៩ | ៥២ |
| ១៦. | %មនុស្សរកការងារធ្វើក្នុងប្រទេស | 0.៦ | 0.៣ | 0.៦ |
| ១៧. | %មនុស្សរកការងារធ្វើក្រៅប្រទេស | 0.៤ | 0.៣ | 0.៣ |
| ១៨. | %ខ្នងផ្ទះមានអគ្គិសនីប្រើប្រាស់ | ១00 | ១00 | ១00 |

## ១.២ ការបែងចែកមណ្ឌលរដ្ឋបាលដែនដី និងស្ថានភាពនៃការប្រើប្រាស់ដី

### ១.២.១ មណ្ឌលរដ្ឋបាលដែនដី

នៅក្នុងឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺចែកចេញជា២១ភូមិដែលមានផ្ទៃដីសរុបចំនួន ១៦៩៨.៧៧ ហិកតា។

**តារាងទី២.តារាងឈ្មោះភូមិ នៃឃុំសែនដី**[4]

| ល.រ | ឈ្មោះភូមិ | | | | |
|---|---|---|---|---|---|
| ១. | ភូមិព្រៃស្បា | ៨. | ភូមិអូរចេក | ១៥. | ភូមិព្រៃរំដួល |
| ២. | ភូមិស្វាយតារង | ៩. | ភូមិមហាលំពាំងទី១ | ១៦. | ភូមិត្រពាំងប្រីយ |
| ៣. | ភូមិសែនដី | ១០. | ភូមិទំនប់ | ១៧. | ភូមិត្រោកវែង |
| ៤. | ភូមិស្រះស្រង់ | ១១. | ភូមិថ្លុកអណ្តាស់ | ១៨. | ភូមិវាលវង់ |
| ៥. | ភូមិផ្លូវជ្រូក | ១២. | ភូមិសំរោងជើងភ្នំ | ១៩. | ភូមិត្រពាំងកែស |
| ៦. | ភូមិដូនកែវ | ១៣. | ភូមិមហាលំពាំងទី២ | ២០. | ភូមិព្រៃជ្រាវ |
| ៧. | ភូមិទួលតាសុខ | ១៤. | ភូមិស្រែត្រោក | ២១. | ភូមិត្រពាំងដំរី |

[4] - សៀវភៅស្តីពីកម្មវិធីវិនិយោគបីឆ្នាំរំកិល២០២៤ - ២០២៦ ឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។

### ១.២.២ ស្ថានភាពនៃការប្រើប្រាស់ដីធ្លី

ឃុំសែនដី មានផ្ទៃដីសរុបចំនួន ១៦៩៨.៧៧ហិកតា ដែលនៅក្នុងនោះផ្ទៃដីកសិកម្មមានចំនួន ១,១៧២ ហិកតា។ ក្រៅពីនោះផងដែរ ជាផ្ទៃដីលំនៅដ្ឋាន ដីភ្នំ ដីទំនប់ បឹងនិងប្រឡាយ។ ឃុំសែនដីកំពុងចុះវាស់វែងដីធ្លីជាលក្ខណៈប្រព័ន្ធ។ សណ្ឋានដីឃុំមានចំនួន២ផ្នែកគឺ ដីទំនាប និងដីភ្នំ។ បច្ចុប្បន្ននេះ មិនមានបងប្អូនប្រជាពលរដ្ឋណាម្នាក់ពុំមានដីសាងសង់ទេ គឺមានតែការខ្វះខាតដីបង្កបង្កើនផល។ ចំណែកដីកសិកម្មវិញ ដោយសារតែឃុំសែនដីមានប្រឡាយមេ រលាំងជ្រៃខាងត្បូង ហូរឆ្លងកាត់ឃុំ ទើបបានធ្វើឱ្យប៉ែកខាងជើងឃុំមានប្រឡាយរង អូរ បឹង។ ក្រៅពីស្ថានដីខាងលើក៏មានដីពុះឡូត៍លក់របស់ឈ្មួញអាជីកម្ម ដីឡូត៍ជាប្រភេទផ្ទះល្វែងនិងដីឧស្សាហកម្មរោងចក្រផ្សេងៗ។

## ២. ស្ថានភាពនៃការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

### ២.១ ការគ្រប់គ្រងរដ្ឋបាល

ការគ្រប់គ្រង និងចាត់ចែងកិច្ចការរដ្ឋបាល គឺមានការបែងចែកស្របទៅតាមប្រកាសរបស់ក្រសួងមហាផ្ទៃជាពិសេសតួនាទី និងភារកិច្ចរបស់មេឃុំ ជំទប់ និងសមាជិកក្រុមប្រឹក្សាឃុំ ដោយបានអនុវត្តតាមអនុក្រឹតលិខិតបទដ្ឋានគតិយុត្តនានា។

ការធ្វើសេចក្តីសម្រេចគឺធ្វើតាមបែបបទប្រជាធិបតេយ្យ ដោយបើកទូលាយ ឱ្យមានការចូលរួមពីប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា។ ការអនុវត្តការងាររដ្ឋបាល ការកសាងផែនការអភិវឌ្ឍ ការចំណាយថវិកាមូលនិធិឃុំ ប្រកបដោយតម្លាភាព សុចរិតភាព និងគណនេយ្យភាព។ ទោះបីជាមានចំណុចល្អៗច្រើនហើយក៏ដោយ ក៏ឃុំនៅមានចំណុចខ្វះខាតមួយចំនួនដូចជា ៖

- ការអនុវត្តការងារមានការយឺតយ៉ាវ មូលហេតុក្រុមប្រឹក្សាឃុំ និងថ្នាក់ដឹកនាំភូមិមានវ័យចំណាស់
- មិនមាន ជំនាញលើសម្ភារបច្ចេកវិទ្យា និងការងារបច្ចេកទេសមួយចំនួន។

ដើម្បីឱ្យការគ្រប់គ្រងរដ្ឋបាលកាន់តែប្រសើរឡើង ទាំងក្រុមប្រឹក្សាឃុំ ស្មៀនឃុំ ជំនួយការហិរញ្ញវត្ថុ ជំនួយការរដ្ឋបាល ជនបង្គោល ថ្នាក់ដឹកនាំភូមិ ត្រូវមានការបណ្តុះបណ្តាលពង្រឹងសមត្ថភាព បច្ចេកទេស និងការងាររដ្ឋបាលបន្ថែម ។

### ២.២ សមាសភាពនៃក្រុមប្រឹក្សាឃុំ សង្កាត់

ក្រុមប្រឹក្សាឃុំ សង្កាត់កើតឡើងពីការបោះឆ្នោតដោយផ្ទាល់ពីប្រជាពលរដ្ឋនៅក្នុងឃុំ សង្កាត់ និងមានស្វ័យភាពក្នុងការដឹកនាំ ការចាត់ចែងកិច្ចការនានាក្នុងការបម្រើសេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន សំដៅឆ្លើយតបទៅ នឹងសេចក្តីត្រូវការជាអាទិភាពជាក់ស្តែងរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

ក្រុមប្រឹក្សាឃុំ សង្កាត់មានសមាជិកពី ០៥រូប ទៅ ១១រូប ផ្អែកតាមភូមិសាស្ត្រ និងចំនួនប្រជាពលរដ្ឋ

ដែលកំពុងរស់នៅក្នុងឃុំ សង្កាត់នីមួយៗ។ ចំនួនជាក់ស្តែងនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវកំណត់ ដោយអនុក្រឹត្យ។ ក្រុមប្រឹក្សាឃុំ សង្កាត់មានអាណត្តិ៥ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលមានក្រុមប្រឹក្សាឃុំ សង្កាត់ថ្មីចូលកាន់តំណែង។

ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗមានប្រធាន០១រូប ដែលហៅថាប្រធានក្រុមប្រឹក្សាឃុំ សង្កាត់។ ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ គឺជាមេឃុំ ចៅសង្កាត់។ ឃុំ សង្កាត់នីមួយៗមានមេឃុំ ចៅសង្កាត់ម្នាក់។ មេឃុំ ចៅសង្កាត់មានជំនួយការ០២រូប គឺជំទប់ទី១ ឬចៅសង្កាត់រងទី១ និងជំទប់ទី២ ឬចៅសង្កាត់រងទី២។

ជាមួយនេះ ឃុំ សង្កាត់ត្រូវមានបុគ្គលិកក្របខណ្ឌរដ្ឋបាលនៃក្រសួងមហាផ្ទៃមួយរូបជា ស្មៀនឃុំសង្កាត់។ ទន្ទឹមនេះ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗ ត្រូវរៀបចំជ្រើសរើសឱ្យមានមេភូមិ និងជំនួយការភូមិសម្រាប់ភូមិនីមួយៗក្នុងឃុំ សង្កាត់របស់ខ្លួន។ ក្រុមប្រឹក្សាក៏អាចធ្វើការជ្រើសរើសបុគ្គលិកក្រៅក្របខណ្ឌរដ្ឋ ដើម្បីជួយដល់កិច្ចការរបស់ខ្លួនផងដែរ។[5]

## ២.៣ រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាល

**តារាងទី៣. រចនាសម្ព័ន្ធរដ្ឋបាលឃុំ សង្កាត់**




[5] - សៀវភៅណែនាំស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០២២។

## ២.៤ តួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់

ក្រុមប្រឹក្សាឃុំសង្កាត់មានតួនាទី និងភារកិច្ចចាត់ចែងកិច្ចការជាចាំបាច់នានា សម្រាប់បម្រើផលប្រយោជន៍ឃុំ សង្កាត់ និងប្រជាពលរដ្ឋ ក្នុងឃុំសង្កាត់របស់ខ្លួន ។

- **តួនាទីក្នុងការរៀបចំកិច្ចប្រជុំ៖** ក្រុមប្រឹក្សាឃុំសង្កាត់ ត្រូវបំពេញការងាររបស់ខ្លួនតាមរយៈកិច្ចប្រជុំក្រុមប្រឹក្សា។ កិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវប្រជុំយ៉ាងតិចឱ្យបានមួយដងក្នុងមួយខែ។ កិច្ចប្រជុំក្រុមប្រឹក្សាត្រូវធ្វើការពិនិត្យ ពិភាក្សា និងអនុម័តលើកិច្ចការនានាពាក់ព័ន្ធទៅនឹងការអនុវត្ត មុខងារ និងអំណាចរបស់ក្រុមប្រឹក្សា ។
- **តួនាទីក្នុងការរៀបចំបទបញ្ជាផ្ទៃក្នុង៖** មុនចាប់ផ្តើមការងារ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗត្រូវរៀបចំ និងអនុម័តបទបញ្ជាផ្ទៃក្នុង ដើម្បីកំណត់នូវវិធានទាំងឡាយសម្រាប់អង្គប្រជុំ និងរបៀបរបបធ្វើការងាររបស់ក្រុមប្រឹក្សា។ បទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើជាទម្រង់ដីកា និងត្រូវពិភាក្សា អនុម័តក្នុងកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់យ៉ាងយូរបំផុតក្នុងរយៈពេល ៣០ថ្ងៃ បន្ទាប់ពីកិច្ចប្រជុំដំបូង មុននឹងឈានទៅអនុវត្តកិច្ចការផ្សេងទៀត។

### ២.៤.១ ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ មានភារកិច្ច ៖

- ធ្វើជាអធិបតី នៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- ធានាថា ក្រុមប្រឹក្សាឃុំ សង្កាត់បានប្រជុំយ៉ាងតិចមួយដង ក្នុងមួយខែ
- ធានាថាកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានប្រព្រឹត្តឡើង ស្របទៅតាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា ឃុំ សង្កាត់
- រក្សារបៀបរៀបរយ និងសណ្តាប់ធ្នាប់ក្នុងពេលប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់។

### ២.៤.២ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់មានភារកិច្ច ៖

- ធានាថាក្រុមប្រឹក្សាឃុំ សង្កាត់ប្រើប្រាស់អំណាចតួនាទី និងមុខងារ ដូចមានចែងនៅក្នុងច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធ
- ចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- ធ្វើកិច្ចសហប្រតិបត្តិការជាមួយប្រជាពលរដ្ឋ។

### ២.៥ តួនាទី និងភារកិច្ច

#### ២.៥.១ មេឃុំចៅ សង្កាត់

- មានសិទ្ធិចុះហត្ថលេខាលើដីកា និងសេចក្តីសម្រេចរបស់ឃុំ សង្កាត់របស់ខ្លួន
- មានសិទ្ធិតែងតាំងគណៈកម្មាធិការជំនួយការនានាតាមការចាំបាច់ ដើម្បីផ្តល់យោបល់ឱ្យខ្លួន
- មានសិទ្ធិចុះហត្ថលេខាលើលិខិតស្នើសុំសេវារដ្ឋបាលនៅឃុំ សង្កាត់របស់ខ្លួន
- ធានាថាសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានអនុវត្តន៍
- រាយការណ៍អំពីការបំពេញការងារប្រចាំខែជូនក្រុមប្រឹក្សាឃុំ សង្កាត់
- ផ្តល់យោបល់ និងជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់លើការងារកសាងផែនការ ការងារថវិកាហិរញ្ញវត្ថុ និងការអនុវត្តអំណាច តួនាទីនិងមុខងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- ផ្ទេរសិទ្ធិដល់ជំទប់ ចៅសង្កាត់រងតាមឋានានុក្រមពេលខ្លួនអវត្តមាន
- បំពេញភារកិច្ចផ្សេងទៀតដែលក្រុមប្រឹក្សាឃុំ សង្កាត់ប្រគល់ឱ្យ។

#### ២.៥.២ ជំទប់ទី១ ចៅសង្កាត់រងទី១

- ទទួលជួយមេឃុំចៅសង្កាត់លើកិច្ចការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បំពេញការងារជាមេឃុំ ចៅសង្កាត់ស្តីទី ក្នុងករណីដែលមេឃុំ ចៅសង្កាត់អវត្តមាន
- នៅពេលទទួលស្តីទី មិនអាចផ្ទេរទៅឱ្យជំទប់ទី២ ចៅសង្កាត់រងទី២បានឡើយ
- បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់របស់មេឃុំ ចៅសង្កាត់។

#### ២.៥.៣ ជំទប់ទី២ ចៅសង្កាត់រងទី២

- ជួយមេឃុំ ចៅសង្កាត់លើការងារផ្នែករដ្ឋបាល សេវាសង្គមកិច្ច សេវាសាធារណៈ និងសណ្តាប់ធ្នាប់សាធារណៈ
- បំពេញការងារជាមេឃុំ ចៅសង្កាត់ស្តីទី ក្នុងករណីដែលមេឃុំ ចៅសង្កាត់ និងជំទប់ទី១ចៅសង្កាត់រងទី១អវត្តមាន នៅពេលទទួលស្តីទី មិនអាចផ្ទេរបន្តបានឡើយ
- បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់របស់មេឃុំ ចៅសង្កាត់។

# ផ្នែកទី២ ៖ ស្ថានភាពបច្ចុប្បន្ន និងការងារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

## ១. ស្ថានភាពបច្ចុប្បន្នក្នុងមូលដ្ឋានឃុំសែនដី

### ១.១ ស្ថានភាពសេដ្ឋកិច្ច

- **កសិកម្ម៖** ឃុំសែនដីមានផ្ទៃដីបង្កបង្កើនផលសរុប១១៧២ហិកតា និងមានប្រជាពលរដ្ឋចំនួន ប្រមាណ ៦២.២% ប្រកបរបរធ្វើស្រែ និងចម្ការ ដាំដំណាំរួមផ្សំ និងចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ។ ភូមិសាស្ត្រឃុំភាគច្រើនជាតំបន់វាល ហើយមានភ្នំនៅភាគនិរតី ដីភាគច្រើនជាដីគ្រួសក្រហម ដីល្បាយ ខ្សាច់ និងដីឥដ្ឋ

ពុំសូវមានជីវជាតិទេ។ ឃុំមានប្រឡាយមេ ០១ខ្សែ គឺប្រឡាយមេរលាំងជ្រៃខាងត្បូង និង ប្រឡាយរង ០៣ ខ្សែ ជាប្រភពទឹកសម្រាប់ស្រោចស្រពប៉ែកខាងជើងនៃឃុំ។ ឃុំក៏មានទំនប់ ប្រាំបីកន្លែងនិង ស្រះទឹក ជាអាងស្តុបទឹកប្រើប្រាស់តាមតម្រូវការរបស់បងប្អូនប្រជាពលរដ្ឋបានមួយចំនួនផងដែរ។

❖ **ការប្រកបរបរអាជីវកម្ម និងសិប្បកម្ម៖** ការប្រកបរបរអាជីវកម្ម និងសិប្បកម្មក្នុងឃុំសែនដី មិនមានអ្វីគួរឱ្យកត់សម្គាល់ទេគឺមានតែកសិដ្ឋានខ្លះៗ និងសិប្បកម្មលក្ខណៈគ្រួសារបន្តិចបន្តួច។ ក្រៅពីនោះមានការប្រកបរបរលក់ដូរខ្នាតតូចៗ ដើម្បីបម្រើសេចក្តីត្រូវការរបស់បងប្អូនប្រជាពលរដ្ឋក្នុងឃុំ។

❖ **ឧស្សាហកម្ម៖** នៅប៉ុន្មានឆ្នាំចុងក្រោយនេះវិស័យឧស្សាហកម្មបានរីកចម្រើនក្នុងឃុំគួរឱ្យកត់សម្គាល់ជាក់ស្តែងក្នុងឃុំសែនដីមានសួនឧស្សាហកម្មចំនួន ០១កន្លែង រោងចក្រ០៤កន្លែងដែលស្រូបយកកម្មករប្រមាណជាង១៥០០០នាក់។

❖ **គមនាគមន៍៖** ប៉ែកខាងកើតនៃឃុំសែនដីជាប់និងផ្លូវជាតិលេខ៤១ កាត់ទឹកដីឃុំប្រវែងប្រមាណ ៥គីឡូម៉ែត្រដែលជាផ្លូវតភ្ជាប់សេដ្ឋកិច្ចមួយយ៉ាងសំខាន់របស់ឃុំ ក៏ដូចជាស្រុក និងខេត្តកំពង់ស្ពឺទៅខេត្តផ្សេងៗទៀត។ ហេតុដូចនេះហើយទើបប្រជាពលរដ្ឋឃុំសែនដីមានឱកាសច្រើនក្នុងការប្រកបរបរផ្សេងៗចិញ្ចឹមជីវភាពប្រចាំថ្ងៃរបស់ពួកគាត់។ ក្រៅពីនេះឃុំសែនដីក៏មានផ្លូវលំក្រាលកៅស៊ូ០២ខ្សែ ផ្លូវបេតុងប្រវែង៣២១៨ម៉ែត្រ គ្រួសក្រហមជាច្រើនខ្សែទៀតដែលសាងសង់ និងជួសជុលដោយ **ឯកឧត្តមបណ្ឌិត ម៉ុង ឫទ្ធី** មន្ទីរអភិវឌ្ឍន៍ជនបទ និងមូលនិធិឃុំ និងសប្បុរសជន ក្រៅពីនេះមានស្ពានចំនួន០៣កន្លែងនិងលូកាត់ផ្លូវជាច្រើនទៀត និងមានស្ពានប្រឡាយ០៤ខ្សែ។

❖ **សេវាកម្ម៖** ឃុំសែនដីមិនមានផ្សារលក់ដូរធំនោះទេ មានត្រឹមតែតូបលក់ចាប់ហួយតូចៗតាមភូមិ ក្នុងឃុំ។ អ្នកបម្រើការងារលក់ដូរ និងជំនួញ មានចំនួន១.៣% ការងារជាជាងជួសជុលមានចំនួន0.២% អ្នកបម្រើការងារស៊ីឈ្នួលក្នុងវិស័យកសិកម្ម កម្មករ សំណង់៨.៤% អ្នកបម្រើការងារក្នុងវិស័យឯកជន (កម្មកររោងចក្រ បុគ្គលិក អង្គការ)មានចំនួន៤០.៨% អ្នកបម្រើការងារជាមន្ត្រីរាជការ១.២%។ ឃុំសែនដីមានប្រព័ន្ធអគ្គិសនីប្រើប្រាស់គ្រប់ភូមិ។ រីឯប្រព័ន្ធទឹកស្អាតមានការតភ្ជាប់បាន២១ភូមិហើយ ។

❖ **ការវិនិយោគ ៖** ការចូលរួមរបស់វិស័យឯកជនក្នុងការអភិវឌ្ឍ បានធ្វើឱ្យឃុំមានការរីកចម្រើនយ៉ាងខ្លាំងវិស័យឯកជន ជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ច ប្រជាពលរដ្ឋដែលនឹងឈានទៅរកការអភិវឌ្ឍការលើកកម្ពស់ជីវភាពរស់នៅ និងគុណភាពជីវិតដែលកំពុងតែកើនឡើង។ ជាក់ស្តែងការវិនិយោគ លើវិស័យកាត់ដេរ បានធ្វើឱ្យកម្រិតជីវភាពប្រជាជនមានការរីកចម្រើនប្រាក់ចំណូលទទួលបានសមរម្យពីការងាររោងចក្រ។ ឃុំសែនដី ក៏បានទទួលការវិនិយោគលើវិស័យកសិកម្ម ដំណាំចំការ របស់ **ឯកឧត្តមបណ្ឌិត ម៉ុង ឫទ្ធី** នៅលើផ្ទៃដីជើងភ្នំក្នុងភូមិសំរោងជើងភ្នំ ដែលធ្វើឱ្យប្រជាពលរដ្ឋ នៅក្នុងឃុំមានការងារធ្វើ

កាត់បន្ថយនៅភាពក្រីក្រមួយកម្រិតផងដែរ។

## ១.២ ស្ថានភាពសង្គមកិច្ច

- **ការអប់រំ ៖** ការរីកចម្រើន ក្នុងវិស័យអប់រំរបស់ឃុំសែនដីបានចូលរួមចំណែកឱ្យការអប់រំមានគុណភាព ស្របតាមគោលនយោបាយ និងយុទ្ធសាស្ត្រនៃវិស័យអប់រំ។ ជាក់ស្តែងក្នុងឃុំមាន អនុវិទ្យាល័យ០១កន្លែង សាលាបឋមសិក្សា០៤កន្លែង និងមត្តេយ្យសិក្សាសហគមន៍០៨កន្លែង ក្នុងនោះមានសិស្សានុសិស្សពីកម្រិតបឋមដល់អនុវិទ្យាល័យចំនួន១៦៤៧នាក់ ស្រី៨២៣នាក់ និងគ្រូបង្រៀនសរុបចំនួន៣៨នាក់ ស្រី២៤នាក់។
- **សុខាភិបាល ៖** ក្នុងឃុំសែនដីមិនទាន់មានមណ្ឌលសុខភាពទេ ប្រជាពលរដ្ឋក្នុងឃុំអាចទទួល បានសេវាសុខភាពពីមន្ទីរពេទ្យបង្អែកខេត្តកំពង់ស្ពឺ ឬមណ្ឌលសុខភាពរលាំងសែន មណ្ឌលរកាកោះ និងមណ្ឌលរលាំងចក។ ឯការយល់ដឹងពីសុខភាព អនាម័យរបស់ប្រជាពលរដ្ឋនៅឃុំក៏មានការកើនឡើងដែរ។ ជាក់ស្តែង អត្រាគ្រួសារមានបង្គន់អនាម័យប្រើប្រាស់មានលើសពី៩៩.២៦% ហើយ អត្រាគ្រួសារប្រើប្រាស់ទឹកស្អាតមានចំនួនប្រហែល៩៩.៥២%។ នេះក៏បានមកពីការខិតខំប្រឹងប្រែង អប់រំផ្សព្វផ្សាយពីសុខភាពអនាម័យ របស់ក្រុមប្រឹក្សាឃុំ គណកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ(គ.ក.ន.ក) របស់ឃុំ និងមន្ទីរជំនាញនិងដៃគូរអភិវឌ្ឍន៍។
- **សាសនា ៖** រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាបានចែងថា ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ក្រោយថ្ងៃរំដោះ ៧ មករា ឆ្នាំ១៩៧៩ ព្រះពុទ្ធសាសនានិងសាសនានានាត្រូវបានបង្កើតឡើងវិញ។ បច្ចុប្បន្ននៅក្នុងឃុំសែនដីមានវត្តអារាមសរុបចំនួន៤វត្ត ព្រះសង្ឃមានចំនួន៧៥អង្គ និងមានតាជីយាយជី ចំនួន៦៣នាក់។ នៅក្នុងឃុំមាន ព្រះវិហាគ្រឹះសាសនាចំនួន៣កន្លែង។ ប្រជាពលរដ្ឋនៅក្នុងឃុំសែនដីកាន់ព្រះពុទ្ធសាសនាចំនួនប្រហែល៩៥%។
- **យេនឌ័រ ៖** ការលើកកម្ពស់យេនឌ័រមានការរីកចម្រើនគួរឱ្យកត់សម្គាល់ជាក់ស្តែង ក្នុងអាណត្តិទី៥ របស់ក្រុមប្រឹក្សាឃុំមានស្ត្រីមួយនាក់ ស្មៀនឃុំជាស្ត្រី និងស្ត្រីជាថ្នាក់ដឹកនាំភូមិមាន២៥នាក់ ហើយមានជនបង្គោលផ្សព្វផ្សាយវាយតម្លៃឃុំជាស្ត្រី។ គណៈកម្មាធិការទទួលបន្ទុកកិច្ចការស្ត្រីនិងកុមារឃុំ ដោយមានជនបង្គោលទទួលបន្ទុកកិច្ចការស្ត្រី និងកុមារ ជាសេនាធិការបានខិតខំអនុវត្តការងារក្នុងការលើកកម្ពស់ស្ត្រី និងកុមារក្នុងឃុំ ដូចជាបង្កើតការអប់រំជំនាញដល់ស្ត្រីក្រីក្រក្នុងឃុំ និងក្មេងស្រីៗការពារផ្លូវច្បាប់ដល់ស្ត្រីនិងកុមារ និងការផ្សព្វផ្សាយការលើកកម្ពស់សុខភាពស្ត្រី និងកុមារក៏ដូចជាការបង្កើនតួនាទីស្ត្រីក្នុងការសម្រេចចិត្ត។

- **ភាពក្រីក្រ ៖** ផ្អែកតាមលទ្ធផលជំរឿនភាពក្រីក្របន្ទាត់ក្រីក្ររបស់ឃុំសែនដីមានចំនួន៨,៤៥% ក្នុងឆ្នាំ ២០២៣ កម្រិតភាពក្រីក្ររបស់ប្រជាពលរដ្ឋឃុំសែនដីត្រូវបានថយចុះបន្តិចម្តងៗជាបន្តបន្ទាប់។ ហើយ កត្តានៃភាពក្រីក្រនេះបណ្តាលមកពីការខ្វះដីធ្វើស្រែ (ដីលក់បន្តបន្ទាប់) កសិករមួយចំនួន គ្មានជំនាញ និងដើមទន់ក្នុងការប្រកបមុខរបរបន្ថែមហើយ គ្រួសារខ្លះមានកូនច្រើន និងកម្មករ កម្មការិនីរោងចក្រ មួយចំនួនត្រូវបានព្យួរការងារ និងអត្រាបាត់បង់ការងារ និង គ្រោះមហន្តរាយជាដើម។ ដោយការយក ចិត្តទុកដាក់របស់រាជរដ្ឋាភិបាល លោកបានបង្កើតឱ្យមានកម្មវិធីជាច្រើនដើម្បីជួយសម្រួលដល់ប្រជា ពលរដ្ឋងាយរងគ្រោះដូចជា កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងគ្រោះ ដែលមានប័ណ្ណសមធម៌ កម្មវិធីឧបត្ថម្ភប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារក្រោមអាយុ២ឆ្នាំ និងប្រាក់ឧបត្ថម្ភដល់គ្រួសារហានិភ័យ កម្មវិធីទាំងនេះបានជួយសម្រួលដល់ជីវភាពដែលគ្រួសារងាយរងគ្រោះ និងគ្រួសារងាយរងហានិភ័យបាន មួយកម្រិត។

## ២. ការគ្រប់គ្រងស្ថិតិ និងការងារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

### ២.១ ការងារគ្រប់គ្រងស្ថិតិ

សម្រាប់ការងារអត្រានុកូលដ្ឋានរបស់ឃុំសែនដី បានដំណើរការចុះជារៀងរាល់ថ្ងៃ មកដល់ដើមឆ្នាំ២០២៣ នេះ ឃុំបានចុះសំបុត្រកំណើតបានប្រមាណជា៩៩%ហើយ។

ទោះជាយ៉ាងក្តី ឃុំនៅជួបប្រទះបញ្ហាក្នុងការបម្រើសេវាអត្រានុកូលដ្ឋានដូចជា ៖

- ខ្វះសៀវភៅអត្រានុកូលដ្ឋាន និង ឯកសារអត្រានុកូលដ្ឋានដើម្បីសរសេរ និងចេញជូនប្រជាពលរដ្ឋ
- សំបុត្រកំណើត និងបញ្ជាក់កំណើតរបស់ប្រជាជនខុសអក្ខរាវិរុទ្ធ ឬថ្ងៃខែឆ្នាំកំណើត នៅពេលមានការ ផ្ទៀងផ្ទាត់ជាមួយសញ្ញាបត្រ សៀវភៅគ្រួសារ អត្តសញ្ញាណប័ណ្ណ និងប័ណ្ណសម្គាល់នានា
- ប្រជាពលរដ្ឋ ខ្វះការយកចិត្តទុកដាក់ ក្នុងការថែរក្សាសំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទ បណ្តាលឱ្យ មានការខូចខាត និងបាត់បង់។

### ២.២ ការងារសន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈ

ការងារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ នៅក្នុងឃុំសែនដីទាំងមូលមានភាពល្អប្រសើរឡើងជាលំដាប់ ជាក់ស្តែងបទល្មើសផ្សេងៗត្រូវបានថយចុះ បញ្ហាបងតូចបងធំក៏លែងមាន ដោយសារតែតាមភូមិនីមួយៗមាន ប្រជាការពារយ៉ាងតិច ១០នាក់ក្នុងមួយភូមិ ជាហេតុធ្វើឱ្យមុខសញ្ញាដែលធ្លាប់ធ្វើសកម្មភាពកន្លងមកមិនហ៊ាន ធ្វើសកម្មភាព ឯការលួចឆក់ប្លន់ឬល្បែងស៊ីសងជាដើមក៏មានការថយចុះដែរ។

ម្យ៉ាងទៀតឃុំបានយកចិត្តទុកដាក់ក្នុងការផ្សព្វផ្សាយ ពីគោលនយោបាយ ភូមិឃុំមានសុវត្ថិភាព៧ចំណុច ផ្សព្វផ្សាយអំពីផលវិបាកនៃការប្រើប្រាស់គ្រឿងញៀន ផ្សព្វផ្សាយអំពីច្បាប់ចរាចរណ៍ ការធ្វើវេទិកាសាធារណៈតាមភូមិជារៀងរាល់ឆ្នាំ ដើម្បីស្តាប់ពីទុក្ខកង្វល់របស់ប្រជាពលរដ្ឋ និងមានវិធានការឆ្លើយតប ចំពោះប្រជាពលរដ្ឋ។

❖ គោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ៧ចំណុចរួមមាន៖

- ការផ្តល់សេវាសាធារណៈ ជាពិសេស សេវារដ្ឋបាលប្រកបដោយគុណភាព តម្លាភាព និងទទួលបានជំនឿទុកចិត្ត
- គ្មានបទល្មើសលួច ឆក់ ប្លន់ គ្រឿងញៀន ល្បែងស៊ីសងខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ
- មានសណ្តាប់ធ្នាប់សាធារណៈល្អ ជាពិសេសគ្មានគ្រោះថ្នាក់ចរាចរណ៍
- គ្មានអំពើអនាចារ គ្មានការជួញដូរមនុស្ស ពិសេសស្ត្រី និងកុមារ គ្មានអំពើហិង្សាក្នុងគ្រួសារ និងក្មេងទំនើង
- ដោះស្រាយវិវាទនៅមូលដ្ឋានក្រៅប្រព័ន្ធតុលាការប្រកបដោយគុណភាព និងប្រសិទ្ធភាព
- មានអនាម័យ មានសោភ័ណភាពល្អ និងបរិស្ថានល្អ
- ឆ្លើយតបបានទាន់ពេលវេលាចំពោះគ្រោះមហន្តរាយ និងរាល់ជំងឺឆ្លងរាតត្បាតកាចសាហាវប្រកបដោយប្រសិទ្ធភាព។

# ជំពូកទី ២

# សញ្ញាណលទ្ធកម្មសាធារណៈ នៅកម្ពុជា

# ជំពូកទី២

# សញ្ញាណលទ្ធកម្មសាធារណៈនៅកម្ពុជា

## ផ្នែកទី១ ៖ បរិបទទូទៅនៃការអនុវត្តលទ្ធកម្មសាធារណៈ

### ១. សាវតានៃលទ្ធកម្មសាធារណៈនៅកម្ពុជា

លទ្ធកម្មសាធារណៈ គឺជាសមាសធាតុដ៏សំខាន់មួយដែលមិនអាចខ្វះបាននៅក្នុងដំណាក់កាលនៃការគ្រប់គ្រងចំណាយធនធានហិរញ្ញវត្ថុសាធារណៈ និងការអនុវត្តការចំណាយថវិការរបស់រដ្ឋ។ មុនពេលការមកដល់នៃរបបអាណានិគមបារាំង នៅពុំទាន់មានឯកសារណាមកបញ្ជាក់បានឡើយ អំពីការអនុវត្តលទ្ធកម្មរបស់កម្ពុជាក្នុងសង្គមខ្មែរនាសម័យនោះទេ។ ប៉ុន្តែដោយពឹងផ្អែកទៅលើមូលដ្ឋាន អនុសញ្ញាបារាំង-ខ្មែរ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៨៨៤ គឺជាការបើកផ្លូវដ៏សំខាន់មួយនៃការឆ្ពោះទៅរកការធ្វើកំណែទម្រង់ប្រព័ន្ធគ្រប់គ្រង់រដ្ឋបាលសាធារណៈរបស់កម្ពុជា។ នៅក្នុងសម័យនៃរបបអាណានិគមបារាំង យើងអាចសង្កេតឃើញថាបទបញ្ញត្តិដែលទាក់ទងនិងការអនុវត្តកិច្ចលទ្ធកម្ម នៅពេលនោះត្រូវបានគេហៅថា៖ **ការដេញថ្លៃ ឬការដេញតថ្លៃ ឬជាវលក់ដោយដេញថ្លៃ** ដូចមានចែងក្នុងប្រការ២៨ និងប្រការ២៩នៃព្រះរាជប្រកាសចុះថ្ងៃទី១ ខែដេសម(ធ្នូ) ឆ្នាំ១៩១៦ និងប្រកាសអារេតេចុះថ្ងៃទី៥ ខែដេសម(ធ្នូ) ឆ្នាំ១៩១៦។ នៅក្នុងសម័យសង្គមរាស្ត្រនិយម និងរបបសាធារណរដ្ឋខ្មែរ ក៏ពុំមាននូវឯកសារគតិយុត្តណាដែលទាក់ទងដល់ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ នៅក្នុងនយោបាយគ្រប់គ្រងសង្គមខ្មែរនៅឡើយ។ បន្ទាប់មកនាសម័យរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈត្រូវបានលេចរូបរាងចាប់កំណើតសារជាថ្មីវិញម្តងទៀត តាមរយៈសេចក្តីសម្រេចលេខ៨៤ ស.ស.រ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៨៨ ស្តីពីគោលការណ៍ដាក់ឱ្យដេញថ្លៃលើការធ្វើអាជីវកម្មដាក់ដាយចាប់កូនត្រីប្រា ដែលជាកិច្ចលទ្ធកម្មចំណូល។[6]

ផ្អែកលើមូលដ្ឋានច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុឆ្នាំ១៩៩៤ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធទៅនឹងលទ្ធកម្មសាធារណៈមួយចំនួនត្រូវបានបង្កើតឡើង ដែលរួមមានអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៩៥ ស្តីពីលទ្ធកម្មសាធារណៈ និងប្រកាសលេខ ៣១៩សហវ.ប្រក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៩៥ ស្តីពីវិធាននិងបទប្បញ្ញត្តិសម្រាប់គ្រប់គ្រងលទ្ធកម្មសាធារណៈ។ ចាប់តាំងពីឆ្នាំ២០០៤មក តាមរយៈកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងផ្អែកតាមបទពិសោធន៍នៃការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ និងការវិវឌ្ឍសង្គមសេដ្ឋកិច្ចរបស់កម្ពុជា លិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងលទ្ធកម្មសាធារណៈមួយចំនួន ត្រូវបាន

[6] - សៀវភៅ លទ្ធកម្មសាធារណៈនៅកម្ពុជា ស្រាវជ្រាវដោយ៖ លោក ឡាញ់ ដា បោះពុម្ពឆ្នាំ២០២២។

បង្កើតបន្ថែមទៀត និងកែលម្អជាបន្តបន្ទាប់សំដៅធានាឱ្យការគ្រប់គ្រងនិង ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈប្រព្រឹត្តទៅកាន់តែមានតម្លាភាព គណនេយ្យភាព ភាពប្រកួតប្រជែង និង ប្រសិទ្ធភាព។

ដើម្បីធានាដល់ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈឱ្យកាន់តែមានប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព និងការសន្សំសំចៃ ជាមួយគ្នានោះដែររាជរដ្ឋាភិបាលបានដាក់ចេញនូវវិធាន នីតិវិធី សេចក្តីណែនាំ ព្រមទាំងការផ្ទេរសិទ្ធិសហមជ្ឍការលទ្ធកម្មដែលទាក់ទងនិងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈទៅរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ។[7]

## ២. និយមន័យ

- លទ្ធកម្ម សំដៅទៅដល់ការទិញ ឬការរកបាននូវទំនិញ សំណង់ សេវាកម្ម ឬសេវាទីប្រឹក្សា តាមរយៈវិធីសាស្ត្រដែលមានចែងក្នុងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ។
- កិច្ចលទ្ធកម្ម សំដៅទៅដល់ដំណើរការលទ្ធកម្ម ចាប់ពីពេលរៀបចំឯកសារដេញថ្លៃរហូតដល់ទទួលបានទំនិញ សំណង់ សេវាកម្ម ឬសេវាទីប្រឹក្សា។
- លទ្ធកម្មសាធារណៈ សំដៅដល់កិច្ចលទ្ធកម្មដែលធ្វើឡើងដោយក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល អង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត និងដៃគូរឯកជនសាធារណៈ។[8]
- លទ្ធកម្មសាធារណៈ ជាដំណើរការទិញទំនិញ ជួលសេវាកម្ម និងគម្រោងសាងសង់ជាសាធារណៈ ដែលមានតម្លៃសមរម្យបំផុត ប្រកបដោយគុណភាព និងបរិមាណ ទាន់ពេលវេលា មានធនធានគ្រប់គ្រាន់។[9]

### ២.១ គោលបំណងនៃកិច្ចលទ្ធកម្ម

ការបង្កើតឡើងនូវវិធាន និងបទប្បញ្ញត្តិនានាដែលពាក់ព័ន្ធនឹងលទ្ធកម្ម ក្នុងគោលបំណងធានាឱ្យការអនុវត្តចំពោះគ្រប់កិច្ចលទ្ធកម្មសាធារណៈទាំងអស់ ដោយមិនគិតពី**ប្រភពមូលនិធិ** សម្រាប់ការទិញ ការសាងសង់ ការជួសជុល ការជួលសេវាកម្ម និងការជួលសេវាទីប្រឹក្សា ប្រព្រឹត្តទៅប្រកបដោយ **តម្លាភាព គណនេយ្យភាព យុត្តិធម៌ ប្រសិទ្ធភាពគុណភាព សមភាព ការសន្សំសំចៃ និងភាពទាន់ពេលវេលា** ព្រមទាំងធានាឱ្យបាននូវ**ប្រព័ន្ធលទ្ធកម្មសាធារណៈឯកភាព** មួយនៅកម្ពុជា។

[7] - យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ២០១៩-២០២៥។

[8] - សទ្ទានុក្រមជាឧបសម្ព័ន្ធនៃច្បាប់ ស្តីពីលទ្ធកម្មសាធារណៈ ឆ្នាំ ២០១២។

[9] - សៀវភៅណែនាំស្តីពី លទ្ធកម្មសាធារណៈ ដោយអង្គការសីលការ។

### ២.២ ផលប្រយោជន៍នៃកិច្ចលទ្ធកម្មសាធារណៈ

គោលដៅចម្បងនៃការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ គឺការជួយរឹតបន្តឹងទៅលើប្រព័ន្ធចាយវាយថវិការបស់ជាតិ ការគ្រប់គ្រងលើការចំណាយហិរញ្ញវត្ថុរបស់ស្ថាប័នរដ្ឋ មន្ត្រីរាជការ ដើម្បីធានាឱ្យបាននូវការចំណាយដែលមានគណនេយ្យភាព ការសន្សំសំចៃ និងការចេះត្បិតត្បៀតនូវការចំណាយដែលមិនចាំបាច់ផ្សេងៗ របស់រដ្ឋ។

កម្មវត្ថុនៃលទ្ធកម្មសាធារណៈ មានគោលដៅសំខាន់ៗ ដូចជា៖

- ការត្បិតត្បៀត និងជួយសន្សំសំចៃថវិកាជាតិក្នុងការចំណាយលើគម្រោងនានារបស់រដ្ឋ ចំពោះលទ្ធកម្មទំនិញ សំណង់ ការជួសជុល សេវាកម្ម និងការជួលសេវាទីប្រឹក្សាជាដើម
- ទទួលបានសេវាកម្មមួយដែលល្អ និងមានគុណភាព
- បង្ហាញពីគណនេយ្យភាព តម្លាភាព របស់មន្ត្រីរាជការសាធារណៈ
- ធានាបានប្រសិទ្ធភាពនៃការគ្រប់គ្រងថវិកាជាតិ
- ទទួលបានការជឿទុកចិត្តពីសំណាក់សាធារណជន ជុំវិញការប្រើប្រាស់ ឬការចំណាយថវិកាជាតិ
- ធានាបានសេវាកម្មមួយល្អ និងបម្រើផលប្រយោជន៍សាធារណៈ
- បង្ហាញពីគណនេយ្យភាព និងតម្លាភាពនៃកិច្ចលទ្ធកម្មសាធារណៈ។[10]

## ៣. ប្រភេទនៃកិច្ចលទ្ធកម្មឃុំ សង្កាត់

ការអនុវត្តកិច្ចលទ្ធកម្ម នៅរដ្ឋបាលឃុំ-សង្កាត់ត្រូវបានបែងចែកជា០៣ ប្រភេទ គឺ លទ្ធកម្មទំនិញ លទ្ធកម្មសំណង់ និងលទ្ធកម្មសេវាកម្ម។ លទ្ធផលនៃកិច្ចលទ្ធកម្ម គឺជាកិច្ចសន្យា ដូចជា៖

- លទ្ធផលនៃលទ្ធកម្មសំណង់ គឺកិច្ចសន្យាសំណង់
- លទ្ធផលនៃលទ្ធកម្មទំនិញ គឺកិច្ចសន្យាទំនិញ
- លទ្ធផលនៃលទ្ធកម្មសេវាកម្ម គឺកិច្ចសន្យាសេវាកម្ម។

### ៣.១ លទ្ធកម្មសំណង់

លទ្ធកម្មសំណង់ គឺសម្រាប់ការសាងសង់ ការជួសជុល ឬការថែទាំហេដ្ឋារចនាសម្ព័ន្ធ ឬអគារនានា។ ជួនកាលកិច្ចសន្យាសំណង់ ក៏អាចរួមបញ្ចូលផងដែរនូវការផ្គត់ផ្គង់សម្ភារបរិក្ខារដែលត្រូវបំពាក់ទៅនឹងលទ្ធផលនៃកិច្ចសន្យា(ឧទាហរណ៍៖ ការសាងសង់អគារសិក្សាមួយខ្នង និងការផ្គត់ផ្គង់គ្រឿងសង្ហារឹម ដូចជាតុ កៅអីជាដើម)។ កិច្ចសន្យាសំណង់ត្រូវអនុវត្តដោយ **អ្នកទទួលការសំណង់ ឬអ្នកទទួលការសាងសង់**។

[10] - សៀវភៅ លទ្ធកម្មសាធារណៈនៅកម្ពុជា ស្រាវជ្រាវដោយ៖ លោក ឡាញ់ ដា បោះពុម្ពឆ្នាំ២០២២។

❖ **សម្គាល់៖** ដើម្បីមានសិទ្ធិចូលរួមដេញថ្លៃ លើរាល់គម្រោងការងារសាងសង់សាធារណៈគ្រប់ប្រភេទ នៅតាមបណ្ដាក្រសួង ស្ថាប័ន និងខេត្តក្រុង ក្រុមហ៊ុនសាងសង់នៅព្រះរាជាណាចក្រកម្ពុជា ដែលមាននីតិសម្បទាត្រឹមត្រូវ ត្រូវតែបានមកចុះឈ្មោះក្នុងបញ្ជី (អ្នកទទួលការសាងសង់) នៅនាយកដ្ឋានលទ្ធកម្មសាធារណៈ (បច្ចុប្បន្នអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ) នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីបញ្ជាក់ពីប្រភេទរបស់ក្រុមហ៊ុន និងចំណាត់ថ្នាក់នៃគម្រោងដែលក្រុមហ៊ុនអាចធ្វើបាន។[11]

### ៣.២ លទ្ធកម្មទំនិញ

លទ្ធកម្មទំនិញ ត្រូវបានប្រើប្រាស់សម្រាប់ការទិញទំនិញនានា។ អ្នកផ្គត់ផ្គង់មិនចាំបាច់ធ្វើការងារអ្វីច្រើននោះទេ គឺគ្រាន់តែផ្គត់ផ្គង់ទំនិញដល់រដ្ឋបាលឃុំ សង្កាត់ប៉ុណ្ណោះ។ នៅពេលទំនិញត្រូវបានប្រគល់ជូនរួចរាល់ហើយ រដ្ឋបាលឃុំ សង្កាត់ត្រូវធ្វើការទូទាត់ជូនអ្នកផ្គត់ផ្គង់ ហើយការបញ្ជាទិញត្រូវបានបញ្ចប់ត្រឹមនេះ។

ប្រសិនបើមានសកម្មភាពណាមួយដែលអ្នកផ្គត់ផ្គង់ត្រូវធ្វើ បន្ទាប់ពីទិញទំនិញត្រូវបានផ្គត់ផ្គង់រួចហើយនោះ រដ្ឋបាលឃុំ សង្កាត់ត្រូវចុះកិច្ចសន្យាការងារ ឬកិច្ចសន្យាផ្ដល់សេវាកម្មជាមួយអ្នកផ្គត់ផ្គង់។

### ៣.៣ លទ្ធកម្មសេវាកម្ម

លទ្ធកម្មសេវាកម្ម គឺសម្រាប់ការផ្ដល់សេវាកម្មនានា។ កិច្ចសន្យាសេវាកម្មនេះ អាចមានសកម្មភាពនានាដូចជា ការអប់រំបណ្ដុះបណ្ដាល ការរៀបចំក្រុមសហគមន៍ និងការផ្ដល់សេវាកម្មផ្នែកកសិកម្មជាដើម។

កិច្ចសន្យាសម្រាប់ការធ្វើអង្កេត និងការរៀបចំគម្រោង ការគ្រោងហេដ្ឋារចនាសម្ព័ន្ធនានា ក៏ជាកិច្ចសន្យាសេវាកម្មផងដែរ (សេវាកម្មប្រភេទនេះហៅថា សេវាវិស្វកម្ម)។

កិច្ចសន្យាសេវាកម្មត្រូវអនុវត្តដោយអ្នកផ្ដល់សេវាកម្ម។ កិច្ចសន្យាសេវាកម្ម អាចរួមបញ្ចូលទាំងការផ្គត់ផ្គង់ទំនិញ ឬសម្ភារបរិក្ខារនានា និងសំណង់តូចតាច ដែលបម្រើឱ្យសកម្មភាពនៃសេវាកម្មទាំងនោះ មួយចំណែកដើម្បីឱ្យសេវាកម្មនោះសម្រេចបាននូវគោលបំណងរបស់ខ្លួន។

## ៤. គោលការណ៍នៃកិច្ចលទ្ធកម្មសាធារណៈ

ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ត្រូវផ្អែកលើគោលការណ៍សំខាន់ៗដូចជា៖

- អ្នកទទួលការ អ្នកផ្ដល់សេវាកម្ម និងអ្នកផ្គត់ផ្គង់ ត្រូវបានផ្ដល់ឱកាសស្មើៗគ្នាដើម្បីចូលរួមនៅក្នុងដំណើរការដេញថ្លៃ ក្រោមលក្ខខណ្ឌយុត្តិធម៌ និងស្មើភាព
- លទ្ធផលនៃការដេញថ្លៃត្រូវផ្សព្វផ្សាយជាសាធារណៈ

[11] - ប្រកាសលេខ៣៦៣ សហវ.លស.ប្រក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីការចុះឈ្មោះក្នុង បញ្ជីអ្នកទទួលការសាងសង់។

➢ លទ្ធកម្មសំណង់ លទ្ធកម្មទំនិញ និងលទ្ធកម្មសេវាកម្មត្រូវអនុវត្តន៍ក្នុងលក្ខខណ្ឌមួយដែលមានតម្លាភាព ប្រសិទ្ធភាព សមភាព គណនេយ្យភាព សន្សំសំចៃ និងមានក្រមសីលធម៌វិជ្ជាជីវៈបំផុតតាមដែលអាចធ្វើទៅបានដោយធានាគុណភាពដូចជា៖

## ៤.១ ការសន្សំសំចៃ

គោលការណ៍នេះមានកម្មវត្ថុចម្បងគឺ ដើម្បីឱ្យមន្ត្រីរាជការទទួលបន្ទុកកិច្ចលទ្ធកម្មត្រូវប្រឹងប្រែងឱ្យអស់ពីសមត្ថភាព ដើម្បីរួមចំណែកក្នុងការប្រើប្រាស់ថវិការជាតិឱ្យទទួលបានលទ្ធផលល្អ។ គោលការណ៍នេះត្រូវបានគេហៅម៉្យាងទៀតថា**តម្លៃជាប្រាក់** ដែលជារង្វាស់នៃប្រសិទ្ធភាព ហើយត្រូវបានប្តូរជាមួយនិងធនធានហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល។ មន្ត្រីលទ្ធកម្មត្រូវចាំថា **តម្លៃជាប្រាក់** រួមផ្សំ និងកត្តាមួយចំនួនទៀត មិនមែនត្រឹមតែជាកត្តាប្រាក់ប៉ុណ្ណោះទេ។ កត្តាទាំងនោះរួមមាន៖

- ភាពសមស្របនៃទំនិញ/សំណង់/សេវាកម្ម/សេវាទីប្រឹក្សា
- អាយុកាលប្រើប្រាស់នូវទំនិញ/សំណង់/សេវាកម្ម/សេវាទីប្រឹក្សា
- ចំណាយសម្រាប់ប្រតិបត្តិការ ការថែទាំ និងការផ្តល់សេវា
- ចំណាយរដ្ឋបាលក្នុងការអនុវត្តវិធីសាស្ត្រដែលបានជ្រើសរើស
- រយៈពេលប្រគល់-ទទួល
- ថ្លៃចំណាយដឹកជញ្ជូនបន្ត
- ថ្លៃចំណាយក្នុងការស្តុកទុក/រក្សាទុក
- ពេលវេលាចំណាយសម្រាប់ធ្វើកិច្ចលទ្ធកម្ម។

## ៤.២ តម្លាភាព

ភ្នាក់ងារ និងស្ថាប័នអនុវត្តលទ្ធកម្មត្រូវធានាចំពោះមុខសាធារណជនថា វិធីសាស្ត្រ និងនីតិវិធីលទ្ធកម្ម ត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវដោយការធានាឱ្យបាននូវតម្លាភាពក្នុងកិច្ចលទ្ធកម្ម។ តម្លាភាពនេះនិងជំរុញលើកទឹកចិត្តដល់អ្នកផ្គត់ផ្គង់/អ្នកទទួលការឱ្យចូលរួមប្រកួតប្រជែង ដើម្បីទទួលបានកិច្ចសន្យាពីរាជរដ្ឋាភិបាល ពោលគឺបង្កើតបរិយាកាសប្រកួតប្រជែង ដែលនាំឱ្យតម្លៃលក់ធ្លាក់ចុះ។

## ៤.៣ គណនេយ្យភាព

មន្ត្រីលទ្ធកម្មត្រូវយកចិត្តទុកដាក់ និងទទួលខុសត្រូវខ្ពស់ចំពោះការងារដែលរាជរដ្ឋាភិបាលបានប្រគល់ជូនក្នុងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ដើម្បីធានាឱ្យបាននូវគោលការណ៍នេះ ព្រោះថាគណនេយ្យភាពគឺជាមូលដ្ឋានគ្រឹះនៅក្នុងការអនុវត្តលទ្ធកម្មសាធារណៈ ។

### ៤.៤ ប្រសិទ្ធភាព

ការអនុវត្តកិច្ចលទ្ធកម្ម ជាការប្រមូលទិន្នន័យស្តីពីលទ្ធភាព និងសមត្ថភាពរបស់អ្នកផ្គត់ផ្គង់ក្នុងការបំពេញតម្រូវការក្នុងលក្ខខណ្ឌសមស្របណាមួយតាមកិច្ចព្រមព្រៀងរបស់រាជរដ្ឋាភិបាល និងអ្នកផ្គត់ផ្គង់។ ការអនុវត្តកិច្ចលទ្ធកម្ម ជាកិច្ចការមួយដើម្បីធានាឱ្យការប្រើប្រាស់ហិរញ្ញវត្ថុសាធារណៈប្រកបដោយប្រសិទ្ធភាព ។

### ៤.៥ សមភាព

អ្នកផ្គត់ផ្គង់/អ្នកទទួលការ ដែលមានសិទ្ធិចូលរួមដេញថ្លៃទាំងអស់ត្រូវទទួលបាននូវការជូនដំណឹងស្តីពីឱកាសចូលរួមដេញថ្លៃ។ គោលការណ៍នេះមិនត្រឹមតែធានាឱ្យបាននូវសមភាពក្នុងការប្រកួតប្រជែងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធ្វើឱ្យមានយុត្តិធម៌ដល់អ្នកដេញថ្លៃថ្នាក់ជាតិ និងអន្តរជាតិ អ្នកផ្គត់ផ្គង់/អ្នកទទួលការ និងទីប្រឹក្សា ឬដៃគូរអភិវឌ្ឍន៍ផ្សេងៗក្នុងកម្មវត្ថុបង្កើនជម្រើសដល់រាជរដ្ឋាភិបាលក្នុងការវិនិច្ឆ័យថា តើក្រុមហ៊ុនណាមួយដែលមានលក្ខខណ្ឌសមស្របក្នុងការផ្គត់ផ្គង់ដល់តម្រូវការរបស់រដ្ឋ។

### ៤.៦ ក្រមសីលធម៌វិជ្ជាជីវៈ

ក្នុងកិច្ចដំណើរការលទ្ធកម្ម ភ្នាក់ងារទទួលបន្ទុកត្រូវប្រកាន់ភ្ជាប់នូវការគោរពក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួន ដែលឆ្លើយតបទៅនិងគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ អំពើបន្លំ អំពើឃុបឃិត និងអំពើបង្ខិតបង្ខំដល់អ្នកដេញថ្លៃដើម្បីតែផលប្រយោជន៍ផ្ទាល់ខ្លួន ដែលប្រាស់ចាកពីផលប្រយោជន៍សង្គមជាតិ។

ស្ថាប័នដែលទទួលបន្ទុកលើកិច្ចការលទ្ធកម្មត្រូវរក្សា នឹងពង្រឹងកេរ្តិ៍ឈ្មោះរបស់រាជរដ្ឋាភិបាលដោយៈ

- រក្សានូវភាពស្មោះត្រង់ និងសេចក្តីថ្លៃថ្នូរ ចំពោះរាល់ទំនាក់ទំនងក្នុង និងក្រៅស្ថាប័នរបស់ខ្លួន
- បង្កើនសមត្ថភាពវិជ្ជាជីវៈស្របតាមបទដ្ឋានខ្ពស់មួយតាមលទ្ធភាពដែលអាចធ្វើបាន
- ប្រើប្រាស់នូវមូលនិធិ និងធនធានរបស់ខ្លួន ដើម្បីជាប្រយោជន៍ដល់ជាតិ
- ត្រូវគោរពតាមខ្លឹមសារ និងស្មារតីនៃរដ្ឋធម្មនុញ្ញ ច្បាប់ និងបទប្បញ្ញត្តិផ្សេងៗនៃព្រះរាជាណាចក្រកម្ពុជា ក្រមសីលធម៌វិជ្ជាជីវៈ និងកាតព្វកិច្ចដែលបានកំណត់ក្នុងកិច្ចសន្យា
- ត្រូវប្រាស់ចាកអំពីទំនាស់ផលប្រយោជន៍ និងក្រមសីលធម៌វិជ្ជាជីវៈដូចជា ការទម្លាយការសម្ងាត់ ឬព័ត៌មានផ្ទៃក្នុង មានភាពលំអៀង និងការស៊ីសំណូក សូកប៉ាន់។

# ផ្នែកទី២ ៖ វិធីសាស្ត្រ និងនីតិវិធីលទ្ធកម្មរបស់រដ្ឋបាលឃុំ សង្កាត់

## ១.ក្របខណ្ឌគតិយុត្ត

ដើម្បីធានាឱ្យដំណើរការនៃការបំពេញការងាររបស់រដ្ឋបាលឃុំ សង្កាត់អាចដំណើរការ ដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងបរិយាបន្ន[12] រដ្ឋបាលឃុំ សង្កាត់ត្រូវមានបុគ្គលិកឱ្យបានគ្រប់គ្រាន់ទាំងបរិមាណ និងគុណភាព ដោយផ្អែកទៅតាមតម្រូវការចាំបាច់ជាក់ស្តែង និងធនធានដែលមាន ទន្ទឹមនឹងការប្រើប្រាស់បុគ្គលិកទាំងនោះប្រកបដោយភាពប៉ិនប្រសព្វ និងប្រសិទ្ធភាព។

ជាមួយគ្នាដែរនេះ ដើម្បីធានាថារដ្ឋបាលឃុំ សង្កាត់អាចឆ្លើយតបទៅនឹងតម្រូវការជូនប្រជាពលរដ្ឋនៅមូលដ្ឋានប្រកបដោយប្រសិទ្ធភាព សមធម៌ និងបរិយាបន្ន ទាមទារឱ្យរដ្ឋបាលឃុំ សង្កាត់ មានលទ្ធភាពក្នុងការកំណត់បញ្ហា ធ្វើការវិភាគ និងចាត់អាទិភាពនៃបញ្ហា រៀបចំផែនការនិងការអនុវត្ត សកម្មភាព និងថវិកា ព្រមទាំងធ្វើការតាមដានត្រួតពិនិត្យ និងវាយតម្លៃសកម្មភាពទៅតាមពេលវេលាសមស្របជាមុនសិន។ ជាពិសេសចំពោះការអនុវត្តលទ្ធកម្មនៅឃុំ សង្កាត់គឺពិតជាមានសារៈសំខាន់ណាស់ សម្រាប់ការចំណាយ និងបានរួមចំណែកក្នុងការសន្សំសំចៃថវិការឃុំ សង្កាត់ផងដែរ។

ហេតុដូចនេះហើយច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ត្រូវបានបង្កើតឡើងក្នុងគោលបំណងធានាឱ្យដំណើរការលទ្ធកម្មសាធារណៈប្រព្រឹត្តទៅដោយតម្លាភាព សមភាព គណនេយ្យភាព យុត្តិធម៌ ប្រសិទ្ធភាព ការសន្សំសំចៃ ព្រមទាំងធានាឱ្យបាននូវប្រព័ន្ធលទ្ធកម្មសាធារណៈមួយដែលមានការឯកភាពគ្នានៅក្នុងប្រទេសកម្ពុជា។

## ២. វិធីសាស្ត្រលទ្ធកម្មឃុំ សង្កាត់

ជាទូទៅកិច្ចលទ្ធកម្មឃុំ សង្កាត់ ប្រព្រឹត្តទៅតាមលំនាំ ពីរយ៉ាងដូចជា៖

- វិធីសាស្ត្រការដេញថ្លៃដោយប្រកួតប្រជែងជាចំហ(សាធារណៈ)
- វិធីសាស្ត្រផ្សេងទៀតដែលមិនមែនជាការដេញថ្លៃ ដោយប្រកួតប្រជែងជាចំហ
  - ការស្ទង់តម្លៃក្នុងស្រុក
  - ការទិញផ្ទាល់ ឬការចុះកិច្ចសន្យាផ្ទាល់។

### ២.១ វិធីសាស្ត្រការដេញថ្លៃដោយប្រកួតប្រជែងជាចំហ

ការដេញថ្លៃដោយប្រកួតប្រជែងជាចំហ ត្រូវបានអនុវត្តនៅពេលដែលមានអ្នកផ្គត់ផ្គង់ ឬអ្នកទទួលការច្រើនគ្រប់គ្រាន់ (យ៉ាងតិច ៣) ដែលអាចផ្តល់នូវទំនិញ សេវាកម្ម ឬសំណង់ការសាងសង់ជួសជុលដែលជាតម្រូវ

[12] - បរិយាបន្ន ជាការលើកកម្ពស់ស្ថានភាពរបស់បុគ្គល និងក្រុមនានា ក្នុងការចូលរួមនិងទទួលផលពីសកម្មភាពនានារបស់សង្គមដោយមិនរើសអើង។

ការរបស់ឃុំ សង្កាត់។ ការងារនេះនិងផ្តល់នូវអត្ថប្រយោជន៍ដល់ឃុំ សង្កាត់ប្រសិនបើការប្រកួតប្រជែង និងនាំទៅដល់ការជ្រើសរើសអ្នកផ្គត់ផ្គង់ ឬអ្នកទទួលការណាមួយ ដែលផ្តល់នូវសំណើត្រឹមត្រូវ និងមានតម្លៃអនុវត្តគម្រោងទាបបំផុត។ វិធីសាស្ត្រដេញថ្លៃប្រកួតប្រជែងជាចំហត្រូវបានអនុវត្តចំពោះ ៖

- គម្រោងចំណាយចរន្តលើការងារអភិវឌ្ឍន៍មូលដ្ឋាន[13]ដែលមានទំហំទឹកប្រាក់ចាប់ពី២លានរៀលឡើង។
- គម្រោងចំណាយមូលធនលើការងារអភិវឌ្ឍន៍មូលដ្ឋាន[14] ដោយមិនគិតពីទំហំទឹកប្រាក់គ្រោង។
- គម្រោងចំណាយសម្រាប់សកម្មភាពដទៃទៀត ដែលមានទំហំទឹកប្រាក់ចាប់ពី២លានរៀល ឡើងទៅនឹងអាចមានអ្នកចូលរួមដេញថ្លៃក្នុងស្រុកយ៉ាងច្រើននិងអាចផ្តល់នូវលទ្ធភាពដ៏ទូលំទូលាយមួយក្នុងការជ្រើសរើសយកសំណើដែលល្អបំផុត ។
- កម្រិតទំហំទឹកប្រាក់នេះ អាចនឹងត្រូវធ្វើការកែប្រែ ប្រសិនបើមានករណីចាំបាច់ណាមួយ។

## ២.២ វិធីសាស្ត្រផ្សេងទៀតដែលមិនមែនជាការដេញថ្លៃ ដោយប្រកួតប្រជែងជាចំហ

### ២.២.១ ការស្ទង់តម្លៃក្នុងស្រុក

ការស្ទង់តម្លៃក្នុងស្រុក គឺតម្រូវឱ្យមានតារាងតម្លៃចំនួនបីយ៉ាងតិច ពីអ្នកផ្គត់ផ្គង់ក្នុងស្រុក។ វិធីសាស្ត្រនេះត្រូវបានអនុវត្តក្នុងកិច្ចសន្យាផ្គត់ផ្គង់ដែលទិញដោយផ្ទាល់ពីហាងនូវរាល់វត្ថុ សម្ភារ ឬ គ្រឿងផ្គត់ផ្គង់គ្រឿងបន្លាស់ ឬមួយជាគ្រឿងម៉ាស៊ីនតូចតាច និងបរិក្ខារដែលអាចផ្តល់ដោយអ្នកផ្គត់ផ្គង់ក្នុងស្រុក នៅតាមមូលដ្ឋានឬមួយក៏ភ្នាក់ងារ ទទួលសិទ្ធិនៃអ្នកផ្គត់ផ្គង់បរទេស និងប្រើប្រាស់ក្នុងកិច្ចសន្យាសាងសង់ជួសជុល ដែលមានទំហំទឹកប្រាក់មិនធំ។

វិធីសាស្ត្រនេះត្រូវអនុវត្តចំពោះសកម្មភាពអភិវឌ្ឍន៍មូលដ្ឋានដែលជា ចំណាយចរន្ត និងមានទំហំទឹកប្រាក់តិចជាង ២,០០០,០០០៛(ពីរលានរៀល) និងក្រៅពីសកម្មភាពអភិវឌ្ឍន៍មូលដ្ឋាន ដែលជាចំណាយមូលធន និងមានទំហំទឹកប្រាក់ចាប់ពី ៤០០,០០០៛(បួនរយពាន់រៀល) ដល់ទាបជាង ២,០០០,០០០៛(ពីរលានរៀល)។

### ២.២.២ ការទិញផ្ទាល់ ឬការចុះកិច្ចសន្យាផ្ទាល់

វិធីសាស្ត្រនេះត្រូវអនុវត្តចំពោះតែករណីពិសេស ហើយត្រូវមានភស្តុតាង និងឯកសារច្បាស់លាស់ដែលមានការអនុញ្ញាតពីអភិបាលរាជធានីខេត្តជាមុន នៅពេលដែលមិនអាចអនុវត្តវិធីសាស្ត្រការដេញថ្លៃដោយប្រកួតប្រជែងជាចំហ និងវិធីសាស្ត្រការស្ទង់តម្លៃក្នុងស្រុកបាន ។

---

[13] - ចំណាយចរន្តសម្រាប់សកម្មភាពអភិវឌ្ឍន៍មូលដ្ឋាន រួមមាន៖ ចំណាយសម្រាប់សេវាកម្មផ្សេងៗ និង សេវាកម្ម វិជ្ជាជីវៈក្រៅពីសេវាកម្មគំនូសប្លង់ ការត្រួតពិនិត្យការអនុវត្តកិច្ចសន្យាសំណង់ស៊ីវិល និង ការជួសជុលថែទាំជាប្រចាំលើការងារសំណង់ស៊ីវិល ។

[14] - ចំណាយមូលធនសម្រាប់សកម្មភាពអភិវឌ្ឍន៍មូលដ្ឋាន រួមមាន៖ ចំណាយសម្រាប់ការងារសាងសង់ ឬការងារជួសជុលធំសម្រាប់សំណង់ស៊ីវិល សេវាកម្មវិជ្ជាជីវៈគំនូសប្លង់ ការត្រួតពិនិត្យការអនុវត្តកិច្ចសន្យា សំណង់ស៊ីវិល និង ការធ្វើលទ្ធកម្មទំនិញ ដែលទំនិញនោះមានអាយុកាលប្រើប្រាស់លើសពីមួយឆ្នាំ។

វិធីសាស្ត្រនេះក៏អាចអនុវត្តបានផងដែរ ចំពោះកិច្ចសន្យាថែទាំជាប្រចាំដែលក្រុមប្រឹក្សាឃុំ សង្កាត់សម្រេចចិត្តផ្តល់កិច្ចសន្យានេះ ឱ្យទៅអង្គការសហគមន៍នៅក្នុងមូលដ្ឋាន[15] ជាអ្នកអនុវត្តន៍។

ការទិញផ្ទាល់ ឬការចុះកិច្ចសន្យាផ្ទាល់ គឺជាវិធីធ្វើការទាក់ទងចរចាផ្ទាល់ជាមួយអ្នកផ្គត់ផ្គង់ ឬអ្នកទទួលការតែមួយគត់ ហើយត្រូវបានអនុវត្តចំពោះ ៖

- ការធ្វើលទ្ធកម្មទំនិញ ឬសេវា និងការសាងសង់ ការជួសជុលនោះមិនលើសពី ៤០០,០០០រៀល (សម្រាប់សកម្មភាពក្រៅពីអភិវឌ្ឍន៍មូលដ្ឋាន) ។
- គម្រោងចំណាយដែលមានលក្ខណៈជាចំណាយចរន្ត សម្រាប់ការងារអភិវឌ្ឍន៍មូលដ្ឋាន និងមានទំហំទឹកប្រាក់ទាបជាង២លានរៀល និងមានគោលបំណងជាក់លាក់ ដើម្បីគាំទ្រកម្មវិធីអភិវឌ្ឍន៍របស់អង្គការសហគមន៍មូលដ្ឋាន នឹងត្រូវបានស្នើសុំឱ្យអង្គការសហគមន៍មូលដ្ឋានចូលរួមអនុវត្តកិច្ចសន្យានេះ។

មេឃុំ ចៅសង្កាត់អាចស្នើសុំការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអភិបាលខេត្ត ក្រុង ដើម្បីលើកលែងការធ្វើលទ្ធកម្មតាមលក្ខណៈប្រកួតប្រជែងជាចំហ និងប្រើជាជំនួសវិញដោយការទិញផ្ទាល់ ឬការចុះកិច្ចសន្យាចំពោះករណី ដូចខាងក្រោម ដោយមិនគិតពីចំនួនទឹកប្រាក់នៃប្រតិបត្តិការឡើយ ៖

- ការធ្វើលទ្ធកម្មទំនិញ សេវាកម្ម និងការងារសាងសង់ ដែលមិនអាចរកបានអ្នកទទួលការ ឬអ្នកផ្គត់ផ្គង់ បន្ទាប់ពីបានដំណើរការអនុវត្តន៍វិធីសាស្ត្រដេញថ្លៃប្រកួតប្រជែងជាចំហម្តងរួចមកហើយ។
- ការធ្វើលទ្ធកម្មទំនិញ សេវាកម្ម និង ការងារសាងសង់ ដែលមានលក្ខណៈបច្ចេកទេស អាចអនុវត្តបានចំពោះតែអ្នកផ្គត់ផ្គង់ ឬចំពោះតែអ្នកទទួលការតែម្នាក់។
- ការធ្វើលទ្ធកម្មទំនិញ សេវាកម្ម និងការងារសាងសង់ដែលមិនអាចជាកម្មវត្ថុនៃការពន្យាពេលដោយដំណើរការប្រកួតប្រជែងថ្លៃ ពីព្រោះវាមានលក្ខណៈជាបន្ទាន់ដែលជាតម្រូវតាមកាលៈទេសៈ និងមិនបានគ្រោងទុកជាមុន។
- ការធ្វើលទ្ធកម្មទំនិញ សេវា និងការងារសាងសង់ ដែលតម្រូវឱ្យមានការពង្រីក ឬជួសជុលឧបករណ៍ដែលមានស្រាប់។

[15]- អង្គការសហគមន៍មូលដ្ឋាន ជាអង្គការមិនស្វែងរកប្រាក់ចំណេញដែលសមាជិក សមាជិកានៃអង្គការសហគមន៍ នេះមានលំនៅដ្ឋាននៅក្នុងឃុំ សង្កាត់នោះ ។ អង្គការសហគមន៍មូលដ្ឋាន មានភារកិច្ចដូចខាងក្រោម:

- អនុវត្តកម្មវិធីដែលរួមចំណែក ដើម្បីសម្រេច គោលបំណងនៃផែនការអភិវឌ្ឍន៍ឃុំ សង្កាត់
- សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់មិនអាចជាប្រធានអង្គការសហគមន៍មូលដ្ឋាន និង បានផលកម្រៃពីអង្គការសហគមន៍មូលដ្ឋាននេះទេ។
- អង្គការសហគមន៍មូលដ្ឋាននេះ ត្រូវទទួលស្គាល់ជាផ្លូវការដោយអភិបាលខេត្ត-ក្រុង។

- ការបញ្ជាទិញថ្មីដដែលមួយទៀតនូវមុខទំនិញដែលដេញថ្លៃរួចហើយតាមរយៈការប្រកួតប្រជែងថ្លៃ ហើយវាអាចនឹងគ្មានតម្លៃណាទាបជាងនេះទៀតនោះទេ ទោះតាមរយៈការដេញថ្លៃណាផ្សេងទៀតក៏ដោយ។
- ការទិញដែលត្រូវធ្វើឡើងដោយភ្នាក់ងាររដ្ឋាភិបាល ណាផ្សេងទៀត ឬការសាងសង់ ដែលត្រូវធ្វើឡើងតាមរយៈស្ថាប័នរដ្ឋ ដោយប្រើប្រាស់មធ្យោបាយផ្ទាល់ក្នុងករណីចាំបាច់ និងបន្ទាន់។

ក្នុងករណីពិសេស ការប្រើវិធីសាស្ត្រលទ្ធកម្ម ដែលមានតម្លៃកិច្ចសន្យាខុសពីប្រការដែលកំណត់ក្នុងផ្នែកនេះ ត្រូវធ្វើការពិនិត្យពីករណីដោយឡែកនីមួយៗ ដោយផ្អែកលើសេចក្តីសម្រេចរបស់អភិបាលខេត្ត ក្រុង។[16]

## ៣. នីតិវិធីលទ្ធកម្មឃុំ សង្កាត់

### ៣.១ នីតិវិធីលទ្ធកម្មសំណង់

គ្រប់ការងារសាងសង់ទាំងអស់ ត្រូវចុះកិច្ចសន្យាការងារជាមួយអ្នកម៉ៅការឯករាជ្យ ។ អភិបាលខេត្ត ក្រុង ត្រូវបង្កើតគណៈកម្មការបច្ចេកទេសចុះបញ្ជីអ្នកទទួលការសាងសង់ដែលបានធ្វើបុរេលក្ខណៈសម្បត្តិ ដើម្បីចូលរួមដេញថ្លៃលើការងារសាងសង់របស់ឃុំ សង្កាត់ តាមប្រភេទការងារឱ្យបានទៀងទាត់ជាប្រចាំ។ អ្នកទទួលការសាងសង់ទាំងអស់ដែលប្រគល់ការងារដោយឃុំ សង្កាត់ នឹងត្រូវចុះឈ្មោះនៅក្នុងបញ្ជីអ្នកទទួលការ[17]សាងសង់នេះ ។ រាល់កិច្ចសន្យាការងារសាងសង់ទាំងអស់ ត្រូវផ្តល់ឱ្យអ្នកម៉ៅការតាមវិធីសាស្ត្រដេញថ្លៃប្រកួតប្រជែងជាចំហ។

#### ៣.១.១ ការកំណត់អ្នកដែលមានសិទ្ធដាក់សំណើរដេញថ្លៃដោយក្រុមប្រឹក្សាឃុំ សង្កាត់

នៅពេលទទួលបានបញ្ជីឈ្មោះអ្នកទទួលការដែលបានសម្រេចដោយអភិបាលរាជធានី ខេត្ត ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវកោះប្រជុំក្រុមប្រឹក្សារបស់ខ្លួន ដើម្បីពិនិត្យ និងអនុម័តអំពីអ្នកទទួលការក្នុងបញ្ជីនេះ ដែលមានសិទ្ធិដាក់សំណើដេញថ្លៃកិច្ចសន្យាឃុំ សង្កាត់របស់ខ្លួន។ ក្នុងចំណោមអ្នកទទួលការដែលមានឈ្មោះក្នុងបញ្ជីអ្នកទទួលការ ក្រុមប្រឹក្សាឃុំ សង្កាត់ មានសិទ្ធិមិនអនុញ្ញាតឱ្យដាក់សំណើដេញថ្លៃកិច្ចសន្យាឃុំ សង្កាត់របស់ខ្លួនចំពោះអ្នកទទួលការដែលៈ

- មិនព្រមទទួលយកកិច្ចសន្យា ឬមិនបានគោរពតាមលក្ខខណ្ឌកិច្ចសន្យា ដែលបានចុះកិច្ចសន្យាជាមួយឃុំ សង្កាត់កន្លងមកដោយផ្អែកតាមឯកសារកំណត់ត្រា
- ត្រូវបានរកឃើញថា មានការពាក់ព័ន្ធនឹងការឃុបឃិត ការក្លែងបន្លំ ការបង្ខិតបង្ខំ[18] និងការប្រព្រឹត្ត

[16]- ប្រកាសណែនាំលេខ ២៣១ សហវ. ប្រក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥ ស្តីពីការងារលទ្ធកម្មរបស់ឃុំ សង្កាត់

[17] - អ្នកទទួលការ គឺជាឯកត្តជន ឬជាក្រុមហ៊ុនដែលចុះកិច្ចសន្យាលើការសាងសង់ ឬសេវាចូល ។

[18] - ការបង្ខិតបង្ខំ សំដៅដល់ការហាមឃាត់ឬការគំរាមកំហែងដោយផ្ទាល់ឬដោយប្រយោលធ្វើឱ្យ មានគ្រោះថ្នាក់ដល់បុគ្គល ឬទ្រព្យសម្បត្តិរបស់បុគ្គល ដើម្បីធ្វើឱ្យមានឥទ្ធិពលដល់ការចូលរួមក្នុងដំណើរការលទ្ធកម្មសាធារណៈរបស់បុគ្គលនោះ ឬធ្វើឱ្យមានការជះឥទ្ធិពលលើការអនុវត្តកិច្ចសន្យា។

អំពើពុករលួយនៅក្នុងដំណើរការលទ្ធកម្ម និងការអនុវត្តកិច្ចសន្យាឃុំ សង្កាត់

- ស្ថិតក្នុងបញ្ជីខ្មៅ[19] អ្នកទទួលការ

រាល់មូលហេតុនៃការមិនអនុញ្ញាតឱ្យអ្នកទទួលការដាក់សំណើដេញថ្លៃត្រូវកត់ត្រាឱ្យបានច្បាស់លាស់ដោយភ្ជាប់មកជាមួយនូវឯកសារភស្តុតាង។ ការសម្រេចចិត្តទាំងឡាយណាដែលពាក់ព័ន្ធនឹង គណៈកម្មការលទ្ធកម្មនិងបញ្ជីឈ្មោះអ្នកទទួលការ ត្រូវកត់ត្រានៅក្នុងកំណត់ហេតុកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ និងមានចុះកាលបរិច្ឆេទ ហើយត្រូវរក្សាទុកក្នុងសំណុំឯកសារគម្រោងឱ្យបានត្រឹមត្រូវ។

### ៣.១.២ ដំណាក់កាលនៃកិច្ចលទ្ធកម្មសម្រាប់ការដេញថ្លៃដោយប្រកួតប្រជែងជាចំហ

ដំណើរការដេញថ្លៃដោយប្រកួតប្រជែងជាចំហ មានដំណាក់កាលសំខាន់ៗដូចខាងក្រោម៖

❖ **ដំណាក់កាលទី១ ៖ មុនពេលប្រកាសដេញថ្លៃ**

➢ **ការបង្កើតគណៈកម្មការលទ្ធកម្ម**

រដ្ឋបាលឃុំ សង្កាត់នីមួយៗត្រូវបង្កើតគណៈកម្មការលទ្ធកម្មមួយសម្រាប់អនុវត្តកិច្ចលទ្ធកម្មនៅឃុំសង្កាត់របស់ខ្លួន។ មេឃុំ ចៅសង្កាត់ត្រូវរៀបចំសេចក្តីសម្រេចស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណកម្មការលទ្ធកម្មដែលកំណត់អំពីសមាសភាព តួនាទី ភារកិច្ច និងរបៀបរបបការងាររបស់គណៈកម្មការលទ្ធកម្ម ហើយដាក់ជូនកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ពិនិត្យនិងអនុម័ត។ សេចក្តីសម្រេចនេះត្រូវចុះហត្ថលេខាដោយមេឃុំ និងចៅសង្កាត់។ នៅពេលមានការផ្លាស់ប្តូរសមាសភាពគណៈកម្មការលទ្ធកម្មណាម្នាក់ ឬនៅអាណត្តិថ្មីនីមួយៗនៃក្រុមប្រឹក្សាឃុំ សង្កាត់ ឬរដ្ឋបាលឃុំ សង្កាត់ត្រូវដាក់ចេញនូវសេចក្តីសម្រេចថ្មីស្តីពីរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការ។

ជាធម្មតាមេឃុំ ចៅសង្កាត់គឺជាប្រធានគណៈកម្មការលទ្ធកម្ម។ ក្នុងករណីចាំបាច់ មេឃុំ ចៅសង្កាត់អាចប្រគល់សិទ្ធិឱ្យជំទប់ ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាម្នាក់ធ្វើជាប្រធានគណៈកម្មការលទ្ធកម្មបាន។

➢ **ការរៀបចំឯកសារដេញថ្លៃ**

- គណៈកម្មការលទ្ធកម្ម ត្រូវរៀបចំឯកសារដេញថ្លៃ ដោយមានមន្ត្រីគាំទ្របច្ចេកទេសជាជំនួយការ។
- ឯកសារដេញថ្លៃត្រូវបញ្ជាក់ប្រាប់នូវរាល់ព័ត៌មានចាំបាច់ទាំងឡាយដែលអាចឱ្យអ្នកដេញថ្លៃមានមូលដ្ឋានដើម្បីធ្វើសេចក្តីសម្រេចចិត្តក្នុងការចូលរួមដេញថ្លៃ និងរៀបចំសំណើដេញថ្លៃ។
- ព័ត៌មានដែលផ្តល់ឱ្យអ្នកចូលរួមដេញថ្លៃ ត្រូវរួមបញ្ចូលនូវតម្លៃប៉ាន់ស្មានដែលនឹងត្រូវប្រើជាមូលដ្ឋានក្នុងការវាយតម្លៃលើសំណើដេញថ្លៃ។

[19] - បញ្ជីខ្មៅ សំដៅដល់បញ្ជីហាមឃាត់ការចូលរួមរបស់អ្នកដេញថ្លៃ ក្នុងដំណើរការលទ្ធកម្មសាធារណៈដែលសម្រេចដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

➢ **ការកំណត់ពេលវេលា និងកាលបរិច្ឆេទអំពីការដេញថ្លៃ**

រាល់គ្រប់កិច្ចសន្យារបស់ឃុំ សង្កាត់ទាំងអស់ មេឃុំ និងចៅសង្កាត់ត្រូវពិភាក្សាជាមួយទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្តអំពីពេលវេលា និងកាលបរិច្ឆេទសម្រាប់ការដាក់សំណើដេញថ្លៃ និងប្រជុំបើកសំណើដេញថ្លៃ។ ការធ្វើដូច្នេះប្រសិនបើមានឃុំ សង្កាត់ចំនួន ២ឬច្រើន រៀបចំប្រជុំបើកសំណើដេញថ្លៃក្នុងពេលតែមួយ អ្នកទទួលការ អ្នកផ្តល់សេវាកម្ម ឬអ្នកផ្គត់ផ្គង់ មិនអាចចូលរួមប្រជុំបើកសំណើដេញថ្លៃទាំងនោះបានទេ។

➢ **ការប្រកាសជូនដំណឹងស្តីពីការដេញថ្លៃ**

មេឃុំ ចៅសង្កាត់ត្រូវប្រកាសជូនដំណឹងស្តីពីការដេញថ្លៃ ដើម្បីអញ្ជើញអ្នកទទួលការ អ្នកផ្តល់សេវាកម្ម ឬអ្នកផ្គត់ផ្គង់ ទាំងអស់ដែលមានសិទ្ធិដាក់សំណើដេញថ្លៃ។

ការប្រកាសជូនដំណឹងស្តីពីការដេញថ្លៃ ត្រូវធ្វើឡើងជាសាធារណៈ ឱ្យបានទូលំទូលាយដោយបិទលើក្តារព័ត៌មានរបស់សាលាឃុំ សង្កាត់ សាលាក្រុង ស្រុក ខណ្ឌ និងសាលារាជធានី ខេត្ត។ ការប្រកាសជូនដំណឹងនេះត្រូវបិទផ្សាយឱ្យបានរយៈពេល ០២សប្តាហ៍មុនពេលផុតកំណត់នៃការដាក់សំណើដេញថ្លៃ។

➢ **ការលក់ឯកសារដេញថ្លៃ**

- មុនពេលផ្សព្វផ្សាយការអញ្ជើញចូលរួមដេញថ្លៃ គណៈកម្មការលទ្ធកម្មត្រូវរៀបចំឯកសារដេញថ្លៃឱ្យមានជាស្រេច និងលក់ក្នុងតម្លៃប្រហាក់ប្រហែលថ្លៃដើមជូនចំពោះអ្នកទទួលការដែលចាប់អារម្មណ៍។
- ប្រធានគណៈកម្មការលទ្ធកម្មត្រូវរៀបចំឱ្យមានការប្រជុំមួយមុនពេលទទួលសំណើដេញថ្លៃ ស្តីពីការណែនាំលើការងារបច្ចេកទេស និងការត្រួតពិនិត្យលើការដ្ឋានគម្រោង។ ក្នុងករណីមានព័ត៌មានបន្ថែមត្រូវផ្តល់ដំណឹងដល់អ្នកចូលរួមដេញថ្លៃ ហើយព័ត៌មានទាំងនោះត្រូវបញ្ជាក់នៅក្នុងអង្គប្រជុំមុនពេលទទួលសំណើដេញថ្លៃ ដើម្បីជាផលប្រយោជន៍ដល់អ្នកចូលរួមដេញថ្លៃ។

❖ **ដំណាក់កាលទី២៖ ការប្រជុំបើកសំណើរដេញថ្លៃ**

➢ **ការដាក់ និង ទទួលសំណើដេញថ្លៃ**

- សំណើរដេញថ្លៃត្រូវដាក់ក្នុងស្រោមសំបុត្របិទជិត ហើយប្រគល់ជូនគណៈកម្មការលទ្ធកម្មឱ្យបានមុនថ្ងៃឱសានវាទ។
- សំណើដេញថ្លៃមិនត្រូវបានទទួលយក ឬអនុញ្ញាតកែប្រែថ្ងៃណាមួយក្រោយថ្ងៃឱសានវាទឡើយ។

➢ **ការប្រកាសបើកសំណើដេញថ្លៃ**

ប្រធានគណៈកម្មការលទ្ធកម្មប្រកាសបើកការដេញថ្លៃជាផ្លូវការ និងប្រកាសអំពីគោលការណ៍សំខាន់ៗនៃការដេញថ្លៃមួយចំនួនដូចខាងក្រោម៖

- ស្រោមសំបុត្រសំណើរដេញថ្លៃនិងបើកជាសាធារណៈ

- គណៈកម្មការលទ្ធកម្មនឹងពិនិត្យសុពលភាពនៃសំណើរដេញថ្លៃ ក្នុងនោះពិនិត្យមើលដូចជា៖
  - សំណើដេញថ្លៃនេះ ដាក់ដោយអ្នកដេញថ្លៃដែលមានសិទ្ធិចូលរួមដេញថ្លៃដែរឬទេ?
  - តើសំណើដេញថ្លៃមានភ្ជាប់មកជាមួយនូវលិខិតធានាប្រាក់កក់ធានាការដេញថ្លៃ[20] សេចក្ដីប្រកាសស្ដីពីក្រមសីលធម៌ ការមិនក្លែងបន្លំ និងការមិនប្រព្រឹត្តអំពើពុករលួយ និងប័ណ្ណពន្ធប៉ាតង់ ដែលមានសុពលភាព ឬបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធប៉ាតង់ (ចំពោះកិច្ចសន្យាសំណង់ និងទំនិញ) ឬវិញ្ញាបនបត្រចុះបញ្ជីពន្ធដារ (ចំពោះកិច្ចសន្យាសេវាកម្ម)ដែរឬទេ?

❖ **សម្គាល់ ៖** នេះជាកាតព្វកិច្ចរបស់ប្រធានគណៈកម្មការលទ្ធកម្ម ដែលត្រូវធ្វើការប្រកាសបើកការដេញថ្លៃជាផ្លូវការ។ ប្រសិនបើប្រធានគណៈកម្មការលទ្ធកម្ម មិនបានប្រកាសទេនោះការប្រជុំដេញថ្លៃគ្មានសុពលភាព។

➢ **ការបើកសំណើដេញថ្លៃ**

- សំណើដេញថ្លៃដែលទទួលបាន ត្រូវបើកជាសាធារណៈតាមកាលបរិច្ឆេទ ពេលវេលា និង ទីកន្លែងកំណត់ នៅចំពោះមុខគណៈកម្មការលទ្ធកម្ម និងអ្នកចូលរួមដេញថ្លៃ
- ការបើកសំណើដេញថ្លៃត្រូវពន្យាពេលដោយកំណត់កាលបរិច្ឆេទ ពេលវេលា និង ទីកន្លែងថ្មី ប្រសិនបើមានសមាសភាពគណៈកម្មការលទ្ធកម្មណាម្នាក់ (ប្រធាន ឬសមាជិកគណៈកម្មការលទ្ធកម្ម) អវត្តមាន
- នៅពេលកាលបរិច្ឆេទថ្មីនៃការពន្យាពេលឈានមកដល់ ដើម្បីឱ្យការបើកសំណើដេញថ្លៃមានសុពលភាពត្រូវមានការចូលរួមពីសមាជិកនៃគណៈកម្មការលទ្ធកម្មយ៉ាងតិចពីររូប ដែលក្នុងនោះមានមួយរូបជាប្រធានគណៈកម្មការលទ្ធកម្ម។
- គណៈកម្មការលទ្ធកម្ម ត្រូវធ្វើរបាយការណ៍បើកសំណើដេញថ្លៃ ដែលរួមមានបញ្ជីឈ្មោះអ្នកចូលរួមដេញថ្លៃ តម្លៃដាក់ចេញ និងការអង្កេតពាក់ព័ន្ធដទៃទៀត។ របាយការណ៍នេះត្រូវចុះហត្ថលេខាដោយសមាសភាពគណៈកម្មការលទ្ធកម្ម និងអ្នកចូលរួមដេញថ្លៃ។

❖ **ដំណាក់កាលទី៣ ៖ ការវាយតម្លៃលើសំណើរដេញថ្លៃ និងចុះកិច្ចសន្យា**

- គណៈកម្មការលទ្ធកម្ម ត្រូវវាយតម្លៃលើសំណើដេញថ្លៃ ដោយមិនត្រូវឱ្យខ្វះខ្វាយព័ត៌មានមកខាងក្រៅទេ រហូតទាល់តែបានធ្វើការសម្រេចរួច។ ការវាយតម្លៃលើសំណើដេញថ្លៃត្រូវពន្យាពេល និងត្រូវកំណត់កាលបរិច្ឆេទ ពេលវេលា និង ទីកន្លែងជាថ្មី ប្រសិនបើមានសមាសភាពគណៈកម្មការលទ្ធកម្មណាម្នាក់អវត្តមាន។

---

[20] - ប្រាក់កក់ធានាការដេញថ្លៃ ជាប្រាក់ធានាដែលអ្នកដេញថ្លៃត្រូវកក់មុននឹងចូលរួមការដេញថ្លៃ ដើម្បីធានាថាអ្នកដេញថ្លៃ ឈ្នះនឹងទទួលយកកិច្ចសន្យា និងចុះកិច្ចសន្យាជាមួយរដ្ឋបាលក្រុង ស្រុក ខណ្ឌ ស្របតាម ពេលវេលាដែលបានកំណត់នៅក្នុងការជូនដំណឹងស្ដីពីការប្រគល់កិច្ចសន្យា។

- នៅពេលកាលបរិច្ឆេទថ្មីនៃការពន្យាពេលឈានមកដល់ ដើម្បីឱ្យការវាយតម្លៃលើសំណើដេញថ្លៃមានភាពត្រឹមត្រូវនោះ ត្រូវមានការចូលរួមពីសមាសភាពនៃគណៈកម្មការលទ្ធកម្មយ៉ាងតិចពីររូប ដែលក្នុងនោះមានមួយរូប ជាប្រធានគណៈកម្មការលទ្ធកម្ម។
- ការវាយតម្លៃលើសំណើដេញថ្លៃ ត្រូវពិនិត្យលើកម្រិតឆ្លើយតបទៅនឹងឯកសារដេញថ្លៃ ហើយបដិសេធនូវសំណើដេញថ្លៃណាដែលមិនស្របទៅតាមការណែនាំផ្លូវការ ឬមិនឆ្លើយតបទៅនឹងការបញ្ជាក់លក្ខណៈបច្ចេកទេសក្នុងឯកសារដេញថ្លៃ ឬតម្លៃមិនត្រឹមត្រូវ។ រាល់ចំណុចខ្វះខាតនៃសំណើដេញថ្លៃ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ដើម្បីបង្ហាញពីភាពសមហេតុផលលើការបដិសេធនូវសំណើដេញថ្លៃក្នុងពេលវាយតម្លៃ។
- ដំណើរការបន្ទាប់ពីការវាយតម្លៃ គឺត្រូវធ្វើការប្រៀបធៀបតម្លៃដេញ និងកំណត់ផ្តល់កិច្ចសន្យាទៅដល់អ្នកដេញថ្លៃ ដែលមានកម្រិតទាបជាងគេ។
- ក្នុងករណីដែលមានតម្លៃដេញទាបស្មើគ្នាពីរឬច្រើន តម្លៃនេះគឺជាតម្លៃមូលដ្ឋានដេញថ្លៃចុះសម្រាប់ឱ្យគណៈកម្មការលទ្ធកម្មប្រើវិធីដេញថ្លៃឡើងវិញ តែចំពោះអ្នកចូលរួមដេញថ្លៃណាដែលមានតម្លៃដេញទាបស្មើគ្នានោះ ដោយឱ្យអ្នកដែលត្រូវដេញថ្លៃឡើងវិញទាំងនោះត្រូវ **សរសេរតម្លៃដេញថ្លៃថ្មី** ដាក់ក្នុងស្រោមសំបុត្របិទជិត រួចប្រគល់ជូនគណៈកម្មការលទ្ធកម្មព្រមគ្នាក្នុងពេលតែមួយ ហើយគណៈកម្មការលទ្ធកម្មត្រូវបើកស្រោមសំបុត្រទាំងនោះភ្លាមនៅចំពោះមុខ ដើម្បីកំណត់បានអ្នកដេញថ្លៃឈ្នះ ដែលមានតម្លៃដេញទាបជាងគេ។
- គណៈកម្មការលទ្ធកម្មត្រូវដាក់របាយការណ៍បើកឯកសារដេញថ្លៃ និងកំណត់ហេតុវាយតម្លៃសំណើដេញថ្លៃ ដើម្បីប្រគល់កិច្ចសន្យាជូនមេឃុំ ចៅសង្កាត់ ពិនិត្យ និងសម្រេច។
- លិខិតសម្រេចជ្រើសរើសអ្នកទទួលការ ដើម្បីប្រគល់កិច្ចសន្យារបស់មេឃុំ ចៅសង្កាត់ត្រូវផ្សព្វផ្សាយជាសាធារណៈ និងបិទនៅក្តារព័ត៌មានរបស់ឃុំ សង្កាត់។ មេឃុំ ចៅសង្កាត់ត្រូវថតចម្លងលិខិតសម្រេចប្រគល់កិច្ចសន្យាភ្ជាប់ជាមួយរបាយការណ៍បើកឯកសារដេញថ្លៃ និងកំណត់ហេតុវាយតម្លៃសំណើដេញថ្លៃ ដើម្បីប្រគល់កិច្ចសន្យាជូនអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ក្រុង។
- អ្នកដេញថ្លៃណាយល់ឃើញថា ការសម្រេចប្រគល់កិច្ចសន្យាខាងលើធ្វើមិនបានត្រឹមត្រូវនោះ មានសិទ្ធិដាក់ពាក្យបណ្តឹងតវ៉ាទៅអភិបាលខេត្ត ក្រុង ដោយមិនឱ្យយឺតជាងពីរថ្ងៃធ្វើការបន្ទាប់ពីលទ្ធផលនៃការវាយតម្លៃលើសំណើដេញថ្លៃត្រូវបានផ្សព្វផ្សាយជាសាធារណៈ។
- ការដាក់ពាក្យបណ្តឹងតវ៉ានេះ អ្នកដេញថ្លៃត្រូវផ្តល់នូវភស្តុតាងគ្រប់គ្រាន់សម្រាប់គាំទ្រចំពោះការតវ៉ារបស់ខ្លួន និងថតចម្លងពាក្យបណ្តឹងតវ៉ានេះមួយច្បាប់ផ្ញើជូនមេឃុំ ចៅសង្កាត់ជ្រាបជាព័ត៌មាន។ អភិបាលខេត្ត ក្រុង ជាអ្នកធ្វើសេចក្តីសម្រេចលើបណ្តឹងតវ៉ារបស់អ្នកដេញថ្លៃ ក្នុងរយៈពេលប្រាំថ្ងៃធ្វើការបន្ទាប់ពីបាន

ទទួលពាក្យបណ្ដឹងតវ៉ា។ សេចក្ដីសម្រេចរបស់អភិបាលខេត្ត ក្រុង ចាត់ទុកជាការសម្រេចចុងក្រោយ និងបិទការតវ៉ាពីគ្រប់ភាគី។

- ក្រោយរយៈពេលប្រាំពីរថ្ងៃធ្វើការ ដែលអភិបាលខេត្ត ក្រុងបានទទួលលិខិតជ្រើសរើសអ្នកទទួលការ ដើម្បីប្រគល់កិច្ចសន្យា និងមិនមានការជំទាស់ជាលាយលក្ខណ៍អក្សរនោះ មេឃុំ ចៅសង្កាត់ ដោយមានជំនួយពីមន្ត្រីគាំទ្របច្ចេកទេស ត្រូវរៀបចំចុះកិច្ចសន្យា និងប្រគល់ការងារឱ្យអ្នកដេញថ្លៃឈ្នះដើម្បីអនុវត្ត។
- មេឃុំ ចៅសង្កាត់ ត្រូវរៀបចំទម្រង់ និងលក្ខខណ្ឌសន្យាចំនួនបីច្បាប់ (ច្បាប់ដើម) និងចុះហត្ថលេខាលើទម្រង់ និងលក្ខខណ្ឌកិច្ចសន្យាទាំងនោះ។ មេឃុំ ចៅសង្កាត់ត្រូវភ្ជាប់លិខិតសម្រេចជ្រើសរើសអ្នកទទួលការដើម្បីប្រគល់កិច្ចសន្យា ទម្រង់ និងលក្ខខណ្ឌកិច្ចសន្យាមួយច្បាប់(ច្បាប់ដើម)ក្រោយពេលចុះកិច្ចសន្យាជាមួយអ្នកទទួលការ ផ្ញើជូនគណនេយ្យករឃុំ សង្កាត់ នៅរតនាគារខេត្ត ក្រុង។[21]

## ៣.២ នីតិវិធីលទ្ធកម្មទំនិញ

ការទិញទំនិញផ្សេងៗ ត្រូវអនុវត្តន៍តាមនីតិវិធីដេញថ្លៃជាសាធារណៈ វិធីសាស្ត្រស្ទង់តម្លៃក្នុងស្រុក និងវិធីសាស្ត្រទិញផ្ទាល់ តាមកម្រិតទឹកប្រាក់ដែលបានកំណត់ក្នុងវិធីសាស្ត្រនីមួយៗ។

### ៣.២.១ វិធីសាស្ត្រដេញថ្លៃជាសាធារណៈ

វិធីសាស្ត្រនេះ មាននីតិវិធីប្រហាក់ប្រហែល និងវិធីសាស្ត្រដេញថ្លៃជាសាធារណៈ នៃការងារសាងសង់ដែរ។

### ៣.២.២ វិធីសាស្ត្រស្ទង់តម្លៃក្នុងស្រុក

វិធីសាស្ត្រនេះ មាននីតិវិធីប្រហាក់ប្រហែល និងវិធីសាស្ត្រដេញថ្លៃជាសាធារណៈគ្រាន់តែមិនមានលក្ខណៈប្រកួតប្រជែងជាចំហឡើយ។ វិធីសាស្ត្រនេះ មាននីតិវិធីដូចខាងក្រោម៖

❖ **ការរៀបចំ និង ការចេញលិខិតអញ្ជើញអំពីការស្ទង់តម្លៃ**

មេឃុំ ចៅសង្កាត់ ឬអ្នកទទួលសិទ្ធិត្រូវរៀបចំឯកសារស្ទង់តម្លៃឱ្យបានរួចរាល់ បន្ទាប់មកចេញលិខិតអញ្ជើញអ្នកផ្គត់ផ្គង់យ៉ាងតិចបីឱ្យមកបំពេញ និងដាក់តម្លៃក្នុងតារាងតម្លៃ ដោយមានបញ្ជាក់អំពីលក្ខណៈបច្ចេកទេស និងលក្ខខណ្ឌនៃការប្រគល់ទទួលទំនិញ ។

❖ **ការវាយតម្លៃលើសំណើស្ទង់តម្លៃក្នុងស្រុក**

ការវាយតម្លៃលើសំណើស្ទង់តម្លៃ ត្រូវធ្វើឡើងតាមលំនាំដូចគ្នា និងការវាយតម្លៃលើសំណើដេញថ្លៃជាសាធារណៈដែរ ដោយមានជំនួយការពីមន្ត្រីគាំទ្របច្ចេកទេស ។ ការវាយតម្លៃត្រូវផ្ដោតទៅលើអនុលោមភាព[22]

[21] - ប្រកាសណែនាំលេខ ២៣១ សហវ.ប្រក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥ ស្ដីពីការងារលទ្ធកម្មរបស់ឃុំ សង្កាត់។

[22] - អនុលោមភាព សំដៅលើភាពស្របតាម និងការប្រព្រឹត្តតាមគោលការណ៍ ផែនការ នីតិវិធី ច្បាប់ បទប្បញ្ញត្តិ កិច្ចសន្យា និងតម្រូវការផ្សេងទៀត។

ទំនិញដែលបានស្នើឡើងតាមការស្ទង់តម្លៃ និង លក្ខខណ្ឌនៃការប្រគល់ ទទួល។ ការស្ទង់តម្លៃដែលបានទទួល និងកំណត់ហេតុនៃការវាយតម្លៃ ត្រូវភ្ជាប់ជាមួយនឹងសំណើទូទាត់ និងដាក់ជូនទៅគណនេយ្យករឃុំ សង្កាត់នៅពេលដែលទំនិញបានប្រគល់ ទទួល ។

❖ **ការចេញលិខិតបញ្ជាទិញ**

មេឃុំ ចៅសង្កាត់ និងអ្នកទទួលសិទ្ធិត្រូវចេញលិខិតបញ្ជាទិញទៅអ្នកផ្គត់ផ្គង់តាមដំណើរការវាយតម្លៃលើតម្លៃស្ទង់ ។

**៣.២.៣ វិធីសាស្ត្រការទិញផ្ទាល់ ឬការចុះកិច្ចសន្យាផ្ទាល់**

វិធីសាស្ត្រនេះ មាននីតិវិធីដូចខាងក្រោមៈ

❖ **ការរៀបចំ និង ការចេញលិខិតអញ្ជើញ**

មេឃុំ ចៅសង្កាត់ ឬអ្នកទទួលសិទ្ធិ ត្រូវរៀបចំការស្រង់តម្លៃដោយចេញលិខិតអញ្ជើញអ្នកផ្គត់ផ្គង់ណាមួយ ឱ្យដាក់សម្រង់តម្លៃដោយបញ្ជាក់អំពីលក្ខណៈ និងលក្ខខណ្ឌនៃការប្រគល់ ទទួល សម្ភារ ឬទំនិញ ដោយមានជំនួយការពីមន្ត្រីគាំទ្របច្ចេកទេស ។

❖ **ការវាយតម្លៃលើសម្រង់តម្លៃ និង ការចរចាថ្លៃ**

ប្រសិនបើការស្នើថ្លៃបានឆ្លើយតប និងសេចក្តីបញ្ជាក់លើលក្ខណៈ និងលក្ខខណ្ឌនៃការអញ្ជើញឱ្យដាក់សម្រង់តម្លៃ មេឃុំ ចៅសង្កាត់ ត្រូវចរចាថ្លៃជាមួយអ្នកផ្គត់ផ្គង់ ដើម្បីសម្របសម្រួលជាមួយនឹងតម្លៃប៉ាន់ស្មានរបស់រដ្ឋបាលឃុំ សង្កាត់ ។

ប្រសិនបើការចរចារថ្លៃមិនទទួលបានជោគជ័យ ដំណើរការដែលមានលំនាំដូចគ្នានេះត្រូវធ្វើឡើងវិញម្តងទៀតជាមួយនឹងអ្នកផ្គត់ផ្គង់ម្នាក់ផ្សេងទៀត ។

❖ **ការចេញលិខិតបញ្ជាទិញ**

មេឃុំ ចៅសង្កាត់ ឬអ្នកទទួលសិទ្ធិត្រូវចេញលិខិតបញ្ជាទិញ បន្ទាប់ពីការចរចាថ្លៃបានឈានដល់ការព្រមព្រៀងគ្នាហើយ ។

**៣.៣ នីតិវិធីលទ្ធកម្មសេវាកម្ម**

ការជ្រើសរើសអ្នកផ្តល់សេវាត្រូវតែធ្វើឡើងជាសាធារណៈ និងមានតម្លាភាព។ សំណើសម្រាប់សេវាបច្ចេកទេសនានា ត្រូវបិទផ្សាយលើក្តារពត៌មានផ្លូវការនៅការិយាល័យរដ្ឋបាលខេត្ត ក្រុង និង ឃុំ សង្កាត់ ឱ្យបានពីរសប្តាហ៍មុនពេលធ្វើការជ្រើសរើស។ រាល់ការស្នើសុំផ្តល់សេវាកម្មទាំងអស់ ត្រូវដាក់ជូនតាមទម្រង់ស្តង់ដារ ដើម្បីជាលទ្ធភាពអាចឱ្យគេធ្វើការវាយតម្លៃប្រៀបធៀបលើ លក្ខណសម្បត្តិជំនាញ បទពិសោធន៍ និងកម្រៃទូទាត់។

រាល់ការស្នើសុំទាំងអស់ និងត្រូវពិនិត្យឡើងវិញដោយគណៈកម្មការលទ្ធកម្ម និងធ្វើអនុសាសន៍លើការជ្រើសរើសអ្នកផ្តល់សេវាឱ្យមេឃុំ ចៅសង្កាត់ ដើម្បីផ្តល់កិច្ចសន្យា ។

ដោយទទួលបានការអនុញ្ញាតពីក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ អាចតែងតាំងអ្នកមានជំនាញអាជីពម្នាក់ពីផ្នែកឯកជន ឬអង្គភាពមិនគិតប្រាក់ចំណេញ ឱ្យធ្វើជាអ្នកត្រួតពិនិត្យបច្ចេកទេសសម្រាប់កិច្ចសន្យាការងារសាងសង់។ អ្នកត្រួតពិនិត្យបច្ចេកទេសដែលតែងតាំងដោយ មេឃុំ ចៅសង្កាត់រួច ត្រូវបញ្ជូនឈ្មោះដើម្បីចុះបញ្ជីនៅផ្នែករដ្ឋបាលមូលដ្ឋានខេត្ត ក្រុង ។

ការផ្តល់កិច្ចសន្យាដល់អ្នកត្រួតពិនិត្យបច្ចេកទេស ត្រូវធ្វើឡើងដូចគ្នានឹងនីតិវិធីផ្តល់កិច្ចសន្យា ដល់អ្នកផ្តល់សេវាដែរ។ កម្រៃសម្រាប់ទូទាត់ដល់អ្នកត្រួតពិនិត្យបច្ចេកទេសឯករាជ្យ ត្រូវរៀបចំលៃទុក និងគិតគូរដោយឃុំ សង្កាត់ ហើយត្រូវបានគិតបញ្ចូលទៅក្នុងតម្លៃវិនិយោគសរុប នៃកិច្ចសន្យាដែលពាក់ព័ន្ធ ។

# ជំពូកទី ៣
# ការគ្រប់គ្រង និងការអនុវត្ត
# កិច្ចលទ្ធកម្មសាធារណៈក្នុងឃុំសែនដី
# ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ

# ជំពូកទី៣
# ការគ្រប់គ្រង និងការអនុវត្ត
# កិច្ចលទ្ធកម្មសាធារណៈក្នុងឃុំសែនដីស្រុកសំរោងទងខេត្តកំពង់ស្ពឺ

## ផ្នែកទី ១ ៖ ការគ្រប់គ្រងកិច្ចលទ្ធកម្មសាធារណៈ នៅឃុំសែនដី

### ១. ការរៀបចំ និងការសិក្សាគម្រោងថវិកាឃុំ សង្កាត់

គម្រោង គឺជាសំណុំនៃលទ្ធផល ឬសកម្មភាព ដែលរួមគ្នាដើម្បីសម្រេចទិសដៅមួយ ក្នុងក្របខណ្ឌពេលវេលាមួយ និងថវិកាជាក់លាក់។ គម្រោងមានដូចជា គម្រោងហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន គម្រោងសេវាកម្ម និងគម្រោងទំនិញ។

#### ១.១ ការរៀបចំគម្រោង

គម្រោងឃុំ សង្កាត់ គឺជាគម្រោងដែលឆ្លុះបញ្ចាំងនៅក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ហើយថវិកាដែលបានវិភាជន៍សម្រាប់គម្រោងទាំងនេះ ត្រូវឆ្លុះបញ្ចាំងនៅក្នុងគម្រោងថវិកាប្រចាំឆ្នាំរបស់ឃុំ សង្កាត់។ គម្រោងឃុំ សង្កាត់អាចមានលក្ខណៈជាគម្រោងរបស់រដ្ឋបាលឃុំ សង្កាត់នីមួយៗ ឬជាគម្រោងអន្តររដ្ឋបាលរវាងរដ្ឋបាលឃុំ សង្កាត់ជាមួយរដ្ឋបាលប្រភេទដូចគ្នា ឬប្រភេទខុសគ្នា។

គម្រោងថវិកាឃុំ សង្កាត់ ត្រូវរៀបចំឡើងក្រោមការទទួលខុសត្រូវរបស់មេឃុំ ចៅសង្កាត់ ហើយត្រូវដាក់ជូនក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីពិនិត្យ និងអនុម័ត។ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវអនុម័តគម្រោងថវិកា នាកិច្ចប្រជុំជាសាធារណៈឱ្យបានមុនថ្ងៃទី៣១ ខែតុលា។ បន្ទាប់មកមេឃុំ ចៅសង្កាត់ ត្រូវបញ្ជូនគម្រោងថវិកា ដែលបានអនុម័តរួចទៅអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ឱ្យបានមុនថ្ងៃទី០៥ ខែវិច្ឆិកា ដើម្បីសុំការបញ្ជាក់ទទួល ស្គាល់ពីអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ដោយមិនឱ្យហួសថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំជាកំហិត។[23]

ការរៀបចំគម្រោងត្រូវធ្វើឡើង បន្ទាប់ពីគម្រោងត្រូវបានបញ្ចូលក្នុងកម្មវិធីវិនិយោគឃុំ សង្កាត់ និងមុនពេលការចាប់ផ្តើមដំណើរការលទ្ធកម្ម។ ការរៀបចំគម្រោង គឺជាការសិក្សា និងប្រមូលព័ត៌មានទាំងអស់ ដែលត្រូវការដើម្បីរៀបចំឱ្យបាននូវគ្រោងការគម្រោង រួមមាន៖

- ពិនិត្យអំពីតម្រូវការនៃការសិក្សាផលប៉ះពាល់បរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចរបស់គម្រោង
- ការបង្កើតគណៈកម្មការគ្រប់គ្រងគម្រោង
- ការរៀបចំក្រុមប្រើប្រាស់
- ការរៀបចំផែនការសិក្សាគម្រោង

[23]- អនុក្រឹត្យលេខ៩៣ អនក្រ.បក ចុះថ្ងៃទី ០៦ ខែសីហា ឆ្នាំ២០១០ ស្តីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិឃុំ សង្កាត់។

- ការសិក្សា និងប្រមូលព័ត៌មានទូទៅ និងព័ត៌មានបច្ចេកទេស
- ការសិក្សា និងវិភាគផលប៉ះពាល់បរិស្ថាន
- ការសិក្សាដីធ្លី (របាយការណ៍បរិច្ចាគដីធ្លីដោយស្ម័គ្រចិត្ត ឬរបាយការណ៍លទ្ធកម្មដីធ្លី)
- ការរៀបចំរបាយការណ៍ស្តីពីវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិច
- ការរៀបចំគ្រោងការគម្រោង
- ការប៉ាន់ស្មានតម្លៃ
- ការរៀបចំផែនការប្រើប្រាស់ និងថែទាំលទ្ធផលគម្រោង
- ការរៀបចំទម្រង់លទ្ធផល និងតម្លៃប៉ាន់ស្មានគម្រោង
- ការអនុម័តគម្រោង
- ការពិនិត្យព័ត៌មានគម្រោងដោយអង្គភាពរដ្ឋបាលខេត្ត ក្រុង
- ការពិនិត្យបញ្ជាក់បច្ចេកទេស។

បន្ទាប់ពីក្រុមប្រឹក្សាឃុំ សង្កាត់សម្រេចអនុវត្តគម្រោងជាក់លាក់ (គម្រោងដែលប្រើប្រាស់មូលនិធិ ឃុំ សង្កាត់ គម្រោងដែលមានការសន្យាគាំទ្រពីស្ថាប័ន ដៃគូអភិវឌ្ឍន៍នានា) ចាំបាច់រដ្ឋបាលឃុំ សង្កាត់ ត្រូវអនុវត្តទៅតាមសៀវភៅណែនាំស្តីពី ការរៀបចំ និងអនុវត្តន៍គម្រោងមូលនិធិឃុំ សង្កាត់ ។

**១.២ ការសិក្សាគម្រោង** (**គម្រោងហេដ្ឋារចនាសម្ព័ន្ធ**)

ការសិក្សាគម្រោង គឺជាដំណើរការមួយដើម្បីឱ្យដឹងថា ៖

- តើគម្រោងនឹងត្រូវប្រើប្រាស់ថវិកាអស់ប៉ុន្មាន?
- តើជាគម្រោងចាស់ ឬជាគម្រោងដែលពង្រីកលើសពី ២៥ភាគរយ ឬជាគម្រោងថ្មី?

នៅក្នុងដំណើរការនៃការសិក្សាគម្រោង ដោយសារតែក្រុមប្រឹក្សាឃុំ សង្កាត់មិនមានជំនាញ បច្ចេកទេស ដូច្នេះរដ្ឋបាលឃុំ សង្កាត់មានជម្រើសមួយចំនួន ដូចជា៖

- ធ្វើការចាត់តាំងមន្ត្រីដែលមានជំនាញជាក់លាក់នៅក្នុងរដ្ឋបាលឃុំ សង្កាត់
- ជួលអ្នកជំនាញពីវិស័យឯកជន
- ស្នើសុំមន្ត្រីជំនាញពីរដ្ឋបាលរាជធានី ខេត្ត។

នៅពេលធ្វើការសិក្សាគម្រោងដោយអ្នកជំនាញបច្ចេកទេស ចាំបាច់ត្រូវមានការចូលរួមពី ក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រជាពលរដ្ឋមូលដ្ឋាន ដើម្បីឱ្យបានដឹងច្បាស់ថា តើមានការប៉ះពាល់សុវត្ថិភាពទាំងបី (សុវត្ថិភាពបរិស្ថាន សុវត្ថិភាពដីធ្លី សុវត្ថិភាពជនជាតិដើមភាគតិច)ដែរឬទេ។ បន្ទាប់ពីសិក្សាគម្រោងរួច ត្រូវមានការពិនិត្យបញ្ជាក់បច្ចេកទេសពីមន្ទីរជំនាញ ដែលមានទីចាត់ការផែនការ និងវិនិយោគ រាជធានី ខេត្តជាអ្នកសម្របសម្រួលជាមួយ

មន្ទីរជំនាញ ហើយមន្ទីរជំនាញមានពេល១៥ថ្ងៃ ក្នុងការពិនិត្យបញ្ជាក់បច្ចេកទេសបើមិនដូច្នោះចាត់ទុកថាឯកភាព។

## ២. ការគ្រប់គ្រង និងការអនុវត្តគម្រោង

មេឃុំ ចៅសង្កាត់ទទួលខុសត្រូវក្នុងការគ្រប់គ្រងគម្រោង និងការអនុវត្តគម្រោងដែលមាននៅក្នុង កម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ និងគម្រោងថវិកាឃុំ សង្កាត់។

### ២.១ មេឃុំ និងចៅសង្កាត់

នៅក្នុងដំណាក់កាលរៀបចំគម្រោង មេឃុំ សង្កាត់ទទួលខុសត្រូវក្នុងការ ៖

- រៀបចំសេចក្តីព្រាងសេចក្តីសម្រេចស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈកម្មការគ្រប់គ្រងគម្រោង ដើម្បីដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងអនុម័ត
- គ្រប់គ្រងការសិក្សាគម្រោង និងសម្របសម្រួលការងារជាមួយអ្នកពាក់ព័ន្ធទាំងអស់
- កំណត់អ្នកជំនួយបច្ចេកទេសសម្រាប់ជួយក្នុងការសិក្សា និងការរៀបចំគម្រោង
- ចុះហត្ថលេខាលើឯកសារសំណើគម្រោង
- ចាត់ចែងផ្ញើសំណុំឯកសារសំណើគម្រោង (ព័ត៌មានគម្រោង និងឯកសារពាក់ព័ន្ធនានា)ទៅទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្ត ដើម្បីពិនិត្យ។

### ២.២ ក្រុមប្រឹក្សាឃុំ សង្កាត់

ចំពោះប្រភេទគម្រោងមួយចំនួន ក្រុមប្រឹក្សាឃុំ សង្កាត់នឹងទទួលខុសត្រូវផ្ទាល់ក្នុងការប្រតិបត្តិការ និងការថែទាំលទ្ធផលគម្រោង ហើយការចំណាយសម្រាប់កិច្ចប្រតិបត្តិការ និងការថែទាំនេះត្រូវគ្រោងនៅក្នុងគម្រោងថវិកាប្រចាំឆ្នាំរបស់ឃុំ សង្កាត់។ ជាទូទៅគម្រោងទាំងនោះ គឺជា៖

- គម្រោងហេដ្ឋារចនាសម្ព័ន្ធសាធារណៈដែលផ្តល់ផលប្រយោជន៍ដល់សហគមន៍ទាំងមូល
- គម្រោងសេវាកម្មដែលផ្តល់ផលប្រយោជន៍ដល់សហគមន៍ទាំងមូល
- គម្រោងដែលមិនមានភ្នាក់ងាររបស់រាជរដ្ឋាភិបាលណាមួយទទួលខុសត្រូវ។

### ២.៣ គណៈកម្មការគ្រប់គ្រងគម្រោង

គណៈកម្មការគ្រប់គ្រងគម្រោងមានតួនាទី ភារកិច្ចដូចខាងក្រោម៖

#### ២.៣.១ ក្នុងការរៀបចំគម្រោង

- ពិនិត្យ និងអនុម័តផែនការសិក្សាគម្រោង
- គ្រប់គ្រងចាត់ចែងដំណើរការសិក្សា និងរៀបចំគម្រោង
- រៀបចំសំណើគម្រោងដោយមានជំនួយពីអ្នកជំនួយបច្ចេកទេស
- ពិនិត្យ និងអនុម័តសំណើគម្រោង។

### ២.៣.២ ក្នុងការអនុវត្តគម្រោង

- គ្រប់គ្រងចាត់ចែងដំណើរការអនុវត្តគម្រោង
- រៀបចំប្រជុំចាប់ផ្តើម និងបញ្ចប់នៃការអនុវត្តការងារ ឬការផ្គត់ផ្គង់ទំនិញ និងរៀបចំប្រជុំពិនិត្យ និងអនុម័តការទូទាត់គម្រោង
- តាមដានត្រួតពិនិត្យការអនុវត្តគម្រោង
- រៀបចំកិច្ចប្រជុំនានានៅក្នុងអំឡុងពេលអនុវត្តគម្រោង ដើម្បីពិនិត្យ និងវាយតម្លៃការអនុវត្តគម្រោង។

## ២.៤ អ្នកជំនួយបច្ចេកទេស

អ្នកជំនួយបច្ចេកទេស មានភារកិច្ចដូចខាងក្រោម ៖

- ពិនិត្យអំពីតម្រូវការនៃការសិក្សាផលប៉ះពាល់បរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចរបស់គម្រោង
- រៀបចំផែនការសិក្សាគម្រោង
- រៀបចំផែនទីគម្រោង
- អនុវត្តន៍ការសិក្សាលទ្ធភាពគម្រោង
- ជួយក្នុងការសិក្សាផលប៉ះពាល់បរិស្ថានដីធ្លី និងជនជាតិដើមភាគតិច
- រៀបចំគ្រោងការគម្រោង
- ប៉ាន់ស្មានតម្លៃគម្រោង
- បំពេញព័ត៌មានផ្នែកបច្ចេកទេសទៅក្នុងទម្រង់ព័ត៌មានគម្រោង
- ជួយបញ្ចូលព័ត៌មានគម្រោងទៅក្នុងប្រព័ន្ធទិន្នន័យនៃការអនុវត្តគម្រោងឃុំ សង្កាត់។

## ២.៥ ការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់ និងការិយាល័យផែនការ និងអភិវឌ្ឍន៍

ការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់នៃរដ្ឋបាលក្រុង ស្រុក និងការិយាល័យផែនការ និងអភិវឌ្ឍន៍នៃរដ្ឋបាលខណ្ឌ មានតួនាទីដូចខាងក្រោម៖

- គាំទ្រដល់រដ្ឋបាលឃុំ សង្កាត់ក្នុងការកសាង និងការអនុវត្តផែនការអភិវឌ្ឍឃុំ សង្កាត់
- ចូលរួមក្នុងការស្រង់តម្លៃសម្ភារស្តង់ដារសម្រាប់រៀបចំបញ្ជីសម្ភារស្តង់ដារ
- ចូលរួមសម្របសម្រួលក្នុងការសិក្សាគម្រោងឃុំ សង្កាត់ ជាពិសេសការសិក្សាផលប៉ះពាល់បរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច។

## ២.៦ ទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្ត

ទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្តមានតួនាទីដូចខាងក្រោម៖

- សម្របសម្រួល និងគាំទ្រឃុំ សង្កាត់ក្នុងការអនុវត្តផែនការអភិវឌ្ឍ កម្មវិធីវិនិយោគ និងគម្រោងនានាតាមការស្នើសុំ គាំទ្រឃុំ សង្កាត់ក្នុងការសិក្សាគម្រោង ការរៀបចំប្លង់ ការប៉ាន់ស្មានតម្លៃ និងការរៀបចំសំណើគម្រោង
- ចងក្រង និងធ្វើបច្ចុប្បន្នភាពទិន្នន័យគម្រោងឃុំ សង្កាត់ដោយធានាថាការបញ្ចូលព័ត៌មានគម្រោងទៅក្នុងប្រព័ន្ធទិន្នន័យនៃការអនុវត្តគម្រោងឃុំ សង្កាត់ត្រូវបានអនុវត្តទៅតាមសេចក្តីណែនាំរបស់គ.ជ.អ.ប[24] ស្តីពីការបញ្ចូលព័ត៌មានទិន្នន័យគម្រោងទៅក្នុងប្រព័ន្ធទិន្នន័យនៃការអនុវត្តគម្រោងឃុំ សង្កាត់
- រៀបចំបញ្ជីតម្លៃសម្ភារស្តង់ដារសម្រាប់ជាមូលដ្ឋានក្នុងការគណនាតម្លៃប៉ាន់ស្មានគម្រោង
- ពិនិត្យលើភាពត្រឹមត្រូវ និងភាពគ្រប់គ្រាន់នៃរបាយការណ៍សិក្សាផលប៉ះពាល់បរិស្ថាន ដី ធ្លី និងជនជាតិដើមភាគតិច

## ២.៧ ការអនុវត្តគម្រោង

បន្ទាប់ពីមានកិច្ចសន្យារវាងអ្នកទទួលការ(អ្នកឈ្នះការដេញថ្លៃ) និងម្ចាស់គម្រោង(ឃុំ-សង្កាត់) អ្នកទទួលការត្រូវចាប់ផ្តើមអនុវត្តន៍ទៅតាមលក្ខខណ្ឌនៃកិច្ចសន្យា។ នៅក្នុងដំណើរការអនុវត្តកិច្ចសន្យារបស់អ្នកទទួលការ ក្រុមប្រឹក្សាឃុំ សង្កាត់ដោយមានគណៈកម្មការគ្រប់គ្រងគម្រោងមូលនិធិឃុំ សង្កាត់ជាអ្នកតាមដានការអនុវត្តកិច្ចសន្យា ដែលគណៈកម្មការគ្រប់គ្រងគម្រោងមូលនិធិឃុំ សង្កាត់ត្រូវពិនិត្យ មើលផែនការការងាររបស់អ្នកទទួលការ និងគំនូសប្លង់បច្ចេកទេសលម្អិត ដែលភ្ជាប់ជាមួយកិច្ចសន្យា។

គណៈកម្មការគ្រប់គ្រងគម្រោងមូលនិធិឃុំ សង្កាត់ ក៏ត្រូវបានអ្នកគាំទ្របច្ចេកទេសរាជធានី ខេត្តធ្វើការបណ្តុះបណ្តាលបច្ចេកទេស "៦ in ១" (ឧបករណ៍សម្រាប់តាមដានការអនុវត្តគម្រោងទាំង៦ រួមមាន ១.ឋានលេខា ២.ឌីស៊ីភី ៣.តេស្តបេតុង ៤.ខ្សែម៉ែត ៥.កែវស្ទង់ ៦.ក្តារម៉ែត្រ) អំពីការត្រួតពិនិត្យ គម្រោងហេដ្ឋារចនាសម្ព័ន្ធ និងមានសិទ្ធិឃាត់ឱ្យផ្អាកការសាងសង់ ដើម្បីហៅអ្នកគាំទ្របច្ចេកទេសមក ពិនិត្យជាក់ស្តែង។

ក្រៅពីគណៈកម្មការគ្រប់គ្រងគម្រោងមូលនិធិឃុំ សង្កាត់ ប្រជាពលរដ្ឋក៏អាចចូលរួម តាមដានការអនុវត្តរបស់អ្នកទទួលការ និងមានសិទ្ធិផ្តល់ព័ត៌មានទៅគណៈកម្មការគ្រប់គ្រងគម្រោង មូលនិធិឃុំ សង្កាត់ដើម្បីគណៈកម្មការគ្រប់គ្រងគម្រោងមូលនិធិឃុំ សង្កាត់ឃាត់ឱ្យផ្អាកការសាងសង់ ដើម្បីហៅអ្នកគាំទ្របច្ចេកទេសមកពិនិត្យជាក់ស្តែង។

[24]- គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ. ប) គឺជាយន្តការអន្តរក្រសួងសម្រាប់ការលើកកម្ពស់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមរយៈកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការនៅក្នុងប្រទេសកម្ពុជា ។

## ៣. ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការលទ្ធកម្ម

បច្ចុប្បន្នការអនុវត្តកិច្ចលទ្ធកម្មសាធារណៈបាន និងកំពុងអនុវត្តកិច្ចលទ្ធកម្មសាធារណៈតាមបែបវិសហមជ្ឈការ កិច្ចលទ្ធកម្មសាធារណៈ ដោយផ្តល់សិទ្ធិអំណាចនិងការទទួលខុសត្រូវជាបណ្តើរៗ ទៅឱ្យស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់។ ការអនុវត្តគោលនយោបាយនេះ គឺដើម្បីបង្កើនតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាពនៃការគ្រប់គ្រងលទ្ធកម្មសាធារណៈ តាមរយៈការពង្រឹងការបែងចែកមុខងារ ភារកិច្ច និងការទទួលខុសត្រូវឱ្យកាន់តែច្បាស់លាស់នៅកម្រិតគ្រប់គ្រងនិង កម្រិតអនុវត្តន៍។

### ៣.១ គណៈកម្មការលទ្ធកម្ម របស់ឃុំសែនដី

គណៈកម្មការលទ្ធកម្មសាធារណៈថ្នាក់ឃុំ ត្រូវបានបង្កើតឡើងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ ដែលមានសមាភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| ១. លោក កែវ រ៉ន | មេឃុំសែនដី | ជាប្រធាន |
| ២. លោក ខៀវ ឌី | ជំទប់ទី១ | ជាសមាជិក |
| ៣. លោក សួស សំអូន | សមាជិកក្រុមប្រឹក្សាឃុំ | ជាសមាជិក |
| ៤. លោកស្រី ណុប ដារ៉ា | ស្មៀនឃុំសែនដី | ជាលេខាធិការ |

### ៣.២ តួនាទី និងទំនួលខុសត្រូវ នៅក្នុងការអនុវត្តកិច្ចលទ្ធកម្មឃុំសង្កាត់

#### ៣.២.១ ក្រុមប្រឹក្សាឃុំ សង្កាត់

ក្រុមប្រឹក្សាឃុំ សង្កាត់មានតួនាទីដូចជា៖

- អនុម័តជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ចំនួន០២រូប សម្រាប់ជាសមាជិកគណៈកម្មការលទ្ធកម្មឃុំសង្កាត់
- ពិនិត្យ និងអនុម័តទៅលើសេចក្តីព្រាងសេចក្តីសម្រេចស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈកម្មការលទ្ធកម្មឃុំ សង្កាត់
- ពិនិត្យ និងអនុម័តបញ្ជីឈ្មោះអ្នកទទួលដែលមានសិទ្ធិដាក់សំណើដេញថ្លៃគម្រោងឃុំ សង្កាត់
- ពិនិត្យ និងអនុម័តទៅលើសំណើតែងតាំង អ្នកត្រួតពិនិត្យបច្ចេកទេសក្នុងករណីអ្នកត្រួតពិនិត្យបច្ចេកទេសត្រូវបានជ្រើសរើសចេញពីផ្នែកឯកជន
- ត្រួតពិនិត្យមើលទៅលើភាពត្រឹមត្រូវនៃការអនុវត្តគម្រោង
- តាមដាន និងវាយតម្លៃទៅលើវឌ្ឍភាពនៃការអនុវត្តគម្រោង និងផលប៉ះពាល់នានា ដែលបណ្តាលមកពីការអនុវត្តគម្រោង។

### ៣.២.២ មេឃុំ ចៅសង្កាត់

មេឃុំ ចៅសង្កាត់ទទួលខុសត្រូវក្នុងការអនុវត្តកិច្ចលទ្ធកម្មសំណង់ លទ្ធកម្មសេវាកម្ម និងលទ្ធកម្មទំនិញ នៅក្នុងឃុំ សង្កាត់របស់ខ្លួន។មេឃុំ ចៅសង្កាត់មានតួនាទីដូចជា៖

- តែងតាំងអ្នកត្រួតពិនិត្យបច្ចេកទេស
- ជាប្រធានគណៈកម្មការលទ្ធកម្ម
- រៀបចំឯកសារដេញថ្លៃ(ដោយមានជំនួយពីអ្នកជំនួយបច្ចេកទេស)
- ប្រកាសជូនដំណឹងអំពីការដេញថ្លៃ
- រៀបចំប្រជុំបើកសំណើរដេញថ្លៃ ប្រជុំវាយតម្លៃសំណើរដេញថ្លៃ និងប្រជុំប្រកាសលទ្ធផលដេញថ្លៃ
- រៀបចំរបាយការណ៍ដេញថ្លៃ និងព័ត៌មានកិច្ចសន្យា
- ចេញលិខិតជូនដំណឹងស្តីពីការសម្រេចផ្តល់កិច្ចសន្យា ដល់អ្នកទទួលការ ឬអ្នកផ្តល់សេវាកម្ម ឬអ្នកផ្គត់ផ្គង់ទៅតាមលទ្ធផលនៃការដេញថ្លៃ
- ឯកភាពទៅលើផែនការការងារសម្រាប់អនុវត្តន៍កិច្ចសន្យា
- ចុះហត្ថលេខាលើកិច្ចសន្យា
- តាមដានការអនុវត្តកិច្ចសន្យា
- រៀបចំកិច្ចប្រជុំគណៈកម្មការគ្រប់គ្រងគម្រោង
- បោះផ្សាយអាណត្តិបើកប្រាក់។

### ៣.២.៣ គណៈកម្មការលទ្ធកម្ម

➢ គណៈកម្មការលទ្ធកម្មមានតួនាទីដូចជា៖

- អនុវត្តន៍ដំណើរការដេញថ្លៃ ទៅតាមនីតិវិធីដែលបានកំណត់
- ពិនិត្យ និងវាយតម្លៃសំណើដេញថ្លៃ និងឯកសារពាក់ព័ន្ធដែលបានដាក់ដោយអ្នកដេញថ្លៃ
- ផ្តល់អនុសាសន៍ដល់មេឃុំ ចៅសង្កាត់អំពីអ្នកឈ្នះក្នុងការដេញថ្លៃ។

➢ គណៈកម្មការលទ្ធកម្មត្រូវធានាបានថា ៖

- លទ្ធកម្មការងារសាងសង់ សម្ភារ ឬទំនិញ និងសេវា ត្រូវបានប្រព្រឹត្តិទៅប្រកបដោយតម្លាភាព និងសន្សំសំចៃខ្ពស់
- អ្នកទទួលការ និងអ្នកផ្គត់ផ្គង់ ត្រូវបានផ្តល់ឱកាសស្មើៗគ្នាក្នុងការចូលរួមប្រកួតប្រជែងក្នុងការងារសាងសង់ ផ្គត់ផ្គង់សម្ភារ ឬទំនិញ និងផ្តល់សេវា ក្រោមលក្ខខណ្ឌតែមួយ
- លទ្ធផលនៃការដេញថ្លៃ ត្រូវប្រកាសជាសាធារណៈ

- ត្រូវអនុវត្តន៍វិធីសាស្ត្រដេញថ្លៃដោយប្រកួតប្រជែងជាចំហ សម្រាប់ការងារសាងសង់ផ្គត់ផ្គង់សម្ភារ ឬទំនិញ និងសេវា ចំពោះការចំណាយ និងតាមលក្ខខណ្ឌដូចខាងក្រោម៖
  - រាល់ការចំណាយសម្រាប់អភិវឌ្ឍន៍មូលដ្ឋានដោយមិនគិតពីទំហំទឹកប្រាក់នៃកិច្ចសន្យានីមួយៗទេ
  - ការចំណាយសម្រាប់សកម្មភាពដទៃទៀត ដែលមានទំហំទឹកប្រាក់លើសពី២លានរៀលក្នុងកិច្ចសន្យានីមួយៗ។[25]

### ៣.២.៤ មន្ត្រីគាំទ្របច្ចេកទេសរាជធានី ខេត្ត

មន្ត្រីគាំទ្របច្ចេកទេស គឺជាមន្ត្រីដែលបានជ្រើសរើសមកពី មន្ទីរជំនាញខេត្ត ក្រុង និង ត្រូវតែងតាំងដោយអភិបាលខេត្ត ក្រុង មានភារកិច្ចត្រូវត្រួតពិនិត្យ តាមដាន ដំណើរការលទ្ធកម្មក្នុងនាមអភិបាលខេត្ត ក្រុង ។ ក្នុងករណីមានសំណើពីឃុំ សង្កាត់ មន្ត្រីគាំទ្របច្ចេកទេសត្រូវជួយក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការគ្រប់គ្រងការងារបច្ចេកទេសការចាត់ចែងនៃដំណើរការដេញថ្លៃ និងអនុវត្តន៍កិច្ចសន្យា និងអាចបំពេញភារកិច្ចការជាអ្នកត្រួតពិនិត្យបច្ចេកទេសផងដែរដោយមិនគិតថ្លៃ ។

មន្ត្រីបច្ចេកទេសរាជធានីខេត្ត អាចផ្តល់យោបល់ទៅលើសំណើដេញថ្លៃណាមួយបាន លុះត្រាតែមានការស្នើសុំពីប្រធានគណៈកម្មការលទ្ធកម្ម។ ប្រសិនបើគណៈកម្មការលទ្ធកម្មធ្វើការសម្រេចណាមួយដែលផ្ទុយនិងការណ៍ណែនាំ មន្ត្រីគាំទ្របច្ចេកទេសរាជធានីខេត្ត ត្រូវសរសេរនៅក្នុងរបាយការណ៍ស្តីពីការដេញថ្លៃរបស់ខ្លួនដោយបញ្ជាក់ឱ្យបានច្បាស់លាស់ អំពីការសម្រេចដែលមិនត្រឹមត្រូវតាមគោលការណ៍ណែនាំ។

មន្ត្រីគាំទ្របច្ចេកទេស មិនត្រូវព្យាយាមបញ្ចុះបញ្ចូលឱ្យគណៈកម្មការលទ្ធកម្មឱ្យទទួលយក ឬបដិសេធសំណើដេញថ្លៃណាមួយឡើយ។ ប្រសិនបើគណៈកម្មការលទ្ធកម្មជឿជាក់ថាមន្ត្រីគាំទ្របច្ចេកទេស បានព្យាយាមបញ្ចុះបញ្ចូលឱ្យខ្លួនផ្តល់ភាពលំអៀងដល់អ្នកដេញថ្លៃណាម្នាក់ គឺជាបញ្ហាមិនមានតម្លាភាពនិគណនេយ្យភាពឡើយ។

### ៣.២.៥ អ្នកត្រួតពិនិត្យ

អ្នកត្រួតពិនិត្យបច្ចេកទេស គឺជាអ្នកដែលត្រូវបានជ្រើសតាំងដោយ ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីធ្វើការត្រួតពិនិត្យ បញ្ជាក់ពីបរិមាណ និង គុណភាពការងារ សាងសង់ និង សេវាកម្ម ។

អ្នកត្រួតពិនិត្យត្រូវជួយមេឃុំ ចៅសង្កាត់លើការងាដូចជា៖

- បង្រៀនគណៈកម្មការគ្រប់គ្រងគម្រោងឬតំណាងម្ចាស់គម្រោងអំពីចំណុចសំខាន់ៗផ្នែកច្ចេកទេស ដើម្បីតាមដានការត្រួតពិនិត្យការអនុវត្តកិច្ចសន្យា
- ត្រួតពិនិត្យការអនុវត្តកិច្ចសន្យា

[25] - ប្រកាសណែនាំលេខ ១៧២ សហវ.ប្រក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០៣ ស្តីពីការងារលទ្ធកម្មរបស់ឃុំ សង្កាត់។

- រៀបចំរបាយ៍ការរីកចម្រើនដែលបញ្ជាក់ទៅលើគុណភាព និងបរិមាណនៃការងារ ឬទំនិញរបស់អ្នកទទួលការ ឬអ្នកផ្គត់ផ្គងសេវាកម្ម ឬអ្នកផ្គត់ផ្គង់។

### ៣.២.៦ អង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ក្រុង

អង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ក្រុងមានតួនាទី ដូចខាងក្រោមៈ

- សម្របសម្រួលអំពីកាលបរិច្ឆេទនៃការប្រជុំបើកសំណើដេញថ្លៃរបស់ឃុំ សង្កាត់
- តាមដានដំណើរការលទ្ធកម្ម និងការអនុវត្តកិច្ចសន្យាឃុំ សង្កាត់
- ទទួលរបាយការណ៍ស្តីពីដំណើរការដេញថ្លៃ និងព័ត៌មាននៃកិច្ចសន្យា ពីមេឃុំ ចៅសង្កាត់
- សរសេររបាយការណ៍ និងផ្តល់យោបល់ជូនអភិបាលខេត្ត ក្រុងអំពីដំណើរការលទ្ធកម្ម និងការអនុវត្តកិច្ចសន្យាឃុំ សង្កាត់
- សម្របសម្រួលដំណើរការអនុវត្តកិច្ចសន្យាឃុំ សង្កាត់
- ប្រមូលព័ត៌មានវាយតម្លៃ ការអនុវត្តការងាររបស់អ្នកទទួលការ ពីក្រុមប្រឹក្សាឃុំ សង្កាត់
- ជួយឃុំ សង្កាត់ក្នុងការរៀបចំកិច្ចប្រជុំជាមួយអ្នកផ្តល់សេវាកម្មនៅថ្នាក់ខេត្ត ក្រុង ឬស្រុក ខណ្ឌ ដើម្បី ផ្សព្វផ្សាយអំពីគម្រោងសេវាកម្ម(បើចាំបាច់)។

### ៣.២.៧ អភិបាលខេត្ត ក្រុង

អភិបាលខេត្ត ក្រុងទទួលខុសត្រូវក្នុងការគ្រប់គ្រងបញ្ជីឈ្មោះអ្នកទទួលការ ដែលអាចដេញថ្លៃបានដើម្បីចុះ កិច្ចសន្យាជាមួយក្រុមប្រឹក្សាឃុំ សង្កាត់។ វិស្វករឯកជនដែលផ្តល់សេវាវិស្វកម្មដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ក៏ត្រូវចុះ ឈ្មោះជាមួយអភិបាលខេត្ត ក្រុងផងដែរ ។ អនុគណៈកម្មការវាយតម្លៃបុរេលក្ខណសម្បត្តិអ្នកទទួលការ នឹងផ្តល់យោបល់ដល់អភិបាលខេត្ត ក្រុងអំពីបញ្ជីឈ្មោះអ្នកទទួលការ ។

អភិបាលខេត្ត ក្រុងមានសិទ្ធិបញ្ឈប់មេឃុំ ចៅសង្កាត់មិនឱ្យចុះហត្ថលេខាលើកិច្ចសន្យា ប្រសិនបើមានបញ្ហាណាមួយកើតឡើងក្នុងដំណើរការលទ្ធកម្ម ដោយយោងតាមរបាយការណ៍ដេញថ្លៃ និងបណ្តឹងតវ៉ានានាពីអ្នកដេញថ្លៃ។ ប្រសិនបើអភិបាលខេត្ត ក្រុងពុំមានការជំទាស់នៅក្នុងរយៈពេល៧ថ្ងៃធ្វើការងារ បន្ទាប់ពីបានទទួលរបាយការណ៍ ការដេញថ្លៃ មេឃុំ ចៅសង្កាត់អាចចុះហត្ថលេខាលើកិច្ចសន្យាបាន។

ប្រសិនបើមានជំម្លោះណាមួយកើតមានឡើងរវាងម្ចាស់គម្រោង និងអ្នកទទួលការនៅក្នុងអំឡុងពេលនៃការអនុវត្តគម្រោង អភិបាលខេត្ត ក្រុងអាចត្រូវបានអញ្ជើញឱ្យជួយដោះស្រាយ ។

ក្នុងករណីនេះ អភិបាលខេត្ត ក្រុងត្រូវបង្កើតក្រុមមួយដើម្បីសិក្សាស្រាវជ្រាវ។ ក្រុមសិក្សាស្រាវជ្រាវនឹងរៀបចំរបាយការណ៍ជូនអភិបាលខេត្ត ក្រុង។អភិបាលខេត្ត ក្រុងត្រូវសម្រេចដោយពិចារណាទៅលើរបាយការណ៍

របស់ក្រុម សិក្សាស្រាវជ្រាវ របាយការណ៍របស់អង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ក្រុង និងរបាយការណ៍របស់ផ្នែកគាំទ្របច្ចេកទេស ។

## ផ្នែកទី ២ ៖ ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ នៅឃុំសែនដី

### ១. ផែនការកិច្ចលទ្ធកម្មសាធារណៈប្រចាំឆ្នាំ

នៅក្នុងឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ចំពោះលទ្ធកម្មសំណង់ គឺបានអនុវត្តវិធីសាស្ត្រដេញថ្លៃដោយប្រកួតប្រជែងជាសាធារណៈជាប្រចាំឆ្នាំ។

ចំណែកឯលទ្ធកម្មសេវាកម្ម និងទំនិញ គឺឃុំ សង្កាត់ មិនបានអនុវត្តវិធីសាស្ត្រដេញថ្លៃដោយប្រកួតប្រជែងជាសាធារណៈឡើយ ត្បិតថាការចំណាយស្ថិតក្រោម ២លានរៀល។

#### ១.១ គម្រោងផែនការកិច្ចលទ្ធកម្មប្រចាំឆ្នាំ ២០២១

ផែនការលទ្ធកម្មនៅឃុំសែនដី ក្នុងឆ្នាំ២០២១ ដោយបានគ្រោង និងដាក់ចេញនូវគម្រោងសាងសង់ផ្លូវបេតុងអាមេ ចំនួន០១គម្រោង ស្ថិតក្នុងភូមិស្រែគោក ដោយប្រើវិធីសាស្ត្រដេញថ្លៃដោយប្រកួតប្រជែងជាចំហ។

ក្រោមការសិក្សាផ្ទាល់ និងគណនាលម្អិតលើតម្លៃ របស់មន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធបានបង្ហាញលទ្ធផលសរុប គឺផ្លូវប្រវែង ០.៣១៥គីឡូម៉ែត្រ ទទឹង ៦ម៉ែត្រ និងកម្រាស់ ០.១៥ ម៉ែត្រ និងស្លាកសញ្ញាគម្រោង ០១កន្លែង ក្នុងតម្លៃប៉ាន់ស្មាន ២១៧,៨៤៤,៨០០ រៀល។

**តារាងទី៤.លទ្ធផល និងតម្លៃប៉ាន់ស្មានគម្រោងហេដ្ឋារចនាសម្ព័ន្ធ ២០២១**

| ខេត្ត៖កំពង់ស្ពឺ | | | ស្រុក៖សំរោងទង | | | រដ្ឋបាលឃុំ៖ ឃុំសែនដី | | | | លេខកូដឃុំ៖០៥០៧០៩ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ឈ្មោះគម្រោង៖ សាងសង់ផ្លូវបេតុងអាមេ | | | | | | | | | | | | | |
| ល.រ | ឈ្មោះភូមិ | លេខកូដលទ្ធផល | ឈ្មោះលទ្ធផល | ថ្មី ឬជួសជុល | តាមប្លង់ គ.ជ.អ.ប (បាទឬទេ) | ស្តង់ដារ ទំហំ១ | | ស្តង់ដារ ទំហំ២ | | តម្លៃប៉ាន់ស្មាន(រៀល) | | | |
| | | | | | | ប្រភេទ | ទំហំ | ប្រភេទ | ទំហំ | ឯកតា | បរិមាណ | តម្លៃឯកតា | សរុប |
| ១ | ស្រែគោក | ១០១០២០៣A | សាងសង់ផ្លូវបេតុងអាមេ | ថ្មី | បាទ | ទទឹង | ៦ម | កម្រាស់ | ១៥០ មម | គ.ម | ០.៣១៥ | ៦៩១,៥៧០,៧៩៣ | ២១៧,៨៤៤,៨០០ |
| **តម្លៃប៉ាន់ស្មានគម្រោងសរុប** | | | | | | | | | | **២១៧,៨៤៤,៨០០** | | | |

#### ១.២ គម្រោងផែនការកិច្ចលទ្ធកម្មប្រចាំឆ្នាំ ២០២២

នៅក្នុងឆ្នាំ២០២២ ឃុំសែនដី បានរៀបចំផែនការលទ្ធកម្មដោយបានគ្រោង និងដាក់ចេញនូវគម្រោងសាងសង់ផ្លូវបេតុងអាមេចំនួន០១គម្រោង ស្ថិតក្នុងភូមិស្រែគោកដោយប្រើវិធីសាស្ត្រដេញថ្លៃដោយប្រកួតប្រជែងជាចំហ។

ក្រោមការសិក្សាផ្ទាល់ និងគណនាលម្អិតលើតម្លៃ របស់មន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធបានបង្ហាញលទ្ធផលសរុប គឺផ្លូវប្រវែង ០.២៣ គីឡូម៉ែត្រ ទទឹង ៦ម៉ែត្រ និងកម្រាស់ ០.១៥ ម៉ែត្រ និងស្លាកសញ្ញាគម្រោង០១កន្លែង ក្នុងតម្លៃប៉ាន់ស្មាន ១៦៧,៧៤៩,២០០ រៀល។

**តារាងទី៥.លទ្ធផល និងតម្លៃប៉ាន់ស្មានគម្រោងហេដ្ឋារចនាសម្ព័ន្ធ ២០២២**

| **ខេត្តៈ**កំពង់ស្ពឺ | | | **ស្រុកៈ**សំរោងទង | | | | **រដ្ឋបាលឃុំៈ** ឃុំសែនដី | | | **លេខកូដឃុំៈ**០៥០៧០៩ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **ឈ្មោះគម្រោង៖** សាងសង់ផ្លូវបេតុងអាមេ | | | | | | | | | | | | | |
| ល.រ | ឈ្មោះភូមិ | លេខកូដលទ្ធផល | ឈ្មោះលទ្ធផល | ថ្មី ឬ ជួសជុល | តាមប្លង់ គ.ជ.អ.ប (បាទឬទេ) | ស្តង់ដារ ទំហំ១ | | ស្តង់ដារ ទំហំ២ | | តម្លៃប៉ាន់ស្មាន(រៀល) | | | |
| | | | | | | ប្រភេទ | ទំហំ | ប្រភេទ | ទំហំ | ឯកតា | បរិមាណ | តម្លៃឯកតា | សរុប |
| ១ | ស្រែត្រោក | ១០១០ ២០៣A | សាងសង់ផ្លូវបេតុងអាមេ | ថ្មី | បាទ | ទទឹង | ៦ម | កម្រាស់ | ១៥០ មម | គ.ម | ០.២៣ | ៧៣៨,០៤០,០០០ | ១៦៧,៧៤៩,២០០ |
| **តម្លៃប៉ាន់ស្មានគម្រោងសរុប** | | | | | | | | | | **១៦៧,៧៤៩,២០០** | | | |

## ១.៣ គម្រោងផែនការកិច្ចលទ្ធកម្មប្រចាំឆ្នាំ ២០២៣

ផែនការលទ្ធកម្មឃុំសែនដី ក្នុងឆ្នាំ២០២៣ ដោយបានគ្រោង និងដាក់ចេញនូវគម្រោងសាងសង់ផ្លូវបេតុងអាមេ ចំនួន ០១ គម្រោង ស្ថិតក្នុងភូមិព្រៃរំដួល ដោយប្រើវិធីសាស្ត្រដេញថ្លៃដោយប្រកួតប្រជែងជាចំហ។

ក្រោមការសិក្សាផ្ទាល់ និងគណនាលម្អិតលើតម្លៃ របស់មន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធបានបង្ហាញលទ្ធផលសរុប គឺ ផ្លូវ ប្រវែង០.៣៨២ គីឡូម៉ែត្រ ទទឹង៦ម៉ែត្រ និងកម្រាស់០.១៥ ម៉ែត្រ និងស្លាកសញ្ញាគម្រោង០១កន្លែង ក្នុងតម្លៃប៉ាន់ស្មាន ២៩៦,៦១១,៩០០ រៀល។

**តារាងទី៦.លទ្ធផល និងតម្លៃប៉ាន់ស្មានគម្រោងហេដ្ឋារចនាសម្ព័ន្ធ ២០២៣**

| **ខេត្តៈ**កំពង់ស្ពឺ | | | **ស្រុកៈ**សំរោងទង | | | | **រដ្ឋបាលឃុំៈ** ឃុំសែនដី | | | **លេខកូដឃុំៈ**០៥០៧០៩ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **ឈ្មោះគម្រោង៖** សាងសង់ផ្លូវបេតុងអាមេ | | | | | | | | | | | | | |
| ល.រ | ឈ្មោះភូមិ | លេខកូដលទ្ធផល | ឈ្មោះលទ្ធផល | ថ្មី ឬ ជួសជុល | តាមប្លង់ គ.ជ.អ.ប (បាទឬទេ) | ស្តង់ដារ ទំហំ១ | | ស្តង់ដារ ទំហំ២ | | តម្លៃប៉ាន់ស្មាន(រៀល) | | | |
| | | | | | | ប្រភេទ | ទំហំ | ប្រភេទ | ទំហំ | ឯកតា | បរិមាណ | តម្លៃឯកតា | សរុប |
| ១ | ព្រៃរំដួល | ១០១០ ២០៣A | សាងសង់ផ្លូវបេតុងអាមេ | ថ្មី | បាទ | ទទឹង | ៦ម | កម្រាស់ | ១៥០ មម | គ.ម | ០.៣៨២ | ៧៧៦,៤៧០,៨៧៦ | ២៩៦,៦១១,៩០០ |
| **តម្លៃប៉ាន់ស្មានគម្រោងសរុប** | | | | | | | | | | **២៩៦,៦១១,៩០០** | | | |

# ២. ការអនុវត្ត និង លទ្ធផល នៃការអនុវត្តកិច្ចលទ្ធកម្ម

## ២.១ ការអនុវត្តផែនការគម្រោងនៃកិច្ចលទ្ធកម្ម

គម្រោងផែនការលទ្ធកម្មដែលបានរៀបចំ និងបន្ទាប់ពីបានធ្វើការសិក្សាគម្រោងដោយអ្នកជំនាញបច្ចេកទេសរួចរាល់ហើយ ក្រុមប្រឹក្សាឃុំ សង្កាត់ដែលមានគណៈកម្មការលទ្ធកម្មឃុំ សង្កាត់ត្រូវធ្វើការសម្របសម្រួលជាមួយទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្តក្នុងការប្រកាសកិច្ចលទ្ធកម្មរបស់ឃុំ សង្កាត់ ដោយមានការផ្សព្វផ្សាយក្នុងវេបសាយ គ.ជ.អ.ប ផងដែរ។

កិច្ចលទ្ធកម្មគម្រោងឃុំ សង្កាត់អាចប្រព្រឹត្តិទៅបានលុះត្រាតែមានអ្នកទទួលការយ៉ាងតិចចំនួន ៣ក្រុមហ៊ុនបានដាក់សំណើដេញថ្លៃ។ សំណើដេញថ្លៃដែលមានតម្លៃទាបជាងគេហើយមានសុពលភាព គឺជាសំណើដេញថ្លៃដែលទទួលជ័យជំនះ។ អ្នកទទួលការដែលឈ្នះការដេញថ្លៃ មានសិទ្ធិទទួលកិច្ចសន្យា ឬ បដិសេធ ហើយក្រុមប្រឹក្សាឃុំ សង្កាត់ ធ្វើការពិចារណាអ្នកឈ្នះបន្ទាប់ដើម្បីចុះកិច្ចសន្យាអនុវត្តន៍គម្រោង។

គណៈកម្មការលទ្ធកម្ម បានធ្វើសកម្មភាពលទ្ធកម្មនៅក្នុងឃុំសែនដី ស្រុកសំរោងទង ចន្លោះពីឆ្នាំ ២០១៩ ដល់ ២០២៣ បានសម្រេចយ៉ាងជោគជ័យទៅតាមផែនការដែលបានគ្រោងទុក ដោយឆ្លើយតបបានទៅតាមគោលការណ៍សន្សំសំចៃ តម្លាភាព និងប្រកបដោយស្តង់ដារគុណភាពខ្ពស់។

## ២.២ លទ្ធផលនៃការអនុវត្តកិច្ចលទ្ធកម្មក្នុង ឃុំសែនដី

ការអនុវត្តកិច្ចលទ្ធកម្មរបស់ឃុំសែនដី ទទួលបានវឌ្ឍនភាពនៃភាពសម្រេចតាមផែនការលទ្ធកម្មប្រចាំឆ្នាំ និងសម្រេចបានលទ្ធផលដូចខាងក្រោម៖

### ២.២.១ ផលចំណេញផ្នែកហិរញ្ញវត្ថុ

- ការអនុវត្តលទ្ធកម្មក្នុងឆ្នាំ ២០២១

កញ្ចប់លទ្ធកម្មសាងសង់ផ្លូវបេតុងអាមេចំនួន១គម្រោង ស្ថិតក្នុងភូមិស្រែតោក ប្រវែង០.៣១៥ គីឡូម៉ែត្រ ទទឹង៦ម៉ែត្រ និងកម្រាស់០.១៥ម៉ែត្រ និងស្លាកសញ្ញាគម្រោង០១កន្លែង ដែលមានតម្លៃគម្រោងប៉ាន់ស្មាន ចំនួន២១៧,៨៤៤,៨០០ រៀល មានក្រុមហ៊ុនចូលរួមដេញថ្លៃចំនួន ០៦ក្រុមហ៊ុន។ ក្នុងនោះ **ក្រុមហ៊ុន ជា គឹមសាន ខនស្រ្តាក់សិន & អេនជីនារីង** បានដាក់សំណើដេញថ្លៃតម្លៃទាបលំដាប់ទីមួយ និងបានសាងសង់ផ្លូវបេតុងអាមេដែលមានតម្លៃកិច្ចសន្យាសំណង់ ១០៨,០០០,០០០ រៀល ។

បើធៀប និងការសិក្សាគម្រោងរបស់មន្ត្រីបច្ចេកទេសខេត្តការអនុវត្តលទ្ធកម្មសំណង់នេះបានជួយសន្សំសំចៃថវិការដ្ឋបានចំនួន **១០៩,៨៤៤,៨០០** រៀល។

**តារាងទី៧.តារាងលទ្ធផលនៃការអនុវត្តកិច្ចលទ្ធកម្មឆ្នាំ២០២១**

| **ខេត្តៈ**កំពង់ស្ពឺ | **ស្រុកៈ**សំរោងទង | **រដ្ឋបាលឃុំៈ**សែនដី | **លេខកូដឃុំៈ**០៥០៧០៩ |
|---|---|---|---|
| **ពិពណ៌នាគម្រោងៈ** ការសាងសង់ផ្លូវបេតុងអាមេ ប្រវែង០.៣១៥ គីឡូម៉ែត្រ ទទឹង៦ម៉ែត្រ កម្រាស់០.១៥ម៉ែត្រ និងស្លាកសញ្ញាគម្រោង០១កន្លែង | | | |
| អ្នកទទួលខុសត្រូវក្នុងការប្រតិបត្តិការ និងការថែទាំលទ្ធផលគម្រោងៈ ក្រុមប្រឹក្សាឃុំ | | | |
| តម្លៃប៉ាន់ស្មានគម្រោង(រៀល) | | តម្លៃកិច្ចសន្យាសំណង់(រៀល) | |
| ២១៧,៨៤៤,៨០០ | | ១០៨,០០០,០០០ | |
| **ផលចំណេញហិរញ្ញវត្ថុ** | | **១០៩,៨៤៤,៨០០** | |

➢ ការអនុវត្តលទ្ធកម្មក្នុងឆ្នាំ ២០២២

គម្រោងសាងសង់ផ្លូវបេតុងអាមេ ចំនួន ១គម្រោង ស្ថិតក្នុងភូមិស្រែតោក ប្រវែង ០.២៣ គីឡូម៉ែត្រ ទទឹង ៦ម៉ែត្រ និងកម្រាស់០.១៥ ម៉ែត្រ និងស្លាកសញ្ញាគម្រោង០១កន្លែង ក្នុងតម្លៃប៉ាន់ស្មាន ១៦៧,៧៤៩,២០០ រៀល និងមានក្រុមហ៊ុនចូលរួមដេញថ្លៃចំនួន ០៣ក្រុមហ៊ុន។ ក្នុងនោះ **ក្រុមហ៊ុន ផល លីហ៉ង** បានដាក់សំណើដេញថ្លៃតម្លៃទាបលំដាប់ទីមួយ និងបានសាងសង់ផ្លូវបេតុងអាមេដែលមានតម្លៃកិច្ចសន្យាសំណង់ ១០៥,៣៤០,០០០ រៀល ។

បើធៀបទៅនិង គម្រោងផែនការរបស់គណៈកម្មការឃុំសង្កាត់ ការអនុវត្តលទ្ធកម្មនេះសំណង់នេះ បានជួយសន្សំសំចៃ ថវិការដ្ឋបានចំនួន **៦២,៤០៩,២០០** រៀល។

**តារាងទី៨.តារាងលទ្ធផលនៃការអនុវត្តកិច្ចលទ្ធកម្មឆ្នាំ២០២២**

| **ខេត្តៈ**កំពង់ស្ពឺ | **ស្រុកៈ**សំរោងទង | **រដ្ឋបាលឃុំៈ**សែនដី | **លេខកូដឃុំៈ**០៥០៧០៩ |
|---|---|---|---|
| **ពិពណ៌នាគម្រោងៈ** ការសាងសង់ផ្លូវបេតុងអាមេ ប្រវែង ០.២៣ គីឡូម៉ែត្រ ទទឹង ៦ម៉ែត្រ កម្រាស់ ០.១៥ ម៉ែត្រ និងស្លាកសញ្ញាគម្រោង ០១កន្លែង | | | |
| អ្នកទទួលខុសត្រូវក្នុងការប្រតិបត្តិការ និងការថែទាំលទ្ធផលគម្រោងៈ ក្រុមប្រឹក្សាឃុំ | | | |
| តម្លៃប៉ាន់ស្មានគម្រោង(រៀល) | | តម្លៃកិច្ចសន្យាសំណង់(រៀល) | |
| ១៦៧,៧៤៩,២០០ | | ១០៥,៣៤០,០០០ | |
| **ផលចំណេញហិរញ្ញវត្ថុ** | | **៦២,៤០៩,២០០** | |

➢ ការអនុវត្តលទ្ធកម្មក្នុងឆ្នាំ ២០២៣

គម្រោងសាងសង់ផ្លូវបេតុងអាមេ ចំនួន១គម្រោង ស្ថិតក្នុងភូមិព្រៃរំដួល ប្រវែង០.៣៨២ គីឡូម៉ែត្រ ទទឹង ៦ម៉ែត្រ និងកម្រាស់ ០.១៥ ម៉ែត្រ និងស្លាកសញ្ញាគម្រោង ០១កន្លែង ក្នុងតម្លៃប៉ាន់ស្មាន ២៩៦,៦១១,៩០០ រៀល

មានក្រុមហ៊ុនចូលរួមដេញថ្លៃចំនួន ១០ក្រុមហ៊ុន។ ក្នុងនោះ **ក្រុមហ៊ុន វិបុលរតនៈ** បានដាក់សំណើដេញថ្លៃតម្លៃទាបលំដាប់ទីមួយ និងបានសាងសង់ផ្លូវបេតុងអាមេដែលមានតម្លៃកិច្ចសន្យាសំណង់១២៤,៩១៤,000 រៀល ។

បើធៀប និងការសិក្សាគម្រោងរបស់មន្ត្រីបច្ចេកទេសខេត្ត ការអនុវត្តលទ្ធកម្មសំណង់នេះបានជួយសន្សំសំចៃថវិការដ្ឋ បានចំនួន **១៧១,៦៩៧,៩០០** រៀល។

**តារាងទី៩.តារាងលទ្ធផលនៃការអនុវត្តកិច្ចលទ្ធកម្មឆ្នាំ២០២៣**

| **ខេត្តៈ**កំពង់ស្ពឺ | **ស្រុកៈ**សំរោងទង | **រដ្ឋបាលឃុំៈ**សែនដី | **លេខកូដឃុំៈ**០៥០៧០៩ |
|---|---|---|---|
| **ពិពណ៌នាគម្រោងៈ** ការសាងសង់ផ្លូវបេតុងអាមេ ប្រវែង០.៣៨២ គីឡូម៉ែត្រ ទទឹង ៦ម៉ែត្រ កម្រាស់ ០.១៥ ម៉ែត្រនិងស្លាកសញ្ញគម្រោង ០១កន្លែង | | | |
| អ្នកទទួលខុសត្រូវក្នុងការប្រតិបត្តិការ និងការថែទាំលទ្ធផលគម្រោងៈ ក្រុមប្រឹក្សាឃុំ | | | |
| តម្លៃប៉ាន់ស្មានគម្រោង(រៀល) | | តម្លៃកិច្ចសន្យាសំណង់(រៀល) | |
| ២៩៦,៦១១,៩០០ | | ១២៤,៩១៤,000 | |
| **ផលចំណេញហិរញ្ញវត្ថុ** | | **១៧១,៦៩៧,៩០០** | |

## ២.២.២ សមិទ្ធិផលផ្នែកគុណភាព

ការអនុវត្តកិច្ចលទ្ធកម្មរបស់ឃុំសែនដី ទាំង៣លើកបានប្រព្រឹត្តទៅដោយរលូន ហើយក្រុមហ៊ុនដែលទទួលបានការប្រគល់កិច្ចសន្យាពីសំណាក់គណៈកម្មការលទ្ធកម្ម គឺបានអនុវត្តទៅតាមលក្ខខណ្ឌនៃកិច្ចសន្យា និងឆ្លើយតបតាមតម្រូវការ និងស្តង់ដាគុណភាពដែលបានកំណត់ទុក ដែលធានាដល់ភាពយូរអង្វែងនៃការប្រើប្រាស់ ។ ក្រៅពីនេះ ក្នុងឃុំ សង្កាត់ក៏មាន មន្ត្រីត្រួតពិនិត្យបច្ចេកទេស ដើម្បីតាមដានការរីកចម្រើននៃការអនុវត្តកិច្ចសន្យារបស់ក្រុមហ៊ុន ផងដែរ។

# ៣. របាយការណ៍រីកចម្រើននៃការអនុវត្តកិច្ចសន្យាសំណង់

របាយការណ៍ចម្រើននៃការអនុវត្តកិច្ចសន្យាសំណង់ ត្រូវបានធ្វើឡើងដោយអ្នកត្រួតពិនិត្យបច្ចេកទេសខេត្ត ចំនួនពីរដង និងរបាយការណ៍បញ្ចប់នៃការអនុវត្តកិច្ចសន្យាសំណង់ ចំនួនម្តង។ អត្ថន័យ និងព័ត៌មានក្នុងរបាយការណ៍នៃ ដំណាក់កាលនីមួយៗ អាស្រ័យទៅលើការអនុវត្តតាមជំហាននៃអង្គភាពអនុវត្តន៍កិច្ចលទ្ធកម្ម។

## ៣.១ របាយការណ៍រីកចម្រើន ដំណាក់កាលទី ១ និងទី ២

ក្នុងរបាយការណ៍នៃការអនុវត្តកិច្ចសន្យាបានពិពណ៌នាអំពី ៖

- ការរីកចម្រើននៃការអនុវត្តការងារ
- ចំនួនឬអត្រាភាគរយនៃការអនុវត្តការងារដែលបានបញ្ចប់

- គុណភាពរបស់សម្ភារដែលបានប្រើប្រាស់នៅក្នុងការសាងសង់
- គុណភាពការងារដែលបានកំណត់នៅក្នុងកិច្ចសន្យា
- សំណង់ត្រូវបានសាងសង់ទៅតាមគំនូសប្លង់បច្ចេកទេស និងយោបល់ផ្សេងៗរបស់អ្នកត្រួតពិនិត្យបច្ចេកទេស។

### ៣.២ របាយការណ៍បញ្ចប់ នៃការអនុវត្តកិច្ចសន្យាសំណង់

របាយការណ៍បញ្ចប់នៃការអនុវត្តកិច្ចសន្យាសំណងបានពិពណ៌នាអំពី ៖

- ស្ថានភាពនៃលទ្ធផលកិច្ចសន្យា
- ការងារដែលអ្នកទទួលការត្រូវបំពេញមុននឹងទទួលបានដោយការទូទាត់ចុងក្រោយនិងយោបល់ផ្សេងៗពីអ្នកត្រួតពិនិត្យបច្ចេកទេស។

### ៣.៣ អាណត្តិបើកប្រាក់

អាណត្តិបើកប្រាក់របស់អ្នកទទួលការ ចែកចេញជា ៣គឺ ៖

- អាណត្តិបើកប្រាក់ លើកទី ១ បន្ទាប់ពី អនុវត្តការងារបាន ៥០%
- អាណត្តិបើកប្រាក់ លើកទី ២ បន្ទាប់ពី អនុវត្តការងារបាន ១០០%
- និងចុងក្រោយ បន្ទាប់ពីធានាសុពលភាពលទ្ធផលកិច្ចសន្យានៅក្នុងកំឡុងពេលថែទាំ ៦ខែ។

ក្នុងការទូទាត់ឱ្យអ្នកទទួលការ គឺផ្អែកតាមលក្ខខណ្ឌនៃកិច្ចសន្យា ប៉ុន្តែនៅពេលដែលមានការស្នើសុំទូទាត់ពីអ្នកទទួលការមួយលើកៗ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការពិនិត្យផ្ទៀងផ្ទាត់លទ្ធផលនៃការអនុវត្តជាក់ស្តែង ដោយត្រូវអញ្ជើញអ្នកពិនិត្យបច្ចេកទេសមកចូលរួមប្រជុំវាយតម្លៃនៅទីតាំង គម្រោងដោយផ្ទាល់តែម្តង។

ចំពោះគម្រោងហេដ្ឋារចនាសម្ព័ន្ធ ត្រូវមានការធានារយៈពេល ៦ខែ ដែលក្នុងពេលធានានេះ រដ្ឋបាលឃុំសង្កាត់ត្រូវកាត់ទុកថវិកាដែលមានក្នុងកិច្ចសន្យា ១០% នៃតម្លៃគម្រោង។ ក្នុងអំឡុងពេលនៃការធានា ប្រសិនបើពិនិត្យឃើញថាមានការខូចខាត ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវហៅអ្នកទទួលការមកធ្វើការជួសជុលឱ្យបានពេញលេញវិញ។ ក្រោយពេលការអនុវត្តគម្រោងបានចប់សព្វគ្រប់ត្រូវ មានការប្រគល់ទទួលលទ្ធផលគម្រោង។

## ៤. បណ្តឹងតវ៉ា និងការអនុវត្តកិច្ចលទ្ធកម្ម

តាមប្រសាសន៍របស់លោកមេឃុំ ដែលជាប្រធានគណៈកម្មការលទ្ធកម្ម បានលើកឡើងថា ការអនុវត្តផែនការនៃកិច្ចលទ្ធកម្មសាធារណៈរបស់ ឃុំសែនដី បានសម្រេចបាននូវលទ្ធផលជាទីគាប់ប្រសើរក្នុងចន្លោះឆ្នាំ ២០២១ដល់២០២៣។

ហើយការអនុវត្តលទ្ធកម្មសំណង់នេះទៀតសោតពុំមានពាក្យបណ្តឹងតវ៉ាណាមួយពីសំណាក់ភាគីដែលមានការពាក់ព័ន្ធក្នុងកិច្ចអនុវត្តលទ្ធកម្មនោះឡើយ។

ចំពោះសមិទ្ធផលដែលបានមកពីការអនុវត្តកិច្ចលទ្ធកម្មទាំងនោះទៀតសោត ត្រូវបានទទួលស្គាល់ដោយប្រជាពលរដ្ឋនៅក្នុងតំបន់ និងទទួលបានទំនុកចិត្តចំពោះសកម្មភាព នៃការប្រើប្រាស់ថវិកាជាតិរបស់រដ្ឋបាលឃុំសែនដី ផងដែរ។

## ៥. ចំណុចខ្លាំង ចំណុចខ្សោយ និងកាលានុវត្តភាព នៃកិច្ចលទ្ធកម្ម

ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈនៅក្នុងរដ្ឋបាលឃុំសែនដី ត្រូវបានបានយកចិត្តទុកដាក់តាំងពី ដំណាក់កាលនៃការកសាងផែនការ ការសិក្សាគម្រោង ការអនុវត្តផែនការលទ្ធកម្ម ការតាមដាន និងត្រួតពិនិត្យ លើការអនុវត្តលទ្ធកម្ម ដើម្បីធានាឱ្យបានថា ដំណើរការអនុវត្តកិច្ចលទ្ធកម្ម ប្រកបដោយប្រសិទ្ធភាព តម្លាភាព សមភាព គណនេយ្យភាព និងការសន្សំសំចៃ។ យ៉ាងណាក៏ដោយ យើងសង្កេតឃើញមាន ទាំងចំណុចខ្លាំង និងចំណុចខ្សោយ បានកើតឡើងទាក់ទងនិងកិច្ចលទ្ធកម្មសាធារណៈ។

### ៥.១ ចំណុចខ្លាំង

- រដ្ឋាភិបាលបានចេញ ប្រកាសណែនាំស្ដីពី ការងារលទ្ធកម្មរបស់ឃុំ សង្កាត់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងការអនុវត្តនកិច្ចលទ្ធកម្មសាធារណៈ និងមានចែងអំពីនីតិវិធីនិង វិធីសាស្ត្រលទ្ធកម្ម ដើម្បីឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិអាចអនុវត្តន៍តាមបាន
- មានរចនាសម្ព័ន្ធច្បាស់លាស់សម្រាប់គ្រប់គ្រង និង អនុវត្តន៍កិច្ចលទ្ធកម្មសាធារណៈ
- មានការបណ្ដុះបណ្ដាលនិងវិក្រឹត្យការជំនាញលទ្ធកម្មសាធារណៈដល់មន្ត្រីលទ្ធកម្ម ជារៀងរាល់ឆ្នាំ
- ឯកសារនិងព័ត៌មានលទ្ធកម្មត្រូវបានផ្សព្វផ្សាយក្នុង គេហទំព័ររបស់អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- ការរៀបចំគម្រោងថវិកាដើម្បីអភិវឌ្ឍន៍ឃុំ សង្កាត់ បានយកអាទិភាព និងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងតំបន់ជាចម្បង
- ការចំណាយថវិកាឃុំ សង្កាត់ ត្រូវបានចំណាយចំគោលដៅ និងមានប្រសិទ្ធិភាព និងសន្សំសំចៃ
- ការផ្សព្វផ្សាយអំពីគម្រោងដេញថ្លៃ មានភាពទូលំទូលាយ និងបើកឱកាសឱ្យអ្នកដេញថ្លៃក្នុងស្រុក អាចចូលរួមបាន
- សមិទ្ធផលដែលបានមកពីការអនុវត្តកិច្ចលទ្ធកម្មសារធារណៈ មានលក្ខណៈតាមស្តង់ដារបច្ចេកទេស និងមានការតាមដាន និងត្រួតពិនិត្យដោយមន្ត្រីបច្ចេកទេស ថ្នាក់ខេត្ត។
- ការអនុវត្តកិច្ចលទ្ធកម្ម ប្រព្រឹត្តទៅដោយរលូន និងមិនមានបណ្ដឹងតវ៉ាពីសំណាក់ភាគីដែលពាក់ព័ន្ធនិងការធ្វើសវនកម្មកិច្ចលទ្ធកម្មត្រូវបានអនុវត្តជាទៀងទាត់។

### ៥.២ ចំណុចខ្សោយ

- ការដាក់ទោសទណ្ឌដល់ស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្ម ដែលបំពាននីតិវិធីសាស្ត្រ និងនីតិវិធីលទ្ធកម្មមិនទាន់ចាត់វិធានការដាក់ស្តែងប្រកបដោយប្រសិទ្ធភាព
- ការផ្លាស់ប្តូរមន្ត្រីទទួលបន្ទុកលទ្ធកម្មញឹកញាប់នៅ តាមស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្ម
- អភិបាលកិច្ចល្អនៅក្នុងប្រព័ន្ធលទ្ធកម្មសាធារណៈមិនទាន់ត្រូវបានពង្រឹងបន្ថែម
- មូលនិធិអភិវឌ្ឍន៍ឃុំ នៅមានលក្ខណៈតិចតួចនៅឡើយ
- មិនទាន់មានជំនឿទុកចិត្តពេញលេញពីសាធារណជន លើប្រព័ន្ធលទ្ធកម្មសាធារណៈ
- អ្នកចូលរួមក្នុងការដេញថ្លៃប្រកួតប្រជែងនៅមានកម្រិត
- ភាពប្រកួតប្រជែងនៅក្នុងការដេញថ្លៃលើគម្រោងលទ្ធកម្មនៅមានកម្រិតនៅឡើយ
- ការជ្រៀតជ្រែក ឬឥទ្ធិពលណាមួយនៅតែកើតមានក្នុងកិច្ចអនុវត្តលទ្ធកម្ម
- ការយល់ដឹងពីសំណាក់អ្នកចូលរួមដេញថ្លៃទាក់ទងនិងកិច្ចលទ្ធកម្មនៅមានកម្រិត។

## ៦.កាលានុវត្តភាព

- រាជរដ្ឋាភិបាលមានឆន្ទៈនយោបាយខ្ពស់ក្នុងការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ
- ច្បាប់ស្តីពីលទ្ធកម្មសាធារណៈដែលកំពុងអនុវត្តអាចយកជាមូលដ្ឋានសម្រាប់ធ្វើវិសោធនកម្ម
- មន្ត្រីលទ្ធកម្មមានឆន្ទៈខ្ពស់ក្នុងការចូលរួមវគ្គបណ្តុះបណ្តាល និងវិក្រឹត្យការជំនាញលទ្ធកម្មសាធារណៈ
- មន្ត្រីអនុវត្តលទ្ធកម្មសាធារណៈចាប់ផ្តើមយល់ច្បាស់ពីនីតិវិធីក៏ដោយជាតួនាទីភារកិច្ចរបស់ខ្លួន ដែល និងធ្វើឱ្យភាពប្រសើរឡើងនៃផលិតភាពការងារកើនឡើង
- ដៃគូអភិវឌ្ឍន៍មួយចំនួនបានផ្តល់ និងមានបំណងផ្តល់ជំនួយបច្ចេកទេសសម្រាប់កែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈនិងអភិវឌ្ឍន៍សមត្ថភាពមន្ត្រីលទ្ធកម្ម
- នៅពេលរដ្ឋាភិបាលផ្ទេរសិទ្ធិសម្រេច និងការទទួលខុសត្រូវទៅឱ្យ ស្ថាប័នអនុវត្តកិច្ចលទ្ធកម្មជាអ្នក មានសិទ្ធិសម្រេចលើផែនការលទ្ធកម្ម នោះវាបានពន្លឿនដំណើរការកសាងផែនការនិងការអនុវត្ត។

## ៧. បញ្ហាប្រឈម និងដំណោះស្រាយ

### ៧.១ បញ្ហាប្រឈម

ទោះបីជា ដំណើរការនៃការអនុវត្តកិច្ចលទ្ធកម្មសាធារណៈនៅឃុំសែនដីបានធ្វើឡើង ប្រកបដោយតម្លាភាព ប្រសិទ្ធភាព ស្របទៅតាមផែនការលទ្ធកម្មប្រចាំឆ្នាំ និងបានជួយសន្សំសំចៃនូវ ថវិកាជាតិជាច្រើនក៏ដោយ ក៏ដំណើរការនៃការអនុវត្តនេះនៅតែជួបប្រទះនូវបញ្ហាប្រឈមមួយចំនួន ដែលមានដូចជា៖

- កង្វះខាតមន្ត្រីជំនាញសម្រាប់បម្រើការងារដោយសារតែ នៅក្នុងគណៈកម្មការលទ្ធកម្ម ឃុំសង្កាត់ មិនទាន់មានមន្ត្រីត្រួតពិនិត្យបច្ចេកទេស ដែលអាចត្រួតពិនិត្យ គុណភាពបានដោយខ្លួនឯងនៅឡើយ
- ភាពខ្វះចន្លោះ នៅក្នុងការបំពេញការងាររបស់មន្ត្រីអនុវត្តលទ្ធកម្មសាធារណៈពាក់ព័ន្ធទៅ នឹងបែបបទ និងនីតិវិធីសម្រាប់អនុវត្តន៍
- បញ្ហាលើការសិក្សា និងការវិភាគអំពីតម្លៃទីផ្សារ។ ការសិក្សា និងការវិភាគលើតម្លៃទីផ្សារនៅតែជួបប្រទះនូវបញ្ហាប្រឈម ដោយសារតែ ការប៉ាន់ស្មានតម្លៃគម្រោងនៅមិនទាន់មានភាពសមស្របទៅតាមតម្លៃទីផ្សារនៅឡើយ ដូចជា ការប៉ានស្មានលើតម្លៃគម្រោងមានតម្លៃថ្លៃជាងសេដ្ឋកិច្ចទីផ្សារ ដែលជាហេតុធ្វើឱ្យមានការខាតបង់នូវថវិកាជាតិ ការប៉ានស្មានលើតម្លៃគម្រោងមានតម្លៃទាបជាងសេដ្ឋកិច្ចទីផ្សារខ្លាំងពេក ដែលធ្វើឱ្យលទ្ធផលដែលទទួលបានបាត់បង់នូវគុណភាព ប្រសិទ្ធភាពជាដើម។
- បញ្ហាពាក់ព័ន្ធនឹងការយល់ដឹងរបស់ភាគីឯកជនអំពីបែបបទ នីតិវិធី និងលក្ខខណ្ឌផ្សេង ទៀតនៃកិច្ចលទ្ធកម្មសាធារណៈនៅមានកម្រិត ដែលបង្កឱ្យមានការរាំងស្ទះដល់ដំណើរការ នៃការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ។

### ៧.២ ដំណោះស្រាយ

ការអនុវត្តកិច្ចលទ្ធកម្មប្រកបដោយ ប្រសិទ្ធភាព តម្លាភាព និងសន្សំសំចៃ គឺជាកត្តាមួយដ៏សំខាន់ក្នុងការចូលរួមចំណែកអភិវឌ្ឍន៍ប្រទេសជាតិឱ្យមានការរីចម្រើន។ ដូច្នេះរាល់បញ្ហាប្រឈមដែលពាក់ព័ន្ធការអនុវត្តលទ្ធកម្មសាសាធារណៈខាងលើ គឺអាចត្រូវបានដោះស្រាយតាមរយៈមធ្យោបាយមួយចំនួនដូចជា៖

- ទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្តបាន បញ្ជូនអ្នកជំនាញបច្ចេកទេស ដើម្បីជួយដល់គណៈកម្មការលទ្ធកម្មឃុំ សង្កាត់ក្នុងការរៀបចំផែនការ និងជួយត្រួតពិនិត្យលក្ខណៈបច្ចេកទេសផ្សេងៗ
- រាជរដ្ឋាភិបាលតាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានបង្កើនការយកចិត្តទុកដាក់ខ្ពស់ដល់ការអភិវឌ្ឍធនធានមនុស្សពាក់ព័ន្ធនឹងផ្នែកលទ្ធកម្មសាធារណៈ ដោយត្រូវធ្វើការណែនាំក៏ដូចជាបង្កើតឱ្យមានវគ្គអប់រំបណ្តុះបណ្តាលបន្ត ដើម្បីឱ្យពួកគាត់មានសមត្ថភាពពេញលេញក្នុងការអនុវត្ត នូវកិច្ចលទ្ធកម្មសាធារណៈប្រកបដោយប្រសិទ្ធភាព។
- មន្ត្រីដែលទទួលបន្ទុកផ្នែកលទ្ធកម្មសាធារណៈ ត្រូវបង្កើនការត្រួតពិនិត្យឱ្យបានច្បាស់លាស់ លើលក្ខណៈបច្ចេកទេស និងពិនិត្យទៅលើបែបបទ នីតិវិធីក្នុងការអនុវត្តកិច្ចលទ្ធកម្ម ឱ្យស្របទៅតាមបញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ ដើម្បីធានាបានថាការរៀបចំនោះគ្មានការខុសឆ្គងណាមួយកើតឡើងឡើយ។

- អ្នកជំនួយបច្ចេកទេស របស់ទីចាត់ការផែនការ និងវិនិយោគរាជធានីខេត្ត ត្រូវបន្ថែមនូវការយកចិត្តទុកដាក់ខ្ពស់ ក្នុងការធ្វើការវិភាគ និងសិក្សាទៅលើតម្លៃទីផ្សារ ដើម្បីធ្វើការប៉ាន់ស្មានតម្លៃគម្រោងប្រកបដោយប្រសិទ្ធភាព។
- ភាគីឯកជនគួរតែបង្កើនការយកចិត្តទុកដាក់ ក្នុងការសិក្សាស្វែងយល់អំពីបែបបទនីតិវិធីនៃលទ្ធកម្មសាធារណៈដែលមានចែងនៅក្នុងបញ្ញត្តិស្ដីពីលទ្ធកម្មសាធារណៈ ក៏ដូចជាតាមដាននូវរាល់ប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពាក់ព័ន្ធនឹងការកំណត់លក្ខខណ្ឌតម្រូវ មុននឹងចូលរួមក្នុងដំណើរការលទ្ធកម្មសាធារណៈ ដើម្បីឱ្យការចូលរួមនោះមានភាពរលូន។

# សេចក្តីសន្និដ្ឋាន

លទ្ធកម្មសាធារណៈ គឺជាយន្តការមួយ នៃគណនេយ្យភាពសង្គមដែលជួយជម្រុញឱ្យប្រទេសជាតិមានការអភិវឌ្ឍ និងមាននូវអភិបាលកិច្ចល្អ។ ដោយហេតុនេះហើយទើបរាជរដ្ឋាភិបាល បានខិតខំប្រឹងប្រែងឥតឈប់ឈរ និងយកចិត្ត ទុកដាក់យ៉ាងខ្លាំង ក្នុងការពង្រឹងទៅទៅលើកិច្ចគ្រប់គ្រងលទ្ធកម្មសាធារណៈ តាមរយៈកម្មវិធីកំណែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយប្រើជាពិសេសលើគណនេយ្យភាពហិរញ្ញវត្ថុ ក្នុងគោលបំណងធានាឱ្យដំណើរការលទ្ធកម្មសាធារណៈសម្រាប់ការទិញ ការសាងសង់ ការជួសជុល ការ ជួលសេវាកម្មប្រព្រឹត្តទៅប្រកបដោយតម្លាភាព គណនេយ្យភាព ភាព យុត្តិធម៌ ប្រសិទ្ធភាព គុណភាព សមភាព ការសន្សំសំចៃ និងភាពទាន់ពេលវេលា។

ដោយហេតុនេះហើយ ទើបយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ ត្រូវបានរៀបចំឡើងដោយឈរលើ មូលដ្ឋាននៃក្របខណ្ឌច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ការវិភាគលើចំណុចខ្លាំងនិងចំណុចខ្សោយ កាលានុវត្តភាព ការគំរាមកំហែង បញ្ហាប្រឈមនានាដែលមាននៅក្នុងប្រព័ន្ធលទ្ធកម្មសាធារណៈកម្ពុជា។ យុទ្ធសាស្ត្រនៃការកែទម្រង់ប្រពន្ធលទ្ធកម្មសាធារណៈ ត្រូវបានរៀបចំឡើង ក្នុងគោលបំណង ដើម្បីពន្លឿន និងសម្រួលនីតិវិធីលទ្ធកម្មសាធារណៈ ឱ្យមានសង្គតិភាពជាមួយទិសដៅនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ។ ជោគជ័យនៃការអនុវត្តយុទ្ធសាស្ត្រកែទម្រង់នេះ គឺអាស្រ័យលើលទ្ធផលនៃការកែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការកែទម្រង់ប្រព័ន្ធថវិកា រួមទាំងការកែទម្រង់សំខាន់ៗផ្សេងទៀតរបស់រាជរដ្ឋាភិបាល រួមមាន ការកែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការនិងការកែទម្រង់រដ្ឋបាលសាធារណៈ ព្រមទាំងការចូលរួមអនុវត្តយ៉ាងសកម្មពីគ្រប់តួអង្គពាក់ព័ន្ធដូចជា ដៃគូអភិវឌ្ឍន៍ វិស័យឯកជន សង្គមស៊ីវិល ថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់ក្រសួងស្ថាប័នទាំងអស់ផងដែរ។

សរុបសេចក្តីមក ក្រោយពីបានសិក្សាស្រាវជ្រាវទៅលើការអនុវត្តកិច្ចលទ្ធសាធារណៈក្នុងឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ រួចមក យើងសង្កេតឃើញថាការអនុវត្តលទ្ធកម្មសាធារណៈក្នុងឃុំ សង្កាត់ មានតួនាទីយ៉ាងសំខាន់ក្នុងការរួមចំណែកធានាឱ្យបាននូវ តម្លាភាព សមភាព គណនេយ្យភាព និងប្រសិទ្ធភាពនៃចំណាយថវិការបស់រដ្ឋ។ការអនុវត្តកិច្ចលទ្ធកម្ម នៅក្នុងឃុំសែនដី បានផ្តល់នូវគុណសម្បត្តយ៉ាងច្រើនដល់ប្រជាពលរដ្ឋ អាជ្ញាធរ និងរាជរដ្ឋាភិបាល ដូចជាការកសាង ការជួលជុល ផ្លូវថ្នល់ សាលារៀន មន្ទីពេទ្យ ជាដើម ថែមទាំងរួមចំណែកជួយត្បិតត្បៀត និងជួយសន្សំសំចៃថវិកាជាតិបន្ថែមទៀតផង។ម្យ៉ាងវិញទៀត តាមរយៈការរៀបចំ និងការប្រព្រឹត្តិទៅនៃវិធីសាស្ត្រ និងនីតិវិធីលទ្ធកម្មឃុំ សង្កាត់ បានធ្វើឱ្យយន្តការនៃការអនុវត្តកិច្ចលទ្ធសាធារណៈក្នុងឃុំសែនដី ទទួលបានសមិទ្ធផលយ៉ាងល្អប្រសើរ ។ បើទោះបីជាឃុំសែនដី បានអនុវត្តកិច្ចលទ្ធសាធារណៈ

ទទួលបានលទ្ធផលល្អយ៉ាងណាក្តី  ក៏ប៉ុន្តែក្នុងនោះប្រសិនបើមន្ត្រីដែលទទួលបន្ទុកការអនុវត្តកិច្ចលទ្ធកម្ម  មិនសូវយល់ច្បាស់អំពីតួនាទី ភារកិច្ច របស់ខ្លួន ព្រមទាំងមិនបានអនុលោមតាមនីតិវិធីនៃការរៀបចំ និងប្រព្រឹត្តទៅនៃដំណើរការលទ្ធកម្មឃុំ សង្កាត់ទេនោះ ប្រាកដណាស់ភាពទន់ខ្សោយនៃលទ្ធកម្មសាធារណៈនៅតែមានជាបន្តបន្ទាប់ ដោយសារកង្វះធនធានមនុស្ស និងមន្ត្រីជំនាញលទ្ធកម្ម សម្រាប់ការងារលទ្ធកម្មនៅក្នុងឃុំ សង្កាត់។

# អនុសាសន៍

ឆ្លងតាមការសិក្សាស្រាវជ្រាវ និងការឆ្លុះបង្ហាញពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈក្នុងឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ យើងខ្ញុំទាំងពីរនាក់ ពិតជាមានសេចក្តីសោមនស្សរីករាយណាស់ ដោយបានសិក្សាស្វែងយល់នូវចំណុចនីមួយៗ នៃប្រធានបទខាងលើនេះ ដោយពួកយើងបានសង្កេតឃើញថា ដំណើរការនៃការអនុវត្តកិច្ចលទ្ធកម្មក្នុងឃុំសែនដី នាពេលបច្ចុប្បន្ន គឺមានលក្ខណៈល្អប្រសើរច្រើន ដោយសារការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល បូករួមនិងការចូលរួមពីអាជ្ញាធរដែនដី និងប្រជាពលរដ្ឋគ្រប់រូប។ យ៉ាងណាមិញទន្ទឹម និងការរីកចម្រើននេះ យើងខ្ញុំទាំងពីរនាក់ សូមអនុញ្ញាតបញ្ចេញនូវ គំនិត យោបល់ដ៏តូចមួយ ដើម្បីចូលរួមចំណែកពង្រឹងនិងពង្រីក នូវសក្តានុពលនៃដំណើការកិច្ចលទ្ធកម្មសាធាណៈក្នុងឃុំ សង្កាត់ ឱ្យកាន់តែមានភាពប្រសើរបន្ថែមទៀត៖

**១. ចំពោះអាជ្ញាធរមានសមត្ថកិច្ច**

- រដ្ឋាភិបាលត្រូវបន្ត ផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈ ពាក់ព័ន្ធនឹងផ្នែកលទ្ធកម្មដល់មន្រ្តីដែលទទួលបន្ទុកការងារលទ្ធកម្មនៅឃុំ សង្កាត់ ដើម្បីធានាបានថាដំណើរការអនុវត្តកិច្ចលទ្ធកម្ម ក្នុងឃុំ សង្កាត់ប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព តម្លាភាព សមភាព គណនេយ្យភាព និងការសន្សំសំចៃ។
- រដ្ឋាភិបាលត្រូវបន្ត តាមដានយកចិត្តទុកដាក់បង្កើននូវធនធានមនុស្សដែលមានចំណេះដឹង និងសមត្ថភាព សម្រាប់បម្រើការក្នុងមូលដ្ឋានឃុំ សង្កាត់ ដើម្បីបង្កភាពងាយស្រួលដល់ការអនុវត្តការងារ និងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ។

**២. ចំពោះឃុំ សង្កាត់**

- ចូលរួមផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋនូវគ្រប់មជ្ឈដ្ឋានទាំងមូល បានយល់ដឹងពីដំណើរការកិច្ចលទ្ធកម្មសាធារណៈ និងនីតិវិធីនៃការអនុវត្តកិច្ចលទ្ធកម្មក្នុងឃុំ សង្កាត់ ឱ្យបានកាន់តែច្រើនឡើង។
- ពាក់ព័ន្ធនឹងការអនុវត្តកិច្ចលទ្ធកម្មមន្ត្រីឃុំសង្កាត់ត្រូវមានជំនាញ សមត្ថភាព និងចំណេះដឹងច្បាស់លាស់អំពីនីតិវិធីនៃការរៀបចំ និងប្រព្រឹត្តទៅនៃ ដំណើការកិច្ចលទ្ធកម្មទាំងមូល។
- ថ្នាក់ដឹងនាំ ឃុំ សង្កាត់ គួរបន្តចូលរួមស្តាប់មតិយោបល់របស់ប្រជាពលរដ្ឋជុំវិញការអភិវឌ្ឍន៍ផ្សេងៗ ដើម្បីជាប្រយោជន៍ក្នុងការគ្រប់គ្រងតំបន់មូលដ្ឋាន។

# ឯកសារយោង

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
- ព្រះរាជាក្រមលេខ១៦៧ នស/រកម/០៥២៣/០០៥ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- អនុក្រឹត្យលេខ៩៣ អនក្រ.បក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១០ ស្តីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិឃុំ សង្កាត់
- អនុក្រឹត្យលេខ១០៥ អនក្រ.កប ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ ស្តីពីលទ្ធកម្មសាធារណៈ
- ប្រកាសណែនាំ លេខ១៧២ សហវ.ប្រក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០៣ ស្តីពីការងារលទ្ធកម្មរបស់ឃុំសង្កាត់
- ប្រកាសណែនាំ លេខ២៣១ សហវ.ប្រក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥ ស្តីពីការងារលទ្ធកម្មរបស់ឃុំសង្កាត់
- ប្រកាសលេខ៣៦៣ សហវ.លស.ប្រក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការចុះឈ្មោះក្នុង បញ្ជីអ្នកទទួលការសាងសង់។
- លោក ឡាញ់ ដា សៀវភៅលទ្ធកម្មសាធារណៈនៅកម្ពុជា បោះពុម្ពលើកទី១ឆ្នាំ២០២២
- សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល ឆ្នាំ២០២៤-២០២៦ របស់ឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ
- អង្គការសីលការ សៀវភៅណែនាំស្តីពីលទ្ធកម្មសាធារណៈ
- សៀវភៅណែនាំស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០២២
- សៀវភៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ ឆ្នាំ២០១៩-២០២៥
- សៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ ចុះផ្សាយ ថ្ងៃទី ១៧ ខែតុលា ឆ្នាំ២០១៧ ដោយ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
- ដំណើរការកិច្ចប្រជុំបើក សំណើដេញថ្លៃឃុំ/សង្កាត់ ចុះផ្សាយដោយអង្គការ សីលការ ( https://images.app.goo.gl/vt7PYKL6TXKoj78H9 )

# ឧបសម្ព័ន្ធ ១
# លិខិតបទដ្ឋានគតិយុត្ត

# ព្រះរាជក្រម

នស/រកម/០៥២៣/០០៥

# យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្ត្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ក្រុមប្រឹក្សាធម្មនុញ្ញ
អគ្គលេខាធិការដ្ឋាន
ចូល លេខ:...១៦៧...
ថ្ងៃទី ២៧.២ ខែ ឧសភា ឆ្នាំ២០២៣
ម៉ោង: ១៥:០០នាទី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៣ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២ ខែឧសភា ឆ្នាំ២០២៣ នាសម័យប្រជុំពេញអង្គលើកទី១០ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

# ច្បាប់

# ស្តីពី

# លទ្ធកម្មសាធារណៈ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ច្បាប់នេះ កំណត់អំពីវិធាន វិធីសាស្ត្រ នីតិវិធី និងរចនាសម្ព័ន្ធសម្រាប់គ្រប់គ្រងនិងអនុវត្តគ្រប់លទ្ធកម្មសាធារណៈ ក្នុងគោលបំណងដើម្បីធានាឱ្យកិច្ចលទ្ធកម្មសម្រាប់ការទិញ ការសាងសង់ ការផ្គត់ផ្គង់ ការផ្តល់សេវាកម្ម និងការផ្តល់សេវាទីប្រឹក្សា ប្រព្រឹត្តទៅប្រកបដោយតម្លាភាព គណនេយ្យភាព សុចរិតភាព ការប្រកួតប្រជែង ភាពយុត្តិធម៌ ប្រសិទ្ធភាព សក្តិសិទ្ធិភាព ចីរភាព គុណភាព ការសន្សំសំចៃ និងភាពទាន់ពេល ព្រមទាំងធានាឱ្យបាននូវប្រព័ន្ធលទ្ធកម្មសាធារណៈ ឯកភាពមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២ .-**

ច្បាប់នេះ មានវិសាលភាពអនុវត្តលើគ្រប់លទ្ធកម្មសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមិនគិតពីប្រភពធនធាន លើកលែងតែ៖

១. លទ្ធកម្មក្រោមគម្រោងហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ ដែលត្រូវអនុវត្តតាមគោលការណ៍ណែនាំ និងនីតិវិធីដូចមានចែងក្នុងកិច្ចព្រមព្រៀងហិរញ្ញប្បទាន។ ប្រសិនបើកិច្ចព្រមព្រៀងមិនបានកំណត់អំពីគោលការណ៍ណែនាំនិងនីតិវិធីលទ្ធកម្មណាមួយផ្សេងទេ ដំណើរការលទ្ធកម្មសាធារណៈត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

២. លទ្ធកម្មដែលត្រូវអនុវត្តតាមច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋនិងឯកជន។

៣. លទ្ធកម្មដែលប៉ះពាល់ដល់ការសម្ងាត់ក្នុងវិស័យការពារជាតិនិងសន្តិសុខសាធារណៈ ដែលត្រូវមានការសម្រេចពីនាយករដ្ឋមន្ត្រី។

**មាត្រា៣ .-**

វាក្យសព្ទសំខាន់ៗដែលប្រើប្រាស់ក្នុងច្បាប់នេះ ត្រូវបានកំណត់និយមន័យនៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់នេះ។

## ជំពូកទី២
## ស្ថាប័នគ្រប់គ្រងលទ្ធកម្មសាធារណៈ

**មាត្រា៤ .-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាស្ថាប័នគ្រប់គ្រងលទ្ធកម្មសាធារណៈដែលបំពេញមុខងារជានិយ័តករនិងត្រួតពិនិត្យការអនុវត្តលទ្ធកម្មសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា មានតួនាទីភារកិច្ចជាអាទិ៍៖

- រៀបចំនិងផ្សព្វផ្សាយគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងលទ្ធកម្មសាធារណៈ
- ត្រួតពិនិត្យ វិភាគ តាមដាន និងវាយតម្លៃលើការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងលទ្ធកម្មសាធារណៈ
- រៀបចំបណ្តុះបណ្តាលជំនាញលទ្ធកម្មដល់មន្ត្រីលទ្ធកម្មនិងបុគ្គលពាក់ព័ន្ធដទៃទៀត
- គ្រប់គ្រងបញ្ជីអ្នកដេញថ្លៃ

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

- ត្រួតពិនិត្យកិច្ចលទ្ធកម្មតាមក្រោយ
- ដោះស្រាយបណ្តឹងតវ៉ាពាក់ព័ន្ធនឹងការអនុវត្តលទ្ធកម្មសាធារណៈ
- ចាត់វិធានការសមស្របចំពោះអំពើល្មើសនឹងច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងលទ្ធកម្មសាធារណៈ
- គ្រប់គ្រងទិន្នន័យ រៀបចំ និងផ្សព្វផ្សាយរបាយការណ៍លទ្ធកម្មសាធារណៈ។

**មាត្រា៥ .-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានភារកិច្ចចេញលិខិតបទដ្ឋានគតិយុត្ត ដើម្បីណែនាំការអនុវត្តលទ្ធកម្មសាធារណៈដល់ស្ថាប័នអនុវត្តលទ្ធកម្ម។ ដោយឡែកចំពោះស្ថាប័នអនុវត្តលទ្ធកម្មដែលជាសហគ្រាសសាធារណៈ ដើម្បីធានានូវប្រសិទ្ធភាព សក្តិសិទ្ធិភាព និងការប្រកួតប្រជែង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអាចចេញលិខិតបទដ្ឋានគតិយុត្តបន្ថែមសម្រាប់ការអនុវត្តលទ្ធកម្មសាធារណៈ។

**មាត្រា៦ .-**

អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ បំពេញមុខងារជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការគ្រប់គ្រងលទ្ធកម្មសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

តួនាទីនិងភារកិច្ចរបស់អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៣
## ស្ថាប័នអនុវត្តលទ្ធកម្ម

**មាត្រា៧ .-**

ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវទទួលខុសត្រូវលើការអនុវត្តលទ្ធកម្មសាធារណៈឱ្យបានត្រឹមត្រូវតាមបទប្បញ្ញត្តិនៃច្បាប់នេះនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត។

**មាត្រា៨ .-**

ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវបង្កើតគណៈកម្មាធិការលទ្ធកម្មមួយ ដើម្បីទទួលខុសត្រូវត្រួតពិនិត្យលើផែនការលទ្ធកម្មនិងឯកសារដេញថ្លៃ ធ្វើការវាយតម្លៃប្រគល់កិច្ចសន្យា គ្រប់គ្រងការអនុវត្តកិច្ចសន្យា និងដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្មតាមសមត្ថកិច្ចរបស់ខ្លួន។ គណៈកម្មាធិការលទ្ធកម្ម ត្រូវដឹកនាំដោយថ្នាក់ដឹកនាំបន្ទាប់មួយរូបតាមការប្រគល់សិទ្ធិពីប្រធានស្ថាប័នអនុវត្តលទ្ធកម្ម។ ប្រធានស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវអនុម័តលើការសម្រេចប្រគល់កិច្ចសន្យានិងចុះហត្ថលេខាលើកិច្ចសន្យា។ ប្រធានស្ថាប័នអនុវត្តលទ្ធកម្ម មានឆន្ទានុសិទ្ធិក្នុងការប្រគល់សិទ្ធិជូនថ្នាក់ដឹកនាំក្រោមឱវាទក្នុងការអនុម័តនិងចុះហត្ថលេខាលើកិច្ចសន្យាក្នុងនាមប្រធានស្ថាប័នអនុវត្តលទ្ធកម្ម។

ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៩ .-**

ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវបង្កើតអង្គភាពលទ្ធកម្មមួយដែលមានរចនាសម្ព័ន្ធច្បាស់លាស់និងមានមន្ត្រីមានសមត្ថភាពជំនាញផ្នែកលទ្ធកម្មសាធារណៈគ្រប់គ្រាន់ ព្រមទាំងមានសិទ្ធិសមស្របដើម្បីទទួលខុសត្រូវអនុវត្តរាល់បែបបទលទ្ធកម្មសាធារណៈ។

អង្គភាពលទ្ធកម្ម មានរចនាសម្ព័ន្ធស្ថិតក្រោមប្រធានស្ថាប័នផ្ទាល់និងជាលេខាធិការឱ្យគណៈកម្មាធិការលទ្ធកម្ម។ អង្គភាពលទ្ធកម្ម ត្រូវដឹកនាំដោយប្រធានមួយរូបដែលមិនត្រូវមានតួនាទីនិងភារកិច្ចពាក់ព័ន្ធនឹងកិច្ចការហិរញ្ញវត្ថុផ្សេងទៀតក្នុងស្ថាប័នរបស់ខ្លួនឡើយ។ ប្រធានអង្គភាពលទ្ធកម្ម ជាលេខាធិការរបស់គណៈកម្មាធិការលទ្ធកម្ម។

ការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពលទ្ធកម្ម ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា១០ .-**

ស្ថាប័នអនុវត្តលទ្ធកម្មដែលជាអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ អាចត្រូវបានអនុញ្ញាតឱ្យបង្កើតក្រុមលទ្ធកម្មសម្រាប់អនុវត្តលទ្ធកម្មសាធារណៈជំនួសឱ្យការបង្កើតគណៈកម្មាធិការលទ្ធកម្មនិងអង្គភាពលទ្ធកម្ម។

លក្ខណវិនិច្ឆ័យ ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមលទ្ធកម្ម ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៤
## វិធីសាស្ត្រលទ្ធកម្មទំនិញ សំណង់ និងសេវាកម្ម

**មាត្រា១១ .-**

វិធីសាស្ត្រលទ្ធកម្មទំនិញ សំណង់ និងសេវាកម្ម ត្រូវធ្វើឡើងដោយអនុលោមតាមមាត្រា១២ មាត្រា១៣ និងមាត្រា១៤ នៃច្បាប់នេះ។

លក្ខខណ្ឌ កម្រិតទឹកប្រាក់ នីតិវិធី និងការផ្តល់ប្រព្រឹត្តិកម្មអនុគ្រោះ សម្រាប់អនុវត្តវិធីសាស្ត្រលទ្ធកម្មនីមួយៗ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១២ .-**

វិធីសាស្ត្រដេញថ្លៃដោយប្រកួតប្រជែងជាសាធារណៈ ជាវិធីសាស្ត្រលទ្ធកម្មសម្រាប់ជ្រើសរើសអ្នកផ្គត់ផ្គង់ទំនិញ អ្នកទទួលការសំណង់ ឬអ្នកផ្តល់សេវាកម្ម ដោយបើកចំហចំពោះគ្រប់អ្នកដេញថ្លៃក្នុងស្រុកនិងអន្តរជាតិ។ វិធីសាស្ត្រដេញថ្លៃដោយប្រកួតប្រជែងជាសាធារណៈ ជាវិធីសាស្ត្រលទ្ធកម្មដែលមានកម្រិតតម្លាភាពខ្ពស់និងដែលត្រូវជំរុញឱ្យប្រើក្នុងលទ្ធកម្មសាធារណៈ។ វិធីសាស្ត្រដេញថ្លៃដោយប្រកួតប្រជែងជាសាធារណៈរួមមាន៖

ក. ការដេញថ្លៃដោយប្រកួតប្រជែងជាលក្ខណៈអន្តរជាតិ : វិធីសាស្ត្រនេះ ត្រូវប្រើសម្រាប់គម្រោងលទ្ធកម្មដែលមានទឹកប្រាក់កម្រិតធំនិង/ឬមានលក្ខណៈបច្ចេកទេសខ្ពស់។

ខ. ការដេញថ្លៃដោយប្រកួតប្រជែងក្នុងស្រុក : វិធីសាស្ត្រនេះ ត្រូវប្រើក្នុងករណីដែលមានផលិតផល ផលិតកម្ម សេវាកម្ម ឬសមត្ថភាពសាងសង់ក្នុងស្រុកគ្រប់គ្រាន់។

**មាត្រា១៣ .-**

វិធីសាស្ត្រដេញថ្លៃដោយប្រកួតប្រជែងដទៃទៀត ជាវិធីសាស្ត្រលទ្ធកម្មដែលមិនមែនជាការដេញថ្លៃដោយប្រកួតប្រជែងជាសាធារណៈរួមមាន៖

ក. ការដេញថ្លៃមានកម្រិត : វិធីសាស្ត្រនេះ ត្រូវប្រើសម្រាប់គម្រោងលទ្ធកម្មដែលមានលក្ខណៈបច្ចេកទេសស្មុគស្មាញនិងដែលតម្រូវឱ្យមានអ្នកដេញថ្លៃមានសមត្ថភាពជំនាញជាក់លាក់សម្រាប់អនុវត្ត។ វិធីសាស្ត្រនេះ តម្រូវឱ្យមានការធ្វើបុរេលក្ខណសម្បត្តិ។

ខ. ការពិគ្រោះថ្លៃ : វិធីសាស្ត្រនេះ ត្រូវប្រើសម្រាប់មុខសញ្ញាលទ្ធកម្មដែលមានរួចជាស្រេចនៅលើទីផ្សារក្នុងស្រុកនិងមានទឹកប្រាក់កម្រិតមធ្យម។

គ. ការស្ទង់តម្លៃ : វិធីសាស្ត្រនេះ ត្រូវប្រើសម្រាប់មុខសញ្ញាលទ្ធកម្មមានរួចជាស្រេចនៅលើទីផ្សារក្នុងស្រុកនិងមានទឹកប្រាក់កម្រិតតូច។

**មាត្រា១៤.-**

វិធីសាស្ត្រលទ្ធកម្មដោយឡែក ជាវិធីសាស្ត្រលទ្ធកម្មសម្រាប់ជ្រើសរើសអ្នកផ្គត់ផ្គង់ទំនិញ អ្នកទទួលការសំណង់ ឬអ្នកផ្តល់សេវាកម្ម ដោយមិនមានការដេញថ្លៃ។ វិធីសាស្ត្រនេះ អាចអនុវត្តបានលុះត្រាតែមានការអនុញ្ញាតជាមុនពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ វិធីសាស្ត្រលទ្ធកម្មដោយឡែករួមមាន៖

ក. ការចុះកិច្ចសន្យាផ្ទាល់ : វិធីសាស្ត្រនេះ អនុញ្ញាតឱ្យចរចាផ្ទាល់ជាមួយនឹងអ្នកផ្គត់ផ្គង់ទំនិញ អ្នកទទួលការសំណង់ ឬអ្នកផ្តល់សេវាកម្មក្នុងកាលៈទេសៈណាមួយដូចខាងក្រោម៖

- មុខសញ្ញាលទ្ធកម្មមានប្រភពតែមួយ
- មុខសញ្ញាលទ្ធកម្មដែលត្រូវបានដេញថ្លៃដោយប្រកួតប្រជែងជាសាធារណៈម្តងរួចមកហើយ ហើយជាតម្រូវការចាំបាច់បន្ទាន់និងមិនមានពេលគ្រប់គ្រាន់សម្រាប់ធ្វើការដេញថ្លៃដោយប្រកួតប្រជែងជាសាធារណៈលើកទី២
- ការដេញថ្លៃដោយប្រកួតប្រជែងជាសាធារណៈលើកទី២ មិនទទួលបានជោគជ័យ ទោះបីជាបានកែសម្រួលឯកសារដេញថ្លៃ ក្រោយការដេញថ្លៃលើកទី១ បរាជ័យក៏ដោយ
- តម្រូវការចាំបាច់បន្ទាន់ក្នុងពេលមានគ្រោះមហន្តរាយធម្មជាតិឬគ្រោះអាសន្នផ្សេងទៀត ហើយមានរយៈពេលខ្លីមិនអាចរង់ចាំឱ្យប្រើវិធីសាស្ត្រផ្សេងទៀតបាន
- សម្រាប់គោលបំណងសិក្សាស្រាវជ្រាវ ដកបទពិសោធ ឬអភិវឌ្ឍ។

ខ. ការបន្តកិច្ចសន្យា: វិធីសាស្ត្រនេះ អនុញ្ញាតឱ្យចរចាផ្ទាល់ជាមួយនឹងអ្នកផ្គត់ផ្គង់ទំនិញ អ្នកទទួលការសំណង់ ឬអ្នកផ្តល់សេវាកម្មក្នុងកាលៈទេសៈដូចខាងក្រោម៖

- មុខសញ្ញាលទ្ធកម្មដូចគ្នានឹងមុខសញ្ញាលទ្ធកម្មក្នុងកិច្ចសន្យាដើម ដែលទទួលបានតាមរយៈការដេញថ្លៃ
- ស្ថិតក្នុងអំឡុងមិនលើសពី៦(ប្រាំមួយ)ខែ បន្ទាប់ពីកិច្ចសន្យាដើមចូលជាធរមាននិងស្ថិតក្នុងឆ្នាំថវិកាតែមួយ
- តម្លៃឯកតាស្មើឬទាបជាងតម្លៃឯកតាក្នុងកិច្ចសន្យាដើម និង
- តម្លៃសរុបមិនលើសពី២៥(ម្ភៃប្រាំ)ភាគរយនៃតម្លៃកិច្ចសន្យាដើម។

គ. ការចុះកិច្ចសន្យាជាមួយនឹងអង្គភាពជំនាញនៃស្ថាប័នរដ្ឋ : វិធីសាស្ត្រនេះ អនុញ្ញាតឱ្យចរចាផ្ទាល់ជាមួយនឹងអង្គភាពជំនាញរបស់ស្ថាប័នរដ្ឋដែលមានធនធាន គ្រឿងចក្រ ឧបករណ៍ សម្ភារៈ និងកម្លាំងពលកម្មគ្រប់គ្រាន់សម្រាប់អនុវត្តកិច្ចសន្យា។

ឃ. ការចុះកិច្ចសន្យាជាមួយនឹងសហគមន៍ : វិធីសាស្ត្រនេះ អនុញ្ញាតឱ្យចរចាផ្ទាល់ជាមួយនឹងសហគមន៍សំដៅលើកទឹកចិត្តសហគមន៍ក្នុងស្រុក ដើម្បីប្រើប្រាស់កម្លាំងពលកម្ម ចំណេះដឹង និងសម្ភារៈក្នុងស្រុកសម្រាប់ចូលរួមក្នុងការអភិវឌ្ឍសហគមន៍។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

## ជំពូកទី៥
## លទ្ធកម្មសេវាទីប្រឹក្សា

**មាត្រា១៥ .-**

ទីប្រឹក្សា អាចត្រូវបានជ្រើសរើសដើម្បីផ្តល់សេវាឯកទេសសម្រាប់គ្រប់គ្រងគម្រោង អនុវត្តកិច្ចសន្យាសំខាន់ៗ ឬផ្តល់យោបល់ជំនាញក្នុងការងារពង្រឹងពង្រីកស្ថាប័នឬបង្កើនសមត្ថភាព។ ទីប្រឹក្សាអាចជាក្រុមហ៊ុនទីប្រឹក្សាឬទីប្រឹក្សាឯកត្តជន។

**មាត្រា១៦ .-**

ក្រុមហ៊ុនទីប្រឹក្សា ត្រូវបានជ្រើសរើសនៅពេលស្ថាប័នអនុវត្តលទ្ធកម្មមានតម្រូវការសេវាទីប្រឹក្សាច្រើនដែលមានការពាក់ព័ន្ធគ្នាក្នុងពេលតែមួយ។ ការជ្រើសរើសក្រុមហ៊ុនទីប្រឹក្សាត្រូវផ្អែកលើការស្នើបច្ចេកទេសនិងការស្នើហិរញ្ញវត្ថុរបស់ក្រុមហ៊ុនទីប្រឹក្សានីមួយៗ។

**មាត្រា១៧ .-**

ទីប្រឹក្សាឯកត្តជន ត្រូវបានជ្រើសរើសដោយផ្អែកលើលក្ខណសម្បត្តិរបស់ទីប្រឹក្សាសម្រាប់ផ្តល់សេវាជូនស្ថាប័នអនុវត្តលទ្ធកម្ម។

**មាត្រា១៨ .-**

វិធីសាស្ត្រជ្រើសរើសទីប្រឹក្សារួមមាន៖

- ការជ្រើសរើសផ្អែកលើគុណភាព
- ការជ្រើសរើសផ្អែកលើគុណភាពនិងថ្លៃ
- ការជ្រើសរើសផ្អែកលើថវិកាកំណត់
- ការជ្រើសរើសផ្អែកលើថ្លៃទាបបំផុត
- ការជ្រើសរើសផ្អែកលើលក្ខណសម្បត្តិរបស់ទីប្រឹក្សា
- ការជ្រើសរើសផ្អែកលើប្រភពតែមួយ
- ការជ្រើសរើសទីប្រឹក្សាឯកត្តជន។

**មាត្រា១៩ .-**

វិធីសាស្ត្រជ្រើសរើសផ្អែកលើគុណភាព ត្រូវប្រើសម្រាប់ជ្រើសរើសក្រុមហ៊ុនទីប្រឹក្សា។ វិធីសាស្ត្រនេះ ត្រូវអនុវត្តសម្រាប់ការងារដែលមានការពាក់ព័ន្ធគ្នាក្នុងពេលតែមួយនិងផ្តោតជាសំខាន់លើកម្រិតបច្ចេកទេសនៃសេវា ហើយត្រូវបានប្រើសមស្របសម្រាប់ការងារដូចខាងក្រោម៖

- ការងារជំនាញឯកទេសខ្ពស់ឬស្មុគស្មាញខ្លាំងដែលពិបាកកំណត់លក្ខខណ្ឌយោងការងារនិងលទ្ធផលការងារច្បាស់លាស់ ហើយការងារនោះអាចធ្វើឡើងបានតាមរបៀបផ្សេងគ្នា
- ការងារដែលមានផលប៉ះពាល់ខ្លាំងផ្នែកសង្គម សេដ្ឋកិច្ច និង/ឬបរិស្ថាន ដែលតម្រូវឱ្យមានក្រុមហ៊ុនទីប្រឹក្សាមានជំនាញនិងសមត្ថភាពខ្ពស់សម្រាប់អនុវត្ត។

**មាត្រា២០ .-**

វិធីសាស្ត្រជ្រើសរើសផ្អែកលើគុណភាពនិងថ្លៃ ត្រូវប្រើសម្រាប់ជ្រើសរើសក្រុមហ៊ុនទីប្រឹក្សា។ វិធីសាស្ត្រនេះ ត្រូវអនុវត្តសម្រាប់ការងារធំៗនិងការងារដែលអាចកំណត់បានច្បាស់លាស់ពីទំហំការងារ លក្ខខណ្ឌយោងការងារ ពេល និងលទ្ធផលការងារ។ ការប្រើវិធីសាស្ត្រនេះ ត្រូវថ្លឹងថ្លែងលើគុណភាពនិងថ្លៃ ដោយត្រូវផ្តល់ទម្ងន់លើគុណភាពខ្ពស់ជាង ថ្លៃស្របតាមកម្រិតបច្ចេកទេសស្មុគស្មាញនៃសេវា។

**មាត្រា២១ .-**

វិធីសាស្ត្រជ្រើសរើសផ្អែកលើថវិកាកំណត់ ត្រូវប្រើសម្រាប់ជ្រើសរើសក្រុមហ៊ុនទីប្រឹក្សា។ វិធីសាស្ត្រនេះ ត្រូវអនុវត្តសម្រាប់ការងារដែលមានលក្ខណៈសាមញ្ញនិងទំហំការងារអាចកំណត់បានច្បាស់លាស់ ហើយថវិកាមានកំណត់។ ការប្រើវិធីសាស្ត្រនេះ ត្រូវបញ្ជាក់ពីចំនួនថវិកាដែលមាន ដើម្បីឱ្យក្រុមហ៊ុនទីប្រឹក្សាដាក់ការស្នើបច្ចេកទេសតម្រូវតាម ចំនួនថវិកានោះ។

**មាត្រា២២ .-**

វិធីសាស្ត្រជ្រើសរើសផ្អែកលើថ្លៃទាបបំផុត ត្រូវប្រើសម្រាប់ជ្រើសរើសក្រុមហ៊ុនទីប្រឹក្សា។ វិធីសាស្ត្រនេះ ត្រូវ អនុវត្តសម្រាប់ការងារដែលមានលក្ខណៈជាបទដ្ឋានឬការងារមានលក្ខណៈជាប្រចាំដែលធ្លាប់អនុវត្តបានល្អនិងមាន បទដ្ឋានរួចជាស្រេច។

**មាត្រា២៣ .-**

វិធីសាស្ត្រជ្រើសរើសផ្អែកលើលក្ខណសម្បត្តិរបស់ទីប្រឹក្សា ត្រូវប្រើសម្រាប់ជ្រើសរើសក្រុមហ៊ុនទីប្រឹក្សា។ វិធីសាស្ត្រនេះ ត្រូវអនុវត្តសម្រាប់ការងារតូចៗឬការងារជំនាញឯកទេស ដែលតម្រូវឱ្យមានទីប្រឹក្សាមានសមត្ថភាព ជំនាញជាក់លាក់សម្រាប់អនុវត្តកិច្ចសន្យា។

**មាត្រា២៤ .-**

វិធីសាស្ត្រជ្រើសរើសផ្អែកលើប្រភពតែមួយ ត្រូវប្រើសម្រាប់ជ្រើសរើសក្រុមហ៊ុនទីប្រឹក្សាឬទីប្រឹក្សាឯកត្តជន នៅក្នុងកាលៈទេសៈពិសេស។ វិធីសាស្ត្រនេះ អាចអនុវត្តបានលុះត្រាតែមានការអនុញ្ញាតជាមុនពីក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ។

កាលៈទេសៈពិសេសដែលសមស្របនឹងវិធីសាស្ត្រនេះរួមមាន៖

- ការងារបន្តពីមុនដែលត្រូវបានអនុវត្តដោយក្រុមហ៊ុនទីប្រឹក្សាឬទីប្រឹក្សាឯកត្តជន
- ករណីបន្ទាន់បំផុតដែលតម្រូវឱ្យមានការឆ្លើយតបភ្លាមៗ ឬ
- ករណីមានតែក្រុមហ៊ុនទីប្រឹក្សាមួយឬទីប្រឹក្សាឯកត្តជនម្នាក់ប៉ុណ្ណោះ ដែលមានសមត្ថភាពគ្រប់គ្រាន់ និងមានបទពិសោធពិសេសសម្រាប់អនុវត្តគម្រោង។

**មាត្រា២៥ .-**

វិធីសាស្ត្រជ្រើសរើសទីប្រឹក្សាឯកត្តជន ត្រូវប្រើសម្រាប់ជ្រើសរើសបុគ្គលទីប្រឹក្សាផ្ទាល់។ ការអនុវត្តវិធីសាស្ត្រនេះ ត្រូវផ្អែកលើចំណេះដឹង កម្រិតជំនាញវិជ្ជាជីវៈ បទពិសោធ និងកម្រិតជំនាញពាក់ព័ន្ធផ្សេងទៀតរបស់ទីប្រឹក្សា។

**មាត្រា២៦ .-**

សេចក្ដីជូនដំណឹងស្ដីពីការដាក់ចំណាប់អារម្មណ៍សម្រាប់គ្រប់វិធីសាស្ត្រលទ្ធកម្មសេវាទីប្រឹក្សា លើកលែងតែវិធីសាស្ត្រជ្រើសរើសផ្អែកលើប្រភពតែមួយ ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈដើម្បីធានាឱ្យមានការប្រកួតប្រជែងដោយស្មើភាពក្នុងចំណោមទីប្រឹក្សាក្នុងស្រុកនិងអន្តរជាតិ។

**មាត្រា២៧ .-**

លក្ខខណ្ឌនិងនីតិវិធីនៃការជ្រើសរើសទីប្រឹក្សាក្រោមវិធីសាស្ត្រជ្រើសរើសទីប្រឹក្សាក្នុងមាត្រា១៨ នៃច្បាប់នេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៦
## លក្ខណសម្បត្តិអ្នកដេញថ្លៃ

**មាត្រា២៨ .-**

គ្រប់អ្នកដេញថ្លៃ ត្រូវបានផ្ដល់ឱកាសដោយយុត្តិធម៌និងស្មើភាពក្នុងការចូលរួមគ្រប់លទ្ធកម្មសាធារណៈស្របតាមលក្ខខណ្ឌកំណត់នៃវិធីសាស្ត្រនីមួយៗ លើកលែងតែអ្នកដេញថ្លៃទាំងឡាយណាដែលពុំមានលក្ខណសម្បត្តិគ្រប់គ្រាន់ កំពុងស្ថិតនៅក្នុងបញ្ជីខ្មៅរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬត្រូវបានហាមឃាត់ដោយតុលាការ។

**មាត្រា២៩ .-**

អ្នកដេញថ្លៃ ត្រូវចុះបញ្ជីចំណាត់ប្រភេទនិងចំណាត់ថ្នាក់អ្នកដេញថ្លៃនៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីមានសិទ្ធិចូលរួមក្នុងលទ្ធកម្មសាធារណៈ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវធ្វើចំណាត់ប្រភេទនិងចំណាត់ថ្នាក់អ្នកដេញថ្លៃតាមកម្រិតសមត្ថភាពរបស់អ្នកដេញថ្លៃដើម្បីធានាការអនុវត្តកិច្ចសន្យា។

នីតិវិធីនៃការធ្វើចំណាត់ប្រភេទនិងចំណាត់ថ្នាក់អ្នកដេញថ្លៃ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៣០ .-**

ការកំណត់បុរេលក្ខណសម្បត្តិអ្នកដេញថ្លៃ ត្រូវធ្វើឡើងដោយស្ថាប័នអនុវត្តលទ្ធកម្មសម្រាប់តែគម្រោងលទ្ធកម្មដែលមានលក្ខណៈបច្ចេកទេសស្មុគស្មាញ។

នីតិវិធីសម្រាប់ធ្វើបុរេលក្ខណសម្បត្តិអ្នកដេញថ្លៃ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៣១ .-**

ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវពិនិត្យនិងវាយតម្លៃលើលក្ខណសម្បត្តិតាមក្រោយរបស់អ្នកដេញថ្លៃនាំមុខ មុនការយល់ព្រមប្រគល់កិច្ចសន្យា។

លក្ខខណ្ឌនិងនីតិវិធីសម្រាប់កំណត់លក្ខណសម្បត្តិតាមក្រោយ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៣២ .-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចុះឈ្មោះអ្នកដេញថ្លៃ អ្នកផ្គត់ផ្គង់ ឬអ្នកទទួលការក្នុងបញ្ជីខ្មៅ បន្ទាប់ពីបានរកឃើញថា អ្នកដេញថ្លៃ អ្នកផ្គត់ផ្គង់ ឬអ្នកទទួលការ ដែលផ្តល់ភស្តុតាងក្លែងបន្លំឬមិនត្រឹមត្រូវក្នុងពេលដាក់ពាក្យប្តឹងតវ៉ាក្នុងដំណើរការលទ្ធកម្មសាធារណៈ ឬប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់នេះឬបទប្បញ្ញត្តិផ្សេងទៀតដែលពាក់ព័ន្ធនឹងលទ្ធកម្មសាធារណៈ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវជម្រះចេញពីបញ្ជីខ្មៅនូវឈ្មោះអ្នកដេញថ្លៃ អ្នកផ្គត់ផ្គង់ ឬអ្នកទទួលការដែលផុតសុពលភាពក្នុងបញ្ជីខ្មៅ។

ការចុះនិងការជម្រះបញ្ជីខ្មៅ ត្រូវផ្សព្វផ្សាយជាសាធារណៈនិងត្រូវចម្លងជូនគ្រប់ស្ថាប័នអនុវត្តលទ្ធកម្មក្នុងព្រះរាជាណាចក្រកម្ពុជា។

នីតិវិធីនៃការចុះ ការជម្រះ និងការផ្សព្វផ្សាយបញ្ជីខ្មៅ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៧
## ផែនការលទ្ធកម្ម

**មាត្រា៣៣ .-**

គ្រប់ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ។ ផែនការលទ្ធកម្ម ត្រូវមានសង្គតិភាពនឹងកញ្ចប់ថវិកាប្រចាំឆ្នាំ។

រាល់គម្រោងចំណាយដែលត្រូវអនុវត្តលទ្ធកម្មសាធារណៈ ត្រូវកត់ត្រាបញ្ចូលក្នុងផែនការលទ្ធកម្ម។ ករណីដែលមិនមានការកត់ត្រាក្នុងផែនការលទ្ធកម្ម មិនត្រូវបានអនុញ្ញាតឱ្យផ្តល់ចំណាយឡើយ។

លក្ខខណ្ឌនិងនីតិវិធីនៃការរៀបចំ ការពិនិត្យ និងការអនុម័តផែនការលទ្ធកម្ម ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៣៤ .-**

ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវចងជាកញ្ចប់លទ្ធកម្ម ចំពោះមុខសញ្ញាលទ្ធកម្មដែលស្ថិតក្នុងប្រភេទដូចគ្នា មានលក្ខណៈដូចគ្នាឬប្រហាក់ប្រហែលគ្នា ស្របតាមតម្រូវការជាក់ស្តែងសម្រាប់ធ្វើកិច្ចលទ្ធកម្មតែមួយលើក ដើម្បីបង្កើនកម្រិតគុណភាពនៃការប្រកួតប្រជែង ការសន្សំសំចៃសោហ៊ុយចំណាយ និងចំណេញពេល។

**មាត្រា៣៥ .-**

ហាមបំបែកគម្រោងជាគម្រោងតូចៗក្នុងគោលបំណងបំពាននីតិវិធីសាស្ត្រលទ្ធកម្ម។

**មាត្រា៣៦ .-**

ផែនការលទ្ធកម្ម ត្រូវបានអនុញ្ញាតឱ្យកែតម្រូវក្នុងករណីចាំបាច់។ រាល់ការកែតម្រូវផែនការលទ្ធកម្មដោយសារមិនមានពេលគ្រប់គ្រាន់សម្រាប់អនុវត្តកិច្ចលទ្ធកម្មឬដើម្បីតម្រូវតាមកិច្ចលទ្ធកម្មដែលបានអនុវត្តរួច ត្រូវហាមឃាត់។ ការកែតម្រូវផែនការលទ្ធកម្មត្រូវស្នើសុំការពិនិត្យនិងសម្រេចពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចចេញលិខិតបទដ្ឋានគតិយុត្តកំណត់លក្ខខណ្ឌដែលអនុញ្ញាតឱ្យស្ថាប័នអនុវត្តលទ្ធកម្មមានសិទ្ធិកែតម្រូវផែនការលទ្ធកម្មដោយមិនចាំបាច់សុំការពិនិត្យនិងសម្រេចពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៣៧ .-**

ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវផ្ញើផែនការលទ្ធកម្មប្រចាំឆ្នាំទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យនិងអនុម័ត ឱ្យបានមុនថ្ងៃទី៣១ ខែធ្នូ មុនឆ្នាំអនុវត្តថវិកា។

**មាត្រា៣៨ .-**

ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវអនុវត្តតាមផែនការលទ្ធកម្មប្រចាំឆ្នាំ ដែលបានអនុម័តដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងត្រូវធ្វើរបាយការណ៍អនុវត្តកិច្ចលទ្ធកម្មជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឱ្យបានទៀងទាត់។

## ជំពូកទី៨
## នីតិវិធីនៃការអនុវត្តកិច្ចលទ្ធកម្ម

**មាត្រា៣៩ .-**

ការអនុវត្តកិច្ចលទ្ធកម្ម ត្រូវអនុលោមតាមដំណាក់កាលដូចខាងក្រោម៖

- ការរៀបចំឯកសារដេញថ្លៃ
- ការផ្សព្វផ្សាយសេចក្តីជូនដំណឹងស្តីពីការដេញថ្លៃ
- ការលក់ឯកសារដេញថ្លៃ និងការទទួលនិងការរក្សាទុកសំណុំឯកសារស្នើដេញថ្លៃ
- ការបើកសំណុំឯកសារស្នើដេញថ្លៃ
- ការវាយតម្លៃសំណុំឯកសារស្នើដេញថ្លៃ
- ការប្រគល់កិច្ចសន្យា
- ការគ្រប់គ្រងកិច្ចសន្យា។

**មាត្រា៤០ .-**

អង្គភាពលទ្ធកម្មនៃស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវរៀបចំឯកសារដេញថ្លៃឱ្យស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ដោយបញ្ជាក់ពីលក្ខខណ្ឌតម្រូវនិងលក្ខណវិនិច្ឆ័យនៃការជ្រើសរើសអ្នកដេញថ្លៃឱ្យបានច្បាស់លាស់ ដែលអាចផ្ទៀងផ្ទាត់បាន ហើយត្រូវពាក់ព័ន្ធនឹងមុខសញ្ញាលទ្ធកម្ម។ ឯកសារដេញថ្លៃ ត្រូវដាក់ជូនប្រធានគណៈកម្មាធិការលទ្ធកម្មពិនិត្យនិងចុះហត្ថលេខា។ ចំពោះគម្រោងលទ្ធកម្មដែលមានទឹកប្រាក់ធំ មានចរិតជាយុទ្ធសាស្ត្រ និងមានលក្ខណៈបច្ចេកទេសដោយឡែកសម្រាប់គ្រប់គ្រង និងគម្រោងដែលមានវេទយិតភាពខ្ពស់ ស្ថាប័នអនុវត្តលទ្ធកម្មត្រូវស្នើសុំទិដ្ឋាការយល់ព្រមលើឯកសារដេញថ្លៃពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

គំរូឯកសារដេញថ្លៃ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៤១ .-**

រាល់សំណុំឯកសារស្នើដេញថ្លៃ ត្រូវភ្ជាប់មកជាមួយនូវឯកសារប្រាក់កក់ធានាការដេញថ្លៃ លើកលែងតែសំណុំឯកសារស្នើដេញថ្លៃនៃកិច្ចលទ្ធកម្មដែលត្រូវអនុវត្តតាមវិធីសាស្ត្រស្តង់តម្លៃនិងវិធីសាស្ត្រជ្រើសរើសទីប្រឹក្សា។

បែបបទនិងនីតិវិធីនៃការកក់ប្រាក់ធានាការដេញថ្លៃ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៤២ .-**

អង្គភាពលទ្ធកម្មនៃស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវរៀបចំសេចក្តីជូនដំណឹងស្តីពីការដេញថ្លៃសម្រាប់ផ្សព្វផ្សាយ ដើម្បីជ្រើសរើសអ្នកដេញថ្លៃ។ សេចក្តីជូនដំណឹងស្តីពីការដេញថ្លៃ ត្រូវមានព័ត៌មានសំខាន់ៗដូចខាងក្រោម៖

- ការពណ៌នាអំពីប្រភេទនិងបរិមាណនៃទំនិញ ការងារសាងសង់ ការងារផ្គត់ផ្គង់ ឬសេវាកម្ម
- ឈ្មោះ អាសយដ្ឋាន អ៊ីម៉ែល និងទូរសព្ទរបស់អង្គភាពលទ្ធកម្មនៃស្ថាប័នអនុវត្តលទ្ធកម្ម
- វិធីសាស្ត្រលទ្ធកម្មដែលត្រូវអនុវត្ត
- លក្ខខណ្ឌតម្រូវនានានៃលក្ខណសម្បត្តិអ្នកដេញថ្លៃ
- កាលបរិច្ឆេទនិងពេលលក់ឯកសារដេញថ្លៃ ទទួល និងបើកសំណុំឯកសារស្នើដេញថ្លៃ
- លក្ខខណ្ឌតម្រូវនៃប្រាក់កក់ធានាការដេញថ្លៃនិងប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា។

**មាត្រា៤៣ .-**

សេចក្តីជូនដំណឹងស្តីពីការដេញថ្លៃនិងសេចក្តីកែសម្រួលនានា ត្រូវប្រកាសផ្សព្វផ្សាយតាមគេហទំព័រលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គេហទំព័ររបស់សាមីស្ថាប័នអនុវត្តលទ្ធកម្ម និងតាមសារព័ត៌មាន ហើយត្រូវបិទផ្សាយនៅលើក្តារបិទផ្សាយព័ត៌មានរបស់ស្ថាប័នអនុវត្តលទ្ធកម្ម។

**មាត្រា៤៤ .-**

អង្គភាពលទ្ធកម្មនៃស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវរៀបចំឯកសារដេញថ្លៃឱ្យបានគ្រប់គ្រាន់សម្រាប់លក់ជូនអ្នកដែលមានបំណងចូលរួមដេញថ្លៃ។ ការលក់ឯកសារដេញថ្លៃ ត្រូវធ្វើឡើងឱ្យបានទូលំទូលាយនៅទីតាំងជាក់លាក់ក្នុងស្ថាប័នអនុវត្តលទ្ធកម្មនិងតាមប្រព័ន្ធអេឡិចត្រូនិករបស់ស្ថាប័នអនុវត្តលទ្ធកម្ម។

បែបបទនៃការលក់និងការកំណត់ថ្លៃលក់ឯកសារដេញថ្លៃ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៤៥ .-**

ប្រសិនបើមានការស្នើសុំបំភ្លឺជាលាយលក្ខណ៍អក្សរពីអ្នកដេញថ្លៃណាមួយអំពីឯកសារដេញថ្លៃ ស្ថាប័នអនុវត្តលទ្ធកម្មត្រូវឆ្លើយតបជាលាយលក្ខណ៍អក្សរទៅអ្នកដេញថ្លៃដែលស្នើសុំនោះ និងត្រូវចម្លងជូនទៅគ្រប់អ្នកដេញថ្លៃដែលបានទទួលឯកសារដេញថ្លៃ។ ក្នុងករណីចាំបាច់ ស្ថាប័នអនុវត្តលទ្ធកម្មត្រូវធ្វើការប្រជុំមុនកាលបរិច្ឆេទឈប់ទទួលសំណុំឯកសារស្នើដេញថ្លៃ ដើម្បីឆ្លើយបំភ្លឺដោយអញ្ជើញអ្នកដេញថ្លៃដែលបានទទួលឯកសារដេញថ្លៃមកចូលរួម។

**មាត្រា៤៦ .-**

អង្គភាពលទ្ធកម្មនៃស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវទទួល ចុះបញ្ជី និងរៀបចំរក្សាទុកសំណុំឯកសារស្នើដេញថ្លៃដែលដាក់ក្នុងស្រោមសំបុត្របិទភ្ជិតនៅកន្លែងមានសុវត្ថិភាព ដោយមិនត្រូវប៉ះពាល់ឱ្យខូចទម្រង់ដើមនៃស្រោមសំបុត្រដាក់សំណុំឯកសារស្នើដេញថ្លៃនោះទេ មុនកាលបរិច្ឆេទបើកសំណុំឯកសារស្នើដេញថ្លៃ។

**មាត្រា៤៧ .-**

សំណុំឯកសារស្នើដេញថ្លៃទាំងអស់ ត្រូវបើកជាសាធារណៈភ្លាមៗបន្ទាប់ពីកាលបរិច្ឆេទឈប់ទទួលសំណុំឯកសារស្នើដេញថ្លៃ។ ព័ត៌មានសំខាន់ៗនៃសំណុំឯកសារស្នើដេញថ្លៃនីមួយៗ ត្រូវប្រកាសនៅចំពោះមុខអ្នកចូលរួមបើកសំណុំឯកសារស្នើដេញថ្លៃនិងត្រូវកត់ត្រាក្នុងកំណត់ហេតុបើកសំណុំឯកសារស្នើដេញថ្លៃ រួចចម្លងជូនគ្រប់អ្នកដេញថ្លៃនិងអ្នកចូលរួមបើកសំណុំឯកសារស្នើដេញថ្លៃទាំងអស់។

ប្រសិនបើក្នុងដំណើរការដេញថ្លៃលើកដំបូងទទួលបានសំណុំឯកសារស្នើដេញថ្លៃតិចជាងបី គណៈកម្មាធិការលទ្ធកម្មនៃស្ថាប័នអនុវត្តលទ្ធកម្ម មិនត្រូវបើកសំណុំឯកសារស្នើដេញថ្លៃទាំងនោះឡើយ ហើយត្រូវបញ្ជូនត្រឡប់ទៅឱ្យអ្នកដេញថ្លៃវិញ។

ក្នុងករណីដែលដំណើរការដេញថ្លៃលើកដំបូងទទួលបានសំណុំឯកសារស្នើដេញថ្លៃតិចជាងបីដូចបានកំណត់ក្នុងកថាខណ្ឌទី២ខាងលើ ពុំទទួលបានសំណុំឯកសារស្នើដេញថ្លៃ ឬពុំមានសំណុំឯកសារស្នើដេញថ្លៃណាមួយឆ្លើយតបនឹងលក្ខខណ្ឌនៃការដេញថ្លៃនោះ ត្រូវដំណើរការដេញថ្លៃឡើងវិញ។

ក្នុងដំណើរការដេញថ្លៃឡើងវិញ ទោះបីទទួលបានសំណុំឯកសារស្នើដេញថ្លៃចំនួនប៉ុន្មានក៏ដោយ ក៏ត្រូវតែដំណើរការបើកសំណុំឯកសារស្នើដេញថ្លៃទាំងនោះតាមកាលបរិច្ឆេទកំណត់។

**មាត្រា៤៨ .-**

គណៈកម្មាធិការលទ្ធកម្មនៃស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវពិនិត្យវាយតម្លៃលើសំណុំឯកសារស្នើដេញថ្លៃទាំងអស់ជាសម្ងាត់ទៅតាមលក្ខខណ្ឌនិងលក្ខណៈវិនិច្ឆ័យដែលមានចែងក្នុងឯកសារដេញថ្លៃ។ លក្ខខណ្ឌនិងលក្ខណៈវិនិច្ឆ័យបន្ថែមដែលមិនមានចែងក្នុងឯកសារដេញថ្លៃ មិនត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ក្នុងការវាយតម្លៃឡើយ។

នីតិវិធីវាយតម្លៃលើសំណុំឯកសារស្នើដេញថ្លៃ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៤៩ .-**

ការប្រគល់កិច្ចសន្យា ត្រូវបានធ្វើឡើងចំពោះអ្នកដេញថ្លៃណាដែលបានដាក់សំណុំឯកសារស្នើដេញថ្លៃ៖

- មានភាពឆ្លើយតបពេញលេញឬច្រើនទៅនឹងលក្ខខណ្ឌដែលបានកំណត់ក្នុងឯកសារដេញថ្លៃ
- មានតម្លៃដែលត្រូវបានវាយតម្លៃថាទាបជាងគេ និង
- មានភាពត្រឹមត្រូវបន្ទាប់ពីការត្រួតពិនិត្យលក្ខណសម្បត្តិតាមក្រោយ។

**មាត្រា៥០ .-**

មុននឹងចាប់ផ្តើមត្រួតពិនិត្យនិងវាយតម្លៃលើសំណុំឯកសារស្នើដេញថ្លៃនៃកិច្ចលទ្ធកម្មនីមួយៗ ប្រធាន អនុប្រធាន និងសមាជិកនៃគណៈកម្មាធិការលទ្ធកម្ម ក្រុមលទ្ធកម្ម ដែលត្រូវចូលរួមវាយតម្លៃប្រគល់កិច្ចសន្យា ត្រូវចុះហត្ថលេខាលើសេចក្តីប្រកាសស្តីពីក្រមសីលធម៌លទ្ធកម្មដូចមានចែងក្នុងជំពូកទី១១ នៃច្បាប់នេះ។

**មាត្រា៥១ .-**

បន្ទាប់ពីបញ្ចប់ការវាយតម្លៃជ្រើសរើសអ្នកដេញថ្លៃ ស្ថាប័នអនុវត្តលទ្ធកម្មត្រូវចេញសេចក្តីជូនដំណឹងស្តីពីការសម្រេចប្រគល់កិច្ចសន្យាទៅឱ្យអ្នកដេញថ្លៃឈ្នះ ដោយចម្លងជូនទៅគ្រប់អ្នកដេញថ្លៃចាញ់។ ស្ថាប័នអនុវត្តលទ្ធកម្មត្រូវទុករយៈពេល១០(ដប់)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីការចេញសេចក្តីជូនដំណឹងស្តីពីការសម្រេចប្រគល់កិច្ចសន្យា ដើម្បីអ្នកដេញថ្លៃចាញ់អាចស្នើសុំការបំភ្លឺឬប្តឹងតវ៉ាអំពីលទ្ធផលនៃការដេញថ្លៃ។

ប្រសិនបើមានការស្នើសុំបំភ្លឺជាលាយលក្ខណ៍អក្សរពីអ្នកដេញថ្លៃចាញ់អំពីមូលហេតុនៃបរាជ័យក្នុងការដេញថ្លៃនោះ ស្ថាប័នអនុវត្តលទ្ធកម្មត្រូវធ្វើការឆ្លើយបំភ្លឺជាលាយលក្ខណ៍អក្សរក្នុងរយៈពេល៥(ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានការស្នើសុំការបំភ្លឺ។

ចំពោះគម្រោងលទ្ធកម្មដែលមានទឹកប្រាក់ធំ មានចរិតជាយុទ្ធសាស្ត្រ និងមានលក្ខណៈបច្ចេកទេសដោយឡែកសម្រាប់គ្រប់គ្រង និងគម្រោងដែលមានវេទយិតភាពខ្ពស់ សេចក្ដីជូនដំណឹងស្ដីពីការសម្រេចប្រគល់កិច្ចសន្យា ត្រូវធ្វើឡើងក្រោយពេលមានការឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៥២ .-**

បន្ទាប់ពីរយៈពេល១០(ដប់)ថ្ងៃនៃថ្ងៃធ្វើការ នៃការចេញសេចក្ដីជូនដំណឹងស្ដីពីការសម្រេចប្រគល់កិច្ចសន្យា ប្រសិនបើមិនមានការប្ដឹងតវ៉ាណាមួយឬបន្ទាប់ពីការប្ដឹងតវ៉ាទាំងអស់ត្រូវបានដោះស្រាយ អង្គភាពលទ្ធកម្មនៃស្ថាប័នអនុវត្តលទ្ធកម្មត្រូវរៀបចំកិច្ចសន្យាលទ្ធកម្មដូចមានចែងក្នុងជំពូកទី៩ នៃច្បាប់នេះ និងត្រូវអញ្ជើញអ្នកដេញថ្លៃឈ្នះមកចុះហត្ថលេខាលើកិច្ចសន្យា ដោយភ្ជាប់មកជាមួយនូវឯកសារប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា។

ក្នុងករណីមានការប្ដឹងតវ៉ាក្នុងអំឡុងដូចបានកំណត់ក្នុងកថាខណ្ឌខាងលើ ស្ថាប័នអនុវត្តលទ្ធកម្មត្រូវចាត់វិធានការដោះស្រាយជាបន្ទាន់។ ប្រសិនបើមិនអាចដោះស្រាយបញ្ចប់ការប្ដឹងតវ៉ា ស្ថាប័នអនុវត្តលទ្ធកម្មត្រូវស្នើសុំការសម្រេចពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៥៣ .-**

ការចុះហត្ថលេខាលើកិច្ចសន្យាលទ្ធកម្ម ត្រូវធ្វើឡើងរវាងប្រធានស្ថាប័នអនុវត្តលទ្ធកម្មឬថ្នាក់ដឹកនាំបន្ទាប់តាមការប្រគល់សិទ្ធិដូចមានចែងក្នុងមាត្រា៨ នៃច្បាប់នេះ និងអ្នកដេញថ្លៃឈ្នះ។

**មាត្រា៥៤ .-**

ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវចាត់ចែងគ្រប់គ្រងកិច្ចសន្យាដើម្បីធានាឱ្យការអនុវត្តកិច្ចសន្យាប្រព្រឹត្តទៅបានត្រឹមត្រូវស្របតាមលក្ខខណ្ឌដូចមានចែងក្នុងកិច្ចសន្យា។

**មាត្រា៥៥ .-**

ប្រភេទនៃគម្រោងលទ្ធកម្មដែលមានទឹកប្រាក់ធំ មានចរិតជាយុទ្ធសាស្ត្រ និងមានលក្ខណៈបច្ចេកទេសដោយឡែកសម្រាប់គ្រប់គ្រង និងគម្រោងដែលមានវេទយិតភាពខ្ពស់ ដែលត្រូវស្នើសុំការពិនិត្យនិងសម្រេចពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៥៦ .-**

ការអនុវត្តលទ្ធកម្មសាធារណៈ ត្រូវអនុលោមតាមបរិបទនៃលទ្ធកម្មប្រកបដោយចីរភាព។ លទ្ធកម្មប្រកបដោយចីរភាព តម្រូវឱ្យមានលក្ខណៈបច្ចេកទេស លក្ខខណ្ឌតម្រូវ និងលក្ខណវិនិច្ឆ័យ ដោយផ្ដល់អាទិភាពដល់ការការពារបរិស្ថាននិងការគ្រប់គ្រងផលប៉ះពាល់លើសង្គម សេដ្ឋកិច្ច។

លក្ខខណ្ឌ វិធាន និងនីតិវិធីសម្រាប់ការអនុវត្តលទ្ធកម្មប្រកបដោយចីរភាព ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៥៧ .-**

លទ្ធកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវបានបង្កើតឡើងជាឧបករណ៍សម្រាប់កសាងប្រព័ន្ធនិងដើម្បីសម្រួលដល់ការអនុវត្តលទ្ធកម្មសាធារណៈ។

គោលការណ៍សំខាន់ៗនៃប្រព័ន្ធលទ្ធកម្មអេឡិចត្រូនិកមានជាអាទិ៍៖

- ការប្រាស្រ័យទាក់ទងគ្នាតាមអេឡិចត្រូនិកមានតម្លៃស្មើគ្នាទៅនឹងការប្រាស្រ័យទាក់ទងគ្នាតាមក្រដាសស្នាម
- តម្រូវការនានាដើម្បីធានានិរន្តរភាពនិងការផ្សាភ្ជាប់រវាងផ្នែកទន់និងផ្នែករឹងដែលប្រើប្រាស់សម្រាប់គាំទ្រដល់ប្រព័ន្ធលទ្ធកម្មអេឡិចត្រូនិក
- តម្រូវការនានាដើម្បីធានាភាពត្រឹមត្រូវ សុចរិតភាព និងការសម្ងាត់ពាក់ព័ន្ធនឹងការបញ្ជូននិងការរក្សាទុកឯកសារពាក់ព័ន្ធ។

វិធាននិងនីតិវិធីនៃការអនុវត្តលទ្ធកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៩
## កិច្ចសន្យាលទ្ធកម្ម

**មាត្រា៥៨ .-**

ការរៀបចំកិច្ចសន្យាលទ្ធកម្ម ត្រូវអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះនិងស្របតាមលក្ខខណ្ឌដែលមានចែងក្នុងឯកសារដេញថ្លៃ ព្រមទាំងស្របតាមគំរូកិច្ចសន្យាដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៥៩ .-**

កិច្ចសន្យាលទ្ធកម្ម ត្រូវធ្វើជាភាសាខ្មែរ។ ក្នុងករណីចាំបាច់ កិច្ចសន្យាអាចសរសេរជាភាសាបរទេសដោយត្រូវបកប្រែចេញពីកិច្ចសន្យាជាភាសាខ្មែរ។ ក្នុងករណីមានខ្លឹមសារមិនស្របគ្នារវាងភាសាខ្មែរនិងភាសាបរទេស កិច្ចសន្យាជាភាសាខ្មែរជាឯកសារផ្លូវការ។

**មាត្រា៦០ .-**

គ្រប់កិច្ចសន្យាលទ្ធកម្ម ត្រូវទូទាត់ជាប្រាក់រៀល លើកលែងតែកិច្ចសន្យាសម្រាប់អនុវត្តគម្រោងលទ្ធកម្មនៅក្រៅប្រទេស ដែលអាចអនុញ្ញាតឱ្យទូទាត់ជារូបិយបណ្ណបរទេស។

**មាត្រា៦១ .-**

លក្ខណៈបច្ចេកទេសទំនិញ សំណង់ សេវាកម្ម និងលក្ខខណ្ឌយោងការងារនៃសេវាទីប្រឹក្សាដែលចែងក្នុងកិច្ចសន្យាត្រូវតែដូចគ្នានឹងលក្ខណៈបច្ចេកទេសនិងលក្ខខណ្ឌយោងការងារដែលមានចែងក្នុងឯកសារដេញថ្លៃ។

**មាត្រា៦២ .-**

តម្លៃកិច្ចសន្យា មិនត្រូវលើសពីតម្លៃដេញឈ្នះក្រោយការកែតម្រូវលេខគណិត។ តម្លៃកិច្ចសន្យាជាតម្លៃថេរក្នុងអំឡុងអនុវត្តកិច្ចសន្យា លើកលែងតែក្នុងកាលៈទេសៈពិសេស ជាអាទិ៍វិបត្តិសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលបង្កឱ្យមានអតិផរណាខ្ពស់និងករណីប្រធានស័ក្តិ។ កាលៈទេសៈពិសេសដែលតម្លៃកិច្ចសន្យាអាចកែប្រែបាន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៦៣ .-**

រាល់កិច្ចសន្យា ត្រូវមានប្រាក់កក់ធានាការអនុវត្តកិច្ចសន្យាលើកលែងតែកិច្ចសន្យាដែលទទួលបានតាមរយៈវិធីសាស្ត្រលទ្ធកម្មស្នងតម្លៃ កិច្ចសន្យាជាមួយនឹងក្រុមហ៊ុនទីប្រឹក្សាឬទីប្រឹក្សាឯកត្តជន កិច្ចសន្យាជាមួយនឹងអង្គភាពជំនាញនៃស្ថាប័នរដ្ឋ និងកិច្ចសន្យាជាមួយនឹងសហគមន៍។ អ្នកដេញថ្លៃឈ្នះ ត្រូវកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យាមុនពេលកិច្ចសន្យាចូលជាធរមាន។ ចំនួនប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា ត្រូវស្មើនឹងចំនួនដែលបានចែងក្នុងឯកសារដេញថ្លៃ។

ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា ត្រូវរឹបអូសបង់ចូលថវិការដ្ឋ ប្រសិនបើអ្នកដេញថ្លៃឈ្នះបដិសេធការអនុវត្តកិច្ចសន្យាដែលបានចូលជាធរមានឬបំពានលក្ខខណ្ឌកិច្ចសន្យា ហើយត្រូវស្ថាប័នអនុវត្តលទ្ធកម្មបញ្ឈប់កិច្ចសន្យាមុនកាលកំណត់។

ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា ត្រូវមានសុពលភាពរហូតដល់ចប់រយៈពេលធានាគុណភាពទំនិញ សំណង់ ឬសេវាកម្ម។

បែបបទនិងនីតិវិធីនៃការកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៦៤ .-**

ការប្រគល់ទទួល ត្រូវធ្វើឡើងឱ្យបានត្រឹមត្រូវតាមទំហំ បរិមាណ គុណភាព លក្ខណៈបច្ចេកទេស និងស្របតាមពេលដែលបានកំណត់ក្នុងកាលវិភាគប្រគល់ទទួលដូចមានចែងក្នុងកិច្ចសន្យា និងត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់គណៈកម្មការប្រគល់ទទួល។

ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មការប្រគល់ទទួល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៦៥ .-**

ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវរៀបចំការទូទាត់តម្លៃកិច្ចសន្យាជូនអ្នកផ្គត់ផ្គង់ឬអ្នកទទួលការដោយផ្អែកលើលក្ខខណ្ឌទូទាត់ក្នុងកិច្ចសន្យា។

**មាត្រា៦៦ .-**

អ្នកដេញថ្លៃឈ្នះ អាចចុះកិច្ចសន្យាបន្តដើម្បីផ្តល់ផ្នែកខ្លះនៃគម្រោងទៅឱ្យភាគីទីបី ប៉ុន្តែត្រូវមានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនរបស់ស្ថាប័នអនុវត្តលទ្ធកម្ម។ ក្នុងករណីដែលកិច្ចសន្យាលទ្ធកម្មត្រូវពិនិត្យនិងសម្រេចដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្ថាប័នអនុវត្តលទ្ធកម្មត្រូវស្នើសុំការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ក្នុងករណីដែលអ្នកដេញថ្លៃឈ្នះ ត្រូវបានអនុញ្ញាតឱ្យចុះកិច្ចសន្យាបន្តជាមួយភាគីទីបី អ្នកដេញថ្លៃឈ្នះត្រូវទទួលខុសត្រូវចំពោះមុខស្ថាប័នអនុវត្តលទ្ធកម្មលើការអនុវត្តកិច្ចសន្យាទាំងមូល។

**មាត្រា៦៧ .-**

រាល់ប្រតិបត្តិការលទ្ធកម្មសាធារណៈ ត្រូវស្ថិតក្រោមនីតិវិធីនៃរបបសារពើពន្ធជាធរមាននិងទទួលបានការលើកលែងនិងការអនុគ្រោះនានាស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី១០
## ការត្រួតពិនិត្យកិច្ចលទ្ធកម្ម សវនកម្ម និងអធិការកិច្ចហិរញ្ញវត្ថុ

**មាត្រា៦៨ .-**

លទ្ធកម្មសាធារណៈ ជាកម្មវត្ថុនៃការត្រួតពិនិត្យកិច្ចលទ្ធកម្មតាមក្រោយដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមានដទៃទៀត។

វិធាននិងនីតិវិធីនៃការត្រួតពិនិត្យកិច្ចលទ្ធកម្មតាមក្រោយ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៦៩ .-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានសិទ្ធិធ្វើការត្រួតពិនិត្យដល់កន្លែងមិនឱ្យដឹងមុនក្នុងអំឡុងនៃការអនុវត្តកិច្ចលទ្ធកម្ម ក្នុងករណីពិនិត្យឃើញថាមានភាពមិនប្រក្រតីកើតឡើង ជាអាទិ៍ការសង្ស័យឬបណ្ដឹងតវ៉ាដែលមានមូលដ្ឋានជាក់លាក់នៅក្នុងដំណាក់កាលណាមួយនៃការអនុវត្តលទ្ធកម្មសាធារណៈ សំដៅធានាអនុលោមភាពនិងប្រសិទ្ធភាពក្នុងការអនុវត្តកិច្ចលទ្ធកម្ម។

វិធាននិងនីតិវិធីនៃការត្រួតពិនិត្យដល់កន្លែងមិនឱ្យដឹងមុន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៧០ .-**

កិច្ចលទ្ធកម្មសាធារណៈរបស់ស្ថាប័នអនុវត្តលទ្ធកម្ម គឺជាកម្មវត្ថុនៃសវនកម្មនិងអធិការកិច្ចហិរញ្ញវត្ថុស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី១១
## ក្រមសីលធម៌លទ្ធកម្ម

**មាត្រា៧១ .-**

ក្នុងការអនុវត្តកិច្ចលទ្ធកម្ម ប្រធាន អនុប្រធាន និងសមាជិកនៃគណៈកម្មាធិការលទ្ធកម្ម ក្រុមលទ្ធកម្ម មន្ត្រីលទ្ធកម្ម អ្នកដេញថ្លៃ ព្រមទាំងមន្ត្រីនិងបុគ្គលដទៃទៀត ដែលមានការពាក់ព័ន្ធនឹងកិច្ចលទ្ធកម្មត្រូវគោរពតាមក្រមសីលធម៌លទ្ធកម្ម។

ក្រមសីលធម៌លទ្ធកម្ម ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី១២
## ការដោះស្រាយបណ្ដឹងតវ៉ានិងវិវាទ

**មាត្រា៧២**

អ្នកដេញថ្លៃ មានសិទ្ធិប្ដឹងតវ៉ាទៅស្ថាប័នអនុវត្តលទ្ធកម្មដោយដាក់ពាក្យប្ដឹងតវ៉ាជាលាយលក្ខណ៍អក្សរពាក់ព័ន្ធនឹងភាពមិនប្រក្រតីណាមួយកើតឡើងនៅក្នុងដំណាក់កាលនីមួយៗនៃកិច្ចលទ្ធកម្មមុនពេលចុះកិច្ចសន្យា។

សាមីស្ថាប័នអនុវត្តលទ្ធកម្ម មានសមត្ថកិច្ចទទួលពិនិត្យនិងដោះស្រាយបណ្ដឹងតវ៉ារបស់អ្នកដេញថ្លៃ។

អ្នកប្ដឹងដែលមិនយល់ព្រមនឹងសេចក្ដីសម្រេចរបស់សាមីស្ថាប័នអនុវត្តលទ្ធកម្ម អាចប្ដឹងទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បីពិនិត្យនិងដោះស្រាយ។

បែបបទនិងនីតិវិធីនៃការប្ដឹងនិងការដោះស្រាយបណ្ដឹងនៅស្ថាប័នអនុវត្តលទ្ធកម្មនិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៧៣ .-**

អ្នកប្ដឹងដែលមិនយល់ព្រមនឹងសេចក្ដីសម្រេចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចប្ដឹងទៅតុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៧៤ .-**

វិវាទទាំងឡាយណាដែលកើតឡើងក្នុងអំឡុងនៃការអនុវត្តកិច្ចសន្យាលទ្ធកម្ម គូភាគីនៃកិច្ចសន្យាត្រូវដោះស្រាយតាមបទប្បញ្ញត្តិនិងយន្តការដែលមានចែងក្នុងកិច្ចសន្យា។

## ជំពូកទី១៣

## ទោសប្បញ្ញត្តិ

**មាត្រា៧៥ .-**

ទណ្ឌកម្មក្នុងច្បាប់នេះ រួមមានទណ្ឌកម្មរដ្ឋបាលនិងទណ្ឌកម្មព្រហ្មទណ្ឌ។

ក. ទណ្ឌកម្មរដ្ឋបាលរួមមាន៖

- ការព្រមានជាលាយលក្ខណ៍អក្សរ
- ការបញ្ឈប់ជាបន្ទាន់ពីក្នុងលទ្ធកម្មសាធារណៈ
- ការផ្អាកសកម្មភាព ការព្យួរ ការដកហូត ឬការលុបចោលកិច្ចសន្យា
- ការដកឈ្មោះចេញពីបញ្ជីអ្នកដេញថ្លៃ
- ការចុះក្នុងបញ្ជីខ្មៅអ្នកដេញថ្លៃ។

ការព្រមានជាលាយលក្ខណ៍អក្សរ ការដកឈ្មោះចេញពីបញ្ជីអ្នកដេញថ្លៃ ការបញ្ឈប់ជាបន្ទាន់ពីក្នុងលទ្ធកម្មសាធារណៈ និងការផ្អាកសកម្មភាព ការព្យួរ ការដកហូត ឬការលុបចោលកិច្ចសន្យា ជាសមត្ថកិច្ចរបស់ស្ថាប័នអនុវត្តលទ្ធកម្ម។

ការចុះក្នុងបញ្ជីខ្មៅអ្នកដេញថ្លៃ ជាសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

អំពើល្មើសដែលត្រូវរងទណ្ឌកម្មរដ្ឋបាល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ក្នុងករណីដែលបុគ្គលណាដែលមិនសុខចិត្តនឹងសេចក្ដីសម្រេចអំពីទណ្ឌកម្មរដ្ឋបាលដូចមានចែងក្នុងច្បាប់នេះ សាមីខ្លួនមានសិទ្ធិប្ដឹងទៅតុលាការក្នុងរយៈពេលយ៉ាងយូរ៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានលិខិតជូនដំណឹងអំពីសេចក្ដីសម្រេចនេះ។

ខ. ទណ្ឌកម្មព្រហ្មទណ្ឌរួមមាន៖

- ពិន័យជាប្រាក់

- ទោសដាក់ពន្ធនាគារ។

**មាត្រា៧៦ .-**

អ្នករាជការសាធារណៈគ្រប់លំដាប់ថ្នាក់ ពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត ដែលបានប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់នេះឬត្រូវបានរកឃើញថា មានការពាក់ព័ន្ធនឹងការប្រព្រឹត្តមិនប្រក្រតីនៅក្នុងដំណើរការលទ្ធកម្មសាធារណៈ ត្រូវទទួលទណ្ឌកម្មខាងរដ្ឋបាលស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។ ទណ្ឌកម្មខាងរដ្ឋបាលនេះមិនមែនជាឧបសគ្គសម្រាប់ការចោទប្រកាន់និងការផ្តន្ទាទោសព្រហ្មទណ្ឌស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជាឡើយ។

**មាត្រា៧៧ .-**

អ្នកដេញថ្លៃ អ្នកទទួលការ ឬអ្នកផ្គត់ផ្គង់ដែលត្រូវបានរកឃើញថា មានការពាក់ព័ន្ធនឹងអំពើពុករលួយ អំពើបន្លំ អំពើឃុបឃិត អំពើបង្ខិតបង្ខំ អំពើហិង្សា ឬអំពើសម្លុតគំរាមនៅក្នុងដំណើរការលទ្ធកម្មសាធារណៈ ឬផ្តល់ភស្តុតាងក្លែងបន្លំ ឬមិនត្រឹមត្រូវក្នុងពេលដាក់ពាក្យប្តឹងតវ៉ានៅក្នុងដំណើរការលទ្ធកម្មសាធារណៈ ត្រូវបញ្ឈប់ជាបន្ទាន់ពីក្នុងលទ្ធកម្មសាធារណៈដែលកំពុងដំណើរការឬលុបកិច្ចសន្យាដែលកំពុងអនុវត្តភ្លាមៗដោយស្ថាប័នអនុវត្តលទ្ធកម្ម។ ទណ្ឌកម្មនេះមិនមែនជាឧបសគ្គសម្រាប់ការដាក់ទណ្ឌកម្មរដ្ឋបាលផ្សេងទៀតដែលជាសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ហើយក៏មិនមែនជាឧបសគ្គសម្រាប់ការចោទប្រកាន់និងការផ្តន្ទាទោសព្រហ្មទណ្ឌស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជាឡើយ។

**មាត្រា៧៨ .-**

បុគ្គលដែលប្រព្រឹត្តនៅក្នុងដំណើរការលទ្ធកម្មសាធារណៈតាមការដេញថ្លៃ ដើម្បីកម្ចាត់អ្នកដេញថ្លៃឬធ្វើឱ្យខូចការដេញថ្លៃដោយអំណោយ ការសន្យា ការព្រមព្រៀង អត្ថប្រយោជន៍អ្វីមួយ ឬតាមគ្រប់មធ្យោបាយទុច្ចរិតដទៃទៀត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំ ទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី៤ ០០០ ០០០(បួនលាន)រៀល ទៅ ១០ ០០០ ០០០(ដប់លាន)រៀល។

**មាត្រា៧៩ .-**

បុគ្គលដែលប្រព្រឹត្តនៅក្នុងដំណើរការលទ្ធកម្មសាធារណៈតាមការដេញថ្លៃ ដើម្បីធ្វើជាឧបសគ្គដល់សេរីភាពនៃការដេញថ្លៃដោយហិង្សា ដោយការបង្ខិតបង្ខំ ឬដោយការសម្លុតគំរាម ដែលអនុវត្តទៅលើអ្នកដេញថ្លៃ អ្នកផ្គត់ផ្គង់ ឬអ្នកទទួលការ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២(ពីរ)ឆ្នាំ ទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី៨ ០០០ ០០០(ប្រាំបីលាន)រៀល ទៅ២០ ០០០ ០០០(ម្ភៃលាន)រៀល។

**មាត្រា៨០ .-**

បទល្មើសដែលមានចែងក្នុងមាត្រា៧៨និងមាត្រា៧៩ នៃច្បាប់នេះ ជាបទល្មើសពុករលួយដែលស្ថិតនៅក្រោមសមត្ថកិច្ចផ្តាច់មុខតែមួយគត់របស់អង្គភាពប្រឆាំងអំពើពុករលួយក្នុងការស៊ើបអង្កេតនិងកសាងសំណុំរឿងពុករលួយ [illegible]

អង្គភាពនិងបុគ្គលដទៃទៀតដែលបានដឹងពីបទល្មើសពុករលួយទាំងឡាយណាដែលមានចែងក្នុងច្បាប់នេះនិងក្នុងច្បាប់និងបទប្បញ្ញត្តិជាធរមានដទៃទៀតនៃព្រះរាជាណាចក្រកម្ពុជា ត្រូវប្តឹងទៅអង្គភាពឬការិយាល័យរាជធានី ខេត្ត ប្រឆាំងអំពើពុករលួយអំពីរឿងហេតុនៃបទល្មើសទាំងនេះ។

**មាត្រា៨១ .-**

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងក្នុងមាត្រា៧៨និងមាត្រា៧៩ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងការប្រព្រឹត្តបទមជ្ឈិមនោះបានសម្រេចដែរ។

**មាត្រា៨២ .-**

ចំពោះបទមជ្ឈិមដែលមានចែងក្នុងមាត្រា៧៨និងមាត្រា៧៩ នៃច្បាប់នេះ ទោសបន្ថែមមួយឬច្រើនដូចមានចែងក្នុងមាត្រា៥៣(ប្រភេទនៃទោសបន្ថែម) នៃក្រមព្រហ្មទណ្ឌអាចត្រូវបានប្រកាស។

**មាត្រា៨៣ .-**

នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌចំពោះបទមជ្ឈិមដែលមានចែងក្នុងមាត្រា៧៨និងមាត្រា៧៩ នៃច្បាប់នេះ។

នីតិបុគ្គលដែលប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា៧៨និងមាត្រា៧៩ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី៤០ ០០០ ០០០(សែសិបលាន)រៀល ទៅ២០០ ០០០ ០០០(ពីររយលាន)រៀល ព្រមទាំងទោសបន្ថែមមួយឬច្រើនដូចមានចែងក្នុងមាត្រា១៦៨(ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ។

**មាត្រា៨៤ .-**

ការអនុវត្តបទប្បញ្ញត្តិនៃជំពូកទី១៣ នៃច្បាប់នេះ មិនរារាំងដល់ការអនុវត្តច្បាប់ព្រហ្មទណ្ឌផ្សេងទៀត ក្នុងករណីដែលអំពើដែលកំណត់ថាជាបទល្មើសដែលមានចែងក្នុងច្បាប់នេះ ជាបទល្មើសដែលបានបញ្ញត្តក្នុងច្បាប់ព្រហ្មទណ្ឌផ្សេងទៀត។

## ជំពូកទី១៤

## អន្តរប្បញ្ញត្តិ

**មាត្រា៨៥ .-**

លិខិតបទដ្ឋានគតិយុត្តទាំងឡាយណា ដែលពាក់ព័ន្ធការអនុវត្តច្បាប់ស្តីពីលទ្ធកម្មសាធារណៈដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ និងដែលពាក់ព័ន្ធនឹងលទ្ធកម្មសាធារណៈដែលនៅជាធរមាន ត្រូវមានអានុភាពអនុវត្តបន្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួសស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

## ជំពូកទី១៥
## អវសានប្បញ្ញត្តិ

**មាត្រា៨៦ .-**

ច្បាប់ស្ដីពីលទ្ធកម្មសាធារណៈដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៨៧ .-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃ អង្គារ ១២ កើត ខែ ពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ២០២៣

[illegible]

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្ដលេខា
**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន
សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

## ឧបសម្ព័ន្ធនៃច្បាប់ស្តីពីលទ្ធកម្មសាធារណៈ

## សទ្ទានុក្រម

- **កញ្ចប់លទ្ធកម្ម** សំដៅដល់ការប្រមូលផ្តុំមុខសញ្ញាលទ្ធកម្មដែលមានប្រភេទដូចគ្នា លក្ខណៈដូចគ្នា ឬប្រហាក់ប្រហែលគ្នាបញ្ចូលក្នុងក្រុមតែមួយសម្រាប់ធ្វើលទ្ធកម្មតែមួយលើក។

- **ការដេញថ្លៃ** សំដៅដល់ដំណើរការលទ្ធកម្មសាធារណៈដែលសំណុំឯកសារស្នើដេញថ្លៃត្រូវបានដាក់ ទទួល និងវាយតម្លៃសម្រាប់គោលបំណងប្រគល់កិច្ចសន្យា។

- **ការត្រួតពិនិត្យកិច្ចលទ្ធកម្មតាមក្រោយ** សំដៅដល់ការត្រួតពិនិត្យដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលើអនុលោមភាពនៃការអនុវត្តកិច្ចលទ្ធកម្មដែលបានអនុវត្តរួចរបស់ស្ថាប័នអនុវត្តលទ្ធកម្ម ដើម្បីតាមដាននិងវាយតម្លៃលើការអនុវត្តកិច្ចលទ្ធកម្ម និងតម្រូវការសម្រាប់កែលម្អនិងបង្កើនប្រសិទ្ធភាពនិងសមត្ថភាពក្នុងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

- **ការប្រកួតប្រជែង** សំដៅដល់ការប្រើប្រាស់នីតិវិធីលទ្ធកម្មដែលមានការចូលរួមពីអ្នកដេញថ្លៃ ដើម្បីជ្រើសរើសសំណុំឯកសារស្នើដេញថ្លៃដែលឆ្លើយតបពេញលេញឬសមស្របជាងគេនិងមានតម្លៃល្អបំផុត។

- **ការសន្សំសំចៃ** សំដៅដល់ការប្រើប្រាស់ថវិកាសមស្របបំផុតក្នុងចំណាយ ដែលក្នុងនោះត្រូវពិចារណាផងដែរលើកត្តាពាក់ព័ន្ធនានាក្នុងការអនុវត្តនីតិវិធីលទ្ធកម្មដើម្បីជ្រើសរើសអ្នកផ្គត់ផ្គង់ឬអ្នកទទួលការ។

- **កិច្ចលទ្ធកម្ម** សំដៅដល់ដំណើរការលទ្ធកម្មសាធារណៈចាប់ពីពេលរៀបចំឯកសារដេញថ្លៃរហូតដល់ពេលទទួលបានទំនិញ សំណង់ សេវាកម្ម ឬសេវាទីប្រឹក្សា។

- **ក្រមសីលធម៌លទ្ធកម្ម** សំដៅដល់ក្រមដែលអ្នកចូលរួមពាក់ព័ន្ធនឹងលទ្ធកម្មសាធារណៈត្រូវយល់ដឹងនិងអនុវត្តដោយស្មោះត្រង់តាមបទប្បញ្ញត្តិគតិយុត្តជាធរមាននិងអនុវត្តឱ្យបានត្រឹមត្រូវតាមតួនាទីនិងមុខងាររបស់ខ្លួន។

- **គណនេយ្យភាព** សំដៅដល់ការទទួលខុសត្រូវរបស់ស្ថាប័នអនុវត្តលទ្ធកម្ម ក្នុងការធ្វើសេចក្តីសម្រេចនិងចាត់វិធានការក្នុងអំឡុងដំណើរការលទ្ធកម្មសាធារណៈ។

- **ចីរភាព** សំដៅដល់ការកាត់បន្ថយនៃផលប៉ះពាល់ដែលអាចកើតមានទៅលើបរិស្ថាន ប្រព័ន្ធអេកូឡូស៊ី និងការបន្តនៃការអភិវឌ្ឍសង្គម សេដ្ឋកិច្ច។

- **តម្លាភាព** សំដៅដល់ការទទួលបាននូវព័ត៌មានដែលពាក់ព័ន្ធនឹងលទ្ធកម្មសាធារណៈដោយចំហនិងសិទ្ធិចូលរួមក្នុងដំណើរការលទ្ធកម្មសាធារណៈតាមវិធីសាស្ត្រនិងនីតិវិធីលទ្ធកម្មសាធារណៈ។

- **ទីប្រឹក្សា** សំដៅដល់ក្រុមហ៊ុនទីប្រឹក្សាឬទីប្រឹក្សាឯកត្តជនដែលមានមុខរបរផ្តល់សេវាផ្នែកបញ្ញា។ ក្រុមហ៊ុនទីប្រឹក្សាអាចជាក្រុមហ៊ុនពាណិជ្ជកម្មឬនីតិបុគ្គលផ្សេងទៀត។

- **ទំនិញ** សំដៅដល់វត្ថុរាវ រឹង និងឧស្ម័នដែលមានតម្លៃឬផលប្រយោជន៍សេដ្ឋកិច្ច ដូចជាគ្រឿងចក្រ ឧបករណ៍ សម្ភារៈ ផ្គត់ផ្គង់ គ្រឿងឧបភោគបរិភោគ ឱសថ និងផលិតផលផ្សេងៗ រួមទាំងអគ្គិសនីផងដែរ។

- **បញ្ជីខ្មៅ** សំដៅដល់បញ្ជីហាមឃាត់ការចូលរួមរបស់អ្នកដេញថ្លៃក្នុងដំណើរការលទ្ធកម្មសាធារណៈដែលសម្រេចដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

- **ប្រសិទ្ធភាព** សំដៅដល់ចំណាយចំគោលដៅចំពោះមុខចំណាយដែលត្រូវអនុវត្តនីតិវិធីលទ្ធកម្ម។

- **ផែនការលទ្ធកម្ម** សំដៅដល់ការកំណត់ពីតម្រូវការរបស់ស្ថាប័នអនុវត្តលទ្ធកម្មក្នុងរយៈពេលជាក់លាក់និងកំណត់ពីពេលនិងនីតិវិធីសម្រាប់អនុវត្តកិច្ចលទ្ធកម្ម ក្នុងគោលបំណងបំពេញបាននូវតម្រូវការប្រើប្រាស់នៅពេលត្រូវការ។

- **មន្ត្រីលទ្ធកម្ម** សំដៅដល់ប្រធាន អនុប្រធាន និងមន្ត្រីទាំងអស់របស់អង្គភាពលទ្ធកម្មនៃស្ថាប័នអនុវត្តលទ្ធកម្ម។

- **មុខសញ្ញាលទ្ធកម្ម** សំដៅដល់មុខទំនិញ សំណង់ សេវាកម្ម ឬសេវាទីប្រឹក្សាដែលជាកម្មវត្ថុនៃការដេញថ្លៃ ពិគ្រោះថ្លៃ ស្ទង់តម្លៃ ឬការចរចាថ្លៃ។

- **លទ្ធកម្ម** សំដៅដល់ការទិញឬការរកបាននូវទំនិញ សំណង់ សេវាកម្ម ឬសេវាទីប្រឹក្សាតាមរយៈវិធីសាស្ត្រដែលមានចែងក្នុងច្បាប់នេះ។

- **លទ្ធកម្មប្រកបដោយចីរភាព** សំដៅដល់ដំណើរការនៃកិច្ចលទ្ធកម្មដោយបានគិតគូរអំពីការកាត់បន្ថយផលប៉ះពាល់ដែលអាចកើតមានឡើងដល់បរិស្ថាន ប្រព័ន្ធអេកូឡូស៊ី និងការអភិវឌ្ឍសហគមន៍ប្រកបដោយនិរន្តរភាព។

- **លទ្ធកម្មសាធារណៈ** សំដៅដល់កិច្ចលទ្ធកម្មដែលធ្វើឡើងដោយស្ថាប័នអនុវត្តលទ្ធកម្ម/អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ។

- **ស្ថាប័នអនុវត្តលទ្ធកម្ម** សំដៅដល់ក្រសួង ស្ថាប័ន អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត ដែលអនុវត្តលទ្ធកម្មសាធារណៈ។

- **សុចរិតភាព** សំដៅដល់ការអនុវត្តគោលការណ៍គ្រឹះនិងក្រមសីលធម៌វិជ្ជាជីវៈដែលមិនអាចរំលោភបំពានបាននៃលទ្ធកម្មសាធារណៈ ទាំងក្របខណ្ឌច្បាប់និងស្ថាប័ន។

- **សេវាកម្ម** សំដៅដល់សកម្មភាពដែលពាក់ព័ន្ធនឹងការប្រើប្រាស់កម្លាំងមនុស្ស គ្រឿងបរិក្ខារ ឬបច្ចេកវិទ្យាដែលនាំមកនូវផលប្រយោជន៍ដល់ស្ថាប័នសាធារណៈ ប៉ុន្តែមិនរាប់បញ្ចូលការងារសាងសង់និងសេវាទីប្រឹក្សាទេ។

- **សេវាទីប្រឹក្សា** សំដៅដល់សេវាជំនាញការដែលផ្តល់ដោយក្រុមហ៊ុនទីប្រឹក្សាឬទីប្រឹក្សាឯកត្តជនដែលពាក់ព័ន្ធនឹងគម្រោងណាមួយឬសម្រាប់ការពង្រឹងពង្រីកស្ថាប័នឬបង្កើនសមត្ថភាព។

- **សំណង់** សំដៅដល់រាល់សកម្មភាពដែលពាក់ព័ន្ធនឹងការងារសាងសង់ ការងារជួសជុល ការធ្វើឡើងជាថ្មី ការដំឡើង ការជីក ការបូម និងការងារប្រហាក់ប្រហែល ដែលបង្កើតឱ្យមានការប្រើប្រាស់កម្លាំងពលកម្មគ្រឿងម៉ាស៊ីន បរិក្ខារ និងបច្ចេកវិទ្យា។

- **សំណុំឯកសារស្នើដេញថ្លៃ** សំដៅដល់សំណុំឯកសាររួមមានឯកសារដេញថ្លៃដែលបានបំពេញដោយអ្នកដេញថ្លៃនិងឯកសារភ្ជាប់មួយចំនួនទៀតដូចមានតម្រូវក្នុងឯកសារដេញថ្លៃ ដែលអ្នកដេញថ្លៃបានដាក់នៅស្ថាប័នអនុវត្តលទ្ធកម្មសម្រាប់គោលបំណងផ្គត់ផ្គង់ទំនិញ ទទួលការសំណង់ ផ្តល់សេវាកម្ម ឬសេវាទីប្រឹក្សា។

- **សក្តិសិទ្ធិភាព** សំដៅដល់បរិសាបេភាពឬកម្រិតដែលសម្រេចបាននូវលទ្ធផលចុងក្រោយឆ្លើយតបនឹងគោលបំណងស្នូលនៃការអនុវត្តលទ្ធកម្មសាធារណៈ។

- **អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ** សំដៅដល់អង្គភាពថវិកាដែលអាណាប័កដើមខ្សែបានប្រគល់សិទ្ធិអំណាចពេញលេញក្នុងការបញ្ជាចំណូល ចំណាយរបស់អង្គភាព ដោយមិនតម្រូវឱ្យឆ្លងអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ និងការត្រួតពិនិត្យនិងសម្រេចពីអាណាប័កដើមខ្សែ។

- **អំពើឃុបឃិត** សំដៅដល់ផែនការឬការរៀបចំឡើងរវាងអ្នកដេញថ្លៃពីរឬច្រើននាក់ ដើម្បីបង្កើតតម្លៃដេញថ្លៃសិប្បនិម្មិតគ្មានលក្ខណៈប្រកួតប្រជែងពិតប្រាកដ ឬធ្វើឱ្យមានឥទ្ធិពលលើសកម្មភាពរបស់ភាគីណាមួយក្នុងដំណើរការលទ្ធកម្មសាធារណៈឬធ្វើឱ្យមានការជះឥទ្ធិពលលើការអនុវត្តកិច្ចសន្យា។

- **អំពើបង្ខិតបង្ខំ** សំដៅដល់ការហាមឃាត់ឬការគម្រាមកំហែងដោយផ្ទាល់ឬដោយប្រយោលធ្វើឱ្យមានគ្រោះថ្នាក់ដល់បុគ្គលឬទ្រព្យសម្បត្តិរបស់បុគ្គល ដើម្បីធ្វើឱ្យមានឥទ្ធិពលដល់ការចូលរួមក្នុងដំណើរការលទ្ធកម្មសាធារណៈរបស់បុគ្គលនោះឬធ្វើឱ្យមានការជះឥទ្ធិពលលើការអនុវត្តកិច្ចសន្យា។

- **អំពើបន្លំ** សំដៅដល់ការបកស្រាយបំភ្លៃហេតុការណ៍ដើម្បីធ្វើឱ្យមានឥទ្ធិពលលើដំណើរការលទ្ធកម្មសាធារណៈ។

- **អ្នកដេញថ្លៃ** សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គលដែលមានបំណងចូលរួមក្នុងលទ្ធកម្មសាធារណៈនិងបានដាក់សំណុំឯកសារស្នើដេញថ្លៃឬការស្នើបញ្ជាក់ពីចំណាប់អារម្មណ៍។

- **អ្នកដេញថ្លៃនាំមុខ** សំដៅដល់អ្នកដេញថ្លៃដែលបានចូលរួមដេញថ្លៃ ហើយសំណុំឯកសារស្នើដេញថ្លៃរបស់ខ្លួនត្រូវបានគណៈកម្មាធិការលទ្ធកម្មវាយតម្លៃថាជាសំណុំឯកសារស្នើដេញថ្លៃឆ្លើយតបសមស្របជាងគេមុនពេលធ្វើលក្ខណសម្បត្តិតាមក្រោយ។

- **អ្នកទទួលការ** សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គលដែលចុះកិច្ចសន្យាលើការងារសាងសង់ ការងារជួសជុល សេវាកម្មឬសេវាទីប្រឹក្សាជាមួយនឹងស្ថាប័នអនុវត្តលទ្ធកម្ម។

- **អ្នកផ្គត់ផ្គង់** សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គលដែលចុះកិច្ចសន្យាលក់ទំនិញជាមួយនឹងស្ថាប័នអនុវត្តលទ្ធកម្ម។

- **ឯកសារដេញថ្លៃ** សំដៅដល់សំណុំឯកសារដែលអង្គភាពលទ្ធកម្មនៃស្ថាប័នអនុវត្តលទ្ធកម្មបានរៀបចំនិងផ្តល់ជាដំបូងទៅឱ្យអ្នកដេញថ្លៃ ដើម្បីប្រើសម្រាប់រៀបចំសំណុំឯកសារស្នើដេញថ្លៃ ដែលរួមមានពាក្យសុំដេញថ្លៃ សេចក្តីអញ្ជើញឱ្យចូលរួមដេញថ្លៃ ការស្នើឱ្យដាក់សំណុំឯកសារស្នើដេញថ្លៃ សេចក្តីអញ្ជើញឱ្យចូលរួមក្នុងការកំណត់បុរេលក្ខណសម្បត្តិ សេចក្តីណែនាំចំពោះអ្នកដេញថ្លៃ លក្ខណៈបច្ចេកទេស ទំហំការងារ លក្ខខណ្ឌយោងការងារ និងលក្ខខណ្ឌនៃកិច្ចសន្យា។



# ឧបសម្ព័ន្ធ ២

# ទម្រង់ឯកសារ

# ការអនុវត្តកិច្ចលទ្ធកម្មឆ្នាំ២០២១

# ឧបសម្ព័ន្ធ៣

# ចម្រង់ឯកសារ

# ការអនុវត្តកិច្ចលទ្ធកម្មឆ្នាំ ២០២២

**ឧបសម្ព័ន្ធទី១៦.១**

## លទ្ធផល និងតម្លៃប៉ាន់ស្មានគម្រោងហេដ្ឋារចនាសម្ព័ន្ធឬសំណង់

| **ខេត្ត ៖** កំពង់ស្ពឺ | **ស្រុក ៖** សំរោងទង | **រដ្ឋបាលឃុំ ៖** សែនដី | **លេខកូដឃុំ ៖** ០៥០៧០៩ |
|---|---|---|---|
| ឈ្មោះគម្រោង ៖ សាងសង់ផ្លូវបេតុងអាមេ | | | |

| ល.រ | ទីតាំងលទ្ធផល (ឈ្មោះភូមិ) | លេខកូដលទ្ធផល | ឈ្មោះលទ្ធផល | ថ្មី ឬកែលម្អ ឬជួសជុល | កាមបូជ គ.ជ.អ.ប (ពាក្យកូដ) | ស្តង់ដាទំហំ១ | | ស្តង់ដាទំហំ២ | | តម្លៃប៉ាន់ស្មាន (រៀល) | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | ប្រភេទ | ទំហំ | ប្រភេទ | ទំហំ | ឯកតា | បរិមាណ | តម្លៃឯកតា | សរុប |
| ១ | ព្រៃត្រោក | ១០១០២០៣A | សាងសង់ផ្លូវបេតុងអាមេ | ថ្មី | បា១ | ទទឹង | ៦ម | កម្រាស់ | ១៥០មម | គ.ម | ០,២៣ | ៧៣៨,០២០,០០០ | ១៦៧,៧៤៩,២០០ |
| **តម្លៃប៉ាន់ស្មានគម្រោងសរុប** | | | | | | | | | | | | | **១៦៧,៧៤៩,២០០** |

**កំណត់សម្គាល់ ៖** មានតែលទ្ធផលគម្រោងដែលថវិកាគ្រប់គ្រាន់សម្រាប់អនុវត្តប៉ុណ្ណោះដែលត្រូវកត់ត្រានៅក្នុងទម្រង់នេះ។

ថ្ងៃទី.០១.ខែ..កុម្ភៈ... ឆ្នាំ២០២២

អ៊ុំ_សារី

ថ្ងៃទី.០១. ខែ..កុម្ភៈ... ឆ្នាំ២០២២

**អ្នកជំនួយបច្ចេកទេស**

**គ្រុយ សុខណ្ណសិរីរ័ត្ន**

**ទម្រង់ទី១៨**

## ផែនការប្រតិបត្តិការ និងថែទាំលទ្ធផលគម្រោង

**ខេត្ត៖** កំពង់ស្ពឺ **ស្រុក៖** សំរោងទង **រដ្ឋបាលឃុំ៖** សែនដី **លេខកូដឃុំ៖** ០៥០៧០៩

ការពិពណ៌នាអំពីគម្រោង ៖ សាងសង់ផ្លូវបេតុងអាមេ ប្រវែង ០,២៣គ.ម ទទឹងខ្នង ៦ម កម្រាស ១៥០មម និងស្លាកសញ្ញាគម្រោង ០១កន្លែង។

អ្នកទទួលខុសត្រូវក្នុងការប្រតិបត្តិការ និងការថែទាំលទ្ធផលគម្រោង ៖ ក្រុមប្រឹក្សាឃុំ

| ផែនការអនុវត្តន៍ | | | | ផែនការហិរញ្ញវត្ថុ | | | |
|---|---|---|---|---|---|---|---|
| ល.រ | សកម្មភាព | ចំនួនដង | អ្នកអនុវត្ត | តម្លៃប៉ាន់ស្មាន (គិតជារៀល) ក្នុង១ដង | ក្នុង១ឆ្នាំ | ប្រភពថវិកា | តម្រូវការផ្សេងៗទៀត |
| **១. ការប្រើប្រាស់** | | | | | | | |
| ១ | ប្រជុំផ្សព្វផ្សាយ | ១ដង ក្នុង ១ឆ្នាំ | ក្រុមប្រឹក្សា | ២០០,០០០ | ២០០,០០០ | មូលនិធិឃុំ | ក្រុមប្រឹក្សាឃុំ និងគណ:កម្មការគ្រប់គ្រងគម្រោង |
| **២. ការថែទាំជាប្រចាំ** | | | | | | | |
| ១ | ជួសជុលកន្លែងប្រេះបែក | ១ដង ក្នុង ១ឆ្នាំ | សហគមន៍ | ៦,០០០,០០០ | ៦,០០០,០០០ | មូលនិធិឃុំ | កម្លាំងពលកម្មសហគមន៍ |
| **៣. ការថែទាំជាខួប** | | | | | | | |
| ១ | សាងសង់ផ្លូវបេតុងថ្មី | ៥ឆ្នាំម្តង | អ្នកទទួលការ | ៥០,៩២៦,៧៦០ | ១០,១៨៦,៩៥២ | មូលនិធិឃុំ | អ្នកទទួលការ |
| | **សរុបតម្លៃក្នុង១ឆ្នាំ** | | | | ១៦,៣៨៦,៩៥២ | | |

ថ្ងៃទី..០១.. ខែ..ធ្នូ... ឆ្នាំ ២០២២

អ៊ុំ សារី

ថ្ងៃទី..០១.. ខែ..ធ្នូ... ឆ្នាំ ២០២២

**តំណាងភ្នាក់ងារទទួលខុសត្រូវក្នុងការប្រតិបត្តិការ និងការថែទាំ**

ឡុង ធី

ថ្ងៃទី..០១.. ខែ..ធ្នូ... ឆ្នាំ ២០២២

**អ្នកជំនួយបច្ចេកទេស**

**គ្រុយ សុវណ្ណសិរីរ័ត្ន**

**ទម្រង់ទី១៧**

| ទីតាំងលទ្ធផលគម្រោង | | | |
|---|---|---|---|
| **ខេត្ត ៖** *កំពង់ស្ពឺ* | | **រដ្ឋបាលឃុំ ៖** *សែនដី* | |
| **ស្រុក ៖** *សំរោងទង* | | **លេខកូដឃុំ ៖** *០៥០៧០៩* | |
| ឈ្មោះគម្រោង ៖ សាងសង់ផ្លូវបេតុងអាមេ | | | |
| **លេខកូដលទ្ធផល** | **GPS X** | **GPS Y** | **យោបល់ផ្សេងៗ** |
| ១០១០២០៣A | ០៤៦១៣៩១ | ១២៦២៥២១ | ដើមផ្លូវភូមិស្រែត្រោក |
| | ០៤៦០២៦៩ | ១២៦២៤៣៨ | ចុងផ្លូវភូមិស្រែត្រោក |

ថ្ងៃទី..០១ ខែ..ឧសភា... ឆ្នាំ.២០២២

អ៊ុំ~សារី

ថ្ងៃទី..០១. ខែ..ឧសភា... ឆ្នាំ២០២២

**អ្នកជំនួយបច្ចេកទេស**

**គ្រុយ សុវណ្ណសិរីរ័ត្ន**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្តកំពង់ស្ពឺ
ស្រុកសំរោងទង
រដ្ឋបាលឃុំសែនដី
លេខ: ០០៧/២២ស.ស.រ

ថ្ងៃសុក្រ ៣ កើត ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
សែនដី ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២២

## សេចក្តីសម្រេច
## ស្តីពី
## ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការគ្រប់គ្រងគម្រោង

### មេឃុំ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ២២អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្តីពីការធ្វើវិមជ្ឈការអំណាចតួនាទី និងភារកិច្ចទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់
- យោងសេចក្តីសម្រេចលេខ០៩៧ សសរ/គ.ជ.អ.ប ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ស្តីពីការដាក់ឱ្យប្រើប្រាស់សៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់
- បានទទួលការអនុម័តនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាឃុំសែនដី......នាថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២២

### សម្រេច

**ប្រការ១._**

ត្រូវបង្កើតគណៈកម្មការគ្រប់គ្រងគម្រោងសាងសង់ផ្លូវបេតុងអាមេ ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. លោក អ៊ុំ សារី | មេឃុំសែនដី | ប្រធាន |
| ២. លោក កែវ ណែ | ជំទប់ទី១ | អនុប្រធាន |
| ៣. លោក យឹម ណាត | ជំទប់ទី២ | សមាជិក |
| ៤. លោក ខៀវ ឌី | សមាជិកក្រុមប្រឹក្សា | សមាជិក |
| ៥. លោក សួស សំអូន | សមាជិកក្រុមប្រឹក្សា | សមាជិក |
| ៦. លោក សួន ធីម | សមាជិកក្រុមប្រឹក្សា | សមាជិក |
| ៧. លោកស្រី ចន សារឿន | សមាជិកក្រុមប្រឹក្សា | សមាជិក |

| | | |
|---|---|---|
| ៨. លោក ម៉ុម គង់ | សមាជិកក្រុមប្រឹក្សា | សមាជិក |
| ៩. លោក អ៊ូ កឿង | សមាជិកក្រុមប្រឹក្សា | សមាជិក |
| ១០. លោក ម៉ុម គីមសិន | មេភូមិស្រែគ្រោក | សមាជិក |
| ១១. លោកស្រី ណុប តារា | ស្មៀនឃុំសែនដី | លេខាធិការ |

**ប្រការ២.**_

គណៈកម្មការគ្រប់គ្រងគម្រោងមានតួនាទី ភារកិច្ចដូចខាងក្រោម៖

ក). **ក្នុងការរៀបចំគម្រោង៖**

- ពិនិត្យ និងអនុម័តផែនការសិក្សាគម្រោង
- គ្រប់គ្រងចាត់ចែងដំណើរការសិក្សា និងរៀបចំគម្រោង
- រៀបចំសំណើគម្រោងដោយមានជំនួយពីអ្នកជំនួយបច្ចេកទេស
- ពិនិត្យ និងអនុម័តសំណើគម្រោង។

ខ). **ក្នុងការអនុវត្តគម្រោង៖**

- គ្រប់គ្រងចាត់ចែងដំណើរការអនុវត្តគម្រោង
- រៀបចំប្រជុំចាប់ផ្តើម និងបញ្ចប់នៃការអនុវត្តការងារ ឬការផ្គត់ផ្គង់ទំនិញ និងរៀបចំប្រជុំពិនិត្យ និងអនុម័តការទូទាត់គម្រោង
- តាមដានត្រួតពិនិត្យការអនុវត្តគម្រោង
- រៀបចំកិច្ចប្រជុំនានានៅក្នុងអំឡុងពេលអនុវត្តគម្រោង ដើម្បីពិនិត្យ និងវាយតម្លៃការអនុវត្តគម្រោង។

**ប្រការ៣.**_

គណៈកម្មការគ្រប់គ្រងគម្រោងមានរបៀបរបបការងារដូចខាងក្រោម៖

- ប្រធានគណៈកម្មការគ្រប់គ្រងគម្រោង ជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំរបស់គណៈកម្មការគ្រប់គ្រងគម្រោង។ ក្នុងករណីប្រធានអវត្តមាន ត្រូវផ្ទេរសិទ្ធិជាលាយល័ក្ខណ៍អក្សរទៅឱ្យអនុប្រធាន ជាប្រធានស្តីទី ហើយប្រធានស្តីទីជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំ
- កិច្ចប្រជុំរបស់គណៈកម្មការគ្រប់គ្រងគម្រោងអាចប្រព្រឹត្តទៅបាន លុះត្រាតែមានវត្តមានសមាជិកលើសពីពាក់កណ្តាលនៃសមាជិកគណៈកម្មការទាំងមូល
- សេចក្តីសម្រេចរបស់អង្គប្រជុំគណៈកម្មការគ្រប់គ្រងគម្រោងអាចយកជាការបាន លុះត្រាតែមានសំឡេងអនុម័តលើសពីពាក់កណ្តាលនៃចំនួនសមាជិកគណៈកម្មការទាំងមូល។ ប្រសិនបើសំឡេងអនុម័តមានចំនួនស្មើគ្នា សំឡេងរបស់អធិបតីនៃអង្គប្រជុំមានឧត្តមានុភាព
- ប្រធានគណៈកម្មការគ្រប់គ្រងគម្រោងអាចអញ្ជើញបុគ្គលិកមកពីទីភ្នាក់ងារនានា ឬតំណាងអង្គការសហគមន៍ មូលដ្ឋានដែលពាក់ព័ន្ធនឹងគម្រោង ដើម្បីចូលរួមកិច្ចប្រជុំគណៈកម្មការក្នុងនាមជាអ្នកសង្កេតការ
- គ្រប់កិច្ចប្រជុំរបស់គណៈកម្មការគ្រប់គ្រងគម្រោង ត្រូវមានកំណត់ហេតុដែលរៀបចំដោយលេខាធិការរបស់គណៈកម្មការ និងត្រូវចុះហត្ថលេខាដោយអធិបតីនៃអង្គប្រជុំ។

**ប្រការ៤.**_

សមាសភាពដូចមានចែងក្នុងប្រការ១ និងអ្នកពាក់ព័ន្ធនានា ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**កន្លែងទទួល៖**

- រដ្ឋបាលខេត្តកំពង់ស្ពឺ
- រដ្ឋបាលស្រុកសំរោងទង
- ដូចប្រការ១
- ឯកសារ-កាលប្បវត្តិ

មេឃុំ
ស្រែគ្រោក

អ៊ុំ សារី

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

## កំណត់ហេតុ
## ស្ដីពី
## ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការគ្រប់គ្រងគម្រោង

ឆ្នាំពីរពាន់ម្ភៃពីរ ខែកុម្ភៈ ថ្ងៃទីបី វេលាម៉ោងប្រាំបីព្រឹក នៅសាលាឃុំសែនដី បានរៀបចំកិច្ចប្រជុំបង្កើតគណៈកម្មការគ្រប់គ្រងគម្រោង ក្រោមអធិបតីភាព លោក អ៊ុំ សារី ប្រធានក្រុមប្រឹក្សាឃុំ ។

**១ .សមាសភាពអ្នកចូលរួម**

ដូចមានបញ្ជីវត្តមានជូនភ្ជាប់មកជាមួយ

**២ .របៀបវារៈ**

១ .មតិបើកអង្គប្រជុំរបស់ប្រធានអង្គប្រជុំ

២. ការពិភាក្សាពីការបង្កើតគណៈកម្មការគ្រប់គ្រងគម្រោង

៣. បញ្ហាផ្សេងៗ និងបិទអង្គប្រជុំ

**៣ .ការពិភាក្សា**

ជាកិច្ចចាប់ផ្ដើម លោក អ៊ុំ សារី ប្រធានអង្គប្រជុំ បានមានមតិថា ជារៀងរាល់ឆ្នាំមុនពេលចាប់ផ្ដើមការសិក្សាគម្រោង ក្រុមប្រឹក្សាឃុំត្រូវប្រជុំរៀបចំបង្កើតគណៈកម្មការគ្រប់គ្រងគម្រោង ដូច្នេះការអញ្ជើញរបស់ក្រុមប្រឹក្សាឃុំយើងមកចូលរួមកិច្ចប្រជុំនាថ្ងៃនេះ គឺក្នុងគោលបំណងរៀបចំគណៈកម្មការគ្រប់គ្រងគម្រោងឃុំសែនដីសម្រាប់ធ្វើការតាមដានការអនុវត្តគម្រោងមូលនិធិឃុំឆ្នាំ២០២២ ។ សមាជិកក្រុមប្រឹក្សាឃុំទាំងអស់គឺត្រូវបញ្ចូលក្នុងគណៈកម្មការគ្រប់គ្រងគម្រោង គឺដើម្បីចូលរួមតាមដានការអនុវត្តគម្រោងរបស់អ្នកទទួលការទាំងអស់គ្នា ។ នៅក្នុងជួរគណៈកម្មការគ្រប់គ្រងគម្រោងក៏ត្រូវមានលោកមេភូមិនៃទីតាំងគម្រោងផងដែរ ពីព្រោះគម្រោងមូលនិធិឃុំឆ្នាំ២០២២ នេះគឺត្រូវសាងសង់នៅក្នុងភូមិស្រែត្រោក។

លោក កែវ រ៉ន ជំទប់ទី១ បានមានមតិថា ខ្ញុំឯកភាពចំពោះរៀបចំសមាសភាពគណៈកម្មការនេះ ហើយការបន្ថែមលោកមេភូមិស្រែត្រោកក្នុងគណៈកម្មការគ្រប់គ្រងគម្រោង គឺដើម្បីបញ្ជាក់ថាលោកមេភូមិត្រូវចូលរួមចំណែកក្នុងការតាមដាន និងទទួលខុសត្រូវចំពោះលទ្ធផលគម្រោងឆ្នាំ២០២២ ដែរ។

ជាទីបញ្ចប់លោកប្រធានអង្គប្រជុំ បានថ្លែងអំណរគុណដល់សមាជិក សមាជិកាដែលចូលរួម និងបានមានមតិបូកសរុបបិទអង្គប្រជុំ។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោងដប់ និងដប់នាទីព្រឹក នាថ្ងៃខែឆ្នាំដដែលក្នុងបរិយាកាសរីករាយ និងស្និទស្នាលក្រៃលែង។

បានឃើញ និងឯកភាព
ប្រធានអង្គប្រជុំ
អ៊ុំ សារី

អ្នកធ្វើកំណត់ហេតុ
ណុប ដារ៉ា

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ខេត្តកំពង់ស្ពឺ**

**ស្រុកសំរោងទង**

**រដ្ឋបាលឃុំសែនដី**

លេខ: ..០០១/២២...ស.ជ.ណ

ថ្ងៃចន្ទ ៨ កើត ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
សែនដី ថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២២

# សេចក្ដីជូនដំណឹង
## ស្ដីពីការដេញថ្លៃកិច្ចសន្យាសំណង់

<table>
<tr><td colspan="2">ការពិពណ៌នាអំពីលទ្ធផលកិច្ចសន្យា ៖<br>• ការសាងសង់ ៖ សាងសង់ផ្លូវបេតុងអារមេ ប្រវែង ០.២៣គ.ម ទទឹងខ្នង ៦ម កម្រាស់ ១៥០មម និងស្លាកសញ្ញាគម្រោង ០១កន្លែង ។<br>• ការថែទាំ ៖ ធានាឱ្យស្ថានភាពផ្លូវនៅស្អាតក្នុងរយៈពេល ៦ខែ បន្ទាប់ពីបញ្ចប់ការងារសាងសង់រួច ១០០%។</td></tr>
<tr><td>តម្លៃប៉ាន់ស្មាន</td><td>១៦៩,៧៤៩,២០០រៀល<br>(មួយរយហុកសិបប្រាំបួនលានប្រាំពីររយសែសិបប្រាំបួនពាន់ពីររយរៀល)</td></tr>
<tr><td>អ្នកដែលអាចដេញថ្លៃ</td><td>អ្នកទទួលការប្រភេទទី១ និងអ្នកទទួលការប្រភេទទី២</td></tr>
<tr><td>ចំនួនប្រាក់កក់ធានាការដេញថ្លៃ</td><td>៣,៣៩៤,៩៨៤ រៀល<br>(បីលានបីរយកៅសិបបួនពាន់ប្រាំបួនរយប៉ែតសិបបួនរយរៀល)</td></tr>
<tr><td>ឈ្មោះធនាគារពាណិជ្ជដែលត្រូវតម្កល់ប្រាក់កក់</td><td>ធនាគារកាណាឌីយ៉ា (ខេត្តកំពង់ស្ពឺ)</td></tr>
<tr><td>រយៈពេលសុពលភាពនៃសំណើដេញថ្លៃ</td><td>ចំនួន៤៥ (សែសិបប្រាំ) ថ្ងៃ ចាប់ពីថ្ងៃប្រជុំបើកសំណើដេញថ្លៃ</td></tr>
<tr><td>ទីកន្លែងដែលអាចទទួលឯកសារដេញថ្លៃ</td><td>នៅសាលាឃុំសែនដី ឬ នៅទីចាត់ការផែនការ និងវិនិយោគ ខេត្តកំពង់ស្ពឺ</td></tr>
<tr><td>ទីកន្លែងនៃការប្រជុំបើកសំណើដេញថ្លៃ</td><td>សាលាឃុំវល្លិសរ</td></tr>
<tr><td>កាលបរិច្ឆេទនៃការប្រជុំបើកសំណើដេញថ្លៃ</td><td>ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២២</td></tr>
<tr><td>• ពេលវេលាចាប់ផ្ដើមទទួលសំណើដេញថ្លៃ</td><td>ម៉ោង ៩:០០ នាទី</td></tr>
<tr><td>• ពេលវេលាឈប់ទទួលសំណើដេញថ្លៃ</td><td>ម៉ោង ៩:១០ នាទី</td></tr>
<tr><td>• ពេលវេលាបើកសំណើដេញថ្លៃ</td><td>ម៉ោង ៩:១០ នាទី</td></tr>
</table>

**កំណត់សម្គាល់ ÷**

- អ្នកដេញថ្លៃត្រូវភ្ជាប់មកជាមួយសំណើដេញថ្លៃរបស់ខ្លួននូវប័ណ្ណពន្ធប៉ាតង់ដែលមានសុពលភាព ឬ បង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធប៉ាតង់ចំនួន០១ច្បាប់ (ច្បាប់ថតចម្លងដែលមាននីត្យានុកូលកម្ម) បើពុំនោះសោតទេ សំណើដេញថ្លៃពុំមានសុពលភាពឡើយ ហើយប្រាក់ធានាការដេញថ្លៃនឹងត្រូវបានរឹបអូសផ្ទេរបង្វែរបង់ចូលថវិការដ្ឋ។
- អ្នកដេញថ្លៃឈ្នះក្នុងការដេញថ្លៃនឹងត្រូវតម្កល់ប្រាក់កក់ធានាការអនុវត្តចំនួន១០%នៃតម្លៃកិច្ចសន្យា។ ប្រាក់កក់នេះមានសុពលភាពរហូតដល់ចប់រយៈពេលថែទាំលទ្ធផលកិច្ចសន្យា ឬ រយៈពេលធានាគុណភាពសំណង់។
- អ្នកទទួលការត្រូវទទួលខុសត្រូវទាំងស្រុងក្នុងការថែទាំលទ្ធផលកិច្ចសន្យា និងជួសជុលនូវរាល់ការខូចខាតទាំងអស់នៅក្នុងអំឡុងពេល៦ខែ បន្ទាប់ពីសាងសង់រួចជាស្ថាពរ។
- អ្នកដេញថ្លៃត្រូវចូលរួមដេញថ្លៃប្រកបដោយការប្រកួតប្រជែង ដោយគ្មានការឃុបឃិត ការក្លែងបន្លំ ការបង្ខិតបង្ខំ ឬ ការប្រព្រឹត្តអំពើពុករលួយ។ ប្រសិនបើត្រូវបានរកឃើញថា អ្នកដេញថ្លៃមានការពាក់ព័ន្ធនឹងឃុបឃិត ការក្លែងបន្លំ ការបង្ខិតបង្ខំ ឬ ការប្រព្រឹត្តអំពើពុករលួយ អ្នកដេញថ្លៃទាំងនោះនឹងត្រូវបានដាក់ក្នុងបញ្ជីខ្មៅជារៀងរហូត និងមិនត្រូវបានអនុញ្ញាតឱ្យដាក់សំណើដេញថ្លៃកិច្ចសន្យាឃុំ សង្កាត់ទាំងអស់នៅទូទាំងប្រទេសកម្ពុជា ហើយប្រាក់កក់ធានាការដេញថ្លៃរបស់អ្នកដេញថ្លៃទាំងនោះនឹងត្រូវបានរឹបអូសផ្ទេរបង្វែរបង់ចូលថវិការដ្ឋ។

**កែវ~រ៉ែន**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**កំណត់ហេតុ**
**ស្តីពី**
**ការប្រជុំបើកសំណើដេញថ្លៃគម្រោងសាងសង់ផ្លូវបេតុងអាមេ**

ឆ្នាំពីរពាន់ម្ភៃពីរ ខែតុលា ថ្ងៃទីដប់ប្រាំពីរ វេលាម៉ោងប្រាំបីព្រឹក រដ្ឋបាលឃុំសែនដី ស្រុកសំពោងទង ខេត្តកំពង់ស្ពឺ បានរៀបចំកិច្ចប្រជុំបើកសំណើដេញថ្លៃ ក្រោមអធិបតីភាពលោក កែវ រ៉ែន ប្រធានគណៈកម្មការលទ្ធកម្ម ឃុំសែនដី។

**សមាសភាពចូលរួម** លោក លោកស្រីដូចមានក្នុងបញ្ជីវត្តមានជូនភ្ជាប់ ។

**របៀបវារៈ**

១. មតិសំណេះសំណាល និងបើកអង្គប្រជុំរបស់គណអធិបតី

២. ប្រធានគណៈកម្មការលទ្ធកម្មឃុំ ជម្រាបជូនរបៀបវារៈនៃការបើកសំណើដេញថ្លៃ

៣. អ្នកទទួលការដាក់សំណើដេញថ្លៃក្នុងប្រអប់ដេញថ្លៃ

៤. ប្រធានគណៈកម្មការលទ្ធកម្មឃុំអានគោលការណ៍សំខាន់ៗនៃការដេញថ្លៃ

៥. ប្រធានគណៈកម្មការលទ្ធកម្មឃុំប្រកាសបើកសំណើដេញថ្លៃជាផ្លូវការណ៍

៦. គណៈកម្មការលទ្ធកម្មឃុំបើកស្រោមសំបុត្រ រួចកត់ត្រាលើក្រដាសផ្ទាំងធំរួច ពិនិត្យសុពលភាព សំណើដេញថ្លៃ និងវាយតម្លៃសំណើដេញថ្លៃ របស់អ្នកទទួលការ

៧. ការប្រកាសលទ្ធផលសំណើដេញថ្លៃ

៨. ការឡើងប្តេជ្ញាចិត្តរបស់អ្នកទទួលការដែលឈ្នះក្នុងការដេញថ្លៃ

៩. មតិបូកសរុប និងបិទកម្មវិធីអង្គប្រជុំរបស់គណៈអធិបតី

ជាកិច្ចចាប់ផ្តើមលោក កង ប៊ុនណាត អភិបាលរង នៃគណៈអភិបាលស្រុកសំពោងទង មានប្រសាសន៍ សំណេះសំណាល និងបើកអង្គប្រជុំ។

ជាកិច្ចបន្ទាប់លោក កែវ រ៉ែន ប្រធានគណៈកម្មការលទ្ធកម្មឃុំសែនដី ជម្រាបជូន របៀបវារៈ នៃការការដេញថ្លៃដល់សមាជិក សមាជិកាដែលមានវត្តមានក្នុងអង្គប្រជុំ និងប្រកាសពេលវេលាដាក់សំណើដេញថ្លៃចាប់ពី ម៉ោង ៩: ០៥នាទីព្រឹក រហូតដល់ ម៉ោង៩:១៥នាទីព្រឹក អ្នកទទួលការដាក់សំណើ ដេញថ្លៃក្នុងប្រអប់ដេញថ្លៃរយៈពេល១០នាទីរួចមកលោក ប្រធានគណៈកម្មការលទ្ធកម្មឃុំអានគោលការណ៍ សំខាន់ៗនៃការដេញថ្លៃ។

ជាកិច្ចបន្ត លោក ប្រធានគណៈកម្មការលទ្ធកម្មឃុំបានប្រកាសចំនួនស្រោមសំបុត្រដែលបានដាក់ដេញថ្លៃ រួចបើកសំណើដេញថ្លៃរបស់អ្នកទទួលការមានចំនួន៦ស្រោមសំបុត្រ និងកត់ត្រាលើក្រដាសផ្ទាំងធំ ៖

១. ឈ្មោះអ្នក ដេញថ្លៃ ស៊ិន ស៊ីឌិន ឈ្មោះ ក្រុមហ៊ុន ផល លីហ៊ង តម្លៃដេញថ្លៃនៅពេលដាក់សំណើដេញ ថ្លៃមានចំនួន១០៥,៣៤០,០០០រៀល

២. ឈ្មោះអ្នកដេញថ្លៃ ហ៊ីង ម៉េង ឈ្មោះ ក្រុមហ៊ុន ហ៊ីង ម៉េង គ្រេនស្ព័ត តម្លៃដេញថ្លៃនៅពេលដាក់សំណើដេញ ថ្លៃមានចំនួន១៦៦,០០០,០០០រៀល

៣. ឈ្មោះអ្នក ដេញថ្លៃ ព្រំ ពៅ ឈ្មោះ ក្រុមហ៊ុន ព្រំ ពៅ តម្លៃដេញថ្លៃនៅពេលដាក់សំណើ ដេញថ្លៃមានចំនួន១៦៤,០០០,០០០រៀល

បន្ទាប់មកទៀតលោក ប្រធានគណៈកម្មការលទ្ធកម្មឃុំ បានប្រកាសលទ្ធផលនៃការដេញថ្លៃ៖

១. ឈ្មោះអ្នក ដេញថ្លៃ ស៊ិន ស៊ីឌិន ឈ្មោះ ក្រុមហ៊ុន ផល លីហ័ង តម្លៃដេញថ្លៃនៅពេលដាក់សំណើដេញ ថ្លៃមានចំនួន១០៥,៣៤០,០០០រៀល តម្លៃទាបលំដាប់ទី១

២. ឈ្មោះអ្នកដេញថ្លៃ ហ៊ីង ម៉េង ឈ្មោះ ក្រុមហ៊ុន ហ៊ីង ម៉េង គ្រេនស្ទ័ត តម្លៃដេញថ្លៃនៅពេលដាក់សំណើដេញ ថ្លៃមានចំនួន១៦៦,០០០,០០០រៀល តម្លៃទាបលំដាប់ទី៣

៣. ឈ្មោះអ្នក ដេញថ្លៃ ព្រំ ពៅ ឈ្មោះ ក្រុមហ៊ុន ព្រំ ពៅ តម្លៃដេញថ្លៃនៅពេលដាក់សំណើ ដេញថ្លៃមានចំនួន១៦៤,០០០,០០០រៀល តម្លៃទាបលំដាប់ទី២

ក្រោយពីប្រកាសលទ្ធផលរួចមក លោកស៊ិន ស៊ីឌិន ឈ្មោះ ក្រុមហ៊ុន ផល លីហ័ង បានឡើងប្តេជ្ញាចិត្តលើកការសាងសង់ផ្លូវបេតុងអាមេ។

ជាចុងបញ្ចប់លោក កង ប៊ុនណាត អភិបាលរងនៃគណអភិបាលស្រុកសំពោងទង បានមានប្រសាសន៍ផ្តាំផ្ញើរ និងប្រកាសបិទអង្គប្រជុំ។

អង្គប្រជុំបានចប់សព្វគ្រប់នៅវេលាម៉ោងដប់មួយព្រឹក នាថ្ងៃខែឆ្នាំដដែលក្នុងបរិយាកាស រីករាយ និងស្និតស្នាលបំផុត ។

ប្រធានអង្គប្រជុំ

កែវ រ៉ន

អ្នកធ្វើកំណត់ហេតុ

Dara

ណុប ដារ៉ា

ទម្រង់ទី៤៤

## តារាងសម្រាប់កត់ត្រានៅពេលបើក និងវាយតម្លៃសំណើដេញថ្លៃ

| រាជធានី ខេត្ត ÷ កំពង់ស្ពឺ | | ក្រុង ស្រុក ខណ្ឌ ÷ សំរោងទង | | រដ្ឋបាលឃុំ សង្កាត់ ÷ សែនដី | លេខកូដឃុំ សង្កាត់ ÷ ០៥០៧០៩ |
|---|---|---|---|---|---|
| ឈ្មោះកិច្ចសន្យា ៖ សាងសង់បេតុងអាមេ(ផ្លូវប្រវែង០,២៣គ.ម ទទឹង ខ្នង៦មកម្រាស់១៥០មម) | | | | តម្លៃប៉ាន់ស្មាន ៖ ១៦៩,៧៤៩,២០០រៀល | |
| ល.រ | ឈ្មោះអ្នកដេញថ្លៃ | ឈ្មោះក្រុមហ៊ុន | តម្លៃដាក់ដេញថ្លៃ នៅពេលបើកសំណើដេញថ្លៃ | តម្លៃដាក់ដេញថ្លៃ ក្រោយពីកែតម្រូវ | កំណត់សម្គាល់ ឬមូលហេតុនៃការបដិសេធ សំណើដេញថ្លៃ |
| 1 | 2 | 3 | 4 | 5 | 6 |
| 1. | ស៊ុន ស៊ីវុន | ឯកលេ ស៊ីហ៊ន | 105,340,000 | | សុចាលភាពទី 1 |
| ២ | ហ៊ុន ឆេង | ហ៊ុន ឆេង ផលស្ទីត | 166,000,000 | | សុចាលភាពទី 3 |
| ៣ | ព្រាំ ចៅ | ព្រាំ ចៅ | 164,000,000 | | សុចាលភាពទី ២ |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |

**កំណត់សម្គាល់ ÷**

- កូឡោនទី១ ទី២ ទី៣ និងទី៤ ត្រូវបំពេញនៅក្នុងពេលប្រជុំបើកសំណើដេញថ្លៃ។
- កូឡោនទី៥ និងទី៦ ត្រូវបំពេញនៅក្នុងពេលប្រជុំវាយតម្លៃសំណើដេញថ្លៃ។
- ទម្រង់នេះត្រូវភ្ជាប់ជាមួយកំណត់ហេតុ និងរបាយការណ៍ដេញថ្លៃ ហើយត្រូវបិទផ្សាយនៅលើក្ដារព័ត៌មាន នៅកន្លែងប្រជុំបើកសំណើដេញថ្លៃ និងវាយតម្លៃសំណើដេញថ្លៃ ០១ម៉ោងក្រោយពីបញ្ចប់កិច្ចប្រជុំវាយតម្លៃសំណើដេញថ្លៃ។

ថ្ងៃទី 17 ខែ 10 ឆ្នាំ 2022

ប្រធានគណៈកម្មការលទ្ធកម្ម

កែវ_រិន

**ទម្រង់ទី៤៣.១**

## របាយការណ៍រីកចម្រើន
## នៃការអនុវត្តកិច្ចសន្យាសំណង់

| | | |
|---|---|---|
| **រាជធានី ខេត្ត** ÷ កំពង់ស្ពឺ | **ក្រុង ស្រុក ខណ្ឌ** ÷ សំរោងទង | **ថ្ងៃឈាឃុំ សង្កាត់** ÷ សែនដី |
| ឈ្មោះកិច្ចសន្យា | គម្រោងសាងសង់ផ្លូវបេតុអាមេ | |
| លេខកិច្ចសន្យា | ០៥០៧០៩/២២/០១-០១ | |
| ឈ្មោះអ្នកទទួលការ | ព្រំ ពៅ | |
| ឈ្មោះអ្នកត្រួតពិនិត្យបច្ចេកទេស | គ្រុយ សុវណ្ណសិរីរ័ត្ន | |
| កាលបរិច្ឆេទចុះត្រួតពិនិត្យ | ២៧/១២/២០២២ | |

**១. ការពិពណ៌នាអំពីការរីកចម្រើននៃការអនុវត្តការងារ ៖**

អ្នកទទួលការ៖

- បានឈូសឆាយសម្អាតទីតាំង និងធ្វើគ្រឹះបាតផ្លូវបានប្រវែង ០,៥គ.ម
- បានចាក់បេតុងសាងសង់ផ្លូវបេតុងអាមេបានប្រវែង ០,៤២២គ.ម
- បានដាក់ស្លាកសញ្ញាគម្រោង ០១កន្លែង
- ក្រោយពីបញ្ចប់ការងារសាងសង់ អ្នកទទួលការបានសំអាតកាកសំណល់សំណង់ និងកាកសំណល់ផ្សេងៗ

| | |
|---|---|
| ២. ចំនួនឬអត្រាភាគរយនៃការអនុវត្តការងារដែលបានបញ្ចប់ | ១00% |
| ៣. តើសម្ភារដែលបានប្រើប្រាស់មានគុណភាពដូចបានកំណត់នៅក្នុងកិច្ចសន្យាដែរឬទេ?<br>(បើគុណភាពសម្ភារដែលបានប្រើប្រាស់មិនដូចក្នុងកិច្ចសន្យា ចូរពន្យល់ចំណុចខ្វះខាតទាំងនោះ) | បាទ |
| ៤. តើការងារមានគុណភាពដូចបានកំណត់នៅក្នុងកិច្ចសន្យាដែរឬទេ?<br>(បើគុណភាពការងារមិនដូចក្នុងកិច្ចសន្យា ចូរពន្យល់ចំណុចខ្វះខាតទាំងនោះ) | បាទ |
| ៥. តើសំណង់បានសាងសង់ទៅតាមគំនូសប្លង់បច្ចេកទេសដែរឬទេ?<br>(បើសំណង់មិនដូចគំនូសប្លង់បច្ចេកទេស ចូរពន្យល់ចំណុចខុសប្លែកទាំងនោះ) | បាទ |

**៦. យោបល់ផ្សេងៗ ៖**

អ្នកទទួលការបានបំពេញលក្ខខ័ណ្ឌនៃការទូទាត់លើកទី១

ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២២

**អ្នកត្រួតពិនិត្យបច្ចេកទេស**

**គ្រុយ សុវណ្ណសិរីរ័ត្ន**

# ឧបសម្ព័ន្ធ៤

# ឯកសារ

# ការអនុវត្តកិច្ចលទ្ធកម្មឆ្នាំ ២០២៣

ទម្រង់ទី១៦.១

## លទ្ធផល និងតម្លៃប៉ាន់ស្មានគម្រោងហេដ្ឋារចនាសម្ព័ន្ធឬសំណង់

| ខេត្ត ៖ កំពង់ស្ពឺ | ស្រុក ៖ សំរោងទង | រដ្ឋបាលឃុំ ៖ សែនដី | លេខកូដឃុំ ៖ ០៥០៧០៩ |
|---|---|---|---|
| ឈ្មោះគម្រោង ៖ គម្រោងសាងសង់ផ្លូវបេតុងអាមេ | | | |

| ល.រ | ទីតាំងលទ្ធផល (ឈ្មោះភូមិ) | លេខកូដលទ្ធផល | ឈ្មោះលទ្ធផល | ថ្មី ឬកែលម្អ ឬជួសជុល | កាមម្លង់ គ.ជ.អ.ប (តាមឆ្នាំ) | ស្តង់ដារទំហំ១ | | ស្តង់ដារទំហំ២ | | តម្លៃប៉ាន់ស្មាន (រៀល) | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | ប្រភេទ | ទំហំ | ប្រភេទ | ទំហំ | ឯកតា | បរិមាណ | តម្លៃឯកតា | សរុប |
| ១ | ព្រៃរំដួល | ១០១០៦០៣A | សាងសង់ផ្លូវបេតុងអាមេ | ថ្មី | បាទ | ទទឹង | ៦ម | កម្រាស់ | ១៥០មម | គ.ម | ០,៣៨៤ | ៧៧៦,៤៧០,៨១៦ | ៤៩៦,៦១១,៩០០ |
| **តម្លៃប៉ាន់ស្មានគម្រោងសរុប** | | | | | | | | | | | | | ៤៩៦,៦១១,៩០០ |

**កំណត់សម្គាល់ ៖** មានតែលទ្ធផលគម្រោងដែលថវិកាគ្រប់គ្រាន់សម្រាប់អនុវត្តប៉ុណ្ណោះដែលត្រូវកត់ត្រានៅក្នុងទម្រង់នេះ។

ថ្ងៃទី...... ខែ...... ឆ្នាំ២០២១

មេឃុំ

កែវ រិន

ថ្ងៃទី.៣១... ខែ..មីនា..... ឆ្នាំ២០២១

**អ្នកជំនួយបច្ចេកទេស**

**គ្រុយ សុខណ្ណសិរីរ័ត្ន**

ទម្រង់ទី១៨

# ផែនការប្រគល់ភារកិច្ចគ្រប់គ្រង និងថែទាំលទ្ធផលគម្រោង

| | | | | | | | |
|---|---|---|---|---|---|---|---|
| **ខេត្ត៖** កំពង់ស្ពឺ | | **ស្រុក៖** សំរោងទង | | | **រដ្ឋបាលឃុំ៖** សែនដី | | **លេខកូដឃុំ៖** ០៥០៧០៩ |
| ការពិពណ៌នាអំពីគម្រោង ៖ គម្រោងសាងសង់ផ្លូវបេតុងអាមេ ប្រវែង ០,៣៨៦គ.ម ទទឹងខ្នង ៦ម កម្រាស ១៥០មម និងស្លាកសញ្ញាគម្រោង ០១កន្លែង។ | | | | | | | |
| អ្នកទទួលខុសត្រូវក្នុងការប្រតិបត្តិការ និងការថែទាំលទ្ធផលគម្រោង ៖ ក្រុមប្រឹក្សាឃុំ | | | | | | | |
| ផែនការអនុវត្តន៍ | | | | ផែនការហិរញ្ញវត្ថុ | | | |
| ល.រ | សកម្មភាព | ចំនួនដង | អ្នកអនុវត្ត | តម្លៃប៉ាន់ស្មាន (គិតជារៀល) | | ប្រភពថវិកា | តម្រូវការផ្សេងៗទៀត |
| | | | | ក្នុង១ដង | ក្នុង១ឆ្នាំ | | |
| **១. ការប្រើប្រាស់** | | | | | | | |
| ១ | ប្រជុំផ្សព្វផ្សាយ | ១ដង ក្នុង ១ឆ្នាំ | ក្រុមប្រឹក្សា | ៦០០,០០០ | ៦០០,០០០ | មូលនិធិឃុំ | ក្រុមប្រឹក្សាឃុំ និងគណៈកម្មការគ្រប់គ្រងគម្រោង |
| **២. ការថែទាំជាប្រចាំ** | | | | | | | |
| ១ | ជួសជុលកន្លែងប្រេះបែក | ១ដង ក្នុង ១ឆ្នាំ | សហគមន៍ | ៤,០០០,០០០ | ៤,០០០,០០០ | មូលនិធិឃុំ | កម្លាំងពលកម្មសហគមន៍ |
| **៣. ការថែទាំជាខួប** | | | | | | | |
| ១ | សាងសង់ផ្លូវបេតុងថ្មី | ៥ឆ្នាំម្តង | អ្នកទទួលការ | ៨៨,៩៨៣,៥៤០ | ១៧,៧៩៦,៧០៨ | មូលនិធិឃុំ | អ្នកទទួលការ |
| **សរុបតម្លៃក្នុង១ឆ្នាំ** | | | | | ២១,៩៩៦,៧០៨ | | |

ថ្ងៃទី... ខែ... ឆ្នាំ២០២៣

មេឃុំ

កែវ_រិន

ថ្ងៃទី.31... ខែ...មីនា.... ឆ្នាំ២០២៣

**តំណាងភ្នាក់ងារទទួលខុសត្រូវក្នុងការប្រគល់ភារកិច្ច និងការថែទាំ**

ឡៅ ផ្ទី

ថ្ងៃទី.31.... ខែ..មីនា..... ឆ្នាំ២០២៣

**អ្នកជំនួយបច្ចេកទេស**

**គ្រុយ សុវណ្ណសិរីរ័ត្ន**

**ទម្រង់ទី១៧**

| ទីតាំងលទ្ធផលគម្រោង | | | |
|---|---|---|---|
| **ខេត្ត៖** កំពង់ស្ពឺ | | **រដ្ឋបាលឃុំ៖** សែនដី | |
| **ស្រុក៖** សំរោងទង | | **លេខកូដឃុំ៖** ០៥០៧០៩ | |
| ឈ្មោះគម្រោង៖ គម្រោងសាងសង់ផ្លូវបេតុងអាមេ | | | |
| **លេខកូដលទ្ធផល** | GPS X | GPS Y | **យោបល់ផ្សេងៗ** |
| ១០១០២០៣A | ០៤៦១០២០ | ១២៦២៥០០ | ដើមផ្លូវភូមិព្រៃរំដួល |
| | ០៤៦០១៥៨ | ១២៦២៣០១ | ចុងផ្លូវភូមិព្រៃរំដួល |

ថ្ងៃទី..៣១..ខែ..មីនា.... ឆ្នាំ២០២៣

មេឃុំ

កែវ~រិន

ថ្ងៃទី..៣១... ខែ...មីនា.... ឆ្នាំ២០២៣

**អ្នកជំនួយបច្ចេកទេស**

**គ្រុយ សុវណ្ណសិរីរ័ត្ន**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ខេត្តកំពង់ស្ពឺ**
**ស្រុកសំរោងទង**
**រដ្ឋបាលឃុំសែនដី**

លេខ:..០២៨./២៣.ស.ស.រ

ថ្ងៃព្រហស្បត្តិ៍ ៥ កើត ខែមាឃ ចត្វាស័ក ព.ស.២៥៦៦
សែនដី ថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៣

# សេចក្តីសម្រេច
## ស្តីពី
## ការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈកម្មការគ្រប់គ្រងគម្រោង

### មេឃុំ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ២២អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្តីពីការធ្វើវិមជ្ឈការអំណាចតួនាទី និងភារកិច្ចទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់
- យោងសេចក្តីសម្រេចលេខ០៩៧ សសរ/គ.ជ.អ.ប ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ស្តីពីការដាក់ឱ្យប្រើប្រាស់សៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់
- បានទទួលការអនុម័តនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាឃុំ.វិសាមញ្ញ........នាថ្ងៃទី.២៧..ខែ.មករា...ឆ្នាំ២០២៣

### សម្រេច

**ប្រការ១._**

ត្រូវបង្កើតគណៈកម្មការគ្រប់គ្រងគម្រោងសាងសង់ផ្លូវបេតុងអារមេ ដែលមានសមាសភាព ដូចខាងក្រោម៖

| | | |
|---|---|---|
| ១. លោក កែវ រ៉ែន | មេឃុំសែនដី | ប្រធាន |
| ២. លោក ខៀវ ឌី | ជំទប់ទី១ | អនុប្រធាន |
| ៣. លោក សួស សំអូន | សមាជិកក្រុមប្រឹក្សា | សមាជិក |
| ៤. លោក ឃិន គីម | សមាជិកក្រុមប្រឹក្សា | សមាជិក |
| ៥. លោក ព្រំ ទ្រី | មេភូមិព្រៃវង្វេល | សមាជិក |
| ៦. លោក មួង សារិន | អនុប្រធានភូមិព្រៃវង្វេល | សមាជិក |
| ៧. លោកស្រី ណុប តារា | ស្មៀនឃុំសែនដី | លេខាធិការ |

**ប្រការ២._**

គណៈកម្មការគ្រប់គ្រងគម្រោងមានតួនាទី ភារកិច្ចដូចខាងក្រោម៖

ក). ក្នុងការរៀបចំគម្រោង៖

- ពិនិត្យ និងអនុម័តផែនការសិក្សាគម្រោង
- គ្រប់គ្រងតាមដានដំណើរការសិក្សា និងរៀបចំគម្រោង
- រៀបចំសំណើគម្រោងដោយមានជំនួយពីអ្នកជំនួយបច្ចេកទេស
- ពិនិត្យ និងអនុម័តសំណើគម្រោង។

ខ). ក្នុងការអនុវត្តគម្រោង៖

- គ្រប់គ្រងតាមដានដំណើរការអនុវត្តគម្រោង
- រៀបចំប្រជុំចាប់ផ្តើម និងបញ្ចប់នៃការអនុវត្តការងារ ឬការផ្គត់ផ្គង់ទំនិញ និងរៀបចំប្រជុំពិនិត្យ និងអនុម័តការទូទាត់គម្រោង
- តាមដានត្រួតពិនិត្យការអនុវត្តគម្រោង
- រៀបចំកិច្ចប្រជុំនានានៅក្នុងអំឡុងពេលអនុវត្តគម្រោង ដើម្បីពិនិត្យ និងវាយតម្លៃការអនុវត្តគម្រោង។

**ប្រការ៣._**

គណៈកម្មការគ្រប់គ្រងគម្រោងមានរបៀបរបបការងារដូចខាងក្រោម៖

- ប្រធានគណៈកម្មការគ្រប់គ្រងគម្រោង ជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំរបស់គណៈកម្មការគ្រប់គ្រងគម្រោង។ ក្នុងករណីប្រធានអវត្តមាន ត្រូវផ្ទេរសិទ្ធិជាលាយល័ក្ខណ៍អក្សរទៅឱ្យអនុប្រធាន ជាប្រធានស្តីទី ហើយប្រធានស្តីទីជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំ
- កិច្ចប្រជុំរបស់គណៈកម្មការគ្រប់គ្រងគម្រោងអាចប្រព្រឹត្តទៅបាន លុះត្រាតែមានវត្តមានសមាជិកលើសពីពាក់កណ្តាលនៃសមាជិកគណៈកម្មការទាំងមូល
- សេចក្តីសម្រេចរបស់អង្គប្រជុំគណៈកម្មការគ្រប់គ្រងគម្រោងអាចយកជាការបាន លុះត្រាតែមានសំឡេងអនុម័តលើសពីពាក់កណ្តាលនៃចំនួនសមាជិកគណៈកម្មការទាំងមូល។ ប្រសិនបើសំឡេងអនុម័តមានចំនួនស្មើគ្នា សំឡេងរបស់អធិបតីនៃអង្គប្រជុំមានឧត្តមានុភាព
- ប្រធានគណៈកម្មការគ្រប់គ្រងគម្រោងអាចអញ្ជើញបុគ្គលិកមកពីទីភ្នាក់ងារនានា ឬតំណាងអង្គការសហគមន៍ មូលដ្ឋានដែលពាក់ព័ន្ធនឹងគម្រោង ដើម្បីចូលរួមកិច្ចប្រជុំគណៈកម្មការក្នុងនាមជាអ្នកសង្កេតការ
- គ្រប់កិច្ចប្រជុំរបស់គណៈកម្មការគ្រប់គ្រងគម្រោង ត្រូវមានកំណត់ហេតុដែលរៀបចំដោយលេខាធិការរបស់គណៈកម្មការ និងត្រូវចុះហត្ថលេខាដោយអធិបតីនៃអង្គប្រជុំ។

**ប្រការ៤._**

សមាសភាពដូចមានចែងក្នុងប្រការ១ និងអ្នកពាក់ព័ន្ធនានា ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

មេឃុំ

កែច~រិន

**កន្លែងទទួល៖**

- រដ្ឋបាលខេត្តកំពង់ស្ពឺ
- រដ្ឋបាលស្រុកសំរោងទង
- ដូចប្រការ១
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# កំណត់ហេតុ
## ស្តីពី
## ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការគ្រប់គ្រងគម្រោង

ឆ្នាំពីរពាន់ម្ភៃបី ខែមករា ថ្ងៃទីម្ភៃប្រាំមួយ វេលាម៉ោងប្រាំបី និងសាមសិបនាទីព្រឹក នៅសាលាឃុំសែនដី បានរៀបចំកិច្ចប្រជុំបង្កើតគណៈកម្មការគ្រប់គ្រងគម្រោង ក្រោមអធិបតីភាព លោក **កែវ រ៉ន** ប្រធានក្រុមប្រឹក្សាឃុំ ។

**១ .សមាសភាពអ្នកចូលរួម**

ដូចមានបញ្ជីវត្តមានជូនភ្ជាប់មកជាមួយ

**២ .របៀបវារៈ**

១ .មតិបើកអង្គប្រជុំរបស់ប្រធានអង្គប្រជុំ

២. ការពិភាក្សាពីការបង្កើតគណៈកម្មការគ្រប់គ្រងគម្រោង

៣. បញ្ហាផ្សេងៗ និងបិទអង្គប្រជុំ

**៣ .ការពិភាក្សា**

ជាកិច្ចចាប់ផ្តើម លោក **កែវ រ៉ន** ប្រធានអង្គប្រជុំ បានមានមតិថា ជារៀងរាល់ឆ្នាំមុនពេលចាប់ផ្តើមការសិក្សាគម្រោង ក្រុមប្រឹក្សាឃុំត្រូវប្រជុំរៀបចំបង្កើតគណៈកម្មការគ្រប់គ្រងគម្រោង ដូច្នេះការអញ្ជើញរបស់ក្រុមប្រឹក្សាឃុំយើងមកចូលរួមកិច្ចប្រជុំនាថ្ងៃនេះ គឺក្នុងគោលបំណងរៀបចំគណៈកម្មការគ្រប់គ្រងគម្រោងឃុំសែនដីសម្រាប់ធ្វើការតាមដានការអនុវត្តគម្រោងមូលនិធិឃុំឆ្នាំ២០២៣ ។ សមាជិកក្រុមប្រឹក្សាឃុំយើងមួយចំនួន ត្រូវបញ្ចូលក្នុងគណៈកម្មការគ្រប់គ្រងគម្រោង គឺដើម្បីចូលរួមតាមដានការអនុវត្តគម្រោងរបស់អ្នកទទួលការទាំងអស់គ្នា ។ នៅក្នុងគណៈកម្មការគ្រប់គ្រងគម្រោងក៏ត្រូវមានលោកមេភូមិ នៃទីតាំងគម្រោងផងដែរ ពីព្រោះគម្រោងមូលនិធិឃុំឆ្នាំ២០២២៣ នេះគឺត្រូវសាងសង់នៅក្នុងភូមិព្រៃវង្វេល ។

លោក **ខៀវ ឌី** ជំទប់ទី១ បានមានមតិថា ខ្ញុំឯកភាពចំពោះរៀបចំសមាសភាពគណៈកម្មការនេះ ហើយការបន្ថែមលោកមេភូមិស្រែគ្រោកក្នុងគណៈកម្មការគ្រប់គ្រងគម្រោង គឺដើម្បីបញ្ជាក់ថាលោកមេភូមិត្រូវចូលរួមចំណែក ក្នុងការតាមដាន និងទទួលខុសត្រូវចំពោះលទ្ធផលគម្រោងឆ្នាំ២០២៣ ដែរ។

ជាទីបញ្ចប់លោកប្រធានអង្គប្រជុំ បានថ្លែងអំណរគុណដល់សមាជិក សមាជិកាដែលចូលរួម និងបានមានមតិបូកសរុបបិទអង្គប្រជុំ។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោងដប់ និងដប់នាទីព្រឹក នាថ្ងៃខែឆ្នាំដដែលក្នុងបរិយាកាសរីករាយ និងស្និទស្នាលក្រៃលែង។

បានឃើញ និងឯកភាព
ប្រធានអង្គប្រជុំ
កែវ រ៉ន

អ្នកធ្វើកំណត់ហេតុ
Dara
ណុប ដារ៉ា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ខេត្តកំពង់ស្ពឺ**
**ស្រុកសំរោងទង**
**រដ្ឋបាលឃុំសែនដី**
លេខ:..០១០៧/២៣ស.ស.រ

ថ្ងៃសុក្រ ២ រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
សែនដី ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២៣

# សេចក្ដីសម្រេច
## ស្ដីពី
## ការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈកម្មការលទ្ធកម្មឃុំសែនដី

### មេឃុំ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ២២អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្ដីពីការផ្ទេរមុខងារអំណាចតួនាទី និងភារកិច្ចទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញប្រកាសណែនាំលេខ២៣១ សហវ.ប្រក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្ដីពីការងារលទ្ធកម្មរបស់ឃុំ សង្កាត់
- យោងសេចក្ដីសម្រេចលេខ០៩៧ សសរ/គ.ជ.អ.ប ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ស្ដីពីការដាក់ឱ្យប្រើប្រាស់សៀវភៅណែនាំស្ដីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់
- បានទទួលការអនុម័តនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាឃុំ..វិសាមញ្ញ........ នាថ្ងៃទី០៧ ខែមេសាឆ្នាំ២០២៣

### សម្រេច

**ប្រការ១._**

ត្រូវបង្កើតគណៈកម្មការលទ្ធកម្មឃុំសែនដី ដែលមានសមាសភាព ដូចខាងក្រោម ៖

| | | |
|---|---|---|
| ១. លោក **ភែម រ៉ន** | មេឃុំសែនដី | ប្រធាន |
| ២. លោក **ខៀម ឌី** | ជំទប់ទី១ | សមាជិក |
| ៣. លោក **សុស សំអូន** | សមាជិកក្រុមប្រឹក្សាឃុំ | សមាជិក |
| ៤. លោកស្រី ណុប តារា | ស្មៀនឃុំសែនដី | លេខាធិការ |

**ប្រការ២.-**

គណៈកម្មការលទ្ធកម្មមានតួនាទី ភារកិច្ចដូចខាងក្រោម ៖

- អនុវត្តកិច្ចដំណើរការនៃការដេញថ្លៃ ទៅតាមនីតិវិធីដែលបានកំណត់
- ពិនិត្យ និងវាយតម្លៃសំណើដេញថ្លៃ និងឯកសារពាក់ព័ន្ធដែលបានដាក់ដោយអ្នកដេញថ្លៃ
- ផ្តល់អនុសាសន៍ដល់មេឃុំអំពីអ្នកឈ្នះក្នុងការដេញថ្លៃ។

**ប្រការ៣.-**

គណៈកម្មការលទ្ធកម្មមានរបៀបរបបការងារដូចខាងក្រោម ៖

- ប្រធានគណៈកម្មការលទ្ធកម្ម ជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំរបស់គណៈកម្មការលទ្ធកម្ម។
- កិច្ចប្រជុំរបស់គណៈកម្មការលទ្ធកម្មអាចប្រព្រឹត្តទៅបាន លុះត្រាតែមានវត្តមានសមាជិកគណៈកម្មការលទ្ធកម្មទាំង០៣រូប។ ក្នុងករណីសមាជិកណាម្នាក់អវត្តមាន កិច្ចប្រជុំរបស់គណៈកម្មការលទ្ធកម្មត្រូវពន្យាពេល ដើម្បីឱ្យសមាជិកគណៈកម្មការលទ្ធកម្មទាំង០៣រូបបានចូលរួម។ មូលហេតុនៃការពន្យាពេលនេះត្រូវកត់ត្រានៅក្នុងកំណត់ហេតុ។ នៅពេលកាលបរិច្ឆេទថ្មីនៃការពន្យាពេលឈានមកដល់ កិច្ចប្រជុំរបស់គណៈកម្មការលទ្ធកម្មអាចប្រព្រឹត្តទៅបាន លុះត្រាតែមានវត្តមានសមាជិកគណៈកម្មការលទ្ធកម្មយ៉ាងតិចចំនួន០២រូប ដែលក្នុងនោះ០១រូប គឺជាប្រធានគណៈកម្មការលទ្ធកម្ម។
- សេចក្តីសម្រេចរបស់អង្គប្រជុំគណៈកម្មការលទ្ធកម្មអាចយកជាការបាន លុះត្រាតែមានសំឡេងអនុម័តលើសពីពាក់កណ្តាលនៃចំនួនសមាជិកគណៈកម្មការលទ្ធកម្មទាំងមូល។ ប្រសិនបើសំឡេងអនុម័តមានចំនួនស្មើគ្នា សំឡេងរបស់ប្រធានគណៈកម្មការលទ្ធកម្មមានឧត្តមានុភាព។
- ប្រធានគណៈកម្មការលទ្ធកម្មត្រូវអញ្ជើញមន្ត្រីគាំទ្របច្ចេកទេសខេត្ត ដែលអភិបាលខេត្តបានចាត់តាំងឱ្យជួយគណៈកម្មការលទ្ធកម្មឃុំ ចូលរួមកិច្ចប្រជុំគណៈកម្មការលទ្ធកម្ម។ មន្ត្រីគាំទ្របច្ចេកទេសខេត្តអាចផ្តល់យោបល់ដល់គណៈកម្មការលទ្ធកម្ម ប៉ុន្តែពុំមានសិទ្ធិបោះឆ្នោតអនុម័តឡើយ។
- គ្រប់កិច្ចប្រជុំរបស់គណៈកម្មការលទ្ធកម្ម ត្រូវមានកំណត់ហេតុដែលរៀបចំដោយលេខាធិការរបស់គណៈកម្មការលទ្ធកម្ម និងត្រូវចុះហត្ថលេខាដោយអធិបតីនៃអង្គប្រជុំ។

**ប្រការ៤.-**

សមាសភាពដូចមានចែងក្នុងប្រការ១ និងអ្នកពាក់ព័ន្ធនានា ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

កែវ.រិន

**កន្លែងទទួល** ÷
- រដ្ឋបាលខេត្តកំពង់ស្ពឺ
- រដ្ឋបាលស្រុកសំរោងទង
- ដូចប្រការ១
- ឯកសារ កាលប្បវត្តិ

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

### កំណត់ហេតុ
### ស្តីពី
### ការប្រជុំបើកសំណើដេញថ្លៃគម្រោងសាងសង់ផ្លូវបេតុងអាមេ

ឆ្នាំពីរពាន់ម្ភៃបី ខែមិថុនា ថ្ងៃទីម្ភៃ វេលាម៉ោងប្រាំបីព្រឹក រដ្ឋបាលឃុំរលាំងគ្រើល ស្រុកសំពោងទង ខេត្តកំពង់ស្ពឺ បានរៀបចំកិច្ចប្រជុំបើកសំណើដេញថ្លៃចំនួន៣ឃុំ ឃុំសែនដី និងឃុំរលាំងគ្រើល និងឃុំរលាំងចក ក្រោមអធិបតីភាព លោកស្រី ពិន សុផាណា អភិបាលរងនៃ គណៈអភិបាលស្រុកសំពោងទង។

**សមាសភាពចូលរួម** លោក លោកស្រីដូចមានក្នុងបញ្ជីវត្តមានជូនភ្ជាប់ ។

**របៀបវារៈ**

១. មតិសំណេះសំណាល និងបើកអង្គប្រជុំរបស់គណអធិបតី

២. ប្រធានគណៈកម្មការលទ្ធកម្មឃុំ ជម្រាបជូនរបៀបវារៈនៃការបើកសំណើដេញថ្លៃ

៣. អ្នកទទួលការដាក់សំណើដេញថ្លៃក្នុងប្រអប់ដេញថ្លៃ

៤. ប្រធានគណៈកម្មការលទ្ធកម្មឃុំអានគោលការណ៍សំខាន់ៗនៃការដេញថ្លៃ

៥. ប្រធានគណៈកម្មការលទ្ធកម្មឃុំប្រកាសបើកសំណើដេញថ្លៃជាផ្លូវការណ៍

៦. គណៈកម្មការលទ្ធកម្មឃុំបើកស្រោមសំបុត្រ រួចកត់ត្រាលើក្រដាសសផ្ទាំងធំរួច ពិនិត្យសុពលភាពសំណើដេញថ្លៃ និងវាយតម្លៃសំណើដេញថ្លៃ របស់អ្នកទទួលការ

៧. ការប្រកាសលទ្ធផលសំណើដេញថ្លៃ

៨. ការឡើងប្តេជ្ញាចិត្តរបស់អ្នកទទួលការដែលឈ្នះក្នុងការដេញថ្លៃ

៩. មតិបូកសរុប និងបិទកម្មវិធីអង្គប្រជុំរបស់គណៈអធិបតី

ជាកិច្ចចាប់ផ្តើមលោកស្រី ពិន សុផាន់ណា អភិបាលរងនៃគណៈអភិបាលស្រុកសំពោងទង មានប្រសាសន៍ សំណេះសំណាល និងបើកអង្គប្រជុំ។

ជាកិច្ចបន្ទាប់លោក កែវ រ៉ែន ប្រធានគណៈកម្មការលទ្ធកម្មឃុំសែនដី ជម្រាបជូន របៀបវារៈនៃការការដេញថ្លៃដល់សមាជិក សមាជិកាដែលមានវត្តមានក្នុងអង្គប្រជុំ និងប្រកាសពេលវេលាដាក់សំណើដេញថ្លៃចាប់ពី ម៉ោង ៩: ០៥នាទីព្រឹក ហួតដល់ ម៉ោង៩:១៥នាទីព្រឹក អ្នកទទួលការដាក់សំណើដេញថ្លៃក្នុងប្រអប់ដេញថ្លៃរយៈពេល១០នាទីរួចមកលោកប្រធានគណៈកម្មការលទ្ធកម្មឃុំអានគោលការណ៍សំខាន់ៗនៃការដេញថ្លៃ។

ជាកិច្ចបន្ត លោក ប្រធានគណៈកម្មការលទ្ធកម្មឃុំបានប្រកាសចំនួនស្រោមសំបុត្រដែលបានដាក់ដេញថ្លៃរួច បើកសំណើដេញថ្លៃរបស់អ្នកទទួលការមានចំនួន១០ស្រោមសំបុត្រ និងកត់ត្រាលើក្រដាសសផ្ទាំង ធំ ៖

១. ឈ្មោះអ្នក ដេញថ្លៃ វង្ស អត្ថិល ឈ្មោះ ក្រុមហ៊ុន ផាត់ សុផល តម្លៃដេញថ្លៃនៅពេលដាក់សំណើដេញ ថ្លៃមានចំនួន១៩៥,៩៦៦,០០០រៀល

២. ឈ្មោះអ្នកដេញថ្លៃ អ៊ឹម សុក្សោ ឈ្មោះ ក្រុមហ៊ុន ហ៊ឹង សុខសុវណ្ណារី ឯ.ក តម្លៃដេញថ្លៃនៅពេលដាក់សំណើដេញ ថ្លៃមានចំនួន១៣៤,០០០,០០០រៀល

៣. ឈ្មោះអ្នក ដេញថ្លៃ ហ៊ឹង ម៉េង ឈ្មោះ ក្រុមហ៊ុន ហ៊ឹង ម៉េង គ្រេនស្គ័ត តម្លៃដេញថ្លៃនៅពេលដាក់សំណើដេញថ្លៃមានចំនួន១៤៤,៣៩៦,០០០រៀល

៤. ឈ្មោះ ហាស់ សារឿន ឈ្មោះ ក្រុមហ៊ុន ហាស់ សារឿន តម្លៃដេញថ្លៃនៅពេលដាក់សំណើដេញថ្លៃមានចំនួន១៤៤,៣៩៦,០០០រៀល

៥. ឈ្មោះអ្នក ដេញថ្លៃ សួន ស៊ីលី ឈ្មោះ ក្រុមហ៊ុន ស៊ីមកិវឡុន័រតេនៈ តម្លៃដេញថ្លៃនៅពេលដាក់សំណើដេញថ្លៃមានចំនួន១៣២,៧០៦,៨០០រៀល

៦. ឈ្មោះអ្នក ដេញថ្លៃ គុជ រចនា ឈ្មោះ ក្រុមហ៊ុន សុវណ្ណបញ្ញាស័ក តម្លៃដេញថ្លៃនៅពេលដាក់សំណើដេញថ្លៃមានចំនួន១២៥,០០០,០០០រៀល

៧. ឈ្មោះអ្នក ដេញថ្លៃ ថៃ ឆេង ឈ្មោះ ក្រុមហ៊ុន ស្ថាបនាថៃឆេង តម្លៃដេញថ្លៃនៅពេលដាក់សំណើដេញថ្លៃមានចំនួន១៤៦,៣០៦,០០០រៀល

៨. ឈ្មោះអ្នក ដេញថ្លៃ ឆេង ប៉ូ ឈ្មោះ ក្រុមហ៊ុន ឆេង ប៉ូ តម្លៃដេញថ្លៃនៅពេលដាក់សំណើដេញថ្លៃមានចំនួន១៦០,៤៤០,០០០រៀល

៩. ឈ្មោះអ្នក ដេញថ្លៃ មៀច សុវត្ថិនី ឈ្មោះ ក្រុមហ៊ុន វិបុល រតនៈ តម្លៃដេញថ្លៃនៅពេលដាក់សំណើដេញថ្លៃមានចំនួន១២៤,៩១០,០០០រៀល

១០. ឈ្មោះអ្នក ដេញថ្លៃ សៀង សុខឡា ឈ្មោះ ក្រុមហ៊ុន សំណាងសៀងសុខឡា តម្លៃដេញថ្លៃនៅពេលដាក់សំណើដេញថ្លៃមានចំនួន១៩៥,៩៦៦,០០០រៀល

បន្ទាប់មកទៀតលោក ប្រធានគណៈកម្មការលទ្ធកម្មឃុំ បានប្រកាសលទ្ធផលនៃការដេញថ្លៃ៖

១. ឈ្មោះអ្នក ដេញថ្លៃ មៀច សុវត្ថិនី ឈ្មោះ ក្រុមហ៊ុន វិបុល រតនៈ តម្លៃដេញថ្លៃនៅពេលដាក់សំណើដេញថ្លៃមានចំនួន១២៤,៩១០,០០០រៀល តម្លៃទាបលំដាប់ទី១

២. ឈ្មោះអ្នក ដេញថ្លៃ គុជ រចនា ឈ្មោះ ក្រុមហ៊ុន សុវណ្ណបញ្ញាស័ក តម្លៃដេញថ្លៃនៅពេលដាក់សំណើដេញថ្លៃមានចំនួន១២៥,០០០,០០០រៀល តម្លៃទាបលំដាប់ទី២

៣. ឈ្មោះអ្នក ដេញថ្លៃ សួន ស៊ីលី ឈ្មោះ ក្រុមហ៊ុន ស៊ីមកិវឡុន័រតេនៈ តម្លៃដេញថ្លៃនៅពេលដាក់សំណើដេញថ្លៃមានចំនួន១៣២,៧០៦,៨០០រៀល តម្លៃទាបលំដាប់ទី៣

ក្រោយពីប្រកាសលទ្ធផលរួចមក លោក មៀច សុវត្ថិនី ឈ្មោះ ក្រុមហ៊ុន វិបុល រតនៈ បានឡើងប្តេជ្ញាចិត្តលើកការសាងសង់ផ្លូវបេតុងអាមេ។

ជាចុងបញ្ចប់លោកស្រី ពិន សុជាន់ណា អភិបាលរងនៃគណៈអភិបាលស្រុកសំពោងទង បានមានប្រសាសន៍ផ្តាំផ្ញើរ និងប្រកាសបិទអង្គប្រជុំ។

អង្គប្រជុំបានចប់សព្វគ្រប់ នូវវេលាម៉ោងដប់មួយនឹងដប់ប្រាំនាទីព្រឹក នាថ្ងៃខែឆ្នាំដដែលក្នុងបរិយាកាសរីករាយ និងស្និតស្នាលបំផុត ។

ប្រធានអង្គប្រជុំ　　　　　　　　　　**អ្នកធ្វើកំណត់ហេតុ**

កែវ~រិន

## តារាងសម្រាប់កត់ត្រានៅពេលបើក និងវាយតម្លៃសំណើដេញថ្លៃ

| រាជធានី ខេត្ត ÷ កំពង់ស្ពឺ | | ក្រុង ស្រុក ខណ្ឌ ÷ សំរោងទង | | រដ្ឋបាលឃុំ សង្កាត់ ÷ ស៊ែនដី | លេខកូដឃុំ សង្កាត់ ÷ 050709 |
|---|---|---|---|---|---|
| ឈ្មោះកិច្ចសន្យា ៖ | | | | តម្លៃប៉ាន់ស្មាន ៖ | |
| ល.រ | ឈ្មោះអ្នកដេញថ្លៃ | ឈ្មោះក្រុមហ៊ុន | តម្លៃដាក់ដេញថ្លៃ នៅពេលបើកសំណើដេញថ្លៃ | តម្លៃដាក់ដេញថ្លៃ ក្រោយពីកែតម្រូវ | កំណត់សម្គាល់ ឬមូលហេតុនៃការបដិសេធសំណើដេញថ្លៃ |
| 1 | 2 | 3 | 4 | 5 | 6 |
| 1. | សៀង សុវណ្ណឌី | វិបុល ខេមរៈ | 124,914,000 | | សុពលភាពទី 1 |
| ២. | ភុង រតនា | សុវណ្ណ បញ្ញាសិរ | 125,000,000 | | សុពលភាពទី ២ |
| 3 | សួន ស៊ីលី | ស៊ីម ភ័ទ្រា ខេមរៈ | 132,706,800 | | សុពលភាពទី 3 |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |

**កំណត់សម្គាល់ ÷**
- កូឡោនទី១ ទី២ ទី៣ និងទី៤ ត្រូវបំពេញនៅក្នុងពេលប្រជុំបើកសំណើដេញថ្លៃ។
- កូឡោនទី៥ និងទី៦ ត្រូវបំពេញនៅក្នុងពេលប្រជុំវាយតម្លៃសំណើដេញថ្លៃ។
- ទម្រង់នេះត្រូវភ្ជាប់ជាមួយកំណត់ហេតុ និងរបាយការណ៍ដេញថ្លៃ ហើយត្រូវបិទផ្សាយនៅលើក្ដារព័ត៌មាន នៅកន្លែងប្រជុំបើកសំណើដេញថ្លៃ និងវាយតម្លៃសំណើដេញថ្លៃ ០១ម៉ោងក្រោយពីបញ្ចប់កិច្ចប្រជុំវាយតម្លៃសំណើដេញថ្លៃ។

ថ្ងៃទី20 ខែ06 ឆ្នាំ2023

ប្រធានគណៈកម្មការលទ្ធកម្ម

កែង_រិន

ឧបសម្ព័ន្ធ៥៣.១

| របាយការណ៍រីកចម្រើន<br>នៃការអនុវត្តកិច្ចសន្យាសំណង់ | | |
|---|---|---|
| រាជធានី ខេត្ត ÷ កំពង់ស្ពឺ | ក្រុង ស្រុក ខណ្ឌ ÷ សំរោងទង | រដ្ឋបាលឃុំ សង្កាត់ ÷ សែនដី |
| ឈ្មោះកិច្ចសន្យា | គម្រោងសាងសង់ផ្លូវបេតុងអាមេ | |
| លេខកិច្ចសន្យា | ០៥០៧០៩/២៣/០១-០១ | |
| ឈ្មោះអ្នកទទួលការ | ម៉ម វិបុល | |
| ឈ្មោះអ្នកត្រួតពិនិត្យបច្ចេកទេស | គ្រុយ សុវណ្ណសិរីរ័ត្ន | |
| កាលបរិច្ឆេទចុះត្រួតពិនិត្យ | ២១/០៨/២០២៣ | |

១. ការពិពណ៌នាអំពីការរីកចម្រើននៃការអនុវត្តការងារ ៖

អ្នកទទួលការ៖

- បានឈូសឆាយសម្អាតទីតាំង និងធ្វើគ្រឹះក្រោមផ្លូវបានប្រវែង ១,៤៩៨គ.ម
- បានសាងសង់ផ្លូវបេតុងបានប្រវែង ០,៧៤៩គ.ម
- និងបានដាក់ស្លាកសញ្ញាគម្រោង ០១កន្លែង

| | |
|---|---|
| ២. ចំនួនឬអត្រាភាគរយនៃការអនុវត្តការងារដែលបានបញ្ចប់ | ៥០% |
| ៣. តើសម្ភារដែលបានប្រើប្រាស់មានគុណភាពដូចបានកំណត់នៅក្នុងកិច្ចសន្យាដែរឬទេ?<br>(បើគុណភាពសម្ភារដែលបានប្រើប្រាស់មិនដូចក្នុងកិច្ចសន្យា ចូរពន្យល់ចំណុចខ្វះខាតទាំងនោះ) | បាទ |
| ៤. តើការងារមានគុណភាពដូចបានកំណត់នៅក្នុងកិច្ចសន្យាដែរឬទេ?<br>(បើគុណភាពការងារមិនដូចក្នុងកិច្ចសន្យា ចូរពន្យល់ចំណុចខ្វះខាតទាំងនោះ) | បាទ |
| ៥. តើសំណង់បានសាងសង់ទៅតាមគំនូសប្លង់បច្ចេកទេសដែរឬទេ?<br>(បើសំណង់មិនដូចគំនូសប្លង់បច្ចេកទេស ចូរពន្យល់ចំណុចខុសប្លែកទាំងនោះ) | បាទ |

៦. យោបល់ផ្សេងៗ ៖

អ្នកទទួលការបានបំពេញលក្ខខ័ណ្ឌនៃការទូទាត់លើកទី១

ថ្ងៃទី២១ ខែសីហា ឆ្នាំ២០២៣

អ្នកត្រួតពិនិត្យបច្ចេកទេស

គ្រុយ សុវណ្ណសិរីរ័ត្ន

**ឧបសម្ព័ន្ធទី៥៣.១**

<table>
<tr><td colspan="3" align="center">របាយការណ៍រីកចម្រើន<br>នៃការអនុវត្តកិច្ចសន្យាសំណង់</td></tr>
<tr><td>រាជធានី ខេត្ត ÷ កំពង់ស្ពឺ</td><td>ក្រុង ស្រុក ខណ្ឌ ÷ សំរោងទង</td><td>រដ្ឋបាលឃុំ សង្កាត់ ÷ សែនដី</td></tr>
<tr><td>ឈ្មោះកិច្ចសន្យា</td><td colspan="2">គម្រោងសាងសង់ផ្លូវបេតុងអាមេ</td></tr>
<tr><td>លេខកិច្ចសន្យា</td><td colspan="2">០៥០៧០៩/២៣/០១-០១</td></tr>
<tr><td>ឈ្មោះអ្នកទទួលការ</td><td colspan="2">ម៉ម វិបុល</td></tr>
<tr><td>ឈ្មោះអ្នកត្រួតពិនិត្យបច្ចេកទេស</td><td colspan="2">គ្រុយ សុវណ្ណសិរីរ័ត្ន</td></tr>
<tr><td>កាលបរិច្ឆេទចុះត្រួតពិនិត្យ</td><td colspan="2">២៦/០៩/២០២៣</td></tr>
<tr><td colspan="3">១. ការពិពណ៌នាអំពីការរីកចម្រើននៃការអនុវត្តការងារ ៖<br>អ្នកទទួលការ៖<br>• បានសាងសង់ផ្លូវបេតុងបានប្រវែង ០,៧៤៩គ.ម<br>• ក្រោយពីបញ្ចប់ការងារសាងសង់ អ្នកទទួលការបានសំអាតកាកសំណល់សំណង់ និងកាកសំណល់ផ្សេងៗនៅការដ្ឋានបានរួចរាល់។</td></tr>
<tr><td colspan="2">២. ចំនួនឬអត្រាភាគរយនៃការអនុវត្តការងារដែលបានបញ្ចប់</td><td>១០០%</td></tr>
<tr><td colspan="2">៣. តើសម្ភារដែលបានប្រើប្រាស់មានគុណភាពដូចបានកំណត់នៅក្នុងកិច្ចសន្យាដែរឬទេ?<br>(បើគុណភាពសម្ភារដែលបានប្រើប្រាស់មិនដូចក្នុងកិច្ចសន្យា ចូរពន្យល់ចំណុចខ្វះខាតទាំងនោះ)</td><td>បាទ</td></tr>
<tr><td colspan="2">៤. តើការងារមានគុណភាពដូចបានកំណត់នៅក្នុងកិច្ចសន្យាដែរឬទេ?<br>(បើគុណភាពការងារមិនដូចក្នុងកិច្ចសន្យា ចូរពន្យល់ចំណុចខ្វះខាតទាំងនោះ)</td><td>បាទ</td></tr>
<tr><td colspan="2">៥. តើសំណង់បានសាងសង់ទៅតាមគំនូសប្លង់បច្ចេកទេសដែរឬទេ?<br>(បើសំណង់មិនដូចគំនូសប្លង់បច្ចេកទេស ចូរពន្យល់ចំណុចខុសប្លែកទាំងនោះ)</td><td>បាទ</td></tr>
<tr><td colspan="3">៦. យោបល់ផ្សេងៗ ៖<br>អ្នកទទួលការបានបំពេញលក្ខខ័ណ្ឌនៃការទូទាត់លើកទី២</td></tr>
</table>

ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៣

**អ្នកត្រួតពិនិត្យបច្ចេកទេស**

**គ្រុយ សុវណ្ណសិរីរ័ត្ន**

ឧប្រទ់ទី៥៤.១

## របាយការណ៍បញ្ចប់
## នៃការអនុវត្តកិច្ចសន្យាសំណង់

| | | |
|---|---|---|
| **រាជធានី ខេត្ត** ÷ កំពង់ស្ពឺ | **ក្រុង ស្រុក ខណ្ឌ** ÷ សំរោងទង | **រដ្ឋបាលឃុំ សង្កាត់** ÷ សែនដី |
| ឈ្មោះកិច្ចសន្យា | គម្រោងសាងសង់ផ្លូវបេតុអាមេ | |
| លេខកិច្ចសន្យា | ០៥០៧០៩/២៣/០១-០១ | |
| ឈ្មោះអ្នកទទួលការ | ម៉ម វិបុល | |
| ឈ្មោះអ្នកត្រួតពិនិត្យបច្ចេកទេស | គ្រុយ សុវណ្ណសិរីរ័ត្ន | |
| កាលបរិច្ឆេទចុះត្រួតពិនិត្យ | ០៥/០២/២០២៤ | |

១. ពិពណ៌នាអំពីស្ថានភាពនៃលទ្ធផលកិច្ចសន្យា ៖

- លទ្ធផលកិច្ចសន្យាទាំងអស់ស្ថិតនៅក្នុងស្ថានភាពល្អ អាចទទួលយកបាន
- អ្នកទទួលការបានថែទាំលទ្ធផលកិច្ចសន្យាជាប្រចាំនៅក្នុងអំឡុងពេលថែទាំ៦ខែនេះ និងបាន ជួសជុលកែលម្អផ្លូវមួយលើក នៅមុនពេលបញ្ចប់នៃរយៈពេលថែទាំ។

២. ការងារដែលអ្នកទទួលការត្រូវបំពេញ មុននឹងទទួលបាននូវការទូទាត់ចុងក្រោយ

គ្មាន

៣. យោបល់ផ្សេងៗ ៖

អ្នកទទួលការបានបំពេញនូវល័ក្ខខ័ណ្ឌនានាសម្រាប់ការទូទាត់លើកចុងក្រោយ។

ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២៤

**អ្នកត្រួតពិនិត្យបច្ចេកទេស**

**គ្រុយ សុវណ្ណសិរីរ័ត្ន**

# ឧបសម្ព័ន្ធ ៥
# គំរូតារាងផែនការលទ្ធកម្ម

ឧបសម្ព័ន្ធទី៤០.១

## សំណើដេញថ្លៃកិច្ចសន្យាសំណង់

| ខេត្ត ÷ | ស្រុក ÷ | រដ្ឋបាលឃុំ ÷ |
|---|---|---|
| ឈ្មោះកិច្ចសន្យា ៖ សាងសង់ផ្លូវបេតុងអាមេ ប្រវែង ០,៣៨២គ.ម ទទឹងខ្នង ៦ម កម្រាស់ ១៥០មម និងស្លាកសញ្ញាគម្រោង ០១កន្លែង។ | | |
| ឈ្មោះអ្នកដេញថ្លៃ ៖ | ឈ្មោះក្រុមហ៊ុន ៖ | លេខអត្តសញ្ញាណប័ណ្ណ ៖ |

| ល.រ | ការពិពណ៌នា | ឯកតា | បរិមាណ | តម្លៃឯកតា | សរុប (៛) |
|---|---|---|---|---|---|
| ១ | សាងសង់ផ្លូវបេតុងអាមេ ទទឹងខ្នង ៦ម កម្រាស់ ១៥០មម និងស្លាកសញ្ញាគម្រោង ០១កន្លែង | គ.ម | ០,៣៨២ | | |
| | | | | សរុបតម្លៃនៃការដេញថ្លៃ | |

តម្លៃដេញថ្លៃសរុបជាអក្សរ ៖

**កំណត់សម្គាល់ ÷**

- អ្នកដេញថ្លៃត្រូវភ្ជាប់មកជាមួយសំណើដេញថ្លៃរបស់ខ្លួននូវ (១)សេចក្តីប្រកាសស្តីពីក្រមសីលធម៌ ការមិនក្លែងបន្លំ និងការមិនប្រព្រឹត្តិអំពើពុករលួយ (២)លិខិតធានាប្រាក់កក់ធានាការដេញថ្លៃ និង(៣)ប័ណ្ណពន្ធប៉ាតង់ដែលមានសុពលភាព ឬបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធប៉ាតង់ បើពុំនោះសោតទេ សំណើដេញថ្លៃពុំមានសុពលភាពឡើយ ហើយប្រាក់ធានាការដេញថ្លៃនឹងត្រូវបានរឹបអូសផ្ទេរបង្វែរបង់ចូលថវិការផ្សេ។
- អ្នកដេញថ្លៃឈ្នះក្នុងការដេញថ្លៃនឹងត្រូវតម្កល់ប្រាក់កក់ធានាការអនុវត្តចំនួន១០%នៃតម្លៃកិច្ចសន្យា។ ប្រាក់កក់នេះមានសុពលភាពរហូតដល់ចប់រយៈពេលថែទាំលទ្ធផលកិច្ចសន្យា ឬរយៈពេលធានាគុណភាពសំណង់។
- ខ្ញុំជាអ្នកដេញថ្លៃបានអាន និងយល់ច្បាស់អំពីកិច្ចសន្យា គំនូសប្លង់បច្ចេកទេស និងការបរិយាយលម្អិតលក្ខណៈបច្ចេកទេស។ ខ្ញុំបានយល់ព្រមសាងសង់ទៅតាមកិច្ចសន្យា ពេលវេលាដែលបានកំណត់ និងជួសជុលថែទាំលទ្ធផលកិច្ចសន្យាឱ្យស្ថិតនៅក្នុងល័ក្ខខ័ណ្ឌល្អក្នុងរយៈពេល៦ខែបន្ទាប់ពីសាងសង់រួចជាស្ថាពរ។
- អ្នកដេញថ្លៃត្រូវចូលរួមដេញថ្លៃប្រកបដោយការប្រកួតប្រជែង ដោយគ្មានការឃុបឃិត ការក្លែងបន្លំ ការបង្ខិតបង្ខំ ឬការប្រព្រឹត្តអំពើពុករលួយ។ ប្រសិនបើត្រូវបានរកឃើញថា អ្នកដេញថ្លៃមានការពាក់ព័ន្ធនឹងឃុបឃិត ការក្លែងបន្លំ ការបង្ខិតបង្ខំ ឬការប្រព្រឹត្តអំពើពុករលួយ អ្នកដេញថ្លៃទាំងនោះនឹងត្រូវបានដាក់ក្នុងបញ្ជីខ្មៅជារៀងរហូត និងមិនត្រូវបានអនុញ្ញាតឱ្យដាក់សំណើដេញថ្លៃកិច្ចសន្យាឃុំ សង្កាត់ទាំងអស់នៅទូទាំងប្រទេសកម្ពុជា ហើយប្រាក់កក់ធានាការដេញថ្លៃរបស់អ្នកដេញថ្លៃទាំងនោះនឹងត្រូវបានរឹបអូសផ្ទេរបង្វែរបង់ចូលថវិការផ្សេ។
- កំហុសមួយចំនួនអាចត្រូវបានកែតម្រូវដោយគណៈកម្មការលទ្ធកម្ម។ ប្រសិនបើអ្នកដេញថ្លៃមិនទទួលយកការកែតម្រូវនេះទេ គណៈកម្មការលទ្ធកម្មនឹងបដិសេធសំណើដេញថ្លៃនេះ ដោយចាត់ទុកជាសំណើដេញថ្លៃដែលពុំមានសុពលភាព ហើយប្រាក់កក់ធានាការដេញថ្លៃនឹងត្រូវបានរឹបអូសផ្ទេរបង្វែរបង់ចូលថវិការផ្សេ។
- សំណើដេញថ្លៃនេះមានសុពលភាពរយៈពេល៤៥ថ្ងៃ ចាប់ពីកាលបរិច្ឆេទនៃការប្រជុំបើកសំណើដេញថ្លៃ។

ថ្ងៃទី........ ខែ.............. ឆ្នាំ.........

**ហត្ថលេខា និងឈ្មោះអ្នកដេញថ្លៃ**

ទម្រង់ទី៣៩

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

## សេចក្តីប្រកាសស្តីពី

## ក្រមសីលធម៌ ការមិនក្លែងបន្លំ និងការមិនប្រព្រឹត្តិអំពើពុករលួយ

ខ្ញុំជាអ្នកទទួលការ អ្នកផ្តល់សេវាកម្ម ឬអ្នកផ្គត់ផ្គង់ទំនិញសូមប្រកាសអះអាងដូចខាងក្រោម ÷

១. ខ្ញុំ បុគ្គលិករបស់ខ្ញុំ ទីប្រឹក្សារបស់ខ្ញុំ អ្នកសហការ/ដៃគូរបស់ខ្ញុំ ភ្នាក់ងាររបស់ខ្ញុំ ម្ចាស់ភាគហ៊ុនរបស់ខ្ញុំ និងសាច់ញាតិរបស់ខ្ញុំ ព្រមទាំងអ្នកសហការ និងសាច់ញាតិរបស់ពួកគេ នឹងមិនមានទំនាក់ទំនងណាមួយដែលជាទំនាស់ផលប្រយោជន៍ដែលបានចែងនៅក្នុងឯកសារដេញថ្លៃ ។

២. បើយើងខ្ញុំបានដឹងអំពីទំនាស់ផលប្រយោជន៍ទាំងនេះ យើងខ្ញុំនឹងរាយការណ៍ភ្លាមជូនទៅគណៈកម្មការលទ្ធកម្ម ឃុំ សង្កាត់ អភិបាលខេត្តក្រុង និងក្រុមការងារគណនេយ្យភាពខេត្ត ក្រុង ។

៣. ខ្ញុំ បុគ្គលិករបស់ខ្ញុំ ទីប្រឹក្សារបស់ខ្ញុំ អ្នកសហការ/ដៃគូរបស់ខ្ញុំ ភ្នាក់ងាររបស់ខ្ញុំ ម្ចាស់ភាគហ៊ុនរបស់ខ្ញុំ និងសាច់ញាតិរបស់ខ្ញុំ ព្រមទាំងអ្នកសហការ និងសាច់ញាតិរបស់ពួកគេ នឹងមិនប្រព្រឹត្តអំពើពុករលួយ ក្លែងបន្លំ បង្គាប់បញ្ជា និងឃុបឃិតស៊ុំគ្រលំចំពោះការដាក់សំណើដេញថ្លៃរបស់ខ្ញុំឡើយ ។

៤. យើងខ្ញុំបានដឹងច្បាស់អំពីកាតព្វកិច្ចរបស់ខ្លួន ដែលត្រូវអនុញ្ញាតឱ្យរដ្ឋាភិបាល និងឬទីភ្នាក់ងារផ្តល់មូលនិធិ ធ្វើការត្រួតពិនិត្យនូវរាល់ឯកសារនានាដែលទាក់ទងនឹងការរៀបចំសំណើដេញថ្លៃរបស់យើងខ្ញុំ និងកិច្ចសន្យាណាមួយដែលអាចជាលទ្ធផលពីភាពមិនប្រក្រតីដែលគិតស្មានមិនដល់ ទោះបីជាកិច្ចសន្យានោះយើងខ្ញុំឈ្នះ ឬចាញ់ក៏ដោយ ។

៥. នៅក្នុងដំណើរការនៃការអនុវត្តកិច្ចលទ្ធកម្ម និងកិច្ចសន្យាណាមួយដែលឈ្នះក្នុងការដេញថ្លៃនេះ ខ្ញុំ បុគ្គលិករបស់ខ្ញុំ ទីប្រឹក្សារបស់ខ្ញុំ អ្នកសហការ/ដៃគូរបស់ខ្ញុំ ភ្នាក់ងាររបស់ខ្ញុំ ម្ចាស់ភាគហ៊ុនរបស់ខ្ញុំ និងសាច់ញាតិរបស់ខ្ញុំ ព្រមទាំងអ្នកសហការ និងសាច់ញាតិរបស់ពួកគេ នឹងមិនមានចំណាយប្រាក់ ឬផ្តល់ជូនជាសារគុណឱ្យទៅបុគ្គលិក ទីប្រឹក្សា អ្នកសហការ ឬសាច់ញាតិនៃអ្នកដែលពាក់ព័ន្ធនៅក្នុងដំណើរការលទ្ធកម្ម ការអនុវត្តគម្រោង និងការចេញអាណត្តិទូទាត់ ។

ក្នុងករណីមិនគោរពតាមខ្លឹមសារនៃសេចក្តីប្រកាសនេះ ខ្ញុំជាអ្នកទទួលការ អ្នកផ្តល់សេវាកម្ម ឬអ្នកផ្គត់ផ្គង់ទំនិញ នឹងមិនត្រូវបានអនុញ្ញាតឱ្យដាក់សំណើដេញថ្លៃគម្រោងឃុំ សង្កាត់ទាំងអស់នៅទូទាំងប្រទេសកម្ពុជា ។

ថ្ងៃទី...... ខែ........ ឆ្នាំ......

**ហត្ថលេខា និងឈ្មោះអ្នកដេញថ្លៃ**

ទម្រង់លិខិតធានាប្រាក់កក់ធានាការដេញថ្លៃ

**ធនាគារ.............**

លេខ...................

## លិខិតធានាប្រាក់កក់ធានាការដេញថ្លៃ

**សូមគោរពជូន**

**លោក មេឃុំ .................**

ដោយហេតុថាក្រុមហ៊ុន.................... មានបំណងដាក់ពាក្យសុំដេញថ្លៃ កិច្ចសន្យា.......................... របស់ឃុំ...................... ដែលនឹងត្រូវប្រជុំបើកសំណើដេញថ្លៃនៅថ្ងៃទី....... ខែ......... ឆ្នាំ......... តាមសេចក្តីជូនដំណឹងស្តីពីការដេញថ្លៃសម្រាប់កិច្ចសន្យារបស់ក្រុមប្រឹក្សាឃុំ ...................... ចុះថ្ងៃទី....... ខែ........... ឆ្នាំ.........។

យើងខ្ញុំសូមធានា និងទទួលខុសត្រូវចំពោះ លោកមេឃុំ ................. នូវប្រាក់កក់ធានាការដេញថ្លៃ ចំនួន................................ (ជាអក្សរ...................................................................)។

ក្នុងករណីមានល័ក្ខខ័ណ្ឌណាមួយកើតមានឡើងក្នុងចំណោមល័ក្ខខ័ណ្ឌទាំងបីខាងក្រោម ៖

1. ប្រសិនបើអ្នកដេញថ្លៃដកពាក្យរបស់ខ្លួនក្នុងរយៈពេលសុពលភាពនៃសំណើដេញថ្លៃ
2. ប្រសិនបើអ្នកដេញថ្លៃមិនព្រមចុះហត្ថលេខាលើកិច្ចសន្យា ក្នុងរយៈពេលសុពលភាពនៃសំណើដេញថ្លៃ
3. ប្រសិនបើអ្នកដេញថ្លៃមិនព្រមកក់ប្រាក់ធានាការអនុវត្ត។

នោះធនាគារយើងខ្ញុំនឹងធ្វើការផ្ទេរបង្វែរចូលថវិការដ្ឋនូវចំនួនប្រាក់ខាងលើ នៅពេលដែលបានទទួលពាក្យស្នើសុំជាលាយល័ក្ខណ៍អក្សរពី លោកមេឃុំ .............................។

លិខិតធានានេះនឹងផុតកំណត់៖ ក). ប្រសិនបើអ្នកដេញថ្លៃគឺជាអ្នកដេញថ្លៃឈ្នះទទួលបានការបញ្ជាក់ថាបានចុះកិច្ចសន្យាដោយអ្នកដេញថ្លៃ និងបានចេញលិខិតធានាការអនុវត្ត ខ). ប្រសិនបើអ្នកដេញថ្លៃមិនបានជោគជ័យ (១)បង្ហាញឯកសារច្បាប់ចតចម្លងនៃកិច្ចសន្យារបស់អ្នកដេញថ្លៃឈ្នះ ឬ (២) រយៈពេល៣០ថ្ងៃ បន្ទាប់ពីផុតកំណត់នៃសុពលភាពដេញថ្លៃ ។

ធ្វើនៅ................. ថ្ងៃទី....... ខែ............ ឆ្នាំ.........

**នាយកធនាគារ**

ទម្រង់ទី៤១

## តារាងសម្រាប់កត់ត្រានៅពេលបើក និងវាយតម្លៃសំណើដេញថ្លៃ

| ខេត្ត ក្រុង : | ស្រុក ខណ្ឌ : | ឃុំ សង្កាត់ : | លេខកូដឃុំ សង្កាត់ : |
|---|---|---|---|
| ឈ្មោះកិច្ចសន្យា : | | តម្លៃប៉ាន់ស្មាន : | |

| ល.រ | ឈ្មោះអ្នកដេញថ្លៃ | ឈ្មោះក្រុមហ៊ុន | តម្លៃដាក់ដេញថ្លៃ នៅពេលបើកសំណើដេញថ្លៃ | តម្លៃដាក់ដេញថ្លៃ ក្រោយពីកែតម្រូវ | កំណត់សម្គាល់ ឬមូលហេតុនៃការបដិសេធសំណើដេញថ្លៃ |
|---|---|---|---|---|---|
| 1 | 2 | 3 | 4 | 5 | 6 |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |

**កំណត់សម្គាល់ :**

- កូឡោនទី១ ទី២ ទី៣ និងទី៤ ត្រូវបំពេញនៅក្នុងពេលប្រជុំបើកសំណើដេញថ្លៃ។
- កូឡោនទី៥ និងទី៦ ត្រូវបំពេញនៅក្នុងពេលប្រជុំវាយតម្លៃសំណើដេញថ្លៃ។
- ទម្រង់នេះត្រូវភ្ជាប់ជាមួយកំណត់ហេតុ និងរបាយការណ៍ដេញថ្លៃ ហើយត្រូវបិទផ្សាយនៅលើក្តារព័ត៌មាន នៅកន្លែងប្រជុំបើកសំណើដេញថ្លៃ និងវាយតម្លៃសំណើដេញថ្លៃ ០១ម៉ោងក្រោយពីបញ្ចប់កិច្ចប្រជុំវាយតម្លៃសំណើដេញថ្លៃ។

ថ្ងៃទី...... ខែ.......... ឆ្នាំ.......

**ប្រធានគណៈកម្មការលទ្ធកម្ម**

គ). របាយការណ៍រីកចម្រើននៃកិច្ចសន្យាសេវាកម្ម (ទម្រង់៤៧)

| របាយការណ៍រីកចម្រើននៃកិច្ចសន្យាសេវាកម្ម | | |
|---|---|---|
| ខេត្ត ក្រុង : | ស្រុក ខណ្ឌ : | ឃុំ សង្កាត់ : |
| ឈ្មោះគម្រោង | | |
| លេខកិច្ចសន្យា | | |
| ឈ្មោះផ្តល់សេវាកម្ម | | |
| ឈ្មោះអ្នកត្រួតពិនិត្យបច្ចេកទេស | | |
| កាលបរិច្ឆេទចុះត្រួតពិនិត្យ | | |
| ១. ការពិពណ៌នាអំពីការរីកចម្រើននៃការងារ : | | |
| ២. អត្រាភាគរយនៃការបញ្ចប់ | | |
| ៣. តើសម្ភារៈ/ពូជទាំងនោះមានគុណភាពដូចបានសរសេរក្នុងកិច្ចសន្យាដែរឬទេ?<br>(បើមិនមានគុណភាពដូចចែងក្នុងកិច្ចសន្យា ចូរពន្យល់នូវចំណុចខ្វះខាតទាំងនោះ) | | |
| ៤. តើការអនុវត្តការងារមានគុណភាព ដូចបានសរសេរក្នុងកិច្ចសន្យាដែរឬទេ?<br>(បើមិនមានគុណភាពដូចចែងក្នុងកិច្ចសន្យា ចូរពន្យល់នូវចំណុចខ្វះខាតទាំងនោះ) | | |
| ៥. យោបល់ផ្សេងៗ : | | |

ថ្ងៃទី....... ខែ............. ឆ្នាំ.........

**អ្នកត្រួតពិនិត្យបច្ចេកទេស**

ឃ). របាយការណ៍បញ្ចប់កិច្ចសន្យាសេវាកម្ម (ទម្រង់៥៨)

<table>
<tr><th colspan="3">របាយការណ៍បញ្ចប់កិច្ចសន្យាសេវាកម្ម</th></tr>
<tr><td>ខេត្ត ក្រុង :</td><td>ស្រុក ខណ្ឌ :</td><td>ឃុំ សង្កាត់ :</td></tr>
<tr><td>ឈ្មោះគម្រោង</td><td colspan="2"></td></tr>
<tr><td>លេខកិច្ចសន្យា</td><td colspan="2"></td></tr>
<tr><td>ឈ្មោះផ្តល់សេវាកម្ម</td><td colspan="2"></td></tr>
<tr><td>ឈ្មោះអ្នកត្រួតពិនិត្យបច្ចេកទេស</td><td colspan="2"></td></tr>
<tr><td>កាលបរិច្ឆេទចុះត្រួតពិនិត្យ</td><td colspan="2"></td></tr>
<tr><td colspan="3">១. ការពិពណ៌នាអំពីការរីកចម្រើននៃការងារ :</td></tr>
<tr><td colspan="2">២. អត្រាភាគរយនៃការបញ្ចប់</td><td></td></tr>
<tr><td colspan="2">៣. តើសម្ភារៈ/ពូជទាំងនោះមានគុណភាពដូចបានសរសេរក្នុងកិច្ចសន្យាដែរឬទេ?<br>(បើមិនមានគុណភាពដូចចែងក្នុងកិច្ចសន្យា ចូរពន្យល់នូវចំណុចខ្វះខាតទាំងនោះ)</td><td></td></tr>
<tr><td colspan="2">៤. តើការអនុវត្តការងារមានគុណភាព ដូចបានសរសេរក្នុងកិច្ចសន្យាដែរឬទេ?<br>(បើមិនមានគុណភាពដូចចែងក្នុងកិច្ចសន្យា ចូរពន្យល់នូវចំណុចខ្វះខាតទាំងនោះ)</td><td></td></tr>
<tr><td colspan="3">៥. យោបល់ផ្សេងៗ :</td></tr>
</table>

ថ្ងៃទី...... ខែ.......... ឆ្នាំ.......

**អ្នកត្រួតពិនិត្យបច្ចេកទេស**

# ឧបសម្ព័ន្ធ ៦
# ផែនទីគម្រោង

១.ផែនទីទីតាំងគម្រោងមូលនិធិឃុំសែនដី ឆ្នាំ២០០២១




២.ផែនទីទីតាំងគម្រោងមូលនិធិឃុំសែនដី ឆ្នាំ២០០២២



## ៣.ផែនទីទីតាំងគម្រោងមូលនិធិឃុំសែនជី ឆ្នាំ២០០២៣




## ៤.រូបភាពទីតាំងសាលាឃុំសែនជី



## ៥.ដំណើរការកិច្ចលទ្ធកម្មឃុំសែនដី

រូបភាពទី១.ពិធីប្រជុំបើកសំណើដេញថ្លៃ




រូបភាពទី២.ការដាក់ និងទទួលសំណើដេញថ្លៃ



រូបភាពទី៣.ការបើកសំណើដេញថ្លៃ




រូបភាពទី៤.ការវាយតម្លៃសំណើដេញថ្លៃ



រូបភាពទី៥. អ្នកទទួលការដែលឈ្នះឡើងបង្ហាញខ្លួន និងប្តេជ្ញាចិត្ត



រូបភាពទី៦.សកម្មភាពចុះស្រាវជាវរបស់និស្សិត

